SPP

# សៀវភៅក្បួនទាយ

# តម្រាមើលរាសីតាមផ្ទៃមុខ

## ចាប់ពីអាយុ១-១០០ឆ្នាំ



P103

ប្រែសម្រួលដោយ ចំន្ទ ពិដោរ

$3.50

www.elibraryofcambodia.com

អំណោយរបស់លោក ឡុង ឃុន សំរ៉េម ដល់ក្រុមការខ្មែរ
ដើម្បីទុកតម្កល់ក្នុង elibrary of cambodia
កក្កដា 2015

# តម្រាមើលរាសីតាមផ្ទៃមុខ

www.elibraryofcambodia.org

# រចនាសម្ព័ន្ធ


| | |
|---|---|
| អត្ថបទដោយ | សូរឿន |
| ក្រាហ្វិចកុំព្យូទ័រដោយ | សុខសាន្ត, លីលី, ភ័ក្ត្រា |
| ប្រែសម្រួលដោយ | ច័ន្ទ ពិដោរ |
| ត្រួតពិនិត្យអក្ខរាវិរុទ្ធដោយ | ហួរ, ពិដោរ,ស្រៀង |
| បោះពុម្ពនៅ | រោងពុម្ពនាគមាស |
| បោះពុម្ពលើកទី១ | ចំនួន៤០០០ច្បាប់ |


www.elibraryofcambodia.org

# អារម្ភកថា

ជម្រាបសួរប្រិយមិត្តអ្នកអានជាទីមេត្រី!

នាពេលនេះយើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំងដែលបាននាំជូនមកនូវសៀវភៅក្បួនទាយ "តម្រាមើលរាសីតាមផ្ទៃមុខ" ដែលជាសៀវភៅដែលមានប្រជាប្រិយភាពជាខ្លាំងក្នុងប្រទេសម៉ាឡេស៊ីក៏ដូចជាប្រទេសនានាដែលសម្បូរជនជាតិចិនរស់នៅច្រើនដូចជាសិង្ហបុរី តៃវ៉ាន់ វៀតណាម ថៃ និងកម្ពុជាជាដើម។

សៀវភៅនេះមានលក្ខណៈពិសេសនិងអស្ចារ្យខ្លាំងណាស់ ព្រោះវាត្រូវបានរួមបញ្ចូលនូវក្បួនខ្នាតដ៏ត្រឹមត្រូវរបស់ក្បួនទស្សន៍ទាយចិនបុរាណដូចជា ស៊ីនសៀងឆួនភៀន ម៉ាស៊ី និងលីវចួង...

ម្យ៉ាងទៀតការចេះពិនិត្យវិភាគ ឬ អានផ្ទៃមុខពិតជាចាំបាច់ណាស់សម្រាប់ការងារផ្សេងៗ ដើម្បីឱ្យដឹងពីជោគជតារបស់ខ្លួនមិត្តភ័ក្តិ ឬ ញាតិមិត្តជិតឆ្ងាយរបស់ខ្លួន។ យើងតែងតែធ្លាប់បានឮគេនិយាយថា "មុខមាត់របស់គាត់មានហុងស៊ុយល្អណាស់ ឬ មុខតាប៉ិនេះគ្មានហុងស៊ុយសោះ" តើគេនិយាយបែបនេះ ដោយសម្អាងលើអ្វីទៅ? ពិតជាគ្មានចម្លើយទេ ព្រោះបច្ចុប្បន្ននេះមានមនុស្សមិនច្រើនទេ ដែលចេះវិនិច្ឆ័យមុខមាត់របស់អ្នកដទៃ ដោយផ្អែកតាមក្បួនខ្នាតដ៏ត្រឹមត្រូវមួយ ប៉ុន្តែបែរជាសម្បូរ មនុស្សដែល ចូលចិត្តវិភាគផ្ទៃមុខតាមការចូលចិត្តរបស់ខ្លួនទៅវិញ។

មុននឹងជម្រាបលាប្រិយមិត្តអ្នកអានទាំងឡាយ យើងខ្ញុំសូមគោរពជូនពរជ័យ វិបុលសុខជូនដល់ជនរួមជាតិទាំងអស់ឱ្យជួបប្រទះតែសំណាងល្អគ្រប់ពេលវេលា។

**សូមអរគុណ**

**ចំនួ ពិដោរ**

www.elibraryofcambodia.org

# មាតិកា

មេរៀនទី១........................................................៥
ទឹកមុខមិនធ្លាប់កុហក អំណាចរបស់មៀនសៀង

មេរៀនទី២......................................................១៥
មូលដ្ឋានពិតនៃការមើលទឹកមុខ

មេរៀនទី៣......................................................៥៤
១០០តំណែងលើទម្រង់មុខ

មេរៀនទី៤....................................................១៤៦
វាំងទាំង១២នៃទម្រង់មុខ

មេរៀនទី៥....................................................១៩៩
ប្រជ្រុយមានអត្ថន័យបែបណាខ្លះ?

មេរៀនទី៦....................................................២២២
ផ្ទៃមុខមិនមានថ្ងៃដូចដើមទៀតទេ
វិធីអនុវត្តការមើលទម្រង់មុខ

www.elibraryofcambodia.org

# មេរៀនទី១
# ទឹកមុខមិនធ្លាប់កុហក
# អំណាចរបស់មៀនសៀង

មានសុភាសិតចាស់បុរាណរបស់អង់គ្លេសមួយបានពោលថា" កុំវាយតម្លៃសៀវភៅតាមរយៈក្របរបស់វា" មានន័យថាយើងមិនអាចវាយតម្លៃមនុស្សតែលើសំបកក្រៅបានទេ ។ តែទោះជាយ៉ាងនេះក្តីក៏មនុស្សភាគច្រើននៅតែគិតថារូបរាងមុខមាត់ខាងក្រៅរបស់បុគ្គលនីមួយៗ គឺជាប្រការសំខាន់ដែលអាចឱ្យយើងធ្វើការវាយតម្លៃថាគេជាមនុស្សយ៉ាងម៉េចដោយសំអាងទៅលើក្បួនច្បាប់ដ៏ត្រឹមត្រូវនេះ ។



-គេមើលទៅដូចជាមនុស្សមិនល្អ

-ឯងមើលទៅដូចជាសម្បូរល្បិចណាស់

-គេមើលទៅដូចជាមិត្តល្អណាស់

-គេមើលទៅដូចជាមនុស្សល្អណាស់

មនុស្សភាគច្រើនចូលចិត្តនិយាយពាក្យទាំងនេះណាស់ ។ ប៉ុន្តែនេះមិនមែនជាប្រការល្អនោះទេព្រោះយើងមិនអាចវាយតម្លៃមនុស្សដោយគ្មានមូលដ្ឋានច្បាស់លាស់នោះឡើយ វាដូចជាការវាយតម្លៃជោគសំណាងរបស់មនុស្សម្នាក់តាមរយៈឆ្នាំរបស់គេអ៊ីចឹងដែរ ។ មនុស្សរាប់សែនលាននាក់កើតឆ្នាំនាគ តែពួកគេក៏ពុំមែនជាមនុស្សកំណាច លោភលន់ចង់បានគ្រប់គ្នាឯណា ហើយអ្នកដែលយើងគិតថាអាក្រក់ក៏អាចជាមនុស្សល្អដែរ ។



www.elibraryofcambodia.org

ឥឡូវនេះ យើងខ្ញុំសូមបង្វែរអារម្មណ៍របស់អ្នកចូលមកក្នុង "មៀនសៀង" វិញ ពាក្យថា "មៀន" ប្រែថាទឹកមុខ ឯពាក្យថា "សៀង" ប្រែថាលក្ខណៈសម្គាល់របស់មនុស្ស ។ មៀនសៀងជាសាស្ត្រាដែលមានប្រវត្តិល្បីល្បាញជាយូរយារណាស់មកហើយ ។ វាមានការវិវឌ្ឍន៍មកតាំងពីយុគសម័យខាងទី ឬ ស្តេចចក្រពត្តិលឿង (2700-2150មុនគ.ស) មៀនសៀងជាសិល្បៈដែលកើតមកពីការសង្កេតលក្ខណៈរូបរាងកាយរបស់មនុស្ស រាប់តាំងពីរូបទម្រង់ខ្សែវាសនា គ្រោងឆ្អឹង លក្ខណៈផ្សេងៗ ព្រមទាំងកម្លាំងនៃទឹកមុខតាមរយៈការសង្កេតក្នុងកម្រិតដ៏ម៉ត់ចត់មួយ ។ យើងអាចមើលដឹងពីឧបនិស្ស័យនិងធម្មជាតិរបស់បុគ្គលម្នាក់ៗតាមរយៈការធ្វើចលនាផ្សេងៗ ដូចជា ដេក ដើរ ឈរ អង្គុយ និងការកម្រើកតិចៗនៃមុខនិងទឹកមុខបាន ។ ទិន្នន័យនិងវិធីសាស្ត្រផ្សេងៗជាច្រើនក្នុងមៀនសៀងមានប្រភពមកពីក្បួនតម្រាចិនបុរាណ ដូចជាសឺនសៀងឆួនភៀន សឺនសៀងធៀកូនតៅ ម៉ាអ៊ី និងលីវចួង ដែលបានធ្វើឱ្យមៀនសៀងក្លាយជាសាស្ត្រាមានលក្ខណៈល្អដូច្នេះ ។

នាសម័យដើមដែលមានស្តេចចក្រពត្តិគ្រប់គ្រង ការមើលទឹកមុខជាសាស្ត្រមួយដែលអ្នកយុទ្ធសាស្ត្រនិងទីប្រឹក្សារាជសំណាក់ចិនប្រើដើម្បីផ្តល់ដំបូន្មានផ្នែកយុទ្ធសាស្ត្រដល់ព្រះរាជា ។ ឧទាហរណ៍ដូចជាពេលណាដែលស្តេចចក្រពត្តិទៅជួបនឹងស្តេចភាគីមួយទៀត ឬ ជួបនឹងជនដទៃ ឬ ជនបរទេសដែលមកចូលគាល់ អ្នកយុទ្ធសាស្ត្រប្រចាំរាជសំណាក់តែងតែប្រើប៉ិនមៀនសៀងរបស់ពួកគេ ដើម្បីប្រមើលមើលអ្នកទាំងនោះភ្លាម បន្ទាប់មកក៏ផ្តល់ពាក្យណែនាំដល់ព្រះរាជា ។ នេះជាប្រការមួយដ៏ល្អសម្រាប់ព្រះរាជាដែលអាចកំណត់បានថាខ្លួននឹងត្រូវនិយាយអ្វី ឬ មិនត្រូវនិយាយអ្វីជាមួយអ្នកទាំងនោះ ។

ម្យ៉ាងទៀត ការមើលទឹកមុខក៏អាចកំណត់រកអ្នកដែលសមស្របដែលអាចស្នងតំណែង ឬ មកបំពេញការងារក្នុងរាជសំណាក់បានដែរ ព្រោះនាសម័យនោះស្រុកទេសតែងតែជួបប្រទះនឹងភាពវឹកវរមានសង្គ្រាមរាំងជល់ច្រើន ធ្វើឱ្យមនុស្សភាគច្រើនពុំអាចកត់ចំណាំថ្ងៃខែឆ្នាំកំណើតរបស់ស្វាមីភរិយាខ្លួន ឬ កូនចៅបានត្រឹមត្រូវទេ ទើបហោរាចិនពិបាកព្យាករណ៍ទស្សន៍ទាយអំពីជោគជតារបស់អ្នកទាំងនោះណាស់ ។



www.elibraryofcambodia.org

នៅសម័យនោះ ពេលដែលត្រូវដាក់ពាក្យចូលធ្វើការ គេពុំចាំបាច់យកសន្លឹកប្រវត្តិរូបសង្ខេបទៅបង្ហាញដើម្បីបានការងារធ្វើក្នុងរាជសំណាក់នោះទេ គេគ្រាន់តែបង្ហាញប៉ាជី ឬ ក្រាបជោគជតារបស់គេទៅជាការស្រេច ។ ការពិនិត្យមើលទឹកមុខត្រូវបានទទួលការអភិវឌ្ឍន៍ក្នុងឋានៈជាវិធីមួយដែលអាចជួយឱ្យមន្ត្រីរាជសំណាក់ប្រាកដក្នុងចិត្តថា អ្នកដែលត្រូវគេជ្រើសរើសឱ្យធ្វើការនៅទីនោះមិនបានប្រើថ្ងៃខែឆ្នាំកំណើតក្លែងក្លាយដើម្បីអួតអាងនូវជោគជតាខ្ពស់ហួសហេតុពេកទេ ។



ឪពុកម្តាយកូនកំលោះក៏អាចប្រើការពិនិត្យមើលទឹកមុខដើម្បីសម្រេចឱ្យកូនប្រុសរបស់ខ្លួនរៀបការជាមួយភរិយាដែលនាំជោគសំណាងដល់ឱ្យគ្រួសារដែរ ។ អ្វីដែលសំខាន់ជាងនោះទៅទៀតគឺកូនប្រសាស្រីនោះនឹងមិនអាចនាំគ្រោះមកឱ្យនោះទេ ។ ចំណែកឯឪពុកម្តាយកូនក្រមុំក៏ប្រើការមើលទឹកមុខនេះដើម្បីមើលជោគសំណាងកូនប្រសាប្រុសរបស់គាត់ពិតជាល្អមានសមត្ថភាពអាចមើលថែកូនស្រីខ្លួនបានល្អឬយ៉ាងណា ។

ក្រាបជោគជតាកំណើតក៏អាចមានការខុសឆ្គង ចំណែកឯប្រវត្តិរូបក៏អាចក្លែងក្លាយបានដែរ មនុស្សយើងអាចនិយាយកុហកបានមួយម៉ឺនជំពូក ប៉ុន្តែទឹកមុខមិនអាចកុហកបានទេ ។



www.elibraryofcambodia.org




ការពិនិត្យមើលទឹកមុខគឺជារូបបែបមួយរបស់ " នរលក្ខណៈសាស្ត្រ " ដែលជាសិល្បៈមួយនៅក្នុងចំណោមសិល្បៈទាំង៥របស់ចិន ( អ៊ូស៊ូ ) ។ ពាក្យថា " នរលក្ខណៈសាស្ត្រ " សំដៅលើការសង្កេតមើលលើលក្ខណៈរូបខាងក្រៅរបស់មនុស្សម្នាក់ៗដែលនៅតែមានការពេញនិយមរហូតមកទល់បច្ចុប្បន្ននេះ ។



www.elibraryofcambodia.org



មៀនសៀងមានតិចនិចផ្សេងៗក្នុងការសង្កេតទឹកមុខ គឺមានដូចជាទឹកមុខនិងការប្រែប្រួលបន្តិចបន្តួចរបស់ទឹកមុខ ដូចជាការញាក់ភ្នែក ការញញឹម កែវភ្នែក ការនិយាយស្ដីជាដើម ដែលកិរិយាទាំងអស់នេះសុទ្ធតែបានបង្ហាញនូវចរិតលក្ខណៈរបស់បុគ្គលនោះទាំងអស់ ។



ក្នុងពិភពលោកដ៏ធំធេងនេះមិនមែនមានតែជនជាតិចិននោះទេដែលបានខិតខំស្វែងរកនិងធ្វើការអភិវឌ្ឍន៍លើវិធីសាស្ត្រនៃការសង្កេតទឹកមុខ ចំណែកឯនៅក្រិចបុរាណក៏ដូចគ្នាដែរ ជាក់ស្ដែងដូចជាលោកអ៊ីប៉ូក្រាតជាចិត្តវិទូក៏បានខិតខំអភិវឌ្ឍលើវិធីសាស្ត្រនៃការសង្កេតទឹកមុខមនុស្សដែរ ។ ក្រៅពីនេះ នៅមានអារីស្តូតក៏បានព្យាយាមអធិប្បាយពីវិធីប្រមើលមើលឧបនិស្ស័យរបស់មនុស្សម្នាក់ៗតាមរយៈទឹកមុខក្នុងសៀវភៅរបស់គាត់ដែរ ។

ភាពខុសគ្នារវាងការពិនិត្យមើលទឹកមុខរបស់ជនជាតិចិននិងពួកបស្ចិមប្រទេស គឺការមើលទឹកមុខរបស់ជនជាតិចិនមានលក្ខណៈស៊ីជម្រៅជាង ព្រោះជនជាតិចិនមិនត្រឹមតែស្វែងរកវិធីឱ្យដឹងពីបុគ្គលិកលក្ខណៈនិងឧបនិស្ស័យរបស់មនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែនៅបានរួមបញ្ចូលទាំងភាពមានបាន ជោគសំណាង និងចំណេះដឹង ព្រមទាំងចំណេះធ្វើរបស់មនុស្សទៀតផង ។ មៀនសៀងមិនមែនគ្រាន់តែប្រាប់យើងថា មនុស្សនោះចចេសរឹងរូសទេ វាក៏បានប្រាប់ឱ្យដឹងដែរថាអ្នកនោះនឹងជួបជោគសំណាង ឬ គ្រោះអាក្រក់យ៉ាងម៉េចក្នុងជីវិតទៀតផង។ ក្រៅពីនេះ វាបានប្រាប់អំពីជីវិតគូស្រករល្អអាក្រក់ ព្រមទាំងត្រូវប្រកបអាជីពអ្វីដើម្បីកាន់តែមានបាន ។ល ។ មៀនសៀងជាសាស្ត្រដ៏ស្មុគស្មាញ តែវាបង្ហាញឱ្យឃើញពីការពិតដែលយើងមិនអាចដឹងផងដែរ ។



www.elibraryofcambodia.org

ប្រិយមិត្តអ្នកអានជាទីមេត្រី ខ្លឹមសារសំខាន់នៅលើផ្ទៃមុខគឺជាផែនទីជោគជតា ជោគសំណាង និងភាពមានបានរបស់មនុស្សម្នាក់ៗ។ នៅលើផ្ទៃមុខមានចំណុច ឬ តំណែងចំនួន100 ដែលអាចឱ្យយើងកំណត់ជោគជតា ឬ ភាពមានបានរបស់មនុស្សនោះបាន ចាប់តាំងពីអាយុ 1-100ឆ្នាំ គឺមានទឹកមុខដែលអាចឱ្យយើងដឹងពីឧបនិស្ស័យ ការប្រែប្រួលនានា និងឧបសគ្គផ្សេងៗក្នុងជីវិត។ ផ្ទៃមុខរបស់មនុស្សចែកជា3គឺ លើ កណ្ដាល និងក្រោមដែលបរិវេណនីមួយៗ អាចប្រាប់ឱ្យដឹងពីជោគជតាក្នុងកំឡុងពេលខុសគ្នានៃជីវិតរបស់មនុស្សម្នាក់ៗ។






www.elibraryofcambodia.org

# ជោគជតានិងផ្ទៃមុខ

តាំងពីបុរាណកាលមក ជនជាតិចិនបានខិតខំសិក្សាពីបញ្ហាជោគជតារបស់មនុស្សទម្ងើនេះហើយដែលនាំឱ្យមានសាស្ត្រស្តីអំពីជោគជតានិងអភិទស្សនៈវិជ្ជាចិនដែលគេស្គាល់ក្នុងនាមជាការសិក្សាអំពីជោគជតាដែលជាសិល្បៈមួយក្នុងចំណោមសិល្បៈ5ទាំងរបស់ចិន។






www.elibraryofcambodia.org

មនុស្សខ្លះវង្វេងលើជោគជាតា តែបែរជាមិនព្រមគិតលើបញ្ហានេះទេ។ តើមាននរណាខ្លះដែលមិនចង់ដឹងថាអនាគតរបស់ពួកគេនឹងមានលក្ខណៈយ៉ាងដូចម្ដេចនោះ? តែក៏មានអ្នកដែលគិតថាបញ្ហាជោគជតានោះជាកត្តាកំណត់ក្នុងន័យថាមនុស្សមានកត្តាកំណត់ជាស្រេចសម្រាប់ដំណើររបស់ពួកគេ។

សារប្រយោជន៍ដែលមានឥទ្ធិពលបំផុតនៃការមើលទឹកមុខគឺធ្វើឱ្យអ្នកមានភាពច្បាស់លាស់ក្នុងចិត្តព្រោះជាធម្មតាពេលសន្ទនាគ្នា យើងតែងតែមើលមុខរបស់ដៃគូ។ដូច្នេះហើយយើងអាចលួចសង្កេតទឹកមុខភាគីម្ខាងទៀត ដើម្បីប្រមើលមើលឧបនិស្ស័យធម្មជាតិពិតរបស់គេ រួមទាំងលក្ខណៈបង្កប់របស់ពួកគេក្នុងខណៈដែលអ្នកកំពុងចាប់ដៃពួកគេហើយនិយាយរាក់ទាក់ថា "សួស្ដី" ដោយមិនចាំបាច់ត្រូវសាកសួរអំពីពតិមាន អំពីថ្ងៃខែឆ្នាំកំណើតរបស់ពួកគេឡើយ។

យើងខ្ញុំគិតថាការពិនិត្យមើលទឹកមុខជាវិធីសាស្ត្រដ៏ល្អមួយសម្រាប់ពាណិជ្ជករ អ្នកនយោបាយ អ្នកដឹកនាំ ឬ សូម្បីតែមេផ្ទះ ឬ មនុស្សទូទៅដែលមានក្នុងជីវភាពប្រចាំថ្ងៃ ដូចជាការជួលអ្នកបម្រើ ជួលអ្នកការពារ ជួលអ្នកចិញ្ចឹមក្មេង ក៏គួរតែត្រូវពឹងពាក់លើទិន្នន័យបែបនេះដូចគ្នាដែរ។







www.elibraryofcambodia.org

# មៀនសៀងនិងប៉ាជឺ ជោគជតាមុននិងក្រោយពេលព្រហ្មលិខិត

អ្នកទាយប៉ាជឺភាគច្រើនតែងតែប្រើមៀនសៀង ដើម្បីជំនួយដល់ការផ្តល់ពាក្យប្រឹក្សា។ ម្យ៉ាងទៀតការអះអាងទិន្នន័យតំរុយជោគជតាដោយការពិនិត្យលើទឹកមុខក៏អាចជួយបានច្រើនដែរ ជាពិសេសក្នុងករណីដែលបុគ្គលនោះមិនមានថ្ងៃខែឆ្នាំកំណើតពិតប្រាកដ។

ទោះជាយ៉ាងណាក៏ដោយ ក៏ប៉ាជឺនិងហុងស៊ុយមានលក្ខណៈខុសគ្នាដែរ ក្នុងប៉ាជឺយើងនិយាយទាក់ទងនឹងជោគសំណាងរបស់មនុស្សម្នាក់ដែលកើតមកមានវាស្រេច ឬ ព្រហ្មលិខិតកំណត់មកឱ្យ។ ប៉ាជឺរបស់អ្នកគឺលេខសម្ងាត់ជោគជតាដែលត្រូវកំណត់ដោយសមត្ថភាពដែលអ្នកមានក្នុងជីវិតនេះ នោះគឺអ្នកទៅឆ្ងាយប៉ុណ្ណា? ចំណេះដឹងចំណេះធ្វើរបស់អ្នកគឺអ្វី? អ្នកនឹងមានបានប៉ុណ្ណា? អ្នកនឹងមានជីវិតអាពាហ៍ពិពាហ៍បែបណា? ចំណុចខ្សោយរបស់អ្នកគឺអ្វី? ហើយអ្នកនឹងមានឱកាសអ្វីខ្លះ?



ថ្វីបើរូបឆោមទឹកមុខវាមិនមានលក្ខណៈស្ថិតស្ថេរមែន តែក្នុងសាស្ត្រពិនិត្យមើលទឹកមុខបានប្រើពាក្យថា "សៀងអ៊ីវស៊ីនសឹង"មានន័យថាលក្ខណៈផ្សេងៗនៃទឹកមុខអ្នកបានមកពីបេះដូងអ្នក។

មែនហើយ អ្វីដែលនិយាយនេះមិនមានន័យថាអ្នកអាចក្លាយជាតារាហូលីវូដ ស៊ីនឌី ក្រោហ្វដក្នុងពេលរាត្រីឡើយ។ ប្រការដំបូងដោយសារការប្រែប្រួលនៃទឹកមុខ អ្នកនឹងមានលក្ខណៈស្ងប់ស្ងាត់។ ប្រការទី2 ទឹកមុខរបស់អ្នកអាចប្រែប្រួលបាន តែបរិវេណគ្រោងនៃទម្រង់មុខ(ដូចជា គ្រោងឆ្អឹង)ស្ទើរតែមិនមានការប្រែប្រួលឡើយ។ អ្នកដែលបានអានសៀវភៅ BaZi-The Destiny Code (ប៉ាជឺ-លេខកូដជោគជតា) អាចមានការងឿងឆ្ងល់ថា យី! ជោគជតាមិនត្រូវបានព្រហ្មលិខិតកំណត់ទុកមុនតាំងពីកំណើតទេអី។

ជោគជតាមានពីរផ្នែកគឺ ជោគជតាមុនព្រហ្មលិខិតនិងជោគជតាក្រោយព្រហ្មលិខិត។ ជោគជតាមុនព្រហ្មលិខិតគឺជាផ្នែកមួយដែលត្រូវកំណត់ដោយថ្ងៃ ខែ ឆ្នាំកំណើត និងដួងជតា



www.elibraryofcambodia.org

របស់អ្នក នេះគឺផ្នែកដែលអ្នកអាចផ្លាស់ប្តូរបាន ។ អ្វីដែលអ្នកអាចធ្វើបានមានត្រឹមតែការចៀសវាងនូវអំពើផ្សេងៗតាមដែលអ្នកអាចធ្វើបាន ឬ បន្ថយបន្ថយផលប៉ះពាល់នៃបញ្ហាខ្លះដែលមិនអាចចៀសវាងបានតែប៉ុណ្ណោះ ។

ជោគជតាក្រោយព្រហ្មលិខិតទាក់ទងនឹងទង្វើ ឬ ការចៀសវាងរបស់អ្នក វាស្តែងឱ្យឃើញលើទឹកមុខនិងបាតដៃរបស់អ្នក ។ អ្វីដែលអ្នកជ្រើសរើសធ្វើ ឬ មិនធ្វើនិងផលគុណនៃទង្វើផ្សេងៗរបស់អ្នក វានឹងបង្ហាញឱ្យឃើញនៅលើទឹកមុខរបស់អ្នក ។ ដូច្នេះលក្ខណៈផ្សេងៗលើទឹកមុខអាចមានការប្រែប្រួលបាន បើគេម្នាក់នោះជ្រើសរើសយកទង្វើ ឬ ទស្សនៈការគិតរបស់គេ ។ ប្រាកដណាស់ថាក្នុងផ្នែកជោគជតាមុនព្រហ្មលិខិតកំណត់ អ្នកអាចមានការប្រែប្រួលមិនជាច្រើនទេ តែអ្វីដែលនៅក្នុងជោគជតាខាងក្នុងខ្លួននិងក្នុងបេះដូងរបស់អ្នកនោះអាចផ្លាស់ប្តូរបាន ដូច្នេះហើយទើបជោគសំណាងបានមកពីបេះដូង ។ ចូរផ្លាស់ប្តូរវិធីដែលអ្នកគិត ឬ ធ្វើទឹកមុខនិងជោគជតារបស់អ្នកក៏ផ្លាស់ប្តូរទៅតាមនោះដែរ ។






www.elibraryofcambodia.org

# វិធីសាស្ត្រមើល(ពិនិត្យ)ទឹកមុខ_ហោរាសាស្ត្រ_ហុងស៊ុយគឺជាអ្វី?

មៀនសៀង ប៉ាជឺ និងហុងស៊ុយជាវិជ្ជាខុសគ្នាក្នុងព្រំដែនដ៏ទូលំទូលាយនៃអភិទស្សនវិជ្ជាចិន ។ ប៉ុន្តែទោះជាវាមានលក្ខណៈខុសគ្នាមែន តែវាបានជួយបំពេញគ្នាទៅវិញទៅមកយ៉ាងខ្ជាប់ខ្ជួនដែរ ។

ប៉ាជឺជារូបបែបមួយនៃហោរាសាស្ត្រចិនដែលជួយយើងឱ្យកត់ចំណាំដៅចំណុចនិងប្រាប់លេខកូដជោគជតារបស់យើងតាមរយៈថ្ងៃខែឆ្នាំកំណើតនិងពេលកើតរបស់យើង ។ គ្រូហុងស៊ុយដែលល្អនឹងអាចជួយត្រួតពិនិត្យប៉ាជឺរបស់អ្នកឱ្យធ្វើហុងស៊ុយជានិច្ច មុនពេលណែនាំវិធីកែប្រែហុងស៊ុយ ឬ ធ្វើការផ្លាស់ប្តូរអ្វីមួយ ។

មៀនសៀងអាចជួយឱ្យគ្រូហុងស៊ុយនិងប៉ាជឺមើលឃើញនូវផ្នែកផ្សេងៗក្នុងជោគជតារបស់មនុស្សយើងដោយការសង្កេតលក្ខណៈផ្សេងៗនៃទឹកមុខ វាអាចធ្វើឱ្យមើលឃើញបញ្ហារបស់គេម្នាក់នោះបានយ៉ាងឆាប់រហ័ស ។ បើរកទិន្នន័យទាក់ទងនឹងប៉ាជឺមិនបានដោយប្រការណាមួយ ដូចជាក្នុងពេលដែលយើងឃើញចំណុចលើខ្នង់ច្រមុះ ឬ ស្នាមខ្មៅនៅកន្ទុយភ្នែកហើយថ្ពាល់ ឬ កំផ្លៀងស្រក យើងរមែងដឹងបានភ្លាមថា គេម្នាក់នោះមានបញ្ហាលើផ្នែក "សម្ព័ន្ធភាព" ។

ប៉ាជឺនិងមៀនសៀងធ្វើឱ្យយើងអាចវិនិច្ឆ័យបញ្ហារបស់មនុស្សមុនពេលគេប្រាប់ ឬ ក្នុងក្បួនហុងស៊ុយទៅទៀត យើងអាចរកឃើញបញ្ហាឧបសគ្គ ឬ ភាពលំបាកផ្សេងៗរបស់គេម្នាក់នោះ ។ ក្រៅពីនេះ យើងក៏អាចទាញប្រយោជន៍ពីហុងស៊ុយដើម្បីជួយដោះស្រាយបញ្ហា ឬ កាត់បន្ថយផលប៉ះពាល់របស់វាឱ្យសល់តិចបំផុតវិញដែរ ។





www.elibraryofcambodia.org

## ហេតុអ្វីចាំបាច់ត្រូវចេះមើល (ឬ អាន)ទឹកមុខ?

ព្រោះការមើលទឹកមុខគឺជាបំនិនដ៏ល្អមួយ ដែលមិនត្រឹមតែមានគុណតម្លៃប៉ុណ្ណោះទេ ថែមទាំងមានប្រយោជន៍ច្រើនទៀតផង។ ការចេះមើលទឹកមុខអាចជួយឱ្យយើងមានជំនឿជាក់លើខ្លួនឯងពេលយើងប្រជុំ ឬ ធ្វើកិច្ចសន្យាជាមួយនរណាម្នាក់លើគ្រប់ការងារទាំងអស់។ ព្រោះថាពេលសន្ទនាជាមួយគ្នា អ្នកខ្លះអាចនិយាយប្រាប់តែពីរឿងល្អរបស់ខ្លួន ប៉ុន្តែទឹកមុខរបស់គេក៏អាចមានបង្កប់នូវអ្វីដែលផ្ទុយពីនេះដែរ។

ជាញឹកញាប់ណាស់យើងតែងមានសញ្ចេតនា( អារម្មណ៍ ) ដំបូងទៅលើនរណាម្នាក់ ហើយក៏ធ្វើការវាយតម្លៃលើគេភ្លាមដោយសារការមើលទឹកមុខបូករួមនិងអាកប្បកិរិយាផ្សេងៗ។ ឧទាហរណ៍ដូចជាការជ្រើសរើសអ្នកបម្រើជាដើម ព្រោះថាជីវប្រវត្តិរបស់គេរមែងមិនបានជួយអ្វីគេណាស់ណាទេ ( ព្រោះទិន្នន័យផ្សេងៗអាចត្រូវគេប្រឌិតឡើងបាន ) ។ ដូច្នេះហើយទើបយើងត្រូវពឹងលើអារម្មណ៍ខាងក្រៅរបស់យើង ឬ សង្កេតទឹកមុខរបស់បុគ្គលនោះបន្ថែមទៀត។

ការមានជំនួយដ៏ល្អក្នុងការសម្រេចចិត្តជាការប្រសើរណាស់ មិនថាជាការសម្រេចចិត្តណាត់ជាមួយនរណាម្នាក់ ជួលនរណាម្នាក់ ឬ ធ្វើកិច្ចព្រមព្រៀង កិច្ចការជំនួញតម្លៃរាប់លានដុល្លារជាមួយនរណាម្នាក់ទេ អ្នកក៏អាចប្រើវិធីការមើលទឹកមុខនេះដើម្បីជួយសម្រេចចិត្ត ប្រកបទៅដោយការមានទំនុកចិត្តលើខ្លួនឯង ទោះជាគេម្នាក់ នោះនិយាយពិត ឬ មិនពិតប្រាប់អ្នកក៏ដោយ។



ពេលខ្លះយើងអាចទទួលបាននូវទិន្នន័យដ៏ជាក់លាក់ ហើយថែមទាំងបានទទួលនូវការធានាដ៏ត្រឹមត្រូវដោយឆ្លងកាត់ការ ត្រួតពិនិត្យយ៉ាងស្អិតស្អាញលើផ្នែកបុគ្គលិកលក្ខណៈ ឬ ការសម្ភាសន៍ដ៏ល្អិតល្អន់ តែប្រវត្តិសង្ខេបរបស់គេម្នាក់នោះក៏មិនបានបញ្ជាក់អ្នកថាគេជាមនុស្ស



www.elibraryofcambodia.org

មាត់ច្រើន ឬ អត់... ព្រោះថា មនុស្សម្នាក់ៗតែងតែមានការសម្ងាត់ផ្ទាល់ខ្លួន។ សុភាសិតមួយរបស់ចិនបានពោលថា "មាត់ច្រើនធ្វើឱ្យទូកលិចបាន"។ បើអ្នកមានកិច្ចការជំនួញសម្ងាត់ហើយអ្នកគ្រាន់តែមើលលើជីវប្រវត្តិបុគ្គលិករបស់អ្នកតើអ្នកអាចដឹងដែរឬ ថាបុគ្គលិករបស់អ្នកជាមនុស្សមាត់ច្រើនឬទេ? ហើយអាចធន់នឹងការសម្ងាត់នោះបានឬទេ? គន្លឹះសំខាន់នោះគឺចូរកុំជួលអ្នកដែលញញឹមឃើញធ្មេញ ជាពិសេសកុំជួលមនុស្សភ្នែកធំព្រោះពួកគេងាយចាញ់បញ្ឆោតអ្នកដទៃដោយឆាប់ចងមិត្តជាមួយអ្នកផ្សេងលឿនពេក ហើយមានទំនោរក្នុងការបញ្ចេញរឿងសម្ងាត់ក្នុងកាលៈទេសៈមិនសមស្រប។

អ្វីដែលសំខាន់បំផុតនោះគឺ តិចនិចនៃការធ្វើពិសោធន៍ពីប្រវត្តិនៃបុគ្គលនោះមិនអាចប្រាប់អ្នកថាគេម្នាក់នោះនឹងមានសំណាងល្អ ឬ សំណាងអាក្រក់ទេ ហេតុអ្វីបានជាអ្នកដឹងថាគេម្នាក់នោះនឹងជួបនូវសំណាងល្អ ឬ សំណាងអាក្រក់ជាបញ្ហាសំខាន់? ចម្លើយងាយៗគឺបើអ្នកជួលមនុស្សដែលនឹងជួបសំណាងអាក្រក់ក្នុងឆ្នាំនេះ ឬ ក្នុងកំឡុងជីវិតនេះ ឬ ជួនកាលអាចកំពុងប្រឈមនឹងបញ្ហាច្បាប់ ឬ បញ្ហាផ្សេងៗដែរអ្នកអាចនឹងទទួលផលនៃសំណាងអាក្រក់នោះ ឬនៅជាប់បញ្ហាជាមួយគេម្នាក់នោះ។ ដូច្នេះអ្នកគួរតែធ្វើការបែងចែកឱ្យដាច់ថាជាការល្អ ឬ មិនល្អដែលជួលគេម្នាក់នោះក្នុងឆ្នាំនេះ ឬ ជួនកាលបើរង់ចាំមួយឆ្នាំទៀតអាចនឹងល្អជាង ត្រូវធ្វើការសម្រេចចិត្តឱ្យបានច្បាស់លាស់មុននឹងនាំមនុស្សម្នាក់នោះចូលមកក្នុងស្ថាប័នរបស់អ្នក។

ក្នុងវគ្គជាបន្តទៀត យើងខ្ញុំសូមបង្ហាញអ្នកឱ្យស្គាល់នូវមនោទស្សន៍មូលដ្ឋានរបស់មៀនសៀង មានដូចជាផែនទី100ឆ្នាំរបស់ទឹកមុខ និងវាំងទាំង12របស់ទឹកមុខ រួមទាំងការអធិប្បាយថាយើងមិនត្រឹមតែអាចប្រើលក្ខណៈផ្សេងៗដែលខុសគ្នានៃទឹកមុខដើម្បីមើលឱ្យដឹងពីជោគសំណាងនិងជោគជតារបស់គេម្នាក់នោះទេ គឺថែមទាំងអាចមើលដឹងពីឧបនិស្ស័យនិងលក្ខណៈផ្សេងៗលើបុគ្គលិកលក្ខណៈបានទៀតផង។ ម្យ៉ាងទៀត ស្ថាប័នជំនួញនីមួយៗតែងតែមានការ សម្ងាត់រៀងៗខ្លួន ទើបថៅកែទាំងឡាយតែងតែចង់ បានបុគ្គលិកឬមនុស្សជំនិតដែលមានមាត់ជិតល្អ (អាចលាក់ការសម្ងាត់នានាបាន)។



www.elibraryofcambodia.org

# ការមើលទឹកមុខ
# ធម្មជាតិមនុស្សដែលជាប់មកតាំងពីកំណើត

ការពិនិត្យមើលមុខមិនមែនជារឿងលំបាកដូចដែលអ្នកគិតនោះទេ ព្រោះតាមពិតទៅពួកយើងភាគច្រើនក៏ធ្លាប់មើលទឹកមុខគេខ្លះរួចមកហើយដែរ ដូចជាពួកយើងភាគច្រើនអាចប្រាប់បានថាអ្នកនេះមានសេចក្តីសុខ ឬ ទុក្ខ ខូចអារម្មណ៍ ឬ រីករាយ តាមរយៈទឹកមុខរបស់គេ។ ជាការពិតណាស់ហើយ មៀនសៀងគឺជាសាស្ត្រដែលសិក្សាពីលក្ខណៈផ្សេងៗទាំងអស់នេះ ឬ សិក្សាលម្អិតពីចំណុចផ្សេងៗនៃទឹកមុខដោយចាត់ជាក្រុម។

ចូរចងចាំទុកថាយើងម្នាក់ៗក៏អាចជាអ្នកចេះមើលទឹកមុខដោយញាណនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើងស្រាប់ហើយ។ អ្នកបានអានដល់វគ្គចុងក្រោយនៃសៀវភៅនេះអ្នកនឹងអាចមើលទឹកមុខរបស់បុគ្គលដទៃបានយ៉ាងត្រឹមត្រូវសមស្របតាមក្បួនខ្នាតដ៏ជាក់លាក់។





www.elibraryofcambodia.org

# មេរៀនទី ២
# មូលដ្ឋានពិតនៃការមើលទឹកមុខ

ចំណុចចាប់ផ្ដើមដ៏សំខាន់នៃការមើលទឹកមុខ គឺត្រូវចេះស្គាល់ទម្រង់នៃមុខនីមួយៗឱ្យបានច្បាស់លាស់សិន។ ទម្រង់មុខគឺជាចំណុចចាប់ផ្ដើមដ៏ល្អក្នុងការមើលទឹកមុខ ព្រោះវាជាមូលដ្ឋានដ៏សំខាន់នៃមេរៀននេះ។ ហ្វឹកហាត់ការមើលទឹកមុខរបស់អ្នកដោយធ្វើការបែងចែកនូវភាពខុសគ្នាលើទម្រង់មុខ។ ទម្រង់មុខនឹងជួយឱ្យអ្នកបានដឹងពីលក្ខណៈមូលដ្ឋាន ឬ យល់ពីលក្ខណៈទូទៅរបស់បុគ្គលនោះ។

មូលដ្ឋានដ៏សំខាន់ទាំង5គឺការប្រើធាតុទាំងប្រាំនិងវដ្ដចក្រប្រាំធាតុគឺធាតុភ្លើង ធាតុដី ធាតុមាស ធាតុឈើ និងធាតុទឹក។






www.elibraryofcambodia.org




ការមើលទឹកមុខត្រូវបានគេចាត់ទុកថាជារូបមួយបែបនៃនរលក្ខណៈសាស្ត្រដែលជាសិល្បៈមួយក្នុងចំណោមសិល្បៈទាំង5របស់ចិន។

អ្នកមើលទឹកមុខមិនត្រឹមតែសង្កេតលក្ខណៈផ្សេងៗនៃទឹកមុខប៉ុណ្ណោះទេ តែត្រូវបញ្ចូលទ្រឹស្តី5ធាតុចូលជាមួយទឹកមុខ ហើយកំណត់ថាទំនាក់ទំនងរវាងធាតុទាំង5ផ្តល់ចំពោះការសង្កេតនិងការមើលទឹកមុខរបស់យើងយ៉ាងណាខ្លះ។ ដូចពេលខ្លះបុគ្គលម្នាក់មានរូបទម្រង់មុខធាតុភ្លើង យើងក៏ត្រូវសង្កេតមើលចិញ្ចើម ភ្នែក និងថ្ពាសរបស់គេដែរ ដើម្បីមើលឱ្យដឹងថាវាមានគុណសម្បត្តិសមស្របជាមួយទម្រង់មុខធាតុភ្លើង ឬ អត់។

យើងក៏ត្រូវមើលមាត់ដែលតាងឱ្យធាតុទឹកដើម្បីឱ្យដឹងថាវាមានផលចំពោះទម្រង់មុខធាតុភ្លើងឬអត់។ ត្រឹមត្រូវហើយដែលលក្ខណៈមួយ ឬ ផ្នែកមួយនៃទឹកមុខ ដូចជារូបទម្រង់អាចអានបានផ្សេងគ្នា តែដើម្បីឱ្យទទួលបាននូវចំណុចសរុបច្បាស់លាស់និងសុក្រិត្យទាក់ទងនឹងជោគសំណាងរបស់មនុស្សម្នាក់ ឬ ទាក់ទងនឹងផ្នែកណាមួយនៃជីវិតរបស់គេនោះ យើងត្រូវសង្កេតមើលឱ្យឃើញនូវផ្នែកផ្សេងៗលើទម្រង់មុខ នេះជាតិចនិចនៃការមើលទឹកមុខដែលហៅថាការមើលច្រើនបំផុត (ហ៊ុនលីវហ្វា)។ ដូច្នេះការស្វែងយល់ពីធាតុទាំង5ឱ្យបានល្អនិងការមានចំណេះដឹងទាក់ទងនឹងប៉ាជឺ ធាងមេឃទាំង10និងមែកដីទាំង12ខ្លះៗអាចជួយឱ្យយើងបែងចែកគុណភាពនៃទម្រង់មុខបានច្រើន។

ជាទូទៅទម្រង់មុខធាតុឈើគួរត្រូវបានបន្ថែមដោយលក្ខណៈនៃទម្រង់មុខធាតុទឹក។ ហេតុអ្វីទៅ? ព្រោះថាធាតុទឹកជួយផ្សើមធាតុឈើក្នុងវដ្តចក្រធាតុ។ ដូចគ្នានេះដែរបើទម្រង់មុខធាតុឈើមានលក្ខណៈធាតុមាសដែលរឹងមាំ វាបង្ហាញឱ្យឃើញពីការមិនមានជោគសំណាង ព្រោះក្នុងទ្រឹស្តី5ធាតុបានចែងថាធាតុមាសបំផ្លាញធាតុឈើ។



www.elibraryofcambodia.org

# ស្វែងយល់ពីធាតុទាំង៥(អ៊ូស៊ិង)

ទ្រឹស្តីធាតុ5 ឬ អ៊ូស៊ិងជាមូលដ្ឋានដ៏សំខាន់នៃការសិក្សាអភិទស្សនៈវិជ្ជាចិនដែលគ្របដណ្តប់លើសាស្ត្រពេទ្យចិនរហូតទៅដល់ហុងស៊ុយ តាំងពីបាជីររហូតទៅដល់ការមើលទឹកមុខ។ ជនជាតិចិនជឿជាក់ថាសាស្ត្រទាំងអស់ក្នុងចក្រវាឡរមែងមានទំនាក់ទំនងនឹងធាតុទាំង5គឺធាតុមាស ធាតុឈើ ធាតុទឹក ធាតុភ្លើង និងធាតុដី ហើយថាមពលរបស់វានឹងប្រែប្រួលហើយធ្វើប្រតិកម្មលើគ្នាទៅវិញទៅមក។




តាមការពិតអ៊ូស៊ិងទាក់ទងទៅនឹងថាមពលសំណាង 5 ប្រភេទដូចគ្នាដែលយើងប្រើពាក្យថា "មាស" "ឈើ" "ទឹក" "ភ្លើង" និង "ដី" ព្រោះវាផ្សំឡើងដោយគុណសម្បត្តិផ្សេងៗដែលមានលក្ខណៈស្រដៀងនឹងធម្មជាតិនៃថាមពលសំណាងទាំងប្រាំប្រភេទនោះ។ ក្នុងការសិក្សាអំពីធាតុទាំង5 មានបីវដ្តចក្រសំខាន់ៗដែលត្រូវធ្វើការស្វែងយល់ ហើយដឹងឱ្យច្បាស់នោះគឺវដ្តចក្រនៃការកកើតវដ្តចក្រនៃការស្រេក ស្រុត និងវដ្តចក្រនៃការបំផ្លាញ។

ការយល់ពីធម្មជាតិនិងការរៀបលំដាប់នៃធាតុទាំង5 អាចធ្វើឱ្យយើងយល់បានថាលក្ខណៈនីមួយៗនៃទឹកមុខរបស់មនុស្សធ្វើប្រតិកម្មលើគ្នាទៅវិញទៅមកយ៉ាងណាខ្លះ? យើងនឹងដឹងថាទឹកមុខយើងមានតុល្យភាព ឬ អត់តុល្យភាព។ ពេលទឹកមុខរបស់នរណាម្នាក់មានតុល្យភាពល្អមានន័យថាបុគ្គលនោះមានទឹកមុខ "មានភ័ព្វសំណាងល្អ"។

ការស្វែងយល់ពីធាតុទាំង5 អាចធ្វើបានងាយស្រួលបើអ្នកចេះប្រើវិបារម្មណ៍របស់អ្នក ព្រោះតាមការពិតទៅវាគឺជាបញ្ហាដ៏សាមញ្ញមួយតែប៉ុណ្ណោះ។


www.elibraryofcambodia.org

## វដ្តចក្រនៃការកកើត




ទឹកបន្ទើរមដើមឈើ ដូច្នេះហើយទើបធាតុទឹកបង្កើតធាតុឈើ ។ តែឈើជាឥន្ធនៈរបស់ភ្លើង ដូច្នេះហើយទើបធាតុឈើបង្កើតឱ្យមានធាតុភ្លើង ។ ចំណែកភ្លើងដុតវត្ថុធាតុឱ្យក្លាយទៅជាផេះ ដូច្នេះហើយទើបភ្លើងបង្កើតឱ្យមានធាតុដី ។ ដីជាកន្លែងដែលយើងអាចរកឃើញធាតុរ៉ែ ដូច្នេះហើយទើបធាតុដីបង្កើតឱ្យមានធាតុមាស ។ មាស ( លោហៈ ) ពេលវារលាយក្លាយទៅជាវត្ថុរាវ ដូច្នេះហើយទើបធាតុមាសបង្កើតឱ្យមានធាតុទឹក ។ ចរន្តទាំងអស់នេះយើងហៅថាចរន្ត ឬ វដ្តចក្រនៃការកកើត ។

## វដ្តចក្រនៃការស្រកស្រុត




ពេលធាតុមួយបង្កឱ្យកើតធាតុមួយទៀត ខ្លួនវានឹងចុះខ្សោយព្រោះត្រូវប្រើថាមពលរបស់វាដើម្បីបង្កើតធាតុមួយទៀត ។ ឧទាហរណ៍ដូចជាពេលធាតុដីបង្កើតធាតុមាស ធាតុមាសនឹងរឹងមាំឡើង តែធាតុដីមានការស្រកស្រុតទៅវិញ ។ វដ្តចក្រនៃការស្រកស្រុតគេប្រើច្រើនដើម្បីភាព "ស្ងប់" និងដើម្បី "កាត់បន្ថយ" ថាមពលនៃសំណាងអាក្រក់ ។ ដូច្នេះហើយសូមកុំប្រែន័យ "ការស្រកស្រុត" ថាជាន័យអវិជ្ជមាន ឬ ជារបស់ដែលមិនសមប្រាថ្នាឱ្យសោះ ។ ក្នុងវដ្តចក្រនៃការស្រកស្រុតនៃធាតុទាំង5គឺធាតុទឹកសម្រកធាតុមាស ធាតុមាសសម្រកធាតុដី ធាតុដីសម្រកធាតុភ្លើង ធាតុភ្លើងសម្រកធាតុឈើ ហើយធាតុឈើសម្រកធាតុទឹក ។



www.elibraryofcambodia.org

# វដ្ដចក្រនៃការបំផ្លាញ

នៅក្នុងអភិទស្សនៈវិជ្ជាចិនបានដាស់តឿនយើងថា ពាក្យបំផ្លាញ ការពារ ឬ ទប់ទល់ គ្រាន់តែជាពាក្យបកប្រែតែប៉ុណ្ណោះ មិនត្រូវផ្ដោតទៅលើវដ្ដចក្រថាវាជាភាពវិជ្ជមាន ឬ អវិជ្ជមាន ជាល្អ ឬ អាក្រក់ទេ។ វដ្ដចក្រនៃការបំផ្លាញល្អ ឬ អាក្រក់អាស្រ័យលើសភាពការណ៍ ជួនកាលក៏ចាំបាច់ត្រូវប្រើវដ្ដចក្រនៃការបំផ្លាញដើម្បីនាំយកមកនូវតុល្យភាពបំពេញលើអ្វីម្យ៉ាង។ ជាទូទៅ ពេលធាតុផ្សេងៗបំផ្លាញ ឬ ការពារហួសពេក ឬ ប្រឆាំងខ្លាំងពេក វាអាចធ្វើឱ្យបាត់បង់តុល្យភាព។ ព្រោះតាមធម្មជាតិនៃធាតុទាំង5 ត្រូវបានធ្វើឱ្យមានការផ្លាស់ប្ដូរអាចធ្វើឱ្យមានភាពមិនស្រួលកើតឡើងដែរ។ ធាតុទឹករំលត់ធាតុភ្លើង ធាតុភ្លើងកម្ទេចធាតុមាស ធាតុមាសកម្ចាត់ធាតុឈើ ធាតុឈើ (ឫសឈើ) ជ្រែកធាតុដី ហើយធាតុដីក៏កាត់ធាតុទឹក នេះជាដំណើរការរបស់វដ្ដចក្រនៃការបំផ្លាញ។ ពេលនេះអ្នកក៏អាចល្មមយល់បានហើយថាធាតុទាំង5 មានដំណើរការយ៉ាងដូចម្ដេចហើយ ឥឡូវយើងនាំគ្នាមកពិនិត្យមើល(អាន) អំពីទម្រង់មុខនិងគុណសម្បត្តិផ្សេងៗរបស់វាវិញ។








www.elibraryofcambodia.org

# មូលដ្ឋានធាតុ៥ នៃទម្រង់មុខ

ការប្រើរូបារម្មណ៍ឱ្យចេញជារូបភាពជាប្រការសំខាន់ណាស់ក្នុងការអានសៀវភៅនេះ ព្រោះមិនត្រូវចាំតែទម្រង់មុខប៉ុណ្ណោះទេ តែត្រូវខំព្យាយាមនឹកឱ្យឃើញពីរូបភាពធាតុទាំង5 នោះថាតើវាមានលក្ខណៈយ៉ាងដូចម្ដេច? ហើយវាធ្វើប្រតិកម្មនឹងគ្នាយ៉ាងដូចម្ដេច? ត្រូវប្រើរូបារម្មណ៍នឹកឱ្យឃើញពីទម្រង់របស់វា (ដុំឈើនោះមានលក្ខណៈដូចម្ដេច?) និងលក្ខណៈផ្សេងៗ (ដុំថ្មធំធ្វើឱ្យអ្នកមានចំណាប់អារម្មណ៍ដូចម្ដេចខ្លះ?) វិធីនេះមិនត្រឹមតែជួយឱ្យអ្នកចងចាំលក្ខណៈពិសេសនៃរូបទម្រង់មុខបានប៉ុណ្ណោះទេ គឺវាអាចជួយឱ្យអ្នកបែងចែកនិងដឹងថា ទម្រង់មុខណាជាធាតុអ្វីនៅពេលដែលអ្នកពិនិត្យមើលទឹកមុខគេទៀតផង ។

| ធាតុ | លក្ខណៈដែលខុសគ្នាច្បាស់ |
|---|---|
| 火 ធាតុភ្លើង  |  មុត ស្រួច បីជ្រុង |
| 木 ធាតុឈើ  |  បួនជ្រុង រូបពងក្រពើមូលទ្រវែង |
| 金 ធាតុមាស  |  មូល រូបស៊ុត |
| 水 ធាតុទឹក  |  ស្រគាំ មិនច្បាស់លាស់ |
| 土 ធាតុដី  |  បួនជ្រុងចតុកោណ ទូលាយ |



www.elibraryofcambodia.org

## ទម្រង់មុខធាតុឈើ អ្នកគិត

ជាធម្មតាទម្រង់មុខធាតុឈើមានលក្ខណៈមូលទ្រវែងហើយស្គមស្តើង។ ទម្រង់មុខធាតុនេះមានទម្រង់បីជ្រុង ថ្ងាសទូលាយតែមានចង្កាខ្លីតូច។ មនុស្សមានទម្រង់មុខធាតុឈើរមែងមានលក្ខណៈផ្សេងៗនៃទម្រង់មុខដែលស៊ីចង្វាក់គ្នាគឺច្រមុះស្រួច ត្រចៀកវែង និងចិញ្ចើមវែង។ ចំណែកឯរាងកាយរបស់មនុស្សទម្រង់មុខធាតុឈើមានសណ្ឋានដូចជា "ដើមឈើ" គឺមានន័យថាពួកគេខ្ពស់ ហើយស្គម។



ទម្រង់មុខធាតុឈើ

ក្នុងតម្រាមៀនសៀងបុរាណបានបង្ហាញពីលក្ខណៈទម្រង់មុខធាតុឈើថាជាមនុស្សដែលមាំទាំមានចិត្តល្អ ទូលំទូលាយ និងមានចិត្តមេត្តា ថែមទាំងមានអធ្យាស្រ័យល្អទៀតផង ព្រោះធាតុឈើជាធាតុតែមួយក្នុងចំណោមធាតុទាំង5ដែលតែងតែរីកធំធាត់ជានិច្ច។ ចំណែកឯធាតុភ្លើង ធាតុទឹក ធាតុមាស និងធាតុដីអាចរីកធំធាត់ទៅបានបើសិនជាមានជំនួយ ឧទាហរណ៍ដូចជា ធាតុភ្លើងចាំបាច់ត្រូវមានធាតុឈើចាំជួយទើបអាចធំធាត់។



www.elibraryofcambodia.org

មនុស្សទម្រង់មុខធាតុឈើជាមនុស្សឧស្សាហ៍ព្យាយាម ពុះពារដើម្បីឈានទៅរកភាពជោគជ័យ ។ យើងដឹងហើយថាដើមឈើពុំអាចឈរនៅស្ងៀមនោះទេគឺវារីកដុះដាលលូតលាស់ធំធាត់ជានិច្ច ។ ដូច្នេះហើយ ទើបមនុស្សទម្រង់មុខធាតុឈើជាមនុស្សធ្វើអ្វីយឺត១ តែជានិច្ចកាលតែងតែជាអ្នកឈ្នះការប្រកួតផ្សេង១ ។

មនុស្សទម្រង់មុខធាតុឈើសមស្របសម្រាប់អាជីពជាគ្រូពេទ្យ ការស្រាវជ្រាវនិងការអភិវឌ្ឍ ការសិក្សា ឬ ការគ្រប់គ្រងសង្គម ។ គេជាមនុស្សអាចបង្រៀន សិក្សាស្រាវជ្រាវនិងអាចនាំមកនូវភាពរីកចម្រើន ។ មិនតែប៉ុណ្ណោះ គេក៏អាចទទួលជោគជ័យក្នុងផ្នែកគ្រប់គ្រងសង្គមនិងផ្នែកនយោបាយផងដែរ ព្រោះទម្រង់មុខធាតុឈើជាអ្នកចេះគិតគូរប្រុងប្រៀប និងប្រយ័ត្នប្រយែងដែលអាចធ្វើឱ្យពួកគេក្លាយជាអ្នកយុទ្ធសាស្ត្រនិងជាអ្នកធ្វើផែនការនយោបាយដ៏ល្អ ។



ឥឡូវនេះយើងនឹងបង្ហាញអំពីរបៀបនៃការមើលទឹកមុខដែលមានលក្ខណៈស្មុគស្មាញជាងមុនបន្តិច ។ ធាតុឈើជាធាតុមួយដែលត្រូវការជំនួយ តើធាតុអ្វីដែលអាចជួយធាតុឈើបានទៅ? ចម្លើយគឺគ្មានអ្វីក្រៅពីធាតុទឹកនោះទេ ។

ក្នុងការសិក្សាអំពីការមើលទឹកមុខ តាមរយៈមេរៀននេះគឺរបៀបមើលមាត់ ។

មាត់របស់មនុស្សធាតុឈើដែលមានតុល្យភាពគឺមានន័យថាបបូរមាត់លើនិងបបូរមាត់ក្រោមមានទម្រង់និងខ្នាតប៉ុនគ្នា គឺជាមនុស្សដែលអាចទទួលជោគជ័យបានដោយសារសេចក្តីព្យាយាមខិតខំប្រឹងប្រែង ។

នៅក្នុងជីវភាពប្រចាំថ្ងៃ បើកំណាត់ឈើណោមានសភាពរឹងមាំល្អ គេអាចយកមកប្រើប្រាស់ដើម្បីធ្វើជា "ប្រយោជន៍ផ្សេង១" បាន ។ ដូច្នេះទឹកមុខធាតុឈើដែលមាំទាំផ្គួបជាមួយនឹងលក្ខណៈធាតុមាសនោះ វាបានបង្ហាញឱ្យឃើញថាគេជាមនុស្សដែលមានជំនាញលើកិច្ចការ



www.elibraryofcambodia.org

គណនេយ្យ មានបំនិនក្លាយជាអ្នកដឹកនាំ ឬ មានអំណាចដែលធ្វើឱ្យគេមានស្ថានភាពនិងឋានៈលេចធ្លោក្នុងសង្គម ។ ធាតុមាសជំនួសដោយថ្ពាល់ ទម្រង់មុខធាតុឈើដែលមាំទាំគួរតែមានថ្ពាល់ធំល្មម ព្រោះការមានត្រឹមតែធាតុមាសគឺវាគ្រប់គ្រាន់ទៅហើយ ។ លក្ខណៈដូចនេះបង្ហាញថាគេជាអ្នកជំនាញខាងការគិតគូរ ហើយក៏ជាអ្នកសម្រេចចិត្តដ៏កំពូលទៀតផង ។

បើទម្រង់មុខមនុស្សធាតុឈើមានថ្ពាល់ធំពេកនោះ ធាតុឈើនឹងត្រូវលុបដោយធាតុមាស ហើយប្រការនេះបង្ហាញថាគេជាមនុស្សដែលចូលចិត្តជំទាស់ ឬ មានគំនិតគ្មានហេតុផល ។ អ្នកមានទម្រង់មុខធាតុឈើជាមនុស្សចូលចិត្តគិតគូរ ច្នៃប្រឌិតធ្វើអ្វីផ្សេងៗ ភាគច្រើនតែងកើតមាននៅរដូវស្លឹកឈើលាស់ ដែលជារដូវសំខាន់របស់ធាតុឈើ ។ ម្យ៉ាងទៀត គម្រោងការនិងការខិតខំផ្សេងៗដែលចាប់ផ្តើមនៅខែកុម្ភៈ មីនា និងមេសា តែងតែជួបនូវផលសម្រេច ឬឈានទៅមុខដោយស្រួល ព្រោះថាមពលនៃធាតុឈើមានការរីកចម្រើនខ្លាំងក្នុងខែដូចដែលបានជម្រាបខាងលើនេះឯង ។



ទម្រង់មុខធាតុឈើដែលមានថ្ពាល់ធំ



www.elibraryofcambodia.org

## ទម្រង់មុខធាតុទឹក_ជាថៅកែ ឬ ជាមេការ

ធាតុទឹកមិនមានរូបទម្រង់តែមួយបែប ឬ ទម្រង់ស្លាប់មួយក្រឡានោះទេ ដូច្នេះហើយទើបមនុស្សមានទម្រង់មុខធាតុទឹកតែងតែមានលក្ខណៈនិងទម្រង់មុខមិនសូវច្បាស់លាស់ទេ។ ភាគច្រើនគឺរូបមូល ឬ ធាត់ ស្បែកស្រគាំ ឬ ពណ៌ត្នោត។ មនុស្សមានទម្រង់មុខធាតុទឹកជានិច្ចកាលតែងតែទាប ឬ ខ្លួនតូចបន្តិច ឬ ពេលខ្លះអាចមានទម្ងន់ខ្លួនលើសដែរ តែពុំសូវច្រើនណាស់ណាទេ។ ពួកគេច្រើនជាមនុស្សមានសាច់ឡើងក្រម៉ាប់ៗជាមនុស្សដុះពោះនិងមានត្រគាកធំ។



ទម្រង់មុខធាតុទឹក

មនុស្សទម្រង់មុខធាតុទឹកអាចមិនមែនជាទម្រង់មុខរបស់អ្នកដឹកនាំទេ តែពួកគេសម្របខ្លួនឱ្យស្របតាមស្ថានភាពផ្សេងៗ។ ពេលខ្លះធ្វើឱ្យមនុស្សគ្រប់គ្នាគិតថាពួកគេច្រើនតែពូកែយករួចខ្លួន តែតាមពិតទៅពួកគេជាមនុស្សដែលអាចទទួលខុសត្រូវលើផ្នែកលុយកាក់និងអាជីពរបស់ខ្លួន ដោយការប្រឹងប្រែងជម្នះនូវឧបសគ្គផងទាំងពួង ព្រោះពួកគេប្រៀបបានដូចជា



www.elibraryofcambodia.org

ទឹកដែលប្តូររូប ឬ ទម្រង់រូបរាងតាមវត្ថុនានាដែលផ្ទុកវា។ មនុស្សទម្រង់មុខធាតុទឹកមាន សមត្ថភាពក្នុងការសម្របខ្លួនខ្ពស់ ហើយមានភាពវាងវៃណាស់ ធ្វើឱ្យពួកគេភាគច្រើនជាមេការ ឬ អ្នកជំនួញ។ ក្នុងការសិក្សាអំពីធាតុទាំង៥នោះបានឱ្យដឹងថា មនុស្សមានទម្រង់មុខធាតុទឹក ជាមនុស្សឆ្លាត មានបញ្ញាល្អ និងមានសមត្ថភាពក្នុងការសម្រេចចិត្តបានយ៉ាងត្រឹមត្រូវ។

ជួនកាលមនុស្សទម្រង់មុខធាតុទឹកត្រូវគេមើលឃើញថាជាមនុស្សឆក់ឱកាស ជាមនុស្ស ដែលស្វែងរកមាសប្រាក់តាមគ្រប់រូបភាព ឬ ជាមនុស្សស្រេកឃ្លានអំណាច ហើយពេលខ្លះជា មនុស្សគ្មានគោលជំហរច្បាស់លាស់ ទោះជាការពិតពួកគេជាមនុស្សមានបញ្ញាឈ្លាសវៃក៏ ដោយ។ មនុស្សមានទម្រង់មុខធាតុទឹកតែងតែអភិវឌ្ឍជំរុញខ្លួនឆ្ពោះទៅរកភាពជោគជ័យក្នុង ការរកលុយទាំងវ័យក្មេង។ ក្រៅពីនេះ ពួកគេនៅមានភាពជោគជ័យលើវិស័យនយោបាយ ឬ ជោគជ័យលើផ្នែកជំនួញក្នុងវ័យដំបូងនៃជីវិតរបស់ពួកគេទៀតផង។

ក្នុងការមើលទឹកមុខ យើងត្រូវចងចាំជានិច្ចថាមានមូលដ្ឋានទូទៅនិងមានមូលដ្ឋាន គុណសម្បត្តិដែលសមស្រប។ មនុស្សម្នាក់អាចមានទឹកមុខធាតុទឹក តែលក្ខណៈខ្លះនៃទឹកមុខ អាចកំណត់មូលដ្ឋានទូទៅស៊ីចង្វាក់ជាមួយគុណសម្បត្តិដែលសមស្រប ឬ មិនសូវសមស្រប។ ឧទាហរណ៍ដូចជាមនុស្សមានទម្រង់មុខធាតុទឹកដែលមានមាត់ ឬ ចង្កាធំហួស(មានន័យថា មានមាត់ធំតែបបូរមាត់ស្តើងឬចង្កាស្រួចហើយហុច) តែងមានឧបនិស្ស័យដែលគួរឱ្យសង្ស័យថា មានទំនោរជាមនុស្សដែលមានចិត្តជាទេវទត្តមាត់ជាទេវតា។

ហេតុផលដែលនៅខាងក្រោយជាអ្វី? ក្នុងសាស្ត្រានៃការមើលទឹកមុខនោះចាត់ទុកថា មាត់និងចង្កាជាធាតុទឹក។ ពេលដែលមាត់និងចង្កាធំហួសយកមកផ្គុំជាមួយនឹងទម្រង់មុខធាតុ ទឹកបង្ហាញថាមានទឹកច្រើនហួស នេះគឺជាមូលហេតុដែលធ្វើឱ្យឧបនិស្ស័យរបស់បុគ្គលនោះ គួរឱ្យសង្ស័យថាជាមនុស្សឆ្លាតវាងវៃប៉ិនប្រសប់ខាងបោកបញ្ឆោតគេ។



www.elibraryofcambodia.org



ទម្រង់មុខធាតុទឹកដែលមានមាត់ធំហួសពេក

អ្នកដែលមានទម្រង់មុខធាតុទឹកហើយមានស្បែកស្លេកតែងតែជាមនុស្សពូកែនិយាយមានសតិបញ្ញាល្អ និងជាមនុស្សសម្រេចចិត្តលឿន ហើយសម្រេចចិត្តដោយប្រើសតិបញ្ញាទៀតផង។ មនុស្សទម្រង់មុខធាតុទឹកដែលមានស្បែកស្លេកប្រៀបបាននឹង "ទឹកថ្លា" ព្រោះទឹកថ្លាស្អាតប្រៀបដូចជាគំនិតនិងបុគ្គលិកលក្ខណៈរមែងមានរស្មីភ្លឺច្បាស់។ ចំណែកឯទម្រង់មុខធាតុទឹកដែលមានស្បែកស្រគាំគឺប្រៀបដូចជាទឹកល្អក់ដូច្នោះដែរ ដែលអាចបង្ហាញថាគំនិតរបស់ពួកគេមានលក្ខណៈស្រអាប់និងមិនសូវច្បាស់ទៅតាមនោះដែរ។

ប្រិយមិត្តឃើញទេថាងាយស្រួលប៉ុណ្ណាពេលដែលយើងយល់អំពីធម្មជាតិមូលដ្ឋាននៃបុគ្គលិកលក្ខណៈ? ឥឡូវនេះសូមបន្តការអានអំពីធាតុមាសវិញម្តង...



www.elibraryofcambodia.org

# ទម្រង់មុខធាតុមាស  អ្នកដឹកនាំ

ជាទូទៅយើងអាចសង្កេតឃើញទម្រង់មុខធាតុមាសបានដោយងាយស្រួលព្រោះទម្រង់មុខធាតុមាសតែងមានទម្រង់មូល ហើយគ្រោងឆ្អឹងមានលក្ខណៈច្បាស់លាស់ ធ្វើឱ្យទឹកមុខរបស់ពួកគេមើលទៅមានលក្ខណៈរឹងមាំ ដាច់ខាត ហើយស្រួចស្រាល់។ ទម្រង់មុខធាតុមាសតែងតែមានឆ្អឹងមានលក្ខណៈដាច់ខាត ជាធម្មតាពួកគេតែងមានទម្រង់មុខស្រដៀងស៊ុត មានចង្កា និងថ្ពាសទូលាយ ហើយរមែងមានស្បែកស្លេក។



ទម្រង់មុខធាតុមាស

ក្នុងការសិក្សាអំពីធាតុទាំង៥ ធាតុមាសត្រូវគេតំណាងឱ្យភាពយុត្តិធម៌ ភាពត្រឹមត្រូវមើល ប្រយោជន៍រួមជាធំ ភាពក្លាហាន ភាពរឹងប៉ឹង និងភាពមុះមុត។



www.elibraryofcambodia.org

មនុស្សដែលមានទម្រង់មុខធាតុមាសជាមនុស្សដែលមានភាពក្លាហាននិងស្មោះត្រង់ មានភាពស្វិតស្វាញនឹងការងារ ថែមទាំងគោរពច្បាប់ ឬ ប្រយុទ្ធនូវអ្វីដែលពួកគេមានជំនឿជឿជាក់ទៀតផង។ មនុស្សមានទម្រង់មុខធាតុមាសជាមនុស្សប្រយ័ត្នប្រយែងល្អិតល្អន់ក្នុងការសម្រេចចិត្ត តែងតែថ្លឹងថ្លែងល្អអាក្រក់មុននឹងធ្វើអ្វីមួយ មនុស្សធាតុមាសតែងតែសាកសមនឹងការងារច្បាប់ ឬ ការគ្រប់គ្រង។ ពួកគេកើតមកមានទំនោរជាអ្នកដឹកនាំពីធម្មជាតិ ហើយតែងតែផ្តល់ការគាំទ្រដល់អ្នកដែលនៅក្បែរខ្លួនគេជានិច្ច។

ប៉ុន្តែ ពេលខ្លះមនុស្សមានទម្រង់មុខធាតុមាសជាមនុស្សឆាប់ខឹង ហើយចូលចិត្តគិតអ្វីលើផ្លូវអាក្រក់ទៀតផង។ ពេលនេះអ្នកប្រហែលជាឆ្ងល់ហើយថាយើងអាចដឹងពីគុណសម្បត្តិនិងគុណវិបត្តិទាំងអស់នេះបានយ៉ាងដូចម្តេច។ ចូរអ្នកព្យាយាមនឹកឃើញឱ្យចេញជារូបភាព ឬ រូបារម្មណ៍ ពេលដែលអ្នកធ្វើឱ្យធាតុមាសក្តៅគឺ វានឹងក្តៅយូរ ដូច្នេះហើយទើបមនុស្សធាតុមាសបាត់បង់ភាពត្រជាក់ត្រជុំរបស់ខ្លួនបានដោយងាយ បើពួកគេត្រូវគេញុះញង់បាន។ នេះហើយជាហេតុផលដែលមនុស្សមានទម្រង់មុខធាតុមាសជាមនុស្សចូលចិត្តគិតផ្លូវអាក្រក់នោះ។ ជាធម្មតាទៅហើយដែលគេថាមនុស្សមានទម្រង់មុខធាតុមាសសម្រេចចិត្តបានដាច់ស្រឡះល្អ តែបើមុខគេឡើងឆ្អឹងហួស ឬ គ្រោងឆ្អឹងមុខចេញច្បាស់ហួស( ទម្រង់មុខធាតុមាសកម្រមានចេញឆ្អឹងណាស់) ឬ បើគេម្នាក់នោះភ្នែកជ្រៅវិញ គេនឹងក្លាយជាមនុស្សសម្រេចចិត្តយឺតទៅវិញ។



ទម្រង់មុខធាតុមាសដែលមានចង្កាតូច ឬ ថ្ងាសទូលាយ គឺជាមនុស្សចូលចិត្តយកគំនុំមកដាក់ក្នុងចិត្ត គឺគេមិនអាចអត់ឱនឱ្យអ្នកដែលធ្វើឱ្យគេខឹងនោះទេ។



www.elibraryofcambodia.org

# ទម្រង់មុខធាតុភ្លើង អ្នកផ្ដល់នូវភាពរីករាយ

ទម្រង់មុខធាតុភ្លើងមានផ្នែកកណ្ដាលទូលាយ (បរិវេណត្រង់ច្រមុះ) ហើយស្រួចចង្អៀតត្រង់បរិវេណខាងលើ (បរិវេណថ្ងាស) ។ វិធីសង្កេតមើលទម្រង់មុខមនុស្សធាតុភ្លើងមានលក្ខណៈងាយស្រួលគឺមើលរកមនុស្សដែលមានថ្ងាសចង្អៀតតូចនិងចង្កាទូលាយ ។ មនុស្សទម្រង់មុខធាតុភ្លើងមើលទៅមានលក្ខណៈដាច់ខាត ពួកគេមិនមែនជាមនុស្សធាត់ តែមានច្រមុះនិងកំពកថ្ពាល់ច្បាស់ ទម្រង់មុខធាតុភ្លើងតែងមានស្បែកចេញពណ៌ក្រហម ហើយមានភ្នែកដែលទាក់ទាញអារម្មណ៍អ្នកដទៃនិងមានបារមី ។



ទម្រង់មុខធាតុភ្លើង

ក្នុងការសិក្សាលើធាតុទាំង៥ ធាតុភ្លើងមានទំនាក់ទំនងនឹងកិរិយាមាយាទល្អ រួមមានភាពទន់ភ្លន់ ការឱនលំទោន និងភាពស្រស់ស្អាត ។ ដូច្នេះហើយទើបមនុស្សដែលមានទម្រង់មុខធាតុភ្លើងច្រើនមានកិរិយាមាយាទល្អនិងការប្រព្រឹត្តល្អ នេះមកពីធាតុភ្លើងជាធាតុមួយដែលមានទំនាក់ទំនងនឹងសោភ័ណនិងមានអារម្មណ៍លើ "មុខមាត់" របស់គេ ។



www.elibraryofcambodia.org

ក្រសៃភ្នែករបស់គេមានទំនាញស្រូបដោយពន្លឺនិងភាពស្រស់ថ្លា ដូច្នេះហើយទើបមនុស្សធាតុភ្លើងច្រើនធ្វើការក្នុងការងារកម្សាន្ត ទំនាក់ទំនងអ្នកសិល្បៈ ឬ ទំនាក់ទំនងជាមួយប្រជាជនជាដើម ។

ធាតុភ្លើងគឺជាធាតុរុករាននពង្រីកខ្លួន ដូច្នេះទើបមនុស្សទម្រង់មុខធាតុភ្លើងតែងតែចូលចិត្តចែករំលែកគំនិតនិងក្តីស្រមៃផ្សេងៗរបស់ពួកគេជាមួយអ្នកដទៃ ។ ពួកគេច្រើនជាមនុស្សចូលចិត្តនិយាយអូសទាញធ្វើខ្លួនឱ្យមានឥទ្ធិពលលើអ្នកដទៃ ហើយអាចផ្តល់កម្លាំងចិត្តឱ្យអ្នកដទៃបានយ៉ាងល្អ ។

មនុស្សចាស់តែងតែនិយាយប្រាប់ក្មេងថាកុំឱ្យលេងភ្លើងព្រោះភ្លើងវាអាចធ្វើឱ្យយើងរលាក ដូច្នេះហើយទើបមនុស្សមានទម្រង់មុខធាតុភ្លើងច្រើនជាមនុស្សក្លាហាន ស្មុះស្មារ តែខុសត្រង់ឆាប់ខឹងបន្តិច ។

មនុស្សទម្រង់មុខធាតុភ្លើងជាអ្នកផ្សងគ្រោះថ្នាក់ ដែលតែងតែបំពេញតួនាទីរបស់ខ្លួនឆាប់រហ័សលឿនតាមតម្រូវការ តែចូលចិត្តអួតអាងបន្តិច ។ ជាធម្មតាធាតុភ្លើងតែងពូកែខាងកីឡា ការពត់ពេនរាំ ឬ ការបង្ហាញសមត្ថភាពខាងផ្លូវកាយ ។ ធាតុភ្លើងជំនួសឱ្យភាពភ្លឺថ្លា ដូច្នេះហើយទើបមនុស្ស ដែលមានទម្រង់មុខនេះច្រើនតែជាមនុស្សឆ្លាត មានចំណុចគួរទាក់ទាញ ឬ មានទំនាញដូចជាមេដែក តែងតែមានសតិបញ្ញាល្អនិងមានការគិតច្នៃប្រឌិតខ្ពស់ ។



ក្នុងពេលដែលយើងមើលទៅឃើញថាធាតុភ្លើងមានលក្ខណៈភ្លឺថ្លា តែខាងក្នុងរបស់វាបែរជាមានលក្ខណៈ "ប្រហោងធ្លុង" ទៅវិញ ។ ដូច្នេះហើយ ទើបមនុស្សមាន ទម្រង់មុខធាតុភ្លើងតែងតែជាមនុស្សពុំសូវមាន ទំនុកចិត្តលើខ្លួនឯង ហើយជួនកាលក៏ពុំមាន ទំនុកចិត្តលើអ្នកដទៃដែរ ទាំងក្នុងពេលដែលសភាពខាង ក្រៅរបស់គាត់មានលក្ខណៈដូចនោះដែរ ។



www.elibraryofcambodia.org

ជាទូទៅ ទំហំនិងទម្រង់របស់ភ្លើងឥតទៀងទេ ដូច្នេះហើយទើបមនុស្សទម្រង់មុខធាតុភ្លើងមានលក្ខណៈអន់ខ្សោយក្នុងពេលខ្លះ ពួកគេមិនទុកចិត្តនរណាងាយៗទេ ហើយតែងតែចូលចិត្តចាត់ការបញ្ហាផ្សេងៗដោយខ្លួនឯង។



ទម្រង់មុខធាតុភ្លើងដែលមានមាត់ហុច

តើនឹងមានអ្វីកើតឡើងបើអ្នកឃើញមនុស្សទម្រង់មុខធាតុភ្លើងមានមាត់លេចធ្លោហើយហុចខ្លាំង? តើអ្នកនៅចាំបានទេដែលយើងបាននិយាយថាមាត់គឺជាធាតុទឹក? មាត់ដែលហុចហួសបង្ហាញឱ្យឃើញពីធាតុទឹកដែលមានលក្ខណៈរឹងមាំ នេះបង្ហាញឱ្យឃើញពីភាពមិនមានតុល្យភាពនៃធាតុផ្សេងៗ។ ក្នុងសាស្ត្រនៃការមើលទឹកមុខយើងហៅលក្ខណៈនេះថាធាតុភ្លើងនិងធាតុទឹកជួបគ្នា វាបង្ហាញឱ្យឃើញថាមនុស្សម្នាក់នោះមានការគិតជ្រុលហួសហេតុ ឬមានការប្រព្រឹត្តជ្រុលហួសហេតុ។



www.elibraryofcambodia.org



ទម្រង់មុខធាតុភ្លើងដែលមានថ្ពាល់ធំ

ចំណែកឯទម្រង់មុខធាតុភ្លើងដែលផ្សំនឹងកំពកថ្ពាល់ធំគឺជាការល្អប្រសើរណាស់ ។ ថ្ពាល់ជំនួសឱ្យធាតុមាស ហើយក្នុងករណីនេះទម្រង់មុខធាតុមាសដែលមានថ្ពាល់លេចធ្លោគេហៅថារូបបែបធាតុភ្លើងលាយធាតុមាស នេះគឺជាទម្រង់មុខរបស់មនុស្សឧស្សាហ៍ព្យាយាមនិងយកចិត្តទុកដាក់ចំពោះការងារ ។



www.elibraryofcambodia.org

## ទម្រង់មុខធាតុដី អ្នកប្រតិបត្តិ

មនុស្សដែលមានទម្រង់មុខធាតុដីគឺប្រភេទមនុស្សដែលមានទឹកមុខ ឬ ទម្រង់មុខដូចដុំថ្មធំមួយអ៊ីចឹង! ពួកគេមានមុខធំទូលាយ រង្វះមាត់ធំ ច្រមុះធំ ត្រចៀកធំ ហើយចិញ្ចើមបះតិចៗ ទម្រង់មុខពួកគេមើលទៅដូចបួនជ្រុងចតុកោណកែងស្ទើរ។ ជាធម្មតា មនុស្សទម្រង់មុខធាតុដីតែងតែជាមនុស្សស្ងប់ស្ងាត់និងស្ងៀមស្ងាត់បំផុតនៅក្នុងចំណោមមិត្តភក្តិ។ មិនតែប៉ុណ្ណោះពួកគេមានចិត្តត្រជាក់ ចូលចិត្តលាក់ខ្លួន ទោះបីត្រូវស្ថិតនៅក្នុងស្ថានការណ៍ច្របូកច្របល់យ៉ាងណាក៏ដោយក៏ពួកគេនៅតែរក្សាភាពស្ងប់ស្ងាត់បានដែរ។ និយាយរួមទៅគឺគេចូលចិត្តគិតអ្វីតែម្នាក់ឯង។



ទម្រង់មុខធាតុដី

ក្នុងការសិក្សាពីធាតុទាំង5 ធាតុដីជាធាតុតែមួយគត់ដែលមិនធ្វើចលនា។ ដូច្នេះហើយទើបបានជាមនុស្សទម្រង់មុខធាតុដីចាំបាច់ត្រូវការកម្លាំងជំនួយចាំជំរុញ។ ប៉ុន្តែបើកម្លាំងជំរុញធម្មតាៗ នោះពិតជាពុំអាចយកមកប្រើជាមួយមនុស្សធាតុដីបានទេ។ សម្រាប់ពួកគេចាំបាច់ត្រូវមានហេតុផលច្បាស់លាស់ក្នុងការប្រតិបត្តិអ្វីមួយ។ ទោះបីជាមនុស្សទម្រង់មុខធាតុដីភាគច្រើនជាមនុស្សចូលចិត្តពន្យារពេលក៏ដោយ ក៏មិនមែនមានន័យថាពួកគេមានកម្រិតបញ្ញាទាបនោះទេ។



www.elibraryofcambodia.org

ហេតុអ្វីក៏យើងនិយាយបែបនេះ? មនុស្សភាគច្រើនតែងតែគិតថា ដុំថ្មធំមួយដុំពុំចេះធ្វើអ្វី ឬ គ្មានប្រយោជន៍ទេ ប៉ុន្តែអ្នកភ្លេចគិតហើយថាពេលដែលដុំថ្មធំនោះចាប់ផ្តើមកម្រើក គឺវាអាចវាយកិនកម្ទេចនូវឧបសគ្គគ្រប់បែបយ៉ាងដែលពាំងនៅចំពោះមុខ។ មនុស្សដែលមានទម្រង់មុខធាតុដីពេលជឿស្អុងលើអ្វីមួយហើយ អាចក្លាយជាមនុស្សងប់ងល់និងគិតគូរអ្វីដែលប្រកបទៅដោយគំនុំ ពោរពេញទៅដោយល្បិចកលយ៉ាងសាហាវនិងមានអំណាច។

តែទោះជាយ៉ាងណាក៏ដោយក៏មនុស្សទម្រង់មុខធាតុដីគឺជាមនុស្សដ៏រឹងមាំ។ អ្នកមិនអាចមើលស្រាលគេបានឡើយ ព្រោះធាតុដីជាធាតុមួយក្នុងចំណោមធាតុទាំង5ដែលអ្នកអាចជឿទុកចិត្តបាន។ ជាទូទៅ យើងតែងតែប្រទះឃើញកំណប់ផ្សេងៗនៅក្នុងដី ដូច្នេះហើយទើបមនុស្សទម្រង់មុខធាតុដីគួរឱ្យជឿទុកចិត្ត ព្រោះពួកគេតែងតែរក្សាទុកការសម្ងាត់បានល្អ លើកលែងតែចំណុចមួយគឺ មនុស្សទម្រង់មុខធាតុដីមានច្រមុះក្រពឹតដែលក្នុងតម្រាមៀនសៀងបានចែងថាគេជាមនុស្សមានល្បិចកលច្រើន។

មនុស្សដែលមានទម្រង់មុខធាតុដីមានលក្ខណៈយឺតយ៉ាវស្ពឹកស្រពន់ តែពួកគេច្រើនតែជាសេដ្ឋីប្រាក់រាប់លាន ជាអ្នកប្រតិបត្តិ ឧស្សាហ៍ព្យាយាម និងមិនលំអៀង មានន័យថាពួកគេអាចមានទ្រព្យសម្បត្តិដ៏ច្រើនមហាសាលបានដោយសារការងារដ៏ត្រឹមត្រូវនិងសេចក្តីព្យាយាមរបស់ពួកគេ។ ស្រែដែលសាបព្រោះលើកដំបូងអាចមិនសូវបានផលល្អ តែនៅឆ្នាំក្រោយផ្ទៃដីនោះនឹងផ្តល់នូវទិន្នផលខ្ពស់។ ពួកគេមិនត្រឹមតែជាអ្នកមានប៉ុណ្ណោះទេ ការចេះអត់ធន់របស់មនុស្សទម្រង់មុខធាតុដីអាចធ្វើឱ្យពួកគេមានអាយុវែងនិងមានសុខភាពល្អទៀតផង។



មនុស្សទម្រង់មុខធាតុដីដែលមានច្រមុះក្រពឹត



www.elibraryofcambodia.org

## វាគ្រាន់តែជាថ្មមួយដុំ ឬ ជាឈើមួយដុំប៉ុណ្ណោះ

## យើងមិនទាន់អាចនិយាយបានថាវាជាធាតុអ្វីទេ

មិត្តអ្នកអានជាទីមេត្រីចូរកុំអាលភ័យអី បើអ្នកនៅមិនទាន់អាចបែងចែកទម្រង់មុខបានទេនោះ។ សូមចាំទុកថា មនុស្សមិនមានបំនិនប្រើប្រាស់បារម្មណ៍ដូចៗគ្នាទេ អ្នកខ្លះត្រូវការប្រើរយៈពេលយូរដើម្បីស្វែងយល់ពីរបៀបបែងចែកទម្រង់មុខ ដែលផ្ទុយពីអ្នកខ្លះដែលប្រើរយៈពេលខ្លី។ វិធីដ៏ល្អបំផុតគឺយើងត្រូវព្យាយាមសង្កេតមើលទឹកមុខ ឬ ធ្វើការហ្វឹកហាត់ជារឿយៗ។

ទម្រង់មុខខ្លះផ្សំដោយធាតុ2: អ្នកអាចនឹងបានជួបមនុស្សដែលមានទម្រង់មុខមិនប្រាកដជាធាតុអ្វី ឬ អ្នកមិនអាចជួបតែមនុស្សដែលមានទម្រង់មុខជាធាតុភ្លើង ឬ ធាតុទឹករហូតនោះទេ។ មនុស្សខ្លះមានលក្ខណៈស្មុគស្មាញ ហើយទម្រង់មុខរបស់ពួកគាត់ទៀតសោតក៏មានលក្ខណៈស្មុគស្មាញដែរ។ ជាទូទៅ មនុស្សតែងមានធម្មជាតិមូលដ្ឋានច្រើនជាងមួយ ឬ មានឧបនិស្ស័យនិងបុគ្គលិកលក្ខណៈច្រើន។ ដូច្នេះចូរកុំចម្លែកចិត្តឱ្យសោះ ពេលយើងឃើញមនុស្សម្នាក់មានទម្រង់មុខជា2ធាតុ ព្រោះពេលខ្លះអ្នកអាចនឹងបានជួបមនុស្សដែលមានទម្រង់មុខ 5ធាតុរួមបញ្ចូលគ្នាក៏មានដែរ។

វិធីដ៏ល្អគឺត្រូវសម្លឹងរកមើល "ធាតុដែលលេចចេញច្បាស់" ឬ លក្ខណៈដែលឃើញច្បាស់បំផុតនៃទម្រង់មុខ។ ក្រោយពីពេលដែលអ្នកកំណត់បានលក្ខណៈច្បាស់ ហើយអ្នកនឹងអាចកំណត់បានថាគេមានទម្រង់មុខអ្វី។



www.elibraryofcambodia.org

# ១០០តំណែងសម្រាប់ ១០០ឆ្នាំ

គន្លឹះសំខាន់ក្នុងការមើលទម្រង់មុខគឺការប្រើផែនទី 100ឆ្នាំនៃទម្រង់មុខ ។ ផែនទីនេះបានបែងចែកផ្ទៃមុខជា100តំណែង ក្នុងមួយតំណែងៗត្រូវនឹងមួយឆ្នាំនៃជីវិតរបស់មនុស្សយើង ។

ការស្វែងយល់ពីផែនទី100តំណែងនៃទម្រង់មុខពុំមែនជារឿងងាយទេ សូម្បីតែមនុស្សដែលមានសមត្ថភាពក្នុងការចងចាំរូបភាពបានល្អក៏ដោយ ព្រោះវាមាន100តំណែងដែលត្រូវឱ្យយើងចងចាំ ។ ដើម្បីឱ្យកាន់តែមានភាពងាយស្រួល គេបានបែងចែកជា៥ក្រុម ។




ផែនទី 100ឆ្នាំសម្រាប់មនុស្សប្រុស



www.elibraryofcambodia.org




ផែនទី100ឆ្នាំសម្រាប់មនុស្សស្រី



www.elibraryofcambodia.org



ចំណុចសំខាន់មួយទៀតដែលត្រូវចងចាំគឺ100តំណែងរបស់មនុស្សប្រុសនិងមនុស្សស្រីមានលក្ខណៈខុសគ្នា។ ទម្រង់មុខរបស់មនុស្សស្រីនិងមនុស្សប្រុសខុសគ្នាត្រង់ផ្នែកខាងឆ្វេងនិងខាងស្តាំ គឺត្រឡប់ផ្ទុយគ្នាលើកលែងតែត្រង់ជួរកណ្តាល (គឺខ្សែដែលអូសកាត់ពីថ្ងាសរហូតមកដល់ចង្កា) ទេដែលដូចគ្នា។

## មួយតំណែងសម្រាប់តែមួយឆ្នាំនៃអាយុរបស់អ្នក

ជនជាតិចិនចាត់ទុករយៈពេល9ខែដែលនៅក្នុងផ្ទៃរបស់មាតាជាផ្នែកមួយនៃការគណនារកអាយុ។ មានន័យថាពេលនរណាម្នាក់កើតមកគេចាត់ទុកថាអ្នកនោះមានអាយុមួយឆ្នាំហើយ ដូច្នេះអ្នកត្រូវចាំថាត្រូវបន្ថែមអាយុមួយឆ្នាំក្នុងពេលដែលមើលតំណែងអាយុ(ស៊ូលីង) ត្រូវនឹងផែនទីនៃទម្រង់មុខ។ ឧទាហរណ៍បើបច្ចុប្បន្នអ្នកអាយុ28ឆ្នាំអ្នកត្រូវមើលលក្ខណៈទម្រង់មុខក្នុងតំណែង29នៃផែនទី100ឆ្នាំដើម្បីមើលជោគជតារបស់អ្នក។

នេះជាលក្ខណៈទូទៅនៃផែនទី100ឆ្នាំដែលបានគូសចេញមកដើម្បីឱ្យស្គាល់តំណែងផ្សេងៗបានច្រើនជាងការបរិយាយ។ អ្នកត្រូវចាំថាអ្នកចាំបាច់ត្រូវរៀនដើរសិនមុនពេលដែលអ្នករៀនរត់។ តទៅនេះយើងនឹងសិក្សាឱ្យបានស៊ីជម្រៅក្នុងតំណែងនីមួយៗ។



www.elibraryofcambodia.org

## ចាត់ក្រុមតំណែងផ្សេងៗ

មានវិធីមួយដែលលឿនហើយងាយបំផុតក្នុងការធ្វើឱ្យអ្នកឆាប់ចាប់បានតំណែងទាំង 100នោះគឺចាត់ក្រុមតាមអាយុដូចជា វ័យក្មេង វ័យកំលោះក្រមុំ វ័យកណ្ដាល វ័យចាស់ និង វ័យជរា។ នៅក្នុងមេរៀនទី3 ដើម្បីបែងចែកចំណុចលម្អិតៗ យើងខ្ញុំបានប្រមូលទិន្នន័យតូចៗខ្លះ ដែលទាក់ទងនឹងវិធីមើលទម្រង់មុខតាមតំណែងអាយុដែលខុសគ្នាដូចខាងក្រោមៈ

## វ័យក្មេង (អាយុ១_១៤ឆ្នាំ)

ផែនទី100ឆ្នាំរបស់មនុស្សប្រុសនិងមនុស្សស្រីខុសគ្នាក្នុងពេលដែលអ្នកចុះលេខ តំណែងផ្សេងៗសម្រាប់អាយុពី1-14ឆ្នាំ អ្នកត្រូវចាប់ផ្ដើមរាប់ពីត្រចៀកឆ្វេងសម្រាប់មនុស្ស ប្រុសនិងចាប់ផ្ដើមរាប់ពីត្រចៀកស្ដាំសម្រាប់មនុស្សស្រី។ ដូច្នេះសម្រាប់មនុស្សប្រុសត្រចៀក ឆ្វេងជំនួសឱ្យអាយុពី1-7ឆ្នាំ ហើយត្រចៀកស្ដាំជំនួសឱ្យអាយុពី8-14ឆ្នាំ។ ចំណែកមនុស្សស្រី វិញត្រចៀកស្ដាំជំនួសឱ្យអាយុពី1-7ឆ្នាំហើយត្រចៀកឆ្វេងជំនួសឱ្យអាយុពី8-14ឆ្នាំ។




ត្រចៀកស្ដាំ                ត្រចៀកឆ្វេង



www.elibraryofcambodia.org




ត្រចៀកឆ្វេង




ត្រចៀកស្តាំ



www.elibraryofcambodia.org

# ទំយកំលោះក្រមុំ (អាយុ១៥-៣០ឆ្នាំ)

សម្រាប់ទាំងមនុស្សប្រុសនិងមនុស្សស្រីអាយុពី15-30បរិវេណថ្ងាសជាកន្លែងដែលកំណត់ជោគជតារបស់ពួកគេ ។ ប៉ុន្តែតំណែងទាំងនេះមានភាពឆ្លាស់គ្នារវាងមនុស្សប្រុសនិងស្រី ។



និយាយជារួមទៅ មនុស្សដែលមានទម្រង់ថ្ងាសមិនល្អនឹងជួបទុរ្គគ្រោះថ្នាក់ ការរារាំង ឬ ឧបសគ្គផ្សេងៗជាច្រើនក្នុងរវាងអាយុ15-30ឆ្នាំ ។



www.elibraryofcambodia.org



ថ្ងាសទាប



ថ្ងាសខ្ពស់

អ្នកអាចឆ្លល់ថាតើថ្ងាសបែបណាដែលមានទម្រង់មិនល្អនោះ? ថ្ងាសទាប ថ្ងាសចង្អៀត ថ្ងាសដែលមានស្នាម ឬ ថ្ងាសដែលប៉ោង ឬ ពកដូចបូសសុទ្ធតែចាត់ថាជាថ្ងាសដែលមានទម្រង់មិនល្អ ។

ថ្ងាសល្អគឺថ្ងាសមានលក្ខណៈរាប (មិនមានស្នាម ឬ មិនពក) តែខ្ពស់ហើយទូលាយ ។ មនុស្សដែលមានថ្ងាសល្អនឹងបានជោគជ័យក្នុងការសិក្សា ឬ អាជីពតាំងពីនៅវ័យកំលោះក្រមុំ ។ ម្យ៉ាងទៀតមនុស្សដែលមានថ្ងាសល្អតែងតែមានសតិបញ្ញាឆ្លាតវាងវៃជាងមនុស្សផងទាំងពួង ។



www.elibraryofcambodia.org

# មនុស្សវ័យកណ្ដាល (អាយុ៣១-៥០ឆ្នាំ)

តំណែងអាយុ31-50ឆ្នាំបែងចែកចេញជាពីរបរិវេណដូចជា ចិញ្ចើមនិងភ្នែកដែលអាចកំណត់ជោគជតាក្នុងកំឡុងអាយុពី31-40ឆ្នាំ។ រីឯច្រមុះនិងថ្ពាល់កំណត់ជោគជតាក្នុងកំឡុងអាយុ41-50ឆ្នាំ។ អ្នកចាំបាច់ត្រូវ "បញ្ច្រាស" ផែនទីជីវិតដើមដោយអាស្រ័យលើការមើលផ្ទៃមុខរបស់បុរស ឬ ស្ត្រី។ ចំពោះបុរសអាយុ31-34ឆ្នាំ ចាប់ផ្ដើមពីចិញ្ចើមឆ្វេងបញ្ច្រាសនឹងចិញ្ចើមស្ដាំចំពោះស្ត្រី។




អាយុ31-34ឆ្នាំ (មនុស្សប្រុស)



www.elibraryofcambodia.org

អាយុ31-40ឆ្នាំគឺជាកំឡុងពេលដែលមនុស្សភាគច្រើនកំពុងធ្វើឱ្យដំណើរជីវិតនិងអាជីពការងាររីកចម្រើន។ ចិញ្ចើមអាចប្រាប់យើងបានថាពួកគេអាចធ្វើបានល្អប៉ុណ្ណាក្នុងរវាងអាយុពី31-40ឆ្នាំ។ មនុស្សដែលមានចិញ្ចើមដាច់ស្តើង ឬ ក្រាស់ហួសបង្ហាញពីភាពលំបាកផ្សេងៗក្នុងចន្លោះអាយុ31-40ឆ្នាំ ហើយថែមទាំងបង្ហាញឱ្យឃើញពីសេចក្តីឧស្សាហ៍ព្យាយាមរបស់គេក្នុងកំឡុងពេលនោះក៏មានរាសីធ្លាក់ចុះដែរ។ ចិញ្ចើមអន់បង្ហាញឱ្យឃើញពីសេចក្តីលំបាកផ្សេងៗក្នុងអាជីពនិងភាពក្លាហានអង់អាចរបស់ពួកគេដែលខិតខំធ្វើឱ្យរីកចម្រើនលើក្រុមហ៊ុនដែលកំពុងធ្លាក់ចុះ។ ផ្ទុយពីនេះមនុស្សដែលមានចិញ្ចើមស្អាត(មិនក្រាស់ ឬ មិនស្តើងហួសពេក) អាចមានឱកាសជោគជ័យខ្ពស់ក្នុងអាជីពរបស់ខ្លួន ព្រមទាំងមានសំណាងល្អក្នុងកំឡុងអាយុ31-40ឆ្នាំ។



ចិញ្ចើមស្អាត

សម្រាប់អាយុពី35-40ឆ្នាំ យើងត្រូវមើលត្រង់ភ្នែក ជាទូទៅយើងចង់ឱ្យមានភ្នែកទាំងសងខាងមានទំហំប៉ុនគ្នា ព្រោះវាបង្ហាញឱ្យឃើញពីជោគសំណាងនៃភាពមានបាន។ ភ្នែកដែលមានទំហំខុសគ្នាខ្លាំងបង្ហាញឱ្យឃើញពីភាពអពជោគ ព្រមទាំងមានការប្រែប្រួលលើមុខរបរនិងទំនាក់ទំនងផ្សេងៗទៀតផង។






www.elibraryofcambodia.org

ភ្នែកដែលល្អគឺភ្នែកដែលមានភាពស្រស់ថ្លានិងមានវិញ្ញាណ ឬ យើងហៅថា "អៀនសឺន" ក្នុងភាសាចិន។ ចូរកុំច្រឡំនឹងពាក្យថា "វិញ្ញាណ" ព្រោះពេលនេះយើងមិនសំដៅទៅលើខ្មោចព្រាយបិសាចនោះទេ។ បើអ្នកមើលក្នុងវចនានុក្រមអ្នកនឹងឃើញថាន័យរបស់វិញ្ញាណគឺប្រែថាថាមពលនៃជីវិត ឬ ការមានភាពស្រស់ថ្លានោះឯង។ "វិញ្ញាណ" ក្នុងន័យយើងដែលខ្ញុំកំពុងនិយាយនេះគឺភ្នែកមាន "វិញ្ញាណ" យើងសំដៅលើភ្នែកដែលមានសភាពស្រស់ថ្លា រហ័សរហួន និងមានបារមី ជាពិសេសគឺភ្នែកដែលមិនស្លក់។



ភ្នែកមុតរហ័សរហួន



ភ្នែកស្លក់មិនរហ័សរហួន

ចាប់ពីចុងភ្នែកដេញចុះមកតាមចំណុចស្នូលកណ្តាលនៃទម្រង់មុខដល់ច្រមុះរបស់អ្នកអាចកំណត់ជោគជតាក្នុងកំឡុងអាយុពី 41-50ឆ្នាំ។






www.elibraryofcambodia.org

# វ័យចាស់ (អាយុ៥១-៧០ឆ្នាំ)

ចន្លោះអាយុ51-60ឆ្នាំជោគវាសនារបស់មនុស្សយើងត្រូវកំណត់ដោយស្នាមបបូរមាត់លើនិងបបូរមាត់ក្រោម។ ចង្កានិងថ្ពាមមានឥទ្ធិពលចំពោះជោគជតារបស់មនុស្សយើងរវាងចន្លោះអាយុ 61-70ឆ្នាំ។




មាត់និងចង្ការួមគ្នាកំណត់ថាវ័យជរានឹងទៅជាយ៉ាងណា។ ក្នុងវប្បធម៌ចិន គេចូលចិត្តវ័យជរាដែលល្អ ឬ ការបញ្ចប់ដែលល្អជានិច្ច។ គឺមានន័យថាមានមនុស្សជាច្រើនមកចោមរោមអ្នកដើម្បីជួយអ្នកក្នុងវ័យជរាដូចជាមានកូនកតញ្ញូ មានចៅជាច្រើនចោមរោមធ្វើឱ្យអ្នកមានភាពកក់ក្ដៅនិងរីករាយ។ ចំណែកវ័យជរាដែលមិនល្អគឺអ្នកត្រូវរស់នៅឯកោ គ្មានកូន គ្មានចៅ គ្មានអ្នកនៅហែហម ចោមរោមអ្នក ឬ ខ្វះខាតលុយកាក់ជាដើម។

ជាទូទៅយើងចូលចិត្តចង្កាទូលាយមានសាច់ហើយមូលដែលបញ្ជាក់ថាវ័យជរានឹងមានសេចក្ដីចម្រើនរុងរឿង។ ឯចង្កាស្រួចរមែងប្រាប់ពីវ័យជរាដែលត្រូវរស់នៅឯកា។



www.elibraryofcambodia.org



ចង្កាទូលាយមានសាច់ហើយមូល



ចង្កាស្រួច



www.elibraryofcambodia.org

# ទំរុយជរា (អាយុ៧០-១០០ឆ្នាំ)

យើងត្រូវព្រមទទួលស្គាល់ថាមនុស្សដែលអាចរស់នៅបានរហូតដល់អាយុ70ឆ្នាំគឺជាមនុស្សសំណាងណាស់ហើយ។ ប្រាកដជាក់ណាស់ថាក្នុងឋានៈយើងជាអ្នកចេះមើលទម្រង់មុខគឺមិនសូវមានឱកាសបានមើលជោគជតាឱ្យមនុស្សវ័យចាស់ច្រើនទេ តែយើងបន្ថែមតំណែងអាយុទាំងនេះឱ្យដើម្បីឱ្យសៀវភៅនេះកាន់តែមានលក្ខណៈសម្បូរបែប។






www.elibraryofcambodia.org




ពេលនេះអ្នកក៏បានឃើញនូវតំណែងទាំង100ហើយ។ ឥឡូវនេះដល់ពេលទៅមើលចំណុចលម្អិតក្នុងមេរៀនបន្តទៀត។ យើងនឹងសិក្សាឱ្យកាន់តែបានស៊ីជម្រៅពីចំណុចលម្អិតនៃតំណែងទាំង 100និងអ្វីដែលជាជោគសំណាងនៃទម្រង់មុខរបស់អ្នក។



www.elibraryofcambodia.org

# មេរៀនទី៣
# ១០០តំណែងលើទម្រង់មុខ

ការមើលទម្រង់មុខក៏ដូចហុងស៊ុយនិងប៉ាជឺដែរ ព្រោះមានចំណុចដែលជាអំណោះអំណាង នេះហើយគឺគោលដៅនៃផែនទី100ឆ្នាំនៃទម្រង់មុខ។ មេរៀននេះ យើងខ្ញុំនឹងបង្ហាញមួយតំណែងៗនៃតំណែងទាំង100នៅលើផ្ទៃមុខ ក្នុងមេរៀនសៀងហៅផែនទី100ឆ្នាំនេះថា "ប៉ៃស៊ួយធូ"។

ផែនទី100ឆ្នាំនៃទម្រង់មុខកំណត់ឱ្យរាល់ឆ្នាំនៃជីវិតរបស់មនុស្សយើងដោយអាស្រ័យលើភាពខុសប្លែកគ្នានៃទម្រង់មុខ។ ចំណុចដែលខុសគ្នានៅលើផ្ទៃមុខរបស់អ្នកអាចកំណត់នូវលក្ខណៈខុសគ្នានៃទម្រង់មុខដោយកំណត់លើបុគ្គលិកលក្ខណៈនិងឧបនិស្ស័យ។ អ្នកមើលទម្រង់មុខតែងតែនិយាយអំពី "ជោគចក្ខុ (ភ្នែក)" ឬ "ជោគសោត (ត្រចៀក)" ឬ "ជោគឃាន (ច្រមុះ)" វាក្យសព្ទទាំងអស់នេះស្តាប់ទៅដូចជាប្លែកត្រចៀកចំពោះអ្នកដែលមិនយល់ពីការមើលទម្រង់មុខ តែបើអ្នកយល់ពីរបៀបនៃការមើលទម្រង់មុខ អ្នកនឹងដឹងថាមនុស្សក្នុងវ័យសាមសិបឆ្នាំម្នាក់នោះកំពុងដើរចូលក្នុងជោគជតារបស់មនុស្សក្នុងវ័យហាសិបឆ្នាំ ឬ កំពុងឈានចូលក្នុងជោគជិវ្ហាក្នុងឆ្នាំនីមួយៗនៃផែនទី100ឆ្នាំកំណត់ជោគជតាក្នុងកំឡុងអាយុដែលខុសគ្នានៃជីវិតរបស់អ្នក។

ការប្រើផែនទី100ឆ្នាំនៃទម្រង់មុខអាចឱ្យយើងបានដឹងច្បាស់ពីជោគជតារបស់មនុស្សដោយមើលថាតើត្រង់បរិវេណនោះមានការប្រែប្រួល តិច ឬ ច្រើនប៉ុណ្ណា។ ក្នុងតំណែងនីមួយៗមិនគ្រាន់តែជំនួសឱ្យមនុស្សតែប៉ុណ្ណោះទេ គឺវាអាចបង្ហាញពីគុណសម្បត្តិលើផ្នែកផ្សេងៗរបស់អ្នកនោះបានទៀតផង។

ប្រការដំបូងដែលត្រូវចងចាំគឺតំណែងជោគជតាអាយុសម្រាប់មនុស្សប្រុសនិងមនុស្សស្រីគឺតំណែងខ្លះដូចគ្នា ឯតំណែងខ្លះមិនដូចគ្នាទេ។ ក្នុងពេលដំបូង អ្នកប្រហែលជាស្មុគស្មាញ



www.elibraryofcambodia.org

បន្តិច ប៉ុន្តែនៅពេលដែលអ្នកអាចចងចាំបានហើយ អ្នកនឹងអាចមើលទម្រង់មុខមនុស្សប្រុសនិងមនុស្សស្រីក្នុងលក្ខណៈប្តូរទីតាំងអាយុគ្នាបានដោយមិនស្មុគស្មាញ។






www.elibraryofcambodia.org

## ត្រូវចងចាំដូចខាងក្រោមនេះ

| មនុស្សស្រី | មនុស្សប្រុស |
|---|---|
| ចាប់ផ្តើមពីខាង**ស្តាំ**ជានិច្ច | ចាប់ផ្តើមពីខាង**ឆ្វេង**ជានិច្ច |




男左女右

មនុស្សប្រុសផ្នែកខាងឆ្វេង មនុស្សស្រីផ្នែកខាងស្តាំ



www.elibraryofcambodia.org




ផែនទី 100ឆ្នាំសម្រាប់មនុស្សប្រុស



www.elibraryofcambodia.org




ផែនទី 100ឆ្នាំសម្រាប់មនុស្សស្រី



www.elibraryofcambodia.org

# អាយុ១_៧ឆ្នាំ ជោគសោត (ត្រចៀក)

អាយុ1-7ឆ្នាំ ក្នុងមៀនសៀង ផែនទី100ឆ្នាំមានភាពខុសគ្នាតិចតួចព្រោះសម្រាប់មនុស្សស្រីផែនទី100ឆ្នាំចាប់ផ្ដើមត្រង់ត្រចៀកស្ដាំ។ ចំណែកសម្រាប់មនុស្សប្រុសវិញគឺចាប់ផ្ដើមត្រង់ត្រចៀកឆ្វេង។




ត្រចៀកឆ្វេង

*តំណែងពី 1 ដល់ 3 គឺរង្វង់កង់មេឃ ( ធៀនលុន ) តំណែងទី4 គឺឋានសួគ៌ ( ធៀនឆឹង ) តំណែង5 6និង7គឺរង្វង់ជើងមេឃ ( ធៀនខួ ) ។*

តំណែងទាំង7 ត្រង់ត្រចៀកនេះគឺសម្រាប់វ័យក្មេង។ វិត្តដំបូងនៃឧបនិស្ស័យរបស់មនុស្សភាគច្រើនកើតឡើងក្នុងកំឡុងឆ្នាំទាំងអស់នេះ។ ដូច្នេះបើត្រចៀកមានលក្ខណៈល្អដោយត្រូវបានគេមើលថែបានល្អតាំងពីក្មេង បង្ហាញថាគេម្នាក់នោះមានអាកប្បកិរិយាទន់ភ្លន់ ចិត្តល្អ ហើយពោរពេញទៅដោយការស្រឡាញ់។ ផ្ទុយទៅវិញ ត្រចៀកដែលមានលក្ខណៈមិនល្អបង្ហាញឱ្យឃើញថាកាលពីវ័យក្មេងមានភាពក្រីក្រ ឬ មិនល្អ ព្រោះគ្មានការផ្ដល់ឱ្យនិងទទួលនូវសេចក្ដីស្រឡាញ់ដ៏កក់ក្ដៅពីសំណាក់មនុស្សជុំជុំវិញខ្លួនឡើយ។



www.elibraryofcambodia.org



ពេលយើងសម្លឹងមើលត្រចៀកគឺមានន័យថាយើងកំពុងសង្កេតមើលលក្ខណៈជាច្រើនយ៉ាងដូចជាសោភ័ណនិងភាពច្បាស់លាស់នៃត្រចៀក (ត្រចៀកនៅខ្ពស់ ទាប ទន់ ឬ រឹង)។ គុណសម្បត្តិរបស់ត្រចៀកមានសារៈសំខាន់ណាស់ចំពោះជោគជតារបស់មនុស្សក្នុងគ្រាដំបូងនៃជីវិត។ បើត្រចៀកក្មេងមានទំហំតូច ហើយរង្វង់ជុំវិញត្រចៀកមានស្នាមឆែប ឬ ស្នាមក្រហែតក្រហត ក្មេងនោះអាចជួបនឹងគ្រោះចង្រៃក្នុងចន្លោះអាយុ 1-7ឆ្នាំ។ បើមានស្នាមឆែបត្រង់ត្រចៀកត្រូវមើលថាវានៅត្រង់តំណែងអាយុប៉ុន្មាន អ្នកនឹងអាចមើលឃើញច្បាស់ថាក្មេងនោះនឹងមានគ្រោះចង្រៃនៅក្នុងឆ្នាំណាហើយ។

ក្មេងដែលមានអាយុចន្លោះពី1-7ឆ្នាំ គេតែងតែរស់នៅជាមួយឪពុកម្តាយរបស់ខ្លួន ដូច្នេះគ្រោះថ្នាក់ ឬ សុវត្ថិភាពរបស់ពួកគេគឺអាស្រ័យលើការយកចិត្តទុកដាក់និងស្នេហភាពប្រាក់កាសរបស់ឪពុកម្តាយគេដែរ។

ដូច្នេះយើងអាចនិយាយបានថាគ្រោះចង្រៃគឺមានទំនាក់ទំនងនឹងស្ថានភាពនៃជីវិតប្រចាំថ្ងៃ។ វ័យក្មេងដែលលំបាកលំបិន ឬ ឪពុកម្តាយក្រក្រីគឺមិនអាចចិញ្ចឹមកូនបានល្អប៉ុន្មានទេ។

វិធីមើលជោគជតារបស់ឪពុកម្តាយដោយវិធីលឿនរហ័សគឺមើលទៅលើត្រចៀករបស់កូនតូចរបស់ពួកគាត់។ បើកូនរបស់អ្នកមានត្រចៀកដែលមានលក្ខណៈមិនល្អ គឺមានន័យថាអ្នកដែលជាឪពុកម្តាយត្រូវអត់ធន់ចំពោះក្តីលំបាកខ្លះ ឬ ត្រូវទ្រាំលំបាកក្នុងកំឡុងឆ្នាំដំបូងៗរបស់កូន បើលក្ខណៈត្រចៀករបស់កូនល្អគឺមានន័យថាអ្នកដែលជាឪពុកម្តាយនឹងមានដំណើរជីវិតល្អដែរ។





www.elibraryofcambodia.org



ត្រចៀកខ្ពស់

ត្រចៀកមិនត្រឹមតែត្រូវមានរង្វង់ជុំវិញត្រចៀកច្បាស់លាស់នោះទេគឺត្រូវខ្ពស់ទៀតផង ។ តើការនិយាយអំពីត្រចៀកខ្ពស់ចង់និយាយថាម៉េច? ត្រចៀកខ្ពស់គឺត្រចៀកដែលមានចុងខាងលើខ្ពស់ជាងចិញ្ចើម រីឯត្រចៀកទាបមានន័យថាចុងខាងលើនៃត្រចៀកនៅស្មើនឹងភ្នែក ឬ នៅទាបជាងភ្នែក ។ ដើម្បីងាយស្រួលដឹងថានរណាមានត្រចៀកខ្ពស់ ឬ ទាប អ្នកត្រូវមើលពីចំហៀងមុខ បើត្រចៀកក្មេងខ្ពស់ជាងចិញ្ចើម មានន័យថាក្មេងនោះមានសមត្ថភាពខ្ពស់ជាងក្មេងដទៃទៀតក្នុងចំណោមក្មេងដែលមានវ័យស្របាលគ្នា ហើយគេនឹងក្លាយជាមនុស្សមានឈ្មោះបោះសំឡេងទៅថ្ងៃអនាគត ។ អ្នកមានត្រចៀកខ្ពស់ជាមនុស្សមានសតិបញ្ញា ក្មេងដែលមានត្រចៀកខ្ពស់ជាក្មេងដែលមានសុខភាពរឹងមាំអស់មួយជីវិត ថែមទាំងជាក្មេងដែលស្រួលប្រដៃប្រដៅទៀតផង ។

ត្រចៀកដែលល្អមានដូចជាត្រចៀកដែលមើលមិនឃើញពេលសម្លឹងមើលចំពីមុខ ។ ត្រចៀកដែលល្អបំផុតគឺនៅជាប់កៀកនឹងផ្នែកខាងនៃក្បាលបំផុត ។ ត្រចៀកកំប៉េងពុំមែនជាត្រចៀកល្អទេ គឺមានន័យថាត្រចៀកដែលអាចមើលឃើញច្បាស់ពេលយើងសម្លឹងមើលចំពីមុខ (ដូចរូបខាងស្តាំ) ។ មនុស្សដែលមានត្រចៀកជិតជាប់នឹងក្បាល ឬ មើលពុំសូវឃើញពេលមើលចំពីមុខ ច្រើនជាមនុស្សចេះស្តាប់បង្គាប់និងងាយស្រួលចិញ្ចឹមជាងបើប្រៀបធៀបនឹងមនុស្សដែលមានត្រចៀកកំប៉េង ។



ត្រចៀកកំប៉េងអាចមើលឃើញច្បាស់ពីខាងមុខ



www.elibraryofcambodia.org

# ត្រចៀកមនុស្សស្រី




ត្រចៀកស្តាំ

ត្រចៀកស្តាំជំនួសឱ្យអាយុពី1-7ឆ្នាំសម្រាប់មនុស្សស្រី ។ លក្ខណៈសំខាន់បំផុតរបស់ត្រចៀកគឺភាពយឺតទន់របស់វា បើមនុស្សស្រីមានត្រចៀករឹងនិងមិនយឺតទន់បង្ហាញឱ្យឃើញពីជីវិតភាពលំបាកគឺវានឹងកើតឡើងច្រើននៅចន្លោះអាយុពី1-7 លក្ខណៈដែលសំខាន់បន្ទាប់ទៀតនៃត្រចៀករបស់មនុស្សស្រីគឺប្រឡោះខ្យល់ ឬ ចង្កូរត្រចៀក ។

ប្រឡោះខ្យល់ ឬ ចង្កូរត្រចៀកបង្ហាញឱ្យឃើញពីទស្សនគំនិតរបស់មនុស្សនោះ ប្រឡោះខ្យល់ ឬ ចង្កូរត្រចៀកដែលធំហើយទូលាយបង្ហាញឱ្យឃើញពីទស្សនគំនិតដែលបើកទូលាយ ចំណែកឯប្រឡោះខ្យល់ ឬ ចង្កូរត្រចៀកតូចចង្អៀតបង្ហាញឱ្យឃើញថាគេជាមនុស្សបែបអភិរក្សនិយម ។ ព្រោះក្នុងវប្បធម៌ចិន ឪពុកម្តាយភាគច្រើនមិនចង់ឱ្យកូនមានសេរីភាព ឬ មានទស្សនបើកទូលាយពេកទេ គឺពួកគាត់ចង់ឱ្យកូនស្រីក្រមុំមានគំនិតបែបអភិរក្សនិយម ។ ដូច្នោះហើយទើបត្រចៀកសម្រាប់មនុស្សស្រីពុំគួរមានប្រឡោះខ្យល់ ឬ ចង្កូរត្រចៀកដែលធំទូលាយពេកទេ ។



ប្រឡោះខ្យល់ ឬ
ចង្កូរត្រចៀក



www.elibraryofcambodia.org

# អាយុ ៨-១៤ឆ្នាំ




ត្រចៀកស្ដាំ

សម្រាប់មនុស្សប្រុសអាយុពី 8-14ឆ្នាំបង្ហាញដោយត្រចៀកស្ដាំ ចំណែកត្រចៀកឆ្វេងវិញគឺសម្រាប់មនុស្សស្រីកំឡុងអាយុពី 8-14ឆ្នាំ។ វ័យនេះជាកំឡុងពេលនៃការផ្លាស់ប្ដូរចូលទៅយុវភាព។ ជារយៈពេលនៃការមានភាពជារបស់ខ្លួនដែលកំណត់ឧបនិស្ស័យនិងធម្មជាតិរបស់គេ។ ក្នុងវ័យនេះក្មេងអាចធ្លាក់ក្រោមឥទ្ធិពលទង្វើផ្សេងៗបានយ៉ាងងាយ ធ្វើឱ្យគេមានគំនិតផ្សេងៗតាមនោះដែរ។ បញ្ហាច្រើនយ៉ាងដែលកើតឡើងបានក្នុងថ្ងៃនេះនឹងបង្ហាញចេញមកឱ្យឃើញនៅត្រង់ត្រចៀក ដែលអាចជះឥទ្ធិពលលើគេអស់មួយជីវិត។

វិធីផ្សេងៗក្នុងការប្រមើលមើលត្រចៀកស្ដាំ (ឬត្រចៀកឆ្វេងសម្រាប់មនុស្សស្រី) នោះវាមានលក្ខណៈប្រហាក់ប្រហែលគ្នា យើងចាប់អារម្មណ៍លើរង្វង់ជុំវិញត្រចៀកនិងប្រវែង ឬ កម្ពស់របស់ត្រចៀក។ ឧទាហរណ៍បើត្រចៀកស្ដាំស្ដើងខ្លាំងបង្ហាញថាក្នុងវ័យនេះគេមានសុខភាពមិនល្អ ជាពិសេសសុខភាពផ្លូវចិត្តព្រោះថាត្រចៀកត្រូវជំនួសដោយទ្រព្យសម្បត្តិនិងទស្សនគំនិត។ ចំណែកឯត្រចៀកស្ដើងបង្ហាញឱ្យឃើញពីអារម្មណ៍ដែលមិនចេះស្ងប់។



www.elibraryofcambodia.org




ត្រចៀកឆ្វេង

បើចុងខាងលើត្រចៀកស្រួច វាបង្ហាញឱ្យឃើញថាផ្លូវអារម្មណ៍មិនសូវស្រួលដែលបណ្តាលមកពីឪពុកម្តាយ។ ដូចជាឪពុកម្តាយលែងលះគ្នា ឬ នៅបែកគ្នា... គេអាចនឹងប្រតិបត្តិចំពោះភរិយា ឬ គូស្រករក្នុងលក្ខណៈដូចគ្នានាពេលអនាគត។ ក្នុងសាស្ត្រានៃការមើលទឹកមុខ ឬ ទម្រង់មុខ ត្រចៀកស្តាំដែលមានស្នាមឆែបបង្ហាញឱ្យឃើញពីការបាត់បង់ផ្លូវចិត្ត ឬ ខូចអារម្មណ៍ ឬ រឿងដែលបង្កឱ្យមានភាពក្តៅក្រហាយរបស់អ្នកនោះដល់វ័យធំ។ ចំណុចនេះមកពីការពិតដែលថាអាយុ 8-14ឆ្នាំជាវ័យនៃការជាប់ចិត្តនឹងអ្វីមួយ ជាវ័យដែលគេម្នាក់នោះពង្រឹងឧបនិស្ស័យរបស់ខ្លួន។



ត្រចៀកចុងខាងលើស្រួច

វាជារឿងសំខាន់ដែលត្រូវត្រួតពិនិត្យមើលថាត្រចៀកឆ្វេងនិងត្រចៀកស្តាំប៉ុនគ្នាឬអត់។ បើត្រចៀកទាំងសងខាងនៅក្នុងកម្រិតមិនស្មើគ្នា ឬ រូបរាងត្រចៀកធំខុសគ្នាបង្ហាញឱ្យឃើញថាឪពុកម្តាយរបស់គេនោះនឹងបែកគ្នា ឬ លែងលះគ្នាក្នុងកំឡុងអាយុនេះហើយ។ មានលក្ខណៈខ្លះបង្ហាញឱ្យឃើញថាគេអាចមានឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមដែលនឹងបង្ហាញខ្លួនឱ្យឃើញនៅពេលណាមួយក្នុងជីវិតរបស់គេ។



www.elibraryofcambodia.org

សម្រាប់ក្មេងស្រី ពណ៌របស់ត្រចៀកក៏មានលក្ខណៈសំខាន់ដែរ ពណ៌ត្រចៀកគួរតែជាពណ៌ដែលស្រាលជាងពណ៌ផ្ទៃមុខ (ដែលមិនផាត់ម្សៅ)។ បើពណ៌ត្រចៀកស្រគាំជាង ជាពិសេសត្រចៀកឆ្វេង វាបង្ហាញឱ្យឃើញថាក្នុងកំឡុងអាយុ 8-14ឆ្នាំ ពួកនាងតែងតែមានជំងឺតម្កាត់ ឬ កើតអាការសោកសៅដោយងាយ ដែលជួនកាលអាចជះឥទ្ធិពលលើដំណើរជីវិតក្នុងវ័យបន្តទៀតបាន។

## អាយុ១៥ឆ្នាំ ផ្កាយភ្លើង




ផ្កាយភ្លើងដែលនៅពាក់កណ្តាលជើងសក់ត្រង់ចុងខាងលើបំផុតនៃថ្ងាស (សូមមើលរូបឧទាហរណ៍) ជាចំណុចខ្ពស់បំផុតរបស់ថ្ងាស។ ថ្ងាសល្អពុំគួរឱ្យមានស្នាមដំបៅ ស្នាមអុជ ឬ ទូលទេ តែគួរមានសាច់ទើបល្អ។ ពេលថ្ងាសមានលក្ខណៈសមស្របដូចខាងលើនេះ គេចាត់ទុកថាមានធាតុភ្លើងល្អ។ អ្នកត្រូវប្រើជើងសក់ជាគោល បើជើងសក់នៅជិតចិញ្ចើម មានន័យថាគេម្នាក់នោះមានជើងសក់ទាប ហើយផ្កាយភ្លើងគឺស្ថិតនៅកប់ខាងក្នុងជើងសក់ដែលជាផ្កាយភ្លើងមិនសូវល្អ។

ថ្ងាសខ្ពស់ ឬ ផ្កាយភ្លើងខ្ពស់បង្ហាញថាគេជាមនុស្សមានឱកាសក្នុងការសិក្សាខ្ពស់ រៀនពូកែហើយមានសុខភាពល្អ។ ថ្ងាសទាប ឬ ផ្កាយភ្លើង ទាបមានន័យថាអាយុ15ឆ្នាំ "នៅក្នុងជើងសក់របស់អ្នក" ដែលបង្ហាញថាអ្នកត្រូវឆាប់ចេញពីសាលាធ្វើការងារ ឬ អ្នកនោះត្រូវកាលៈទេសៈបង្ខំឱ្យធ្វើការងាររកស៊ីចិញ្ចឹមគ្រួសារ។



www.elibraryofcambodia.org

ខាងក្រោមនេះជាឧទាហរណ៍ដែលបង្ហាញអំពីជើងសក់ខ្ពស់និងទាប ដែលយើងបាននិយាយថាផ្កាយភ្លើងខ្ពស់ ឬ ផ្កាយភ្លើងទាប ( ផ្កាយភ្លើងកប់នៅក្នុងជើងសក់ក្នុងរូបខាងស្តាំ) ។




ជើងសក់ខ្ពស់




ជើងសក់ទាប

ចំពោះមនុស្សស្រីណាដែលមានជើងសក់ខ្ពស់ល្មមនិងថ្ងាសមានសាច់ (ពេលអាយុ ១៥ឆ្នាំ) ត្រង់តំណែងទី១៥ នឹងមានជោគសំណាងលើការទំនាក់ទំនងល្អនឹងការសិក្សា ដោយពួកនាងអាចចុះចូលសម្របសម្រួលខ្លួនបានយ៉ាងល្អជាមួយក្រុមគ្រួសារ មិត្តភ័ក្តិ និងអ្នកគ្រូលោកគ្រូ ព្រមទាំងមានសំណាងល្អក្នុងការសិក្សាទៀតផង ។






www.elibraryofcambodia.org

# អាយុ ១៦ឆ្នាំ ចំណុចសក្តិខ្ពស់

ដើម្បីរកតំណែងទី16 អ្នកចាំបាច់ត្រូវតែរកឱ្យឃើញតំណែងទី15ជាមុនសិន ព្រោះវាស្ថិតនៅខាងក្រោមតំណែងទី15 ដោយឃ្លាតពីគ្នាប្រហែលមួយថ្នាំងដៃដូចមានបង្ហាញក្នុងរូបនេះស្រាប់។

តំណែងនេះមនុស្សប្រុសនិងមនុស្សស្រីមានលក្ខណៈដូចគ្នា។




ចំណុចនេះបង្ហាញអំពីការឡើងសក្តិ កិត្តិយស និងការពេញចិត្តពេញថ្លើមទៅលើអ្វីមួយដើម្បីទទួលបាននូវការរាប់អានពីអ្នកដទៃ។ យើងអាចនិយាយបានថាម្នាក់នោះមានសម្រស់ពីធម្មជាតិដ៏ស្រស់ស្អាតម្យ៉ាងនៅក្នុងខ្លួនរបស់គេ (តែមិនទាក់ទងនឹងរូបឆោមទេ) ដែលអាចធ្វើឱ្យគេអាចទំនាក់ទំនងធ្វើការងារអ្វីក៏បានស្រួល ហើយថែមទាំងជាមនុស្សដែលមានឥទ្ធិពលទៀតផង។

បើតំណែង១៦នេះនៅទាបពេក ឬ ក៏មានស្នាមអុជ ដំបៅ ឬ ពក នឹងធ្វើឱ្យគេមិនអាចមានទំនាក់ទំនងការងារជាមួយអ្នកដទៃបាន ឬ មានគេមិនសូវចូលចិត្ត ឬ គ្មានឥទ្ធិពលអ្វីចំពោះអ្នកដែលនៅជុំវិញខ្លួន។



www.elibraryofcambodia.org

ស្នាមដំបៅ ស្នាមប្រហោង កំពក នៅតំណែងទី16បង្ហាញឱ្យឃើញពីភាពមិនមានជោគសំណាងក្នុងគ្រួសារ ។ ពួកគេច្រើនមានបញ្ហានិងមានឧបសគ្គជាច្រើនក្នុងការសិក្សា ហើយអាចនឹងមិនមានឱកាសសិក្សាដល់ថ្នាក់សាកលវិទ្យាល័យ ឬ មហាវិទ្យាល័យទៀតផង ។

ឥឡូវនេះសូមបំបែរអារម្មណ៍មកមើលរូបខាងក្រោមនេះវិញម្តង ។ យើងហៅលក្ខណៈបែបនេះថាមាន់មាសចឹកថ្មពន្លឺ ។ លក្ខណៈដូចនេះហៅថាកំពូលភ្នំមេម៉ាយដែលបង្ហាញឱ្យឃើញពីស្ត្រីដែលត្រូវធ្វើការក្រៅផ្ទះតាំងពីវ័យក្មេង ឬ ជួនកាលអាចនឹងត្រូវទៅសិក្សានៅក្រៅប្រទេសតែម្នាក់ឯង ឬ ជាស្ត្រីដែលមានទំនាក់ទំនងដ៏លំបាកនិងច្របូកច្របល់ជាមួយឪពុក ។




# 金雞照明堂

លក្ខណៈបែប "មាន់មាសចឹកថ្មពន្លឺ"



www.elibraryofcambodia.org

ចំណុចសក្តិខ្ពស់មានលក្ខណៈសំខាន់ណាស់សម្រាប់មនុស្សស្រី ព្រោះវាបញ្ជាក់ឱ្យឃើញច្បាស់ថាពួកនាងនឹងក្លាយជាភរិយាដែលទន់ភ្លន់ឱនលំទោន ឬ មានះរឹងរូស។ មនុស្សស្រីដែលមានស្នាមកំពកត្រង់តំណែងទី១៦ មានឧបនិស្ស័យជាមនុស្សប្រាកដប្រជា ហើយតែងតែនិយាយបើកចំហត្រង់ទៅត្រង់មក។ ពួកនាងតែងតែមានបញ្ហាជាមួយឪពុក ហើយមានទំនោរក្នុងការមានបញ្ហាជាមួយមនុស្សប្រុសក្នុងជីវិតរបស់ពួកនាង។ ពេលអាយុបាន១៦ឆ្នាំ សុភាពនារីទាំងអស់នោះនឹងមានបញ្ហាក្នុងការសិក្សាព្រោះចិត្តគំនិតរបស់ពួកនាងងាយយល់ខុសណាស់ ។

នារីដែលមានពន្លឺស្បែកស្រអាប់ត្រង់តំណែងទី១៦ (ពណ៌ស្បែកដែលពុំទាន់តុបតែង) បង្ហាញឱ្យឃើញពីការបាត់បង់សម្រស់ មិនសូវមានមោទកភាព និងខ្វះភាពទន់ភ្លន់ជាមនុស្សស្រី។



www.elibraryofcambodia.org

# អាយុ១៧-១៨ឆ្នាំ អាទិត្យនិងចន្ទ

តំណែងទី17ហៅថាតំណែងអាទិត្យ

តំណែងទី18 ហៅថាតំណែងចន្ទ ដូចមានបង្ហាញក្នុងរូបខាងក្រោម៖




អាទិត្យជំនួសឱ្យឪពុកហើយចន្ទជំនួសឱ្យម្តាយ ដូច្នេះហើយទើបតំណែងទាំងពីរនេះអាចកំណត់បាននូវគុណភាពនៃទំនាក់ទំនងជាមួយឪពុកម្តាយរបស់អ្នកនិងភាពស្និទ្ធស្នាលជាមួយឪពុកម្តាយរបស់អ្នក។ តំណែងអាទិត្យនិងចន្ទបង្ហាញថាឪពុកម្តាយអាចផ្តល់ការទំនុកបម្រុងដល់អ្នកដែរឬអត់។

ស្នាមដំបៅ ខ្សែឆ្នូត និងស្នាមកំពកត្រង់តំណែងនេះបង្ហាញឱ្យឃើញពីអាទិត្យនិងចន្ទដែលមានការវិវត្តន៍មិនល្អ ដូច្នេះហើយទើបបានជាត្រូវមានការតស៊ូដោយខ្លួនឯង ឬ ពង្រឹងជំហរដោយខ្លួនឯង។ ផ្ទុយទៅវិញ បើតំណែងអាទិត្យនិងចន្ទមានលក្ខណៈល្អវិញ បង្ហាញថាអ្នកអាចទទួលបាននូវការជួយទំនុកបម្រុងពីឪពុកម្តាយ ឬ បានទទួលមរតកជំនួញពីឪពុកម្តាយ។



www.elibraryofcambodia.org

សម្រាប់នារីវិញ បើពណិស្បែកត្រង់តំណែងអាទិត្យនិងតំណែងទី១៦ស្រអាប់ ហើយថែមទាំងមាន "មាន់មាសចឹកផ្កាពន្លឺ" ទៀតនោះ បង្ហាញឱ្យឃើញពីការគ្មានភាពស្និទ្ធស្នាលរវាងឪពុកម្ដាយ ឬ មានមនុស្សស្រីម្នាក់នាំគ្រោះចង្រៃមកឱ្យឪពុកម្ដាយនាងទៀតផង។

ជាបន្តទៅនេះយើងខ្ញុំនឹងធ្វើការអធិប្បាយទាក់ទងនឹងពាក្យថា" គ្រោះចង្រៃ" បែបខ្លីៗក្នុងវប្បធម៌ចិន។ ពេលឪពុកម្ដាយនិងកូនមិនចុះសម្រុងនឹងគ្នា ឬ កូនក្បាលរឹងមិនស្ដាប់បង្គាប់ គេចាត់ទុកថាជា "គ្រោះចង្រៃ" សម្រាប់ឪពុកម្ដាយ។ បញ្ហានេះមកពីគំនិតដែលគិតថាភាពសុខសាន្តនាំមាសប្រាក់មកឱ្យ ចំណែកការឈ្លោះប្រកែកគ្នាក្នុងរង្វង់គ្រួសារ មានន័យថាទ្រព្យសម្បត្តិនឹងរត់ចេញគឺមិនមែនមានន័យថាគ្រោះចង្រៃដែលមានន័យតាមតួអក្សរទាំងស្រុងនោះទេ។



www.elibraryofcambodia.org

# អាយុ១៩ឆ្នាំ ចំណុចមេឃា

អ្នកត្រូវរកតំណែងទី16លើផ្ទៃមុខរបស់អ្នកឱ្យឃើញដើម្បីងាយស្រួលរកតំណែងចំណុចមេឃា ព្រោះវាស្ថិតនៅខាងក្រោមប្រហែលមួយថ្នាំងដៃ។ តំណែងនេះជំនួសជោគវាសនានៅអាយុ19ឆ្នាំស្ថិតនៅចំកណ្តាលរវាងតំណែងអាទិត្យនិងតំណែងចន្ទ។




តំណែងទី19 មានទំនាក់ទំនងជាមួយនឹងសមត្ថភាពដែលអាចធ្វើបាន ការដាក់ចិត្តធ្វើការឱ្យបានល្អ ការរៀបបូកពាឱ្យខ្ពស់ ទោះជាពួកគេមិនមានលុយច្រើនក៏ដោយក៏តំណែងទី19ផ្តល់នូវអំណាចកិត្តិយសនិងលក្ខណៈជាមនុស្សល្អដល់ពួកគេដែរ ទោះជាពួកគេកើតមកក្នុងគ្រួសារអ្នកមាន ឬ អ្នកក្រក៏ដោយ។ ឧទាហរណ៍ដូចជាសម្តេចព្រះរាជនីអេលីសាបែតទី2នៃចក្រភពអង់គ្លេសទ្រង់មានរស្មីនៃអំណាចនិងកិត្តិយស។

អ្នកនយោបាយដែលល្អចាំបាច់ត្រូវមានតំណែងទី19ល្អ ដើម្បីឱ្យមានភាពប្រាកដក្នុងចិត្តថាពួកគេបានទទួលការគាំទ្រដោយពុំចាំបាច់ខំបញ្ចេញពាក្យសម្តីសូម្បីតែមួយម៉ាត់។ កេរ្តិ៍ឈ្មោះនិងការគោរព វាអាស្រ័យលើតំណែងទី19ដែលមានលក្ខណៈល្អ។ មានន័យថាចំណុចនេះមានសាច់ មិនមានស្នាម និងមានពណ៌ស្បែកល្អស្មើគ្នា។ តំណែងទី16និង19អាចចូលគ្នាក្នុង



www.elibraryofcambodia.org

ផ្នែកផ្សេងៗជាច្រើន អ្នកត្រូវការទាំងពីរតំណែងដើម្បីបូកផ្សំបញ្ចូលគ្នាឱ្យមានថាមពលដ៏គួរឱ្យពេញចិត្ត មានអំណាច កិត្តិយស និងភាពស្រស់ស្អាត។ ទាំងអស់នេះសុទ្ធតែជាភាពចាំបាច់សម្រាប់អ្នកដែលជាសសរទ្រូងរបស់សង្គមដែលនឹងបានទទួលការគោរពរាប់អាននិងសម្រាប់អ្នកដែលចង់បានទទួលការគោរពរាប់អាននិងការលើកសរសើរ។

គុណភាពរបស់តំណែងទី19 ត្រូវអាស្រ័យលើគុណភាពរបស់តំណែងទី17និង18 យ៉ាងខ្លាំង ព្រោះមេឃត្រូវបានទទួលការជ្រោមជ្រែងពីព្រះអាទិត្យនិងព្រះចន្ទ។




តំណែងទី19មានសារសំខាន់ណាស់ចំពោះនារី។ ព្រោះក្រៅពីមានការទាក់ទងនឹងសមត្ថភាពដែលអាចធ្វើឱ្យស្វាមីចាប់អារម្មណ៍ពូកនាង ហើយវានៅមានទំនាក់ទំនងនឹង "ការព្រមទទួល" របស់ស្វាមីទៀតផង។ អ្នកប្រហែលជាឆ្ងល់ថាអ្វីជា "ការព្រមទទួល" នោះ?



www.elibraryofcambodia.org

ក្នុងសង្គមអាស៊ីវាមិនមែនជារឿងខុសប្រក្រតីទេ ដែលស្វាមីអាចមានភរិយាច្រើនជាងម្នាក់ ឬ ប្រពន្ធចុងលួចលាក់។ ពេលមនុស្សស្រី "មិនជាទីព្រមទទួល"របស់ស្វាមី មានន័យថានាងត្រូវចាត់ទុកថាជាភរិយាទី2ដែលអាចនិយាយបានថានាងមិនត្រូវបានព្រមទទួល ព្រោះស្វាមីរបស់នាងមិនបាន "ព្រមទទួល" នាងជាភរិយាចំពោះមុខសាធារណៈជនទេ។

ឧទាហរណ៍ដូចជា ប្រជ្រុយត្រង់តំណែងទី19ជាទូទៅបង្ហាញឱ្យឃើញពីមនុស្សស្រីដែលមិនបានទទួលនូវការរាប់អានពីស្វាមីរបស់នាង ឬ នាងនឹងមានបញ្ហាលើជីវិតអាពាហ៍ពិពាហ៍។

ភរិយាដែលមិនបើកចំហ ឬ ភរិយាលួចលាក់រមែងមានតំណែងទី19មិនល្អនិងមានច្រមុះតូច។ បើតំណែងទី19មិនល្អខ្លាំង គឺពិបាកនឹងទៅរួចណាស់ដែលបុរសនោះនឹងលែងប្រពន្ធរបស់គាត់ដើម្បីមករៀបការជាមួយនាង។ ដូច្នេះហើយទើបបានជានាងមិនបានទទួល "ការព្រមទទួល" ពីស្វាមី។



សម្រាប់មនុស្សស្រីដែលមានតំណែងទី19 មានលក្ខណៈទន់ខ្សោយមកសុំការប្រឹក្សា អ្នកប្រឹក្សាលើផ្នែកជោគជតារមែងណែនាំនាងឱ្យរៀបការជាមួយបុរសដែលលែងប្រពន្ធរួច។ នៅក្នុងសង្គមសម័យថ្មីអាចអនុញ្ញាតឱ្យយើងចៀសផុតពីបញ្ហាទាំងអស់នេះបាន ការរៀបការជាមួយបុរសដែលធ្លាប់លែងប្រពន្ធធ្វើឱ្យអ្នកក្លាយជាប្រពន្ធទី2 ស្របច្បាប់ តែអ្នកនៅតែបានទទួល "ការព្រមទទួល" ពីសាធារណៈជនក្នុងឋានៈជា "ភរិយា" នេះជាវិធីយកឈ្នះចំណុចខ្សោយនៃតំណែងទី19របស់នារី។



www.elibraryofcambodia.org

# អាយុ២០_២១ឆ្នាំ ជំនួយការឆ្វេងនិងជំនួយការស្តាំ




ជំនួយការឆ្វេងនិងជំនួយការស្តាំនៅបន្ទាប់ពីតំណែងអាទិត្យនិងចន្ទដូចមានបង្ហាញក្នុងរូប ។

ជំនួយការឆ្វេងនិងជំនួយការស្តាំអាចកំណត់ថាគេម្នាក់នោះនឹងអាចស្វែងរកជំនួយពីសមាជិករបស់គ្រួសារបាន ឬ មិនបាន។ យើងត្រូវមើលតំណែងជំនួយការឆ្វេងនិងស្តាំគួបផ្សំនឹងតំណែងអាទិត្យនិងចន្ទ បើនៅពាក់កណ្តាលថ្ងាសទូល តំណែងអាទិត្យនិងចន្ទជាមួយជំនួយការឆ្វេងនិងស្តាំអាចទាប ឬ ស្រុតតាមធម្មជាតិ បង្ហាញឱ្យឃើញថាគេម្នាក់នោះពុំបានទទួលការទំនុកបម្រុងពីសមាជិកគ្រួសារ ឬ ស្វែងរកការទំនុកបម្រុងពីសមាជិកគ្រួសារមិនបានក្នុងពេលដែលគេត្រូវការសុំជំនួយ ។

បើតំណែងទី20និង21ខូង ឬ ផត បង្ហាញឱ្យឃើញពីគ្រោះថ្នាក់ក្នុងពេលដែលអ្នកចេញពីផ្ទះ។ ជាពិសេសក្នុងពេលធ្វើដំណើរ ឧទាហរណ៍ដូចជា អ្នកធ្វើឱ្យបាត់ឯកសារ ហើយសូម្បីតែប៉ូលីសក៏ពុំអាចជួយអ្នកបាន ឬ គ្មាននរណាយល់ចិត្តអ្នក អ្នកនឹងជួបនឹងការលំបាកផ្សេងៗ ហើយមើលទៅដូចជាមិនអាចរកមនុស្សមកជួយអ្នកបានអីចឹង ។



www.elibraryofcambodia.org

សម្រាប់មនុស្សស្រី តំណែងអាយុរបស់អ្នកជំនួយការឆ្វេងនិងស្តាំផ្លាស់ប្តូរជាមួយមនុស្សប្រុស ។ តំណែងទាំងអស់នេះអាចមើលឃើញពីជីវិតអាពាហ៍ពិពាហ៍ជាមូលដ្ឋានបានទៀតផង ព្រោះជាធម្មតាទៅហើយអាយុ២០និង២១ឆ្នាំជាវ័យរៀបអាពាហ៍ពិពាហ៍សម្រាប់នារី ។




តំណែងទី20និង21 ត្រូវត្រួតពិនិត្យតួបផ្សំនឹងខ្ចង់ច្រមុះនិងទម្រង់របស់មាត់ ។ អ្វីដែលមនុស្សស្រីចង់បានគឺស្វាមីដែលអាចទុកចិត្តនិងអាចពឹងពាក់បាននាពេលអនាគត ហើយមើលថែនាងបានយ៉ាងល្អ ។ បើតំណែង20និង21មិនល្អ មានន័យថាជោគវាសនាអ្នកផ្តល់ប្រយោជន៍មិនល្អ បើមនុស្សស្រីមានខ្ចង់ច្រមុះទាប ខ្ចង់ច្រមុះមិនល្អ ឬ មាត់ផ្កាប់ បង្ហាញឱ្យឃើញថានាងខ្វះការជួយទំនុកបម្រុងពីគូជីវិត ។



www.elibraryofcambodia.org

# អាយុ២២ឆ្នាំ ចំណុចជឿទុកចិត្ត

តំណែងទី20មានឈ្មោះថាចំណុចនៃការជឿទុកចិត្តដែលនៅឆ្ងាយពីចំណុចមេឃា ឬ តំណែងទី19មានគម្លាតប្រហែលមួយថ្នាំងដៃ។ នេះគឺតំណែងដែលដូចគ្នាសម្រាប់មនុស្សប្រុស និងមនុស្សស្រី។




តំណែងទី22ជាតំណែងដែលមានទំនាក់ទំនងទៅនឹងការជឿជាក់លើខ្លួនឯងនិងការរាប់អានខ្លួនឯង។ ម្នាក់នោះជឿលើសមត្ថភាពរបស់ខ្លួនឬអត់? គេម្នាក់នោះមានការទទួលស្គាល់ថាខ្លួនមានចំណុចវិជ្ជមាននិងចំណុចអវិជ្ជមានឬអត់? ទាំងអស់នេះសុទ្ធតែអាស្រ័យលើតំណែងទី22។

អ្នកដែលមានចំណុចខ្ចង ផត សម្លាក ឬ ហើមជាំត្រង់តំណែងទី22ស្នាមខ្ចងផតកាន់តែជ្រៅប៉ុណ្ណា ឬ ស្នាមសំឡាកច្បាស់ប៉ុណ្ណា គេម្នាក់នោះក៏កាន់តែមានទស្សនៈមិនប្រាកដហើយគោរពខ្លួនឯងទាបប៉ុណ្ណោះដែរ។ ពួកគេតែងតែពូកែអៀនខ្មាស ឬ មានអារម្មណ៍ថាខ្លួនឯងមិនមានលក្ខណៈល្អគ្រប់គ្រាន់ តែងតែក្លាយទៅជាភាគីចាញ់ប្រៀបជានិច្ច ឬ មានអារម្មណ៍សុខចិត្តទទួលបានប្រយោជន៍តិចតួចជាងគេក៏បាន(ទោះជានៅក្នុងស្ថានការណ៍អំណោយផលពេញទីដល់ពួកគេក៏ដោយ)។



www.elibraryofcambodia.org

អ្នកប្រហែលជាធ្លាប់ស្គាល់មនុស្ស ឬ ស្គាល់អ្នកមានច្រើននាក់ ឬ មនុស្សដែលអាចធ្វើអ្វីក៏បាន ភាគច្រើនគេតែងតែមានលក្ខណៈស៊ីជម្រៅ និងជឿជាក់លើខ្លួនឯង។ ចំណែកអ្នកដែលមានបញ្ហាទាក់ទងនឹងតំណែងទី22តែងតែមានអារម្មណ៍ថាខ្លួនឯងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយតែងតែប្រៀបធៀបខ្លួននឹងអ្នកដទៃក្នុងចំណុចដែលអន់ជាង ដែលតាមពិតទៅ បញ្ហានោះវាជាបញ្ហាតិចតួចសោះ។




មនុស្សស្រីដែលមានសម្លាក ឬ ចំណុចផតត្រង់តំណែងទី22រមែងជឿលើអ្វីដែលមិត្តប្រុស ឬ ស្វាមីរបស់ពួកនាងប្រាប់។ ពួកនាងតែងតែស្វែងរកការសរសើរពីមិត្តប្រុស ឬ ស្វាមីរបស់ខ្លួនជានិច្ច។ តំណែងទី22ដែលស្រុត ឬ មានសម្លាកអាចធ្វើឱ្យពួកនាងមានជំងឺមិនឃ្លានអាហាររហូតក្លាយជាមនុស្សស្គមកំព្រឹង ឬ អន់ចិត្តនឹងរូបរាងរបស់ខ្លួនទៀតផង។

បើតំណែងទី22ហើម ឬ ជាំជាសញ្ញាបង្ហាញថាជាមនុស្សស្រីគ្មានប្រយោជន៍ ចូលចិត្តបង្អួតរូបឆោមលោមពណ៌របស់ខ្លួន។ ដូច្នេះបើអ្នកចង់គេចឱ្យផុតពីភរិយាជំពូកនេះចាំបាច់ត្រូវតែយកចិត្តទុកដាក់ចាំឃ្វាលគ្រប់ពេលវេលា អ្នកត្រូវចៀសវាងរៀបការជាមួយមនុស្សស្រីដែលមានតំណែងទី22ហើមជាំឱ្យបាន។



www.elibraryofcambodia.org

បើមនុស្សប្រុសមានតំណែងទី22ហើមជាំ គេមានទំនោរក្លាយជាមនុស្សគ្មានប្រយោជន៍ ចូលចិត្តអួតសម្រស់។ មនុស្សដែលមានតំណែងទី22 ហើមជាំតែងចង់បានភរិយាមកជាគ្រឿងលម្អកំដរជីវិត គឺមិនខុសពីគេចង់បាននាឡិការ៉ូឡិចមកពាក់នៅនឹងកដៃទុកគ្រាន់ដើម្បីបង្ហួតគេឱ្យឃើញតែប៉ុណ្ណោះ។

មកដល់ចំណុចនេះអ្នកប្រាកដជាឆ្ងល់ថាតើត្រូវធ្វើម្តេចដើម្បីឱ្យដឹងថាតំណែងដែលនៅលើផ្ទៃមុខរបស់ខ្លួនមិនល្អ? ក្នុងសាស្ត្រនៃការមើលទម្រង់មុខ លក្ខណៈផ្សេងៗដែលឃើញបានច្បាស់មានដូចជាសម្លាកនិងតំណែងដែលស្រុតអាចឱ្យយើងបែងចែកបានដោយងាយ។ សំខាន់បំផុតគឺព្យាយាមសង្កេតមើលអ្នកផ្សេងត្រង់ចំណុចដែលខុសគ្នា។ ចំណែកគន្លឹះសំខាន់មួយទៀតគឺចៀសវាងការគិតក្នុងផ្លូវអវិជ្ជមាន។ ចូរព្យាយាមសង្កេតមើលធ្វើជារឿយៗក្នុងរយៈពេលមិនយូរទេ អ្នកនឹងដឹងថាអ្នកអាចមើលឃើញអ្វីផ្សេងៗដែលអ្នកពុំធ្លាប់ឃើញនៅលើផ្ទៃមុខរបស់អ្នកដទៃនិងផ្ទៃមុខរបស់អ្នកខ្លួនឯងពីមុនមក។

តំណែងនេះមានទំនាក់ទំនងផ្ទាល់ជាមួយនឹងសមត្ថភាពក្នុងការស្វែងរកចំណុចលេចធ្លោនិងកេរ្តិ៍ឈ្មោះនិងការនាំមកនូវមោទកភាពឱ្យគ្រួសារនិងវង្សត្រកូល (ជនជាតិចិនហៅថា "មិងស៊ី")។ ការនាំកិត្តិយសមកឱ្យគ្រួសារចាត់ទុកថាជាភាពជោគជ័យដ៏ធំមួយក្នុងវប្បធម៌ចិន។ ជាពិសេសទៅទៀត បើតំណែងទី22នៅក្នុងជួរជាមួយគ្នានឹងចុងច្រមុះមានន័យថាអ្នកនឹងអាចសាងកេរ្តិ៍ឈ្មោះល្បីល្បាញឱ្យដល់គ្រួសារនិងធ្វើឱ្យបុព្វបុរសរបស់អ្នកមានមោទកភាពចំពោះភាពជោគជ័យរបស់អ្នក។

ការស្ថិតនៅក្នុងជួរជាមួយគ្នាដោយត្រង់រវាងតំណែងទី 22នឹងចុងច្រមុះមិនងាយកើតឡើងទេ ហើយក៏មិនងាយបែងចែកបានស្រួលនោះដែរ។ អ្នកចាំបាច់ត្រូវនឹកឱ្យឃើញនូវរូបភាព ឬ រូបារម្មណ៍អំពីខ្សែដែលអូសពីចុងច្រមុះជាខ្សែត្រង់180ដឺក្រេនៅក្នុងជួរជាមួយតំណែងទី22។ ជាញឹកញាប់ណាស់ដែលអ្នកឃើញថាវាមិនមែនជាខ្សែត្រង់180ដឺក្រេទេ។

អ្នកដែលមានចុងច្រមុះនិងតំណែងទី22នៅលើខ្សែត្រង់180ដឺក្រេត្រូវបានចាត់ទុក



www.elibraryofcambodia.org

ថាជាលក្ខណៈពិសេសនៅលើទម្រង់មុខរបស់ពួកគេ។

អ្នកដែលមានតំណែងទី22ទាប (មានន័យថាជើងសក់ទាប) មិនអាចមានតំណែងខ្ពស់ក្នុងរាជការ ឬ កិច្ចការសាធារណៈបានទេ។ នេះជារឿងសមហេតុសមផលណាស់ តើមានអ្នកនយោបាយប៉ុន្មាននាក់ដែលអ្នកស្គាល់ដែលមិនមានជំនឿជាក់លើខ្លួនឯងទាបនោះ?




ជើងសក់ទាប តំណែងទី22 ទាប

ទោះជាយ៉ាងណាក៏ដោយ សូមកុំបារម្ភពេកអី ព្រោះយើងមានវិធីកែខៃចំពោះអ្នកដែលមានតំណែងទី22ទាប គឺអ្នកត្រូវព្យាយាមផ្លាស់ប្តូរគោលដៅនិងទស្សនៈរបស់ខ្លួនឱ្យបានច្រើនបំផុត ព្រោះ "លក្ខណៈផ្សេងៗនៃទម្រង់មុខកើតមកពីចិត្ត"។ នេះមានន័យថាបើអ្នកធ្វើការផ្លាស់ប្តូរបាន អ្នកនឹងរកឃើញថាទម្រង់មុខរបស់អ្នកក៏នឹងមានការផ្លាស់ប្តូរទៅតាមដោយយឺតៗដែរ។



www.elibraryofcambodia.org

# អាយុ២៣-២៤ឆ្នាំ អស្សុពីឋានសួគ៌




តំណែងសម្រាប់អាយុ23និង24ឆ្នាំស្ថិតនៅត្រង់ជ្រុងទាំងពីរនៃថ្ងាសដែលមានឈ្មោះថា "ជាយក្រុង" ឬ "អស្សុពីស្ថានសួគ៌"។ សម្រាប់មនុស្សប្រុសតំណែងទី23ស្ថិតនៅផ្នែកខាងឆ្វេង ឯតំណែងទី24ស្ថិតនៅខាងស្តាំ។ ចំណែកមនុស្សស្រីតំណែងនេះស្ថិតនៅបញ្ច្រាសគ្នានឹងមនុស្សប្រុសវិញ។

ហេតុអ្វីបានជាអ្នកដែលធ្វើការភៀសខ្លួនទៅនៅប្រទេសផ្សេងខ្លះមានការលំបាកដោយពួកគេពិបាកសម្របខ្លួនជាមួយសង្គមថ្មីនោះម្ល៉េះ? ហើយហេតុអ្វីក៏អ្នកខ្លះអាច ទៅធ្វើការនៅប្រទេសផ្សេងបានយ៉ាងងាយស្រួល ក្នុងពេលដែលអ្នកដទៃមានក្តីបារម្ភចំពោះវប្បធម៌ដែលខុសគ្នា ហើយមិនអាចនៅឆ្ងាយផ្ទះបាន? ទាំងអស់នេះសុទ្ធតែមកពីតំណែងទី 23 និង24ទាំងអស់។

អ្នកដែលមានតំណែងទី23និង24ទូលាយហើយខ្ពស់ បង្ហាញឱ្យឃើញពីសមត្ថភាព ឬ អាចធ្វើការនៅទីឆ្ងាយបាន ឬ គេជាមនុស្សដែលមានភាពជោគជ័យក្នុងការផ្លាស់ប្តូរទីលំនៅទៅធ្វើការនៅប្រទេសផ្សេងបាន។

ចំណែកអ្នកដែលមានតំណែងទី 23និង24ទាប ឬ គ្របដណ្តប់ដោយជើងសក់មិនអាចទទួលបានជោគជ័យល្អក្នុងការប្តូរទីលំនៅបានទេ នោះដោយសារអស្សុពីឋានសួគ៌ ឬ ថ្ងៃធ្វើ



www.elibraryofcambodia.org

ដំណើររបស់ពួកគេតែងតែមានបញ្ហាសុខភាពនិងលក្ខណៈមិនល្អផ្សេងៗកើតឡើង។

អ្នកដែលមានតំណែងទី23និង24ល្អនិងមានសាច់ ហើយមើលទៅមានលក្ខណៈស្រស់បស់នោះគឺជាអ្នកដែលអាចធ្វើដំណើរទៅមុខទៀតបានយ៉ាងល្អក្នុងឆាកជីវិត។ មិនតែប៉ុណ្ណោះពួកគេគឺជាអ្នកដែលទទួលបាននូវផលប្រយោជន៍តាមរយៈការរកស៊ីចូលហ៊ុនដែលមាននៅក្រៅប្រទេសទៀតផង។

ការមើលទម្រង់មុខអាចប្រើសម្រាប់មើលជោគជតាប្រចាំថ្ងៃ ឬ ភាពមានបានរបស់មនុស្សយើងបាន។ តើអ្នកអាចដឹងបានយ៉ាងដូចម្តេចថាមនុស្សម្នាក់នឹងមានគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ ឬ មានបញ្ហាក្នុងពេលធ្វើដំណើរ?

ចម្លើយគឺត្រូវត្រួតពិនិត្យមើលអស្សស្ថានសូតិរោគសើស្បែក ឬ ស្នាមខ្មៅជាំដែលមានលើខ្លួនរបស់អស្សស្ថានសូតិ ព្រោះជាសញ្ញាបង្ហាញច្បាស់បំផុតចំពោះការធ្វើដំណើរអាចនាំឱ្យមានគ្រោះថ្នាក់។ បើក្នុងពេលនោះគេមានភ្នែកព្រឹលស្រវាំង និងមានជាំខ្មៅត្រង់ច្រមុះ ឬមានមុនត្រង់ច្រមុះ យើងអាចសរុបថាគេម្នាក់នោះនឹងជួបឧប្បត្តិហេតុរថយន្ត តែមិនដល់ថ្នាក់ធ្វើឱ្យបាត់បង់ជីវិតទេ គ្រាន់តែធ្វើឱ្យបាត់បង់ប្រាក់កាសច្រើន។




ស្នាមខ្មៅជាំត្រង់អស្សស្ថានសូតិ



www.elibraryofcambodia.org

## សម្រាប់មនុស្សស្រី តំណែងទី23 និង24 ស្ថិតនៅផ្ទុយគ្នាពីតំណែងរបស់មនុស្សប្រុស




បើមនុស្សស្រីមានតំណែងទី23និង24ខ្ពស់ មានន័យថា នាងនឹងជួបមនុស្សសំខាន់របស់នាងក្នុងខណៈដែលនាងធ្វើដំណើរទៅបន្តការសិក្សា ឬ ដើម្បីធ្វើការនៅក្រៅប្រទេស។ ផ្ទុយទៅវិញ បើមនុស្សស្រីម្នាក់មានតំណែងទី23និង24ទាប ឬ មានជើងសក់គ្របដណ្តប់ធ្វើឱ្យតំណែងទី23និង24មានលក្ខណៈមិនច្បាស់នោះ បង្ហាញថាសុភាពនារីម្នាក់នោះនឹងមិនឈានជើងចេញក្រៅផ្ទះដើម្បីស្វែងរកមនុស្សសំខាន់របស់នាងទេ តែមនុស្សសំខាន់នោះជាអ្នកស្វែងរកនាងវិញ។



www.elibraryofcambodia.org

# អាយុ២៥ឆ្នាំ ចំណុចពាក់កណ្តាល




តំណែងជោគជតាអាយុ24ឆ្នាំរបស់មនុស្សយើងនៅក្រោមតំណែងទី22ចំងាយមួយទទឹងម្រាមដៃ (តំណែងនេះប្រើបានទាំងមនុស្សប្រុសនិងមនុស្សស្រី) តំណែងនេះត្រូវបានគេស្គាល់ក្នុងនាមជាចំណុចពាក់កណ្តាលដែលមានជាប់ទាក់ទងនឹងការមានសមត្ថភាព ហេតុផលនិងភាពសុខដុមរមនារបស់គេ។ ចំណុចពាក់កណ្តាលដែលផត ឬ ទូលខ្ពស់បង្ហាញឱ្យឃើញពីគោលដៅ ឬ ទស្សនវិស័យដែលហួសហេតុពេក ពួកគេគឺជាមនុស្សដែលជាប់ជំពាក់នឹងអ្វីមួយខ្លាំង តែតឹងរឹងចំពោះអ្វីដែលគេមិនចូលចិត្ត។ ពួកគេជារឿយៗមិនសូវនឹកគិតអំពីតុល្យភាពនៃជីវិតរបស់ខ្លួនប៉ុន្មានឡើយ។

តំណែងទី25ដែលមានលក្ខណៈរាបស្មើ មានស្បែកស្រស់ថ្លា មិនមានឆ្អឹងផុស ហើយមិនមានសម្លាក ឬ ខ្សែរឆ្នូតកាត់ មិនខូង មិនទូល ឬ មិនហើមជាំគឺជាតំណែងដែលល្អ។



www.elibraryofcambodia.org

បើតំណែងទី25 មានលក្ខណៈរាបស្មើ វាបង្ហាញឱ្យឃើញពីសំណាងល្អរបស់គេនោះ ។ ពេលអាយុបាន25 ឆ្នាំ យើងត្រូវប្រើវិធីអាន ឬ សង្កេតមើលលើច្រើនតំណែងដើម្បីមើលឱ្យដឹងពី "ព្រំដែន" របស់តំណែងទី 25 ថាមានតិច ឬ ច្រើនប៉ុណ្ណាសម្រាប់មនុស្សម្នាក់នោះ ។ តំណែងទី25 ត្រូវមើលគួបផ្សំនឹងត្រចៀករួមទាំងចិញ្ចើម ព្រោះលក្ខណៈទាំងអស់នេះត្រូវជួយតំណែងទី25 សម្រាប់ជោគជតាអាយុ25 ឆ្នាំ ទើបអាចចាត់ទុកបានថា "ល្អ" បើត្រចៀកចិញ្ចើមមានទម្រង់ល្អអាចជួយតំណែងទី25 បាននោះយើងអាចនិយាយបានថាគេម្នាក់នោះនឹងទទួលបាននូវការតំឡើងតំណែងពេលមានអាយុ25 ឆ្នាំ ។

តទៅនេះ គឺជាបទពិសោធន៍ខ្លះៗក្នុងការមើលច្រើនតំណែងក្នុងពេលតែមួយ ។ បើតំណែងទី25 ផត ផ្សំជាមួយនឹងចិញ្ចើមក្បាលលំពែង ហើយមនុស្សម្នាក់នោះជានារីអាចនិយាយបានថានាងនឹងជួបប្រទះនឹងការបោះជំហានដែលធ្វើឱ្យនាងដើរថយក្រោយ ឬ អន់ថយធំបំផុតនៅពេលមានអាយុ25 ឆ្នាំ ។ ម្យ៉ាងទៀតដំណើរថយក្រោយនេះមានទំនាក់ទំនងសំខាន់ណាស់នឹងខ្លួនរបស់នាងផ្ទាល់ ។





www.elibraryofcambodia.org

# អាយុ២៦_២៧ឆ្នាំ ទាលកប់ខ្មោចនិងផ្នូរខ្មោច (សម្រាប់បុរស)




នៅពេលដែលយើងគិតដល់តំណែងទី 26និង27 សូមនឹកគិតដល់ពេលដែលអ្នកមានអាការឈឺក្បាល អ្នកនឹងយកដៃចុចត្រង់សៀតផ្កាដើម្បីឱ្យមានភាពធូរស្រាល ។ វិធីនេះអ្នកនឹងបានច្បាស់ក្នុងចិត្តដោយពុំមានថ្ងៃភ្លេចទេថាតំណែងទាំងពីរស្ថិតនៅត្រង់ណា តំណែងទី26និង27 ជាវាលកប់ខ្មោចបុព្វបុរសនិងផ្នូរខ្មោចបុព្វបុរសស្ថិតនៅត្រង់សៀតផ្ការបស់អ្នកវានៅត្រង់ចុងចិញ្ចើម ។

តំណែងនេះបង្ហាញអំពីការមើលឃើញតែប្រយោជន៍អ្នកដទៃជាធំនិងការប្រកាន់ខ្ជាប់ក្នុងរឿងគុណធម៌មេត្រីភាព ។ និយាយជារួមតើបុគ្គលនោះជាមនុស្សអាត្មានិយមឬអត់?



www.elibraryofcambodia.org

# អាយុ២៦-២៧ឆ្នាំ ផ្នូរខ្មោចនិងវាលកប់ខ្មោច (សម្រាប់នារី)




តើពួកគេគិតដល់អ្នកដទៃដូចគិតដល់ខ្លួនឯងឬទេ? ទាំងអស់នេះយើងអាចប្រាប់បានតាមរយៈតំណែងទី 26និង27 យើងកំពុងរកមើលតំណែងទី26និង27ដែលមានសាច់ពេញនិងមានស្បែកស្អាតដោយគ្មានស្នាម ឬ សរសៃឈាមតូចៗនៅត្រង់បរិវេណនេះ។

អ្នកប្រហែលជាឆ្ងល់ហើយថាហេតុអ្វីបានជាឈ្មោះរបស់តំណែងនេះមានជាប់ទាក់ទងនឹងបុព្វបុរស? មានមូលហេតុគួបផ្សំជាច្រើនប្រការ គឺប្រការដំបូង បើបុព្វបុរសរបស់អ្នកជាមនុស្សល្អ ហើយអ្នកបានទទួលបាននូវការចិញ្ចឹមបីបាច់ថែរក្សាបានល្អ អ្នកនឹងក្លាយជាមនុស្សល្អប្រតិបត្តិខ្លួនក្នុងផ្លូវល្អព្រោះអ្នកបានទទួលការអប់រំប្រដៅប្រដៅតាំងពីក្មេងមក។ ផ្ទុយទៅវិញមនុស្សដែលមិនបានទទួលការចិញ្ចឹមបីបាច់ឱ្យធំធាត់ក្នុងផ្លូវល្អទេ ឬ ប្រវត្តិរបស់ពួកគេមិនល្អនោះ គេទាំងអស់នោះនឹងចាត់ទុកទង្វើគុណធម៌និងទឹកចិត្តមិនសូវមានភាពសំខាន់ទេ។



www.elibraryofcambodia.org

មូលហេតុមួយទៀតដែលយើងហៅតំណែងទី26និង27ថាជាផ្នូរខ្មោចបុព្វបុរសនិងវាំលកប់ខ្មោចរបស់បុព្វបុរសនោះ  ដោយសារវាទាក់ទងនឹងវាំលកប់ខ្មោចនិងផ្នូរខ្មោចរបស់បុព្វបុរសពិតៗដែរ។ បើជើងសក់របស់អ្នកដុះជិតលុបថ្ងាស ឬ លុបលើស្មៀតផ្កាបង្ហាញឱ្យឃើញថាហុងស៊ុយផ្នូរខ្មោចបុព្វបុរសអ្នកមិនល្អទេ។  បើតំណែងទាំងអស់នេះស្រុតគឺមានន័យថាវាំលកប់ខ្មោចបុព្វបុរសអ្នកអាចមានលិចទឹក ឬ មានទឹកក្រោមដីលិចដល់មឈូស។

វិធីសាស្ត្រនៃការមើលទម្រង់មុខបានកត់ត្រាទុកថា បើត្រង់តំណែងនេះមានសាច់ពណ៌ស្បែកភ្លឺថ្លាមានន័យថាបុព្វបុរសចាំនាំផ្លូវអ្នកឱ្យដើរទៅរកផ្លូវត្រូវ។





www.elibraryofcambodia.org

# អាយុ២៨ឆ្នាំ កំណប់ទ្រព្យ (សម្រាប់បុរសនិងនារី)




តំណែងទី28ជាតំណែងដែលសំខាន់បំផុតលើទម្រង់មុខសម្រាប់មនុស្សប្រុសនិងមនុស្សស្រីដែលវាមានឈ្មោះថាវាំងជីវិត ឬ កំណាប់ទ្រព្យ ។ កំណាប់ទ្រព្យស្ថិតនៅត្រង់គល់ចិញ្ចើម ។

ការមើលទម្រង់មុខចាប់ផ្តើមពីការមើលវាំងជីវិត បើវាំងជីវិតធំទូលាយមានសាច់ហើយមិនឡើងឆ្អឹង តែម្នាក់នោះនឹងមានគុណភាពជីវិតល្អ ។ តើគុណភាពជីវិតចង់សំដៅលើអ្វី? មនុស្សម្នាក់ៗមានគំនិតប្លែកៗគ្នាទាក់ទងនឹងគុណភាពជីវិត អ្នកខ្លះគិតថាការមានសុខភាពល្អឯអ្នកខ្លះទៀតគិតថាគឺការមានទំនាក់ទំនងល្អ ហើយសម្រាប់មនុស្សភាគច្រើនគិតថាគឺការមានទ្រព្យសម្បត្តិគ្រប់គ្រាន់តាមតម្រូវការ ។ ប៉ុន្តែ តើអ្នកធ្លាប់បានគិតទេថាគុណភាពជីវិតអាចមិនល្អទោះជាគេម្នាក់នោះមានទ្រព្យធនសម្បូរហូរហៀរយ៉ាងណាក៏ដោយ ។ អ្នកខ្លះមានមែនតែឈឺពុំចេះឈប់ ឬ ត្រូវឯកោដោយមិនសូវសម្បូរញាតិមិត្ត ។



www.elibraryofcambodia.org




ទីតាំងរបស់វាំងជីវិត



www.elibraryofcambodia.org

# អាយុ២៩-៣០ឆ្នាំ ព្រៃនៃទម្រង់មុខ




តំណែងទី29និង30ស្ថិតនៅខាងក្នុងជើងសក់ត្រង់តំណែងលើត្រចៀកប្រហែលមួយម្រាមដៃ ដូចមានបង្ហាញក្នុងរូបភាព។ ចំណុចទាំងពីរនេះជំនួសឱ្យអាយុ29និង30ឆ្នាំ។ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយតំណែងទី26និង27។ តំណែងទាំងនេះមិនមានឥទ្ធិពលចំពោះឧបនិស្ស័យជាទូទៅរបស់មនុស្សយើងទេ វាមានទំនាក់ទំនងនឹងហុងស៊ុយនៃវាលកប់ខ្មោចបុព្វបុរសរបស់គេម្នាក់នោះច្រើនជាង។

តំណែងទាំងពីរនេះត្រូវមើលដោយផ្ទួបនឹងតំណែងទី28 ដូច្នេះហើយ ទើបយើងត្រូវមានវិធីសាស្ត្រក្នុងការមើលលើច្រើនតំណែង។ ក្នុងខណៈពេលមើលតំណែង29និង30 បើតំណែង28មានម្លូលមួយស្រួច (សរសៃស្តើងៗដែលមើលទៅដូចជាម្លុលសៀតជាប់ត្រង់តំណែងនេះ) ចាត់ទុកថាតំណែងទី28មានលក្ខណៈថយចុះ។ បើចិញ្ចើមដាច់ រែប ឬ ក្រហតនិងចិញ្ចើមស្តុកខ្លាំងបង្ហាញឱ្យថាអាចនឹងប្រឈមមុខនឹងឧប្បត្តិហេតុធំដែលអាចប៉ះពាល់ដល់អាយុជីវិត ពេលមានអាយុ30ឆ្នាំ។

បើតំណែងទី28ចង្អៀត ហើយតំណែងទី29និង30ស្រុតបង្ហាញថាខណៈអាយុបាន28 ឬ 29ឆ្នាំនឹងមានបញ្ហាផ្នែកសុខភាព ឬ មានឧប្បត្តិហេតុកើតឡើងដែលជាមូលហេតុធ្វើឱ្យមានសុខភាពមិនល្អ។


www.elibraryofcambodia.org

# អាយុឆ្នាំ៣១_៣៤ឆ្នាំ ជោគជតាចិញ្ចើម




ចិញ្ចើមទាំងមូលតំណាងឱ្យអាយុ31-34ឆ្នាំ។ គល់ចិញ្ចើមតំណាងឱ្យអាយុ31ដល់ 32ឆ្នាំ។ ចុងចញ្ចើមតំណាងឱ្យអាយុ33និង34ឆ្នាំ។

តើគល់ចិញ្ចើមនិងចុងចិញ្ចើមនៅត្រង់ណា? សូមក្រឡេកមើលរូបភាពខាងលើ អ្នកត្រូវចាំទុកថាតំណែងទាំងអស់នេះសម្រាប់មនុស្សប្រុសនិងមនុស្សស្រីមិនដូចគ្នាទេ។

**សម្រាប់មនុស្សប្រុស**

-គល់ចិញ្ចើមឆ្វេងតំណាងឱ្យអាយុ31ឆ្នាំ

-គល់ចិញ្ចើមស្តាំតំណាងឱ្យអាយុ32ឆ្នាំ

-ចុងចិញ្ចើមឆ្វេងតំណាងឱ្យអាយុ33ឆ្នាំ

-ចុងចិញ្ចើមស្តាំតំណាងឱ្យអាយុ34ឆ្នាំ

**សម្រាប់មនុស្សប្រុសស្រី**

ការរៀបលំដាប់មុនក្រោយត្រូវចាប់ផ្តើមពីគល់ចិញ្ចើមស្តាំ។

ចិញ្ចើមតំណាងឱ្យឧបនិស្ស័យនិងធម្មជាតិដែលជាមូលដ្ឋានរបស់មនុស្សនោះ។ តើពួកគេជាមនុស្សស្ពឹក រហ័សរហួន ទន់ភ្លន់ មានចិត្តមេត្តាឬទេ? តើពួកគេជាមនុស្សចូលចិត្តដើរខ្សែលើអ្នកឬទេ?



www.elibraryofcambodia.org

អ្នកដែលមានកិរិយា ឬ អត្តចរិតក្មេងក្មាងនិងមានអំណាចតែងតែមានចិញ្ចើមស្លាប (ចិញ្ចើមដែលស្រដៀងនឹងស្លាបមួយគូ) ឬ ចិញ្ចើមឡើងត្រង់។ ផ្ទុយទៅវិញ មនុស្សដែលអៀនហើយកំសាកតែងតែមានចិញ្ចើមកោងចុះ។



ចិញ្ចើមក្បាលលំពែង

មនុស្សដែលមានចិញ្ចើមក្បាលលំពែងតែងជាមនុស្សក្បាលរឹងមានះរឹងរូស ចូលចិត្តប្រកាន់ភ្ជាប់នូវទស្សនរបស់ខ្លួន ឬ អាចនិយាយសាមញ្ញថា "មនុស្សខ្ញុំគឺអីចឹង ខ្ញុំមិនអាចផ្លាស់ប្តូរបានទេ" នេះជាគំនិតងាប់មួយក្រឡា ជារឿយៗពួកគេតែងតែមិនអាចសម្របខ្លួននឹងបរិយាកាសថ្មីៗទេ ពួកគេច្រើនមានបញ្ហានៅរវាងអាយុពី31-34ឆ្នាំ។



ស្នាមសម្លាកនៅក្នុងចិញ្ចើម

ចិញ្ចើមបែកដោយសារមានស្នាមបែកកាត់ពីក្នុង (ដូចជាមានសម្លាកជាដើម) បង្ហាញឱ្យឃើញថានឹងមានបញ្ហានៅអាយុ31ឆ្នាំនិងបង្ហាញថាពួកគេមិនសូវមានភាពជិតស្និទ្ធជាមួយបងប្អូនណាស់ណាទេ។

ចិញ្ចើមស្តើងហើយរ៉ុយៗបង្ហាញថាគេជាមនុស្សមានចិត្តទន់ភ្លន់ ខ្វះការព្យាយាមបន្តិច និងមិនសូវសម្បូរឆន្ទៈ ពួកគេនឹងមិនអាចសម្រេចគោលដៅបានទេ ឬ អាចគ្មានគោលដៅច្បាស់លាស់នៅក្នុងកំឡុងអាយុ30។ បើមានការគិតនិងការបង្កើតឆន្ទៈផ្ទាល់ខ្លួនឱ្យបានរឹងមាំនោះអ្វីៗក៏មិនអាក្រក់ដូចទំនាយនេះប៉ុន្មានដែរ។

អ្នកបានសង្កេតឃើញហើយថាក្នុងសាស្ត្រនៃការមើលទម្រង់មុខនេះ មូលដ្ឋានសម្រាប់មនុស្សប្រុសនិងមនុស្សស្រីមានលក្ខណៈមិនជាខុសគ្នាប៉ុន្មានទេ។ អ្វីដែលល្អសម្រាប់មនុស្សប្រុសក៏មិនចាំបាច់ត្រូវជារបស់មនុស្សស្រីទេ តំណែងដោយឡែកខ្លះមានលក្ខណៈ "ល្អ" ឬ "អាក្រក់" ដែលដូចគ្នាទាំងមនុស្សប្រុសនិងមនុស្សស្រី តែតំណែងភាគច្រើនមានមូលដ្ឋានបែងចែកនិងខុសគ្នាសម្រាប់ភេទនីមួយៗ។



www.elibraryofcambodia.org

សម្រាប់មនុស្សស្រីចិញ្ចើមក្រាស់ជាចិញ្ចើមដែលយើងពុំចង់បានឡើយ ។ មនុស្សស្រីដែលមានចិញ្ចើមក្រាស់ជាពិសេសគល់ចិញ្ចើមបង្ហាញថានាងខ្វះលក្ខណៈជាមនុស្សស្រី ។ នេះមិនមែនចង់និយាយថាពួកនាងស្រួចស្រាវទេ យើងគ្រាន់តែអាចនិយាយបានថាពួកនាងខ្វះភាពទន់ភ្លន់ជាងមនុស្សស្រីទូទៅ ។ លើសពីនេះពួកនាងនៅខ្វះលក្ខណៈនៃការរៀបចំឱ្យមានសណ្តាប់ធ្នាប់ដែលមនុស្សស្រីជាទូទៅមាន ។ ដូច្នេះហើយទើបមនុស្សស្រីទាំងអស់នេះមិនងាយរៀបការតែងតែប្រឈមមុខនឹងការដើរថយក្រោយ រីឯការធ្វើទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកនាងពេលចូលដល់វ័យនេះក៏មិនជាល្អប៉ុន្មានទេ ។


មនុស្សស្រីដែលមានចិញ្ចើមក្រាស់ខ្លាំង

ក្នុងសាស្ត្រក្នុងការមើលទម្រង់មុខ ទម្រង់មុខរបស់មនុស្សប្រុសគួរមានលក្ខណៈជាភេទប្រុស ឬ "យ៉ាង" ។ ចំណែកទម្រង់មុខរបស់មនុស្សស្រីក៏គួរមានលក្ខណៈជាភេទស្រី ឬ "យិន" ដែរ ។ ដូច្នេះហើយក្នុងសាស្ត្រការមើលទម្រង់មុខ បើអ្នករកឃើញទម្រង់មុខមនុស្សប្រុសដែលមានលក្ខណៈដូចជាមនុស្សស្រី តើអ្នកមើលយ៉ាងម៉េចដឹង?


បុរសចិញ្ចើមស្តើងនិងដុះរ៉ុយៗ

ឱ! កំលោះទីក្រុងអ្នកចូលចិត្តធ្វើខ្លួនទាំងឡាយអើយ!

បើអ្នកឃើញមនុស្សប្រុសចិញ្ចើមរ៉ុយៗហួសនោះវាបង្ហាញប្រាប់អ្នកថាពួកគេមានការព្រួយបារម្ភតិចតួចហើយតែងតែរវល់ខុសរឿងដោយចូលចិត្តធ្វើរឿងកំប៉ិកកំប៉ុកផ្សេងៗ ។ សុភាពនារីទាំងឡាយ នេះហើយគឺពួកមនុស្សប្រុសដែលអាចបង្ករឿងឈ្លោះជាមួយអ្នកដោយសារតែពណ៌របស់វាំងននក្នុងផ្ទះ ការតាំងថូផ្កា ឬ ថែមទាំងរអ៊ូនឹងរឿងដាក់រយ៉ាលើមាត់ទ្វា មាត់បង្អួច...



www.elibraryofcambodia.org

ចិញ្ចើមដែលល្អសម្រាប់មនុស្សប្រុសគឺចិញ្ចើមដែលមិនដុះរ៉ុយៗ ឬ ស្តុកហួសពេក ចំណុចសំខាន់បំផុតនោះគឺរោមចិញ្ចើមត្រូវស្របទិសគ្នាដែលជាលក្ខណៈបង្ហាញឱ្យឃើញពីភាពរីកចម្រើនក្នុងមុខរបរពេលមានអាយុ31-32ឆ្នាំទាំងសម្រាប់បុរសនៅលីវនិងរៀបការរួច។

ចុងចិញ្ចើមតំណាងឱ្យតំណែងទី33និង34 មុននេះយើងធ្លាប់បានលើកឡើងហើយថាមិនចូលចិត្តចិញ្ចើមដែលដុះរ៉ុយៗ ឬ ស្តុកពេក។ អ្នកប្រហែលជាឆ្ងល់ហើយថាចិញ្ចើមស្តុកពេកវាយ៉ាងម៉េច? ចិញ្ចើមស្តុកពេកគឺចិញ្ចើមដែលមើលមិនឃើញគល់រោមចិញ្ចើម។ ជួនកាលមនុស្សខ្លះអាចមានគល់ចិញ្ចើមស្តុក តែអាចមើលឃើញគល់រោមចិញ្ចើម ករណីនេះមនុស្សនោះនឹងមានមិត្តភក្តិ ឬ បងប្អូនចាំជួយទំនុកបម្រុងពេលជួបទុក្ខលំបាកផ្សេងៗ។



ចិញ្ចើមស្តុកហួសពេក

យើងក៏មិនចូលចិត្តចិញ្ចើមដែលវែងហួសដែរ។ បើចិញ្ចើមក្រាស់ហើយវែងមកដល់សៀតផ្កាបង្ហាញថាគេជាមនុស្សចិត្តទូលាយជាមួយមិត្តភក្តិហួសពេក ពួកគេអាចនឹងចំណាយលុយជាមួយមិត្តភ័ក្តិដោយមិនចាប់អារម្មណ៍ថាត្រូវស៊ីអំបិលនៅថ្ងៃក្រោយទេ ព្រោះគេអាចឱ្យមិត្តភក្តិខ្ចីលុយដោយងាយៗទៀតផង។

អ្នកប្រហែលជាចង់ដឹងថាមូលដ្ឋាននេះមកពីណាហើយ តើអ្នកនៅចាំបានទេថាតំណែង26ទី27ជំនួសឱ្យការប្រកាន់ភ្ជាប់នូវគុណធម៌ ទឹកចិត្ត ឬ មិត្តភាព ការយល់ដល់ប្រយោជន៍អ្នកដទៃនិងវិធីដែលមនុស្សយើងប្រតិបត្តិចំពោះមិត្តភក្តិជាទូទៅ។ ចិញ្ចើមក្រាស់បង្ហាញឱ្យឃើញនូវការប្រកាន់ភ្ជាប់នូវមិត្តភាពតែហាក់ដូចជាអួតបន្តិចនិងតែងតែចូលចិត្តបង្ហាញការជួយទំនុកបម្រុងចំពោះមិត្តភក្តិយ៉ាងច្រើនលើសលប់។



www.elibraryofcambodia.org

ចិញ្ចើមរ៉ុយៗត្រង់តំណែងទី33និង34នឹងបង្ហាញថាជាមនុស្សទុកលុយមិនសល់ព្រោះពួកគេចាយធំណាស់។ តើយើងមើលយ៉ាងម៉េចឱ្យដឹងថាវាមានលក្ខណៈរ៉ុយៗ? ជាធម្មតា លក្ខណៈបែបនេះបង្ហាញឱ្យឃើញតាមរយៈគល់រោមចិញ្ចើមនិងរោមដែលដុះនៅឆ្ងាយពីគ្នា។




ចិញ្ចើមដែលដុះរ៉ុយៗហើយស្តើងមិនមែនជាការគួបផ្សំល្អនោះទេ វាបង្ហាញឱ្យឃើញពីលក្ខណៈប្រុសដែលគ្មានសមត្ថភាពក្នុងការទាញប្រយោជន៍ពីឱកាសផ្សេងៗ ទោះជាគេយកលុយដាក់ជើងពានមកប្រគេនហើយក៏ដោយ។ ទោះជាក្រោយពេលដែលគេម្នាក់នោះឆ្លងផុតអាយុ34ឆ្នាំទៅហើយក៏ដោយ ក៏លក្ខណៈបែបនេះនៅតែជាប់ខ្លួនគេអស់មួយជីវិតដែរ លើកលែងតែគេលះបង់ ហើយព្យាយាមប្រើសតិបញ្ញានិងកម្លាំងចិត្តដោយពេញទំហឹងដើម្បីក្លាយជាមនុស្សដែលមានសមត្ថភាពនិងសម្រេចភាពជោគជ័យឱ្យបាន។

សុភាពនារីទាំងឡាយបើអ្នកចង់ដឹងចង់ស្គាល់អំពីឧបនិស្ស័យរបស់មនុស្សប្រុស អ្នកត្រូវសង្កេតមើលចិញ្ចើមរបស់គេស្តុកឬយ៉ាងណា។ អ្នកអាចដៅបានភ្លាមថាក្នុងកំឡុងពេលដែលគេមានអាយុ33ឬ 34 ឆ្នាំ អ្នកអាចក្លាយជាបុគ្គលលំដាប់លេខពីរក្នុងជីវិតរបស់គេ ព្រោះគេនឹងអស់លុយកាក់មាសប្រាក់ដោយសារមិត្តភក្តិនិងបងប្អូនរបស់គេ។ បើចិញ្ចើមរបស់គេរ៉ុយៗ ក្នុងរវាងអាយុ33ឬ 34ឆ្នាំ គេជាមនុស្សទុកលុយមិនគង់ទេ ដែលជូនកាលអ្នកត្រូវទទួលខុសត្រូវលើបញ្ហាលុយកាក់ដោយខ្លួនឯង។ ស្វាមីដែលល្អគឺមនុស្សដែលមានរោមចិញ្ចើមក្រាស់ស្មើគ្នា លក្ខណៈបែបនេះបង្ហាញថាម្នាក់នោះមានលក្ខណៈប្រាកដប្រជាមានការរៀបចំល្អ ហើយថែមទាំងមានថាមពលជួយជំរុញជោគជតាជីវិតឱ្យល្អទៀតផង។



www.elibraryofcambodia.org

# អាយុ ៣៥-៣៦ ឆ្នាំ មាន "យ៉ាង" និង "យិន" ធំ

កែវភ្នែកបង្ហាញឱ្យឃើញពីចិត្តនិងបេះដូងរបស់មនុស្សម្នាក់ៗ។ ពេលមនុស្សដែលកំពុងនិយាយជាមួយអ្នកមិនហ៊ានសម្លឹងមើលមុខអ្នកដោយចំត្រង់ៗទេ ឬ ញាក់ភ្នែកឆ្វេង ឬ ភ្នែកស្តាំពេលកំពុងនិយាយជាមួយអ្នក នេះជាសញ្ញាប្រាប់យ៉ាងច្បាស់ថាការតាំងចិត្តរបស់គេនៅមិនទាន់បរិសុទ្ធ ឬ ប្រាកដប្រជាទេ។ ការយល់ព្រមរបស់ពួកគេតាមរយៈពាក្យសម្តីនិងទង្វើរបស់ពួកគេនោះសុទ្ធតែខ្វះភាពប្រាកដប្រជា។

កែវភ្នែកជំនួសឱ្យចិត្តនិងបេះដូងពេលភ្នែកមើលមិនចំចិត្តនិងបេះដូងក៏មិនបរិសុទ្ធដែរ។

តំណែងទី35ត្រូវគេស្គាល់ក្នុងនាម "យ៉ាងធំ"នៅត្រង់គល់ភ្នែកឆ្វេង ហើយតំណែងទី36ត្រូវគេស្គាល់ក្នុងនាម "យិនធំ" នៅត្រង់គល់ភ្នែកស្តាំចំពោះមនុស្សប្រុស។

ចំពោះមនុស្សស្រីគឺត្រូវប្តូរផ្លាស់គ្នាដូចក្នុងរូប។

ក្នុងពេលមើលតំណែងទី35និង36វាដូចជាការមើលពេជ្រអ៊ីចឹង ព្រោះយើងកំពុងមើលភាពថ្លានិងពណ៌។ គល់ភ្នែកមិនគួរមានពណ៌ក្រហម ឬ មិនគួរមានសរសៃក្រហមតូចៗនៅត្រង់ចំណុចនេះទេ បើកូនអ្នកជិតដល់ពេលប្រលងហើយ សូមមើលត្រង់គល់ភ្នែកកូនរបស់អ្នក បើមានផុសសរសៃឈាមក្រហមតូចៗច្បាស់លាស់ នោះបង្ហាញថាកូនរបស់អ្នកនឹងប្រលងមិនបាននិទ្ទេសល្អទេ។






www.elibraryofcambodia.org

សរសៃឈាមក្រហមតូចៗត្រង់តំណែងទី៣៥និង៣៦បង្ហាញឱ្យឃើញពីបរាជ័យក្នុងការប្រលង។ ជាការពិតហើយដែលមានមនុស្សអាយុ៣៥និង៣៦ឆ្នាំភាគច្រើនមិនមានការប្រលងអ្វីទៀតទេ ចុះសរសៃឈាមក្រហមតូចៗដែលមានត្រង់ចំណុចទាំងនេះមានន័យយ៉ាងណាសម្រាប់មនុស្សធំ? បើអ្នកសាកពិតអំពីរឿងនេះ អ្នកប្រហែលជានឹងឃើញថាជីវិតគឺជាការប្រលងដ៏វែងឆ្ងាយ។ យើងត្រូវប្រលងនិងសាកល្បងជារៀងរាល់ថ្ងៃជាមួយមនុស្សដែលនៅជុំវិញយើង អ្នកគ្រប់គ្រងយើង កូនឈ្នួលរបស់យើង អ្នកបញ្ជាយើង គូជីវិតយើង ឬ មិត្តភក្តិប្រុសស្រីរបស់យើង។

ការប្រលងធ្លាក់នៅពេលមានអាយុ៣៥ឆ្នាំមានន័យថាអ្នកទាំងអស់នោះតែងតែបរាជ័យក្នុងស្ថាប័នណាមួយដែលពួកគេកំពុងធ្វើការ ហើយក្នុងស្ថាប័ននោះមានការវាយតម្លៃលទ្ធផលការងារ។

អ្នកដែលមានសរសៃឈាមក្រហមតូចៗនៅត្រង់ដើមភ្នែកមើលទៅដូចជាពុំធ្លាប់បានទទួលនូវការវាយតម្លៃល្អទេ (មិនបានទទួលការតំឡើងយស ឬ តំណែង)។ មើលទៅដូចមិនធ្លាប់ធ្វើបានល្អក្នុងការសម្ភាសន៍ការងារ (មិនអាចទទួលបានការងារដែលមានប្រាក់ខែល្អជាងមុន) ឬ អាក្រក់ជាងនោះទៅទៀតគឺទំនាក់ទំនងអាក្រក់ ឬ ត្រូវតែមើលទៅដូចជាមនុស្សមិនអាចរៀបការបាន។ គេទាំងអស់នេះតែងតែត្រូវគេបដិសេធជានិច្ចពេលដែលពួកគេដាក់សំណើសុំរៀបការពីនរណាម្នាក់។





www.elibraryofcambodia.org

# អាយុ ៣៧_៣៨ឆ្នាំ មាន "យ៉ាងមធ្យម" និង "យិនមធ្យម"




តំណែងទី 37 និង 38 ត្រូវជំនួសដោយវាំងផ្លាស់ប្តូរនៃកែវភ្នែកយើងចង់ឱ្យតំណែងទី37និង38 មានលក្ខណៈមុតស្រួច រហ័សហួន និងធ្វើចលនាបានល្អពោរពេញដោយសតិបញ្ញា។ លក្ខណៈបែបនេះបង្ហាញថាគេម្នាក់នោះមានភាពស្រស់ថ្លា វាងវៃ រហ័សរហួន និងមានការគិតច្បាស់លាស់។

អ្នកប្រហែលជាធ្លាប់ឃើញមនុស្សដែលមានភ្នែកមិនវាងវៃ ភ្នែករបស់ពួកគេស្ពឹកៗទុយមុយ គ្មានភាពរស់រវើក មើលទៅហាក់ដូចជាពួកគេកំពុងតែសម្លឹងមើលភាពទទេ នេះប្រៀបដូចជាពាក្យដែលគេនិយាយថា "ភ្លើងបើកតែមិនមាននរណានៅក្នុងផ្ទះ។" មនុស្សដែលមានលក្ខណៈបែបនេះនឹងមានជួបគ្រោះថ្នាក់ពេលអាយុ37និង38ឆ្នាំ។

បើកែវភ្នែកមានសំណើមហើយថ្លាល្អបង្ហាញឱ្យឃើញថាគេម្នាក់នោះមានទឹកចិត្តនិងអារម្មណ៍ទន់ជ្រាយណាស់ ហើយថែមទាំងបង្ហាញឱ្យឃើញថាក្នុងពេលអាយុ37និង38ឆ្នាំ ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេអាចមានការប្រែប្រួល ឬ អាចប្រឈមនឹងបញ្ហាខ្លះដែលធ្វើឱ្យត្រូវតែមានការប្រែប្រួលផ្លាស់ប្តូរ។ បើភ្នែកខ្មៅហើយធំខ្លាំងរហូតធ្វើឱ្យផ្នែកខ្មៅធំជាងផ្នែកស ដែលតែងតែប្រឈមនឹងបញ្ហាផ្នែកអារម្មណ៍ ឬ ធ្វើឱ្យអារម្មណ៍មិនល្អ ឧទាហរណ៍ដូចជាក្តៅក្រហាយព្រោះបញ្ហាទំនាក់ទំនងផ្ទាល់ខ្លួន។



www.elibraryofcambodia.org

សម្រាប់មនុស្សស្រីភ្នែកសនិងភ្នែកខ្មៅត្រូវមានការបែងចែកគ្នាច្បាស់ ការបែងចែកគ្នាបានច្បាស់លាស់តើមានន័យដូចម្តេច? ភ្នែកសដែលមិនចេញពណ៌លឿង ឬ លឿងព្រាលៗ បង្ហាញពីជោគជតាមិនល្អដែលតែងតែនាំមកនូវក្តីលំបាកនិងការប្រែប្រួលខ្លាំងក្នុងអាយុពី35-40ឆ្នាំ។ ពួកគេអាចនឹងមានការផ្លាស់ប្តូរការងារ ឬ ផ្លាស់ប្តូរគូស្រករ បើគេមានភ្នែកមិនថ្លា (ភ្នែកសចេញពណ៌លឿង ឬ ពណ៌ស្រអាប់)។

បើភ្នែកសចេញពណ៌លឿង ឬ មានពណ៌លឿងព្រាលៗ តែភ្នែកថ្លាបង្ហាញឱ្យឃើញពីការប្រែប្រួលទៅរកលក្ខណៈល្អ។ ភាពថ្លាក្នុងពេលនេះសំដៅលើពណ៌ដែលបែងចែកច្បាស់រវាងព្រំដែនភ្នែកសនិងភ្នែកខ្មៅ។






www.elibraryofcambodia.org

បើមនុស្សស្រីមានភ្នែកសើមហើយមើលទៅមានលក្ខណៈសោកសៅនោះពួកនាងគ្មានសេចក្តីសុខក្នុងជីវិតគូស្រករទេ ។ ពួកនាងមានស្នាមញញឹមលើផ្ទៃមុខ តែភ្នែករបស់ពួកនាងប្រាប់អ្នកថានាងមានបញ្ហា ដូច្នេះចូរមើលកែវភ្នែកឱ្យបានជិត ហើយកុំចាញ់បោកស្នាមញញឹមឱ្យសោះ ។

ពេលយើងសម្លឹងមើលភ្នែក ជាពិសេសភ្នែករបស់មនុស្សស្រី យើងត្រូវសម្លឹងមើលត្រង់បរិវេណក្រោមភ្នែក បរិវេណនេះត្រូវគេស្គាល់ក្នុងនាមជាវាំងបុត្រធីតា យើងខ្ញុំនឹងបរិយាយអំពីវាំងបុត្រធីតាឱ្យបានលម្អិតនៅក្នុងវគ្គ "វាំងទាំង១២" ក្នុងមេរៀនក្រោយ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់និយាយអំពីវាំងបុត្រធីតាខ្លះៗដែរក្នុងពេលនេះព្រោះវាមានទំនាក់ទំនងនឹងរឿងជោគជតារបស់មនុស្សស្រី ។

មនុស្សស្រីទាំងអស់សុទ្ធតែជួបប្រទះនូវបញ្ហាថង់ក្រោមភ្នែក ឬ រង្វង់ជាំក្រោមភ្នែករបស់ពួកនាង ។ បើមនុស្សស្រីណាមានថង់ក្រោមភ្នែក ឬ រង្វង់ជាំក្រោមភ្នែក ទោះជាដេកបានគ្រប់គ្រាន់ហើយក៏ដោយនោះគឺត្រូវតែជាមូលហេតុដែលគួរឱ្យព្រួយបារម្ភ ក្នុងសាស្ត្រការមើលទម្រង់មុខលក្ខណៈបែបនេះបង្ហាញថានាងមិនសូវមានភាពជិតស្និទ្ធនឹងកូនៗទេ ។




អ្នកដែលមានកូនឈឺ ឬ កូនពិការរមែងមានសរសៃតូចៗនៅពេញបរិវេណថង់ក្រោមភ្នែក ឬ មានរង្វង់ជាំទៀតផង ។ បើឪពុកម្តាយមានសរសៃនិងរង្វង់ជាំទាំងនេះច្រើនបង្ហាញឱ្យឃើញថាពួកគេមានកូនក្បាលរឹង ឬ ចូលចិត្តបង្កបញ្ហាទៀតផង ។

តែបើកូនជាក្មេងល្អឪពុកម្តាយដែលមានរង្វង់ជាំ ឬ ថង់ក្រោមភ្នែកតែងតែព្រួយបារម្ភ ឬ ជាឪពុកម្តាយដែលការពារកូន ឬ កាន់ជើងកូនជ្រុលពេក ។



www.elibraryofcambodia.org

# អាយុ ៣៩-៤០ឆ្នាំ មាន"យ៉ាងតិច" និង "យិនតិច"




កន្ទុយភ្នែកតំណាងឱ្យអាយុ 39និង40ឆ្នាំ មានឈ្មោះថា "យ៉ាងតិច" និង "យិនតិច"។ កន្ទុយភ្នែកគួរឆ្មៀងឡើងបន្តិចដើម្បីឱ្យមានជោគសំណាងល្អ កន្ទុយភ្នែកដែលឆ្មៀងចុះក្រោម បង្ហាញថាមានគ្រោះថ្នាក់អាក្រក់ក្នុងពេលអាយុបាន 39និង40ឆ្នាំ។ យើងមិនចង់ឃើញសរសៃឈាមក្រហមតូចៗត្រង់ចុងភ្នែកនិងស្បែកគ្របភ្នែកលើធ្លាក់ទេ។

អ្នកដែលមានស្បែកគ្របភ្នែកលើធ្លាក់ហើយបាំងតំណែងទី39 និង 40គឺជាមនុស្សចូលចិត្តតាំងខ្លួនធ្វើជាម្ចាស់របស់ ហើយពុំដែលមានថ្ងៃពេញចិត្តនឹងលទ្ធផលដែលទទួលបានទេ ទោះជាលទ្ធផលនោះល្អហើយក៏ដោយ។ នោះហើយគឺជាប្រភពនៃបញ្ហាក្នុងពេលដែលពួកគេមានអាយុ39និង40ឆ្នាំ។



www.elibraryofcambodia.org

# អាយុ៤១ឆ្នាំ ខ្នង់ច្រមុះ




ខ្នង់ច្រមុះជាតំណែងដ៏សំខាន់មួយបន្ទាប់ពីរាំងជីវិត។ ខ្នង់ច្រមុះបង្ហាញឱ្យឃើញពីបទដ្ឋាននិងគុណធម៌របស់មនុស្ស ជាកន្លែងដែលផ្ទុកនូវជំនឿចិត្តនិងជាថាមពលជួយជំរុញខ្លួនឯង ព្រមទាំងសេចក្តីព្យាយាមរបស់គេម្នាក់នោះ។ តំណែងនេះស្ថិតក្នុងតំណែងដូចគ្នាសម្រាប់មនុស្សប្រុសនិងមនុស្សស្រី។

បើខ្នង់ច្រមុះខ្ពស់ហួសពេក គេនឹងក្លាយជាមនុស្សដែលមានជំនឿជាក់និងប្រកាន់ភ្ជាប់នូវទស្សនៈរបស់ខ្លួនឯងជ្រុលពេក។ តែបើវាទាបហួសពេកអាចនឹងមានបញ្ហាទាក់ទងនឹងការមានទស្សនៈមិនសមហេតុផល។ លក្ខណៈដែលល្អបំផុតរបស់ខ្នង់ច្រមុះគឺទូលាយ ស្មើ ហើយត្រង់។ បើខ្នង់ច្រមុះទាបមានន័យថាដំណើរជីវិតលំបាក ពុំមានអ្នកជួយគាំទ្រគឺគេត្រូវពឹងលើខ្លួនឯងអស់មួយជីវិត ហើយក៏ជាអ្នកកសាងសមត្ថភាពដោយខ្លួនឯងដែរ។



www.elibraryofcambodia.org



ខ្នង់ច្រមុះខ្ពស់



ខ្នង់ច្រមុះទាប

បើខ្នង់ច្រមុះខ្ពស់ (តែមិនខ្ពស់ហួសពេក) បង្ហាញឱ្យឃើញថាគេជាមនុស្សដែលអាចយកឈ្នះពាក្យជំទាស់ផ្សេងៗបានដោយងាយ ហើយអាចប្តូរផលអាក្រក់ឱ្យក្លាយជាផលល្អវិញបាន ឬ អាចប្តូរស្ថានការណ៍ដែលគ្មានប្រយោជន៍ឱ្យក្លាយជាឱកាសល្អបាន។ ពួកគេមានទស្សនៈសុទិដ្ឋិនិយម ហើយមើលទៅជោគវាសនាដូចជានឹងចូលមកខាងពួកគេទោះជាគេស្ថិតក្នុងស្ថានការណ៍ ឬ កាលៈទេសៈមិនអំណោយផលក៏ដោយ។ ជាធម្មតា មនុស្សដែលមានខ្នង់ច្រមុះខ្ពស់ហើយរឹងមាំតែងមានសុខភាពល្អ ឬ ស្រឡាញ់សុខភាពរបស់ខ្លួនជានិច្ច។




មនុស្សស្រីដែលមានខ្នង់ច្រមុះទាបមានការទុកចិត្តលើខ្លួនឯងទាប ហើយតែងមានបញ្ហាចំពោះសុខភាពជានិច្ច ដូច្នេះត្រូវប្រយ័ត្នលើស្នាមឆ្នូតដែលកាត់តាមខ្នង់ច្រមុះផង។ បើស្នាមឆ្នូតនោះជាសរសៃតូចឆ្មារ មានន័យថានឹងមានទំនាក់ទំនងស្នេហាសាហាយស្មន់ តែបើវាជាសរសៃធំក្រាស់ មានន័យថានឹងមានបញ្ហាសុខភាព។ សម្រាប់មនុស្សប្រុសដែលមានខ្នង់ច្រមុះទាប យើងសូមណែនាំកុំឆាប់រៀបការពេក ព្រោះជីវិតគូស្រករដំបូងនឹងមានលក្ខណៈមិនល្អ ហើយអាចត្រូវបញ្ចប់ដោយការលែងលះគ្នាទៀតផង។



www.elibraryofcambodia.org

## អាយុ៤២-៤៣ឆ្នាំ-ផ្លូវឆ្ពោះទៅរកវិញ្ញាណ

តំណែងទី 42និង43ស្ថិតនៅត្រង់ភ្នែក ហើយជាតំណែងដែលគ្របដណ្តប់ទូទៅសម្រាប់មនុស្សប្រុសនិងមនុស្សស្រី ។ យើងអាចមើលឃើញលក្ខណៈខុសគ្នាតិចតួចប៉ុណ្ណោះសម្រាប់ភ្នែកបើធៀបនឹងផ្នែកផ្សេងៗលើទម្រង់មុខ ។ ភ្នែកមិនដូចនឹងច្រមុះ ឬ ថ្ពាល់ក្នុងការធ្វើចលនាទេ តែតើអ្នកធ្លាប់ឮគេថាភ្នែកចេះរាំដែរឬទេ? មនុស្សស្លាប់មានជីវិត? ការបង្ហាញចេញតាមរយៈ ទឹកមុខគឺភាគច្រើនសុទ្ធតែឆ្លងកាត់កែវភ្នែក ។




នេះគឺជាមូលហេតុដែលធ្វើឱ្យយើងត្រូវសម្លឹងមើលភ្នែកក្នុងបរិបទនៃវិធីសាស្ត្រនៃការមើលទម្រង់មុខ ។ យើងចាប់អារម្មណ៍លើកែវភ្នែក គឺមានន័យថាយើងចាប់អារម្មណ៍លើការមានជីវិតនិងការភ្ញាក់ខ្លួនដែលយើងអាចមើលដឹងបាននៅត្រង់ភ្នែក ។ កែវភ្នែករបស់មនុស្សយើងគួរតែមានភាពមុតថ្លាហើយមានពន្លឺទើបល្អ ។

ជាទូទៅយើងមិនចូលចិត្តភ្នែកដែលលិបចូលក្នុងទេ ហើយភ្នែកដែលមានលក្ខណៈហើមៗក៏មិនល្អដូចគ្នាដែរ ។ ភ្នែកដែលលិបចូលក្នុងបង្ហាញឱ្យឃើញពីបញ្ហាទាក់ទងនឹងអារម្មណ៍បញ្ចេញគំនិតមកជាពាក្យសម្តីមានលក្ខណៈលំបាក ឬ មិនពេញចិត្តចំពោះទំនាក់ទំនងក្នុងលក្ខណៈធម្មតា ។



www.elibraryofcambodia.org

ភ្នែកដែលមានលក្ខណៈដូចខ្យងត្រំដែលបើកសំបកពាក់កណ្តាលគឺមើលទៅមានលក្ខណៈជ្រឹមដូចមនុស្សងងុយដេកអឺចឹង។ មនុស្សដែលមានលក្ខណៈបែបនេះរមែងតែនាំយករឿងក្តៅក្រហាយមកដាក់ឱ្យខ្លួនឯងនិងជាមនុស្សដែលចូលចិត្តធ្វើខុសជារឿយៗ។



ភ្នែកដែលជ្រឹមហើយហើម

មនុស្សស្រីដែលមានភ្នែកទុយមុយ  មានសំណើមនៅជុំវិញនិងភ្នែកមានលក្ខណៈដូចជាជាំហើយហើមតែងតែមានទំនាក់ទំនងផ្នែកអារម្មណ៍យ៉ាប់យ៉ឺន។ ដោយសារមានទំនាក់ទំនងមិនល្អជាមួយគូស្រកររបស់នាង ធ្វើឱ្យគេមិនសូវស្រឡាញ់ហើយមិនសូវយល់ចិត្តនាងឡើយ។






www.elibraryofcambodia.org

# អាយុ៤៤-៤៥ឆ្នាំ តំណែងសុខភាព

តំណែងទី44និង45នៅត្រង់ច្រមុះ ។ តំណែងទី44នៅត្រង់ខ្នង់ច្រមុះហៅថានានសាង ។ តំណែងទី45ដែលគេហៅថាសួវសាងក៏នៅត្រង់ខ្នង់ច្រមុះដូចគ្នាដែរ ។ តំណែងទាំងពីរនេះដូចគ្នាចំពោះមនុស្សប្រុសនិងមនុស្សស្រី ។




តំណែងទាំងពីរនេះទាក់ទងនឹងសុខភាព តែសំណួរដ៏សំខាន់ដែលអ្នកត្រូវសួរនោះគឺតើតំណែងនេះមានទំនាក់ទំនងនឹងសុខភាពរបស់អ្នកណា? តំណែងទី44ទាក់ទងនឹងសុខភាពរបស់អ្នកដែលអ្នកកំពុងឱ្យគេមើលទម្រង់មុខ តំណែងនេះគួរតែមានសាច់មិនឡើងឆ្អឹង ថែមទាំងត្រង់មិនបាក់ ប្រការនេះវាបង្ហាញឱ្យឃើញអំពីការមានសុខភាពរឹងមាំ ។

ពេលនេះអ្នកប្រហែលជាសង្កេតឃើញហើយថា មិនមែនតំណែងជោគជតាអាយុគ្រប់តំណែងអាចត្រូវកំណត់ដោយតំណែងដែលផ្តោតនោះតែមួយទេ ជួនកាលត្រូវប្រមើលមើលគុណភាពរបស់តំណែងដោយត្រូវគិតដល់តំណែងផ្សេងៗទៀតផងដែរ ។ ដូច្នេះពេលមើលតំណែងទី 44 ការមើលនៅត្រង់ចុងច្រមុះក៏មានលក្ខណៈសំខាន់ខ្លាំងដូចគ្នាដែរ យើងចូលចិត្តចុងច្រមុះស្រួច ទូលាយ ហើយមូលដើម្បីឱ្យត្រូវនឹងតំណែងទី44 មានសាច់ហើយមិនបាក់ ទើបអាចចាត់ទុកបានថាជាតំណែងដែលល្អ ។



www.elibraryofcambodia.org

ក្នុងការមើលទម្រង់មុខ យើងមិនត្រឹមតែសង្កេតមើលគេពីខាងមុខប៉ុណ្ណោះទេ តែគួរសង្កេតមើលពីចំហៀងក្នុងខណៈដែលពួកគេកំពុងសម្រាក ឬ កំពុងញញឹមផងដែរ ស្នាមឆ្នូតមួយ ឬ ច្រើនដែលកាត់តំណែងទី44 ។ ក្នុងខណៈដែលមនុស្សស្រីម្នាក់នោះកំពុងញញឹម វាបង្ហាញឱ្យឃើញថាអាចមានបញ្ហាទាក់ទងនឹងការសម្រាលកូន។ ស្នាមជាំត្រង់ផ្នែកចំហៀងនៃតំណែងទី 44 បង្ហាញឱ្យឃើញពីបញ្ហាដែលទាក់ទងនឹងខ្នង។

មិនតែប៉ុណ្ណោះតំណែងទី45 អាចប្រាប់យើងអំពីសុខភាពរបស់សមាជិកគ្រួសារ ឬ អ្នកនៅផ្ទះជាមួយមនុស្សដែលយើងកំពុងមើលទម្រង់មុខទៀតផង។ តំណែងទី45នឹងបង្ហាញឱ្យឃើញនូវស្នាមជាំ បើមានអ្នកឈឺនៅផ្ទះរបស់គេម្នាក់នោះ ស្នាមឆ្នូតដែលឆ្លងកាត់តំណែងទី 45ពុំមែនជាសញ្ញាល្អចំពោះសុខភាពទេ វាបង្ហាញអំពីការមានជំងឺតម្កាត់ ឬ ការមានបញ្ហាសុខភាពយូរអង្វែង។




សូមចងចាំថាតំណែងផ្សេងៗ មិនបានជំនួសឱ្យជោគជតាអាយុតែមួយមុខប៉ុណ្ណោះទេ តែវាបានជំនួសឱ្យឧបនិស្ស័យផ្ទាល់ខ្លួន ឬ ទំនាក់ទំនងក្នុងផ្នែកមួយនៃជីវិតរបស់មនុស្សយើងទៀតផង។ ពេលយើងសម្លឹងមើលតំណែងទី44និង45របស់មនុស្សស្រីមានន័យថាយើងកំពុងតែត្រួតពិនិត្យជោគវាសនានៃទំនាក់ទំនងរបស់នាង។ មនុស្សស្រីអាចមានស្វាមីល្អ ហើយមានទំនាក់ទំនងល្អជាមួយគូស្រករ ប្រសិនបើខ្នងច្រមុះរបស់ពួកនាងមិនកោង ឬ មិនខ្ពស់ហួសពេក។



www.elibraryofcambodia.org

## អាយុ៤៦ _ ៤៧ឆ្នាំ ឆ្អឹងអំណាច




តំណែងទី46និង47នៅត្រង់ទូលថ្ពាល់ដែលគេហៅថាឆ្អឹងអំណាច ។ ទូលថ្ពាល់មិនមែនត្រឹមតែជំនួសឱ្យជោគជតារបស់មនុស្សយើងនៅខណៈពេលមានអាយុ46-47ឆ្នាំប៉ុណ្ណោះទេ គឺជំនួសឱ្យឆន្ទៈនិងសមត្ថភាពដែលអាចប្រើអំណាចរបស់គេបានទៀតផង ។ ទូលថ្ពាល់ត្រូវមានសាច់ទើបមានសំណាងល្អនៅពេលមានអាយុ45 និង46ឆ្នាំ ។




ឆ្អឹងអំណាចបែក

យើងមិនចង់ឱ្យមានស្នាមឆ្នូតឆ្វូតកាត់ទូលថ្ពាល់ទេ ព្រោះលក្ខណៈបែបនេះហៅថាឆ្អឹងអំណាចបែក ហើយវាបង្ហាញថាគេអាចមានបញ្ហាដ៏ធំសម្បើមនៅពេលមានអាយុ46-47ឆ្នាំ ដែលអាចទាញទៅរកការបាត់បង់ភាពមានបាន ឬ រលំរលាយ ។ ម្យ៉ាងទៀតយើងក៏មិនចង់ឱ្យមានប្រជ្រុយនៅត្រង់ថ្ពាល់ផងដែរ ។



www.elibraryofcambodia.org

ទួលថ្ពាល់ដែលមានសាច់គួបផ្សំនឹងច្រមុះដែលមានលក្ខណៈល្អ គឺលក្ខណៈនៃទម្រង់មុខដែលអ្នកអាចឃើញចំពោះមនុស្សមានអំណាចនិងឥទ្ធិពលខ្លាំងក្នុងស្ថាប័នមួយ ។ នេះគឺលក្ខណៈដែលអ្នកអាចឃើញលើទម្រង់មុខរបស់ស៊ីអ៊ីអូ (C.E.O) នៃស្ថាប័នកំពូលណាមួយ ឬ អ្នកនយោបាយថ្នាក់ខ្ពស់ ដូចជា ប្រធានាធិបតី ឬ នាយករដ្ឋមន្ត្រី និងបណ្ដានាយពលដែលមានឥទ្ធិពលទាំងឡាយ ។

តើអ្នកធ្វើដូចម្ដេចទើបដឹងថាមនុស្សម្នាក់ជាមនុស្សគួរឱ្យស្រឡាញ់ ទន់ភ្លន់ និងមានភាពកក់ក្ដៅ ឬ ជាមនុស្សរឹងកំព្រឹសកាចសាហាវ? ចូរអ្នកមើលទួលថ្ពាល់របស់ពួកគេ ។ អ្នកដែលមានទួលថ្ពាល់ឡើងឆ្អឹងច្រើនជាមនុស្សឆេវឆាវ ដាច់ខាត ចូលចិត្តដោះស្រាយបញ្ហាដោយប្រើកម្លាំងបាយ ។ ផ្ទុយទៅវិញ មនុស្សដែលមានទួលថ្ពាល់មានសាច់ច្រើនជាមនុស្សទន់ភ្លន់ មានទឹកចិត្ត ហើយផ្ដល់តម្លៃចំពោះមិត្តភាព ។



ទួលថ្ពាល់ដែលធំហើយឡើងឆ្អឹង

បើគេមានទួលថ្ពាល់មិនមានសាច់ ហើយនៅខ្ពស់លើផ្ទៃមុខ នោះបង្ហាញថាគេជាមនុស្សមានចិត្តតស៊ូ អង់អាច ។ ចូរអ្នកកុំខំទៅបញ្ឈប់មនុស្សប្រភេទនេះឱ្យមានចិត្តស្ងប់អី ពួកនេះជនជាតិចិនហៅថា "ពួកមិនចេះខ្លាចស្លាប់" ។

ជាទូទៅយើងមិនចង់ឃើញមនុស្សស្រីដែលមានទួលថ្ពាល់ខ្ពស់ទេ ជាពិសេសគឺទួលថ្ពាល់ដែលខ្ពស់ជាងច្រមុះ ។ ទួលថ្ពាល់ដែលនៅខ្ពស់ជាងចុងច្រមុះបង្ហាញឱ្យឃើញថាជាស្រីដែលគ្រប់គ្រងស្វាមី ឬ មានអំណាចលើស្វាមី ។ បើទួលថ្ពាល់គ្រាន់តែខ្ពស់ជាងច្រមុះ តែមិនប៉ោងធំ មនុស្សស្រីប្រភេទនេះអាចក្លាយជាភរិយាលួចលាក់ ឬ ប្រពន្ធចុងគេ ។

ទួលថ្ពាល់ដែលធ្លាក់ចុះក៏មិនល្អដូចគ្នាដែរ អ្នកដែលមានទួលថ្ពាល់ក្នុងលក្ខណៈបែបនេះជាមនុស្សមិនចូលចិត្តកុសល ជាទូទៅច្រើនជាមនុស្សចិត្តអាក្រក់ហើយអាសអាភាសបន្តិច ។



www.elibraryofcambodia.org

# អាយុ៤៨ឆ្នាំចំណុចមនោគតិ

តំណែងទី48នៅត្រង់ចុងច្រមុះកំណត់ជោគជតារបស់មនុស្សយើងនៅអាយុ 48ឆ្នាំ និងប្រាប់អំពីមនោគតិនិងធម្មជាតិខាងក្នុងរបស់គេ ថាជាមនុស្សកំពូលល្បិច ហើយស្វែងរកផលប្រយោជន៍ពីការខាតបង់របស់អ្នកដទៃឬអត់ ឬមួយថាគេជាមនុស្សមានចិត្តល្អបរិសុទ្ធគួរឱ្យផ្តល់កិត្តិយសឬអត់?( ប្រការទាំងអស់នេះត្រូវបានកត់ត្រាទុកនៅលើចុងច្រមុះរបស់គេម្នាក់នោះ) ។




តាមរូបារម្មណ៍និងផ្នត់គំនិតរបស់ពួកបស្ចិមប្រទេសតែងតែគូសរូបមេធ្មប់ឱ្យមានច្រមុះស្រួចង ។ ជំនឿនេះមិនខុសអ្វីពីទស្សនៈរបស់ជនជាតិចិនក្នុងការមើលទម្រង់មុខអ្នកដែលច្រមុះវែងស្រួចនោះទេ ព្រោះក្នុងសាស្ត្រការមើលទម្រង់មុខ ច្រមុះវែងស្រួចបង្ហាញឱ្យឃើញពីមនុស្សដែលឃោរឃៅនិងអកតញ្ញូ ។ ពួកគេមិនមែនជាពពួកមនុស្សដែលអ្នកចង់បានធ្វើជាមិត្តនោះទេ ( ទោះជាគេជាកូនចៅដែលល្អក្នុងក្រុមជនពាលរបស់អ្នកក៏ដោយ) ។ ផ្ទុយទៅវិញ អ្នកដែលមានចុងច្រមុះមានសាច់ហើយមានលក្ខណៈមូល ជាប្រភេទមនុស្សដែលជនជាតិចិនហៅថា



www.elibraryofcambodia.org

"ជាមនុស្សគ្មានថ្នាំពុលក្នុងបេះដូង"។ ពួកគេជាមនុស្សមានគុណធម៌និងកតញ្ញូតាធម៌ ចេះតបស្នងគុណបានល្អណាស់។

អ្នកអាចរកឃើញក្នុងមេរៀនទី4ដែលយើងខ្ញុំនិយាយអំពីវាំងទាំង12នៃទម្រង់មុខថាតំណែងនេះជាផ្នែកមួយនៃភាពមានបាន។ ចុងច្រមុះដែលមូលមិនត្រឹមតែធ្វើឱ្យមានភាពប្រាកដប្រជាក្នុងចិត្តថាពួកគេនោះជាអ្នកមានមនោគតិប៉ុណ្ណោះទេ តែនៅបានបង្ហាញឱ្យឃើញពីឱកាសនៃភាពមានបានទៀតផង។ ចុងច្រមុះដែលកាន់តែមានសាច់ច្រើន គេម្នាក់នោះក៏មានឱកាសក្លាយជាអ្នកមានអ្នកបានច្រើនទៀតផង។ ចំណែកចុងច្រមុះស្តើង ឬ ឡើងឆ្អឹងមានន័យថាភាពមានបាននិងស្រកស្រុត។

មុនពេលដែលអ្នកចង់ឱ្យមានសក្តានុពលហើយទៅធ្វើច្រមុះឱ្យធំជាងមុន អ្នកត្រូវតែដឹងថាច្រមុះមានទំហំធំពេកមិនមែនមានន័យថាអ្នកនឹងក្លាយជាអ្នកមានលើពីការស្រមៃនោះទេ អ្នកមិនអាចដើរទៅរកការមានបានបែបក្លែងក្លាយនេះទេ (គឺដូចច្រមុះសិប្បនិម្មិតដែលគេនិយមធ្វើសព្វថ្ងៃនេះ)។ អ្នកមិនអាចនិយាយបានថា ខ្ញុំចង់ឱ្យច្រមុះរបស់ខ្ញុំទៅជាបែបនេះ ហើយរំពឹងទុកថាអ្នកនឹងក្លាយជាម្ចាស់ទ្រព្យដ៏ច្រើនមហាសាលនៅថ្ងៃស្អែកបានទេ។



អ្នកគួរយល់ថាច្រមុះត្រូវឱ្យសមនឹងទម្រង់មុខ អ្នកមិនអាចភ្ជាប់ច្រមុះដ៏ធំនៅលើទម្រង់មុខដ៏តូចរបស់អ្នក ឬ ដាក់ច្រមុះធំនៅចន្លោះទួលថ្ពាល់ដ៏តូចរបស់អ្នកបានទេ។ ទំហំច្រមុះត្រូវឱ្យសមនឹងទម្រង់មុខរបស់អ្នក។ បើច្រមុះធំហួសពេក តែទម្រង់មុខតូចលក្ខណៈបែបនេះបង្ហាញអំពីភាពឯកា មានន័យថាជីវិតគូស្រករពុំសូវសមប្រកបអ្នកអាចក្លាយជាស្រីមេម៉ាយ ឬ ប្រុសពោះម៉ាយទាំងនៅក្មេង ឬ គូស្រកររបស់អ្នកមិនដែលនៅផ្ទះ។



www.elibraryofcambodia.org




នាពេលនេះ យើងចង់និយាយខ្លីៗថា ពណ៌របស់ច្រមុះគួរជាទីចំណាប់អារម្មណ៍យ៉ាងណា? តើអ្នកអាចនឹងទទួលបានលទ្ធផលយ៉ាងណាចំពោះកិច្ចសន្យាពាណិជ្ជកម្មដែលអ្នកកំពុងចរចា ឬ ដែលកំពុងសហការគ្នានៅថ្ងៃនេះមានដំណើរការល្អ ឬ មិនល្អ? ចូរអ្នកសម្លឹងមើលពណ៌ច្រមុះរបស់អ្នក សុភាសិតមៀនសៀងបុរាណបានពោលថា "ពណ៌លឿងនៅចំណុចនេះគឺបង្ហាញអំពីភាពមានបានមួយចំណុច"។ ដូច្នេះមានន័យថារាល់ពេលដែលមានពណ៌លឿងលើច្រមុះរបស់អ្នក នោះបង្ហាញឱ្យឃើញអំពីជោគសំណាងនៃភាពមានបានមកដល់ហើយ។



www.elibraryofcambodia.org

## អាយុ៤៩_៥០ឆ្នាំ ស្លាបនៃភាពមានបាន




ស្លាបច្រមុះតំណាងឱ្យអាយុ49និង50ឆ្នាំ ។ តំណែងទាំងអស់នេះឆ្លាស់គ្នារវាងមនុស្សប្រុសនិងមនុស្សស្រីដូចរូបខាងលើជាឧទាហរណ៍ស្រាប់ ។ ស្លាបច្រមុះគួរមានលក្ខណះដែលច្បាស់ បើមិនដូច្នេះទេគឺវានឹងបង្ហាញឱ្យឃើញនូវសេចក្តីលំបាកក្នុងអាយុ49និង50ឆ្នាំ ។ គេនឹងមានតែភាពច្របូកច្របល់ក្នុងផ្លូវបំបែកនៃជីវិតដ៏សប្បាយរុងរឿងនៅពេលអាយុ 49-50ឆ្នាំ ។



www.elibraryofcambodia.org

ស្លាបច្រមុះតំណាងឱ្យភាពវៃឆ្លាតនិងសមត្ថភាពក្នុងការរកលុយ ។ វាមិនមែនជាវាំងមានបានទេ តែវាជាលក្ខណៈមួយដែលត្រូវពិចារណាក្នុងពេលដែលយើងប្រមើលមើលទៅលើវាំងនៃភាពមានបានដូចដែលបានអធិប្បាយក្នុងមេរៀនទី4រួចមកហើយ ។

អ្នកដែលមានសមត្ថភាពរកលុយអាចមានស្លាបច្រមុះហុចចេញទូលាយហើយក្រាស់ពួកគេមានប្រាក់ចំណូលដោយវិធីច្រើនយ៉ាង ។ ភាគច្រើនតែងតែជាអ្នកជំនួញធំដែលគ្រប់គ្រងក្រុមហ៊ុនតូចៗផ្សេងទៀត (ផលប្រយោជន៍ច្រើនយ៉ាង ឬ មានជំនួញធំទូលាយ) ។ ចំណែកអ្នកដែលមានស្លាបច្រមុះមានលក្ខណៈមិនច្បាស់ មានប្រាក់ចំណូលពីការងារ ឬ ឧស្សាហកម្មតែមួយយ៉ាងគត់ ។ ស្លាបច្រមុះប្រាប់យើងថាគេម្នាក់នោះអាចទទួលបន្ទុកការងារបានច្រើនយ៉ាងព្រមគ្នាឬអត់ ឬ ថាអាចរកលុយបានច្រើនវិធី ឬ គ្រាន់តែពឹងតែលើការងារតែមួយមុខ ។

លក្ខណៈដូចនេះត្រូវគេយកមកប្រើជាមួយនឹងមនុស្សស្រីដែរ តែប្រការដែលសំខាន់ដូចគ្នាគឺត្រូវត្រួតពិនិត្យមើលថារន្ធច្រមុះរបស់ពួកនាងងើយឬអត់ ។ រន្ធច្រមុះដែលងើយបង្ហាញឱ្យឃើញថានាងជាមនុស្សស្រីដែលចូលចិត្តអេចអូចនិន្ទានិងលួចខាំគេ ហើយថែមទាំងមាត់រអិលទៀតផង ។ មនុស្សប្រភេទនេះឃើញថាត្រូវគេមិនចូលចិត្តរាប់អាន ឬ រាប់ចូលក្នុងសង្គមទេ ព្រោះតែទង្វើ ឬ ជីវិតធ្លាក់ទាបដោយសារលទ្ធផលនៃការមានមាត់អេចអូចរបស់ខ្លួន ។

រន្ធច្រមុះដែលងើយ ឬ រន្ធច្រមុះធ្លាវក៏ជាសញ្ញាសំគាល់ថាមនុស្សនោះមិនចេះសន្សំលុយកាក់ដែរ ព្រោះថាពេលរន្ធច្រមុះធ្លាវអាចចាត់ទុកថាវាំងនៃភាពមានបានបានបណ្តោយឱ្យភាពមានបាន "ជ្រុះ" ។ តើអ្នកធ្វើដូចម្តេចទើបដឹងថារន្ធច្រមុះរបស់មនុស្សម្នាក់ងើយ? វិធីដែលស្រួលបំផុតគឺមើលទម្រង់មុខអ្នកនោះពីខាងមុខឱ្យចំ ហើយអ្នកអាចមើលឃើញ "រន្ធខ្មៅទាំងពីរ" របស់គេបានច្បាស់ ។



រន្ធច្រមុះងើយ



www.elibraryofcambodia.org

# អាយុ៥១ឆ្នាំ ផ្លូវខ្សែកណ្តាល

តំណែងអាយុ51ឆ្នាំស្ថិតនៅលើចង្អូរបបូរមាត់លើ វានៅក្រោមពាក់កណ្តាលច្រមុះពីចុងច្រមុះរហូតដល់ពាក់កណ្តាលបបូរមាត់លើ មានឈ្មោះថា "រ៉ុនចុង" ដែលមានអត្ថន័យថាដែលមានអត្ថន័យថាគឺផ្លូវខ្សែកណ្តាល ។



ចង្អូរបបូរ
មាត់លើ

ចំណុចនេះជាការប្រមើលមើលទម្រង់មុខរបស់មនុស្សយើង ។ ចង្អូរបបូរមាត់លើជាតំណែងដ៏សំខាន់មួយដែលកំណត់ជោគជតាក្នុងកំឡុងពេលផ្លាស់ប្តូរពីវ័យពាក់កណ្តាលមនុស្សឆ្ពោះទៅរកវ័យជរា ។ វាជាចំណុចផ្តាច់រវាងដំណាក់កាលដំបូងនិងដំណាក់កាលចុងក្រោយនៃជីវិតរបស់មនុស្ស ។ នេះជាលក្ខណៈមួយនៃទម្រង់មុខដែលបង្ហាញអំពី "ភាពជោគជ័យនិងបរាជ័យ" ។ នេះជាតំណែងដែលដូចគ្នាទាំងមនុស្សស្រីនិងមនុស្សប្រុស ។



www.elibraryofcambodia.org

ចង្កូរបបូរមាត់លើកំណត់ថាអ្នកអាចនឹងបាត់បង់នូវអ្វីគ្រប់យ៉ាងដែលអ្នករកបានជោគជ័យ ឬ អត់ក្នុងខណៈដែលអ្នកអាយុបាន51ឆ្នាំ ឬមួយថាអ្នកអាច "យកវាទៅជាមួយអ្នកនាពេលជរាឬទេ"។

ក្នុងហោរាសាស្ត្រចិននៃការមើលទឹកមុខបានពោលថាតំណែងទី51 ប្រាប់យើងឱ្យដឹងថាតើគេនោះអាចប្រឈមនឹងការដើរថយក្រោយដ៏ធ្ងន់ធ្ងរឬ? តើគេអាចរ៉ាប់រងនឹងការខាតបង់ដ៏ធ្ងន់ធ្ងរនោះដែរឬអត់? ហើយវានៅប្រាប់យើងទៀតដែរថាគេនឹងមានអាយុខ្លី ឬ វែង? មិនតែប៉ុណ្ណោះតំណែងទី51 មានទំនាក់ទំនងនឹងភាពមានបានរបស់មនុស្សយើងនិងប្រាប់ថាគេម្នាក់នោះអាចនាំមកនូវភាពមានបានពេលវ័យជរាឬអត់។

ជាទូទៅយើងចង់ឱ្យតំណែងទាំងអស់នេះ "មានសាច់" ច្រើនជាងការដែលវាស្រុតឡើងឆ្អឹង ឬ ស្តើង សរុបមកយើងមិនចង់ឱ្យផ្នែកណាមួយនៃផ្ទៃមុខមានលក្ខណៈផត ឬ ក្រហូងទេ។

ចង្កូរបបូរមាត់លើជាចំណុចលើកលែងតែមួយគត់ព្រោះយើងចង់ឱ្យបបូរមាត់លើធំទូលាយនិងក្រហូងជ្រៅ។ ចូរអ្នកនឹកឱ្យឃើញពីរូបភាពនៃបបូរមាត់លើដែលមានលក្ខណៈដូចជាផ្លូវទឹកនៃជីវិតនៅលើទម្រង់មុខ យើងមិនត្រឹមតែចង់ឱ្យផ្លូវទឹកនៃជីវិតទូលាយប៉ុណ្ណោះទេ តែចង់ឱ្យវាជ្រៅទៀតផង។ អ្នកដែលមានបបូរមាត់លើចង្អៀត មិនត្រឹមតែប្រឈមនឹងភាពដើរថយក្រោយក្នុងដំណាក់កាលធំមួយនៅអាយុ51 ឆ្នាំប៉ុណ្ណោះទេ តែវានៅនាំភាពមានបានទៅ





www.elibraryofcambodia.org

ក្នុងវ័យចាស់ជរាបានដោយក្ដីលំបាកទៀតផង ។

សម្លាក ឬ ស្នាមឆ្នូតដែលកើតឡើងត្រង់តំណែងនេះក្នុងពេលញញឹម បង្ហាញឱ្យឃើញថាឧបសគ្គធំៗដែលនាំមកវិខានដំណើរជីវិតនឹងកើតឡើង ពេលគេមានអាយុ51ឆ្នាំ ។

សម្រាប់មនុស្សស្រី ការមើលបបូរមាត់លើជាវិធីត្រួតពិនិត្យមើលអំពីការបន្តពូជដ៏ល្អ ព្រោះវាទាក់ទងនឹងអវយវៈបន្តពូជ។ ប្រជ្រុយ ឬ សម្លាកដែលមានត្រង់តំណែងនេះ ឬ បើមនុស្សនោះមាត់ឆែប (ឬ មាត់ឆែបតែដេរបានវិញ) នឹងមានការលំបាកក្នុងការសម្រាលកូន ឬ មានបញ្ហាសុខភាពដែលទាក់ទងនឹងប្រដាប់បន្តពូជ ។

ចង្អូរបបូរមាត់លើដែលចង្អៀតហើយវៀច ដូចម្ជុលបង្ហាញឱ្យឃើញពីភាពលំបាកក្នុងការសម្រាលកូន ឬ ពិបាកមានកូន ។

ចង្អូរបបូរមាត់លើដែលខ្លីគួបផ្សំនឹងមាត់ដែលកោងឡើងបង្ហាញឱ្យឃើញថាមានបញ្ហាទាក់ទងនឹងប្រដាប់បន្តពូជ ។

សម្រាប់មនុស្សប្រុសចង្អូរបបូរមាត់លើដែលចង្អៀតបង្ហាញឱ្យឃើញពីបញ្ហាខ្លះដែលទាក់ទងនឹងបំពង់នោម ឬ បញ្ហាទាក់ទងនឹងចំនួនអសុចិ ឬ អសុចិមិនខ្លាំង ។



មានសុភាសិតក្នុងការមើលទម្រង់មុខមួយពោលថា បើ "រ៉ុនចុងភាក់ កូនរបស់អ្នកនឹងក្លាយជាមនុស្សថ្នាក់កណ្ដាល" ។ គេអាចកែបបូរមាត់លើបានដោយការកែច្នៃវះកាត់កែសម្ផស្ស (តែអាចធ្វើឱ្យផលប៉ះពាល់ដល់ខ្លួននាពេលក្រោយ) ដូច្នេះសម្រាប់សុភាពនារី ឬ សុភាពបុរសដែលមានបញ្ហាទាក់ទងនឹងចង្អូរបបូរមាត់លើយើងខ្ញុំសូមណែនាំឱ្យប្រើហ៊ុងស៊ុយដើម្បីជួយពួកគេក្នុងការកសាងគ្រួសារវិញប្រសើរជាង ។



www.elibraryofcambodia.org

# អាយុ៥២_៥៣ឆ្នាំ ឃ្លាំងទេវតា




អាយុ៥២និង៥៣ឆ្នាំជំនួសដោយចំណុចតំណែងដែលនៅផ្នែកខាងឆ្វេងនិងខាងស្តាំនៃចង្ហូរបបូរមាត់លើ ។ អាយុ52ឆ្នាំវាស្ថិតនៅផ្នែកខាងឆ្វេងនិងអាយុ53ឆ្នាំនៅខាងស្តាំនៃចង្ហូរបបូរមាត់លើសម្រាប់មនុស្សប្រុស តំណែងទាំងអស់នេះផ្លាស់ប្តូរផ្ទុយគ្នាជាមួយមនុស្សស្រី ។ ពាក្យថា "ឃ្លាំងទេវតា( សៀនគូ)"ហើយ "ជង្រុក ភោជនា ( ស៊ីឆាង)"តំណែងទី52និង53គឺសំដៅលើការរីកចម្រើនរុងរឿងរបស់មនុស្សយើង ។



www.elibraryofcambodia.org

ក្នុងវប្បធម៌ចិន អាហារមានន័យថាជាការចម្រើនរុងរឿង ។ ពេលដែលជនជាតិចិនជួបគ្នា គេតែងតែសួរគ្នាថា "អ្នកពិសាបាយហើយឬនៅ?" នេះមកពីជនជាតិចិនចាត់ទុកថា ការញ៉ាំជាភាពចម្រើនរុងរឿង ដូច្នេះហើយទើបបានជាវាសួរក្នុងន័យបង្កប់ថា "អ្នកសុខសប្បាយឬទេ?" ។

ក្នុងទស្សនវិជ្ជាចិនការចម្រើនរុងរឿងមិនមែនគ្រាន់តែជាការមានមាសប្រាក់នោះទេ ការចម្រើនរុងរឿងមានន័យថាមនុស្សអាចមានលទ្ធភាពញ៉ាំអាហារបានច្រើនប្រភេទ ហើយចេះក្រេបយកសេចក្តីសុខ ទោះជាអ្នកខ្លះមានទ្រព្យក្នុងកម្រិតធម្មតាៗក៏ដោយ ។

អ្នកដែលគ្មានភាពចម្រើនរុងរឿងពុំចាំបាច់តែជាអ្នកក្រីក្រលំបាកនោះទេ តែគេទាំងអស់នេះមិនស្គាល់របៀបស្វែងរកសេចក្តីសុខតាមរយៈភាពមានបានរបស់ពួកគេក្នុងបែបអ្នកសេពទូវសេចក្តីសុខទេ តើគេទាំងអស់នោះមានតំណែងទី 52និង53ដែលឡើងឆ្អឹង ឬ ស្គម?

សម្រាប់មនុស្សស្រីអ្នកចង់ឱ្យបុរសរបស់អ្នកមានតំណែងទី52និង53ដែលក្រាស់មានសាច់ធ្វើអ្វី? ព្រោះលក្ខណៈដូចនេះបានបង្ហាញឱ្យឃើញថាស្វាមីរបស់អ្នកមើលថែយកចិត្តទុកដាក់ចំពោះអ្នក ហើយអ្នកនឹងមានដំណើរជីវិតដែលល្អក្នុងភាសាចិនហៅប្រការនេះថា "អ៊ីស៊ីអ៊ូអ៊ិវ" បើតាមន័យតួអក្សរមានន័យថាជីវិតដែលសប្បាយ ឬ មិនឃ្លានស្លាប់ និងមិនក្រលំបាក ។

នៅលើផ្ទៃមុខរបស់មនុស្សស្រីយើងមិនចង់ឱ្យមានស្នាមសនៅត្រង់នេះទេហើយក៏មិនចង់ឱ្យមានពុកមាត់ដុះនៅត្រង់បរិវេណនេះដែរ ។ នេះមិនត្រឹមតែបង្ហាញអ្នកនឹងមិនមានថ្ងៃយល់ជ្រាបអំពីរបស់ល្អប្រណិតក្នុងជីវិតប៉ុណ្ណោះទេ តែអ្នកនៅមិនអាចជៀងទាក់ទងនឹងបញ្ហាលុយកាក់ផងដែរ ទំនោរគឺថានាងៗទាំងអស់នោះត្រូវមើលថែខ្លួនឯងអស់មួយជីវិត ។



www.elibraryofcambodia.org

# អាយុ៥៤-៥៥ឆ្នាំ ជង្រុកភោជនា

តំណែងដែលកំណត់ជតាអាយុ54 និង55ឆ្នាំ នៅបន្ទាប់ពីតំណែងទី52និង53ទៅខាងស្តាំ វានៅលើបបូរមាត់ដូចបានបង្ហាញក្នុងរូប ។ តំណែងទាំងពីរនេះត្រូវគេស្គាល់ក្នុងនាមជាជង្រុកភោជនា ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងតំណែង52និង53 ។






www.elibraryofcambodia.org

ក្នុងពេលមើលជង្រុកភោជនា ចំណុចសំខាន់ដូចគ្នាដែរនោះគឺការមើលរង្វង់មាត់ បើមាត់មានរង្វង់ដែលច្បាស់លាស់ហើយ "ញញឹម" ជានិច្ចនោះ វាជាមាត់ដែលល្អពិតក្នុងសាស្ត្រានៃការមើលទម្រង់មុខ។ បើតំណែងទី54និង55មានលក្ខណៈល្អមាត់របស់គេនោះមើលទៅដូចជាកំពុងតែញញឹមជានិច្ច ទោះជាពេលដែលគេមិនសប្បាយចិត្ត ឬ មិនបានញញឹមក៏ដោយ។

មិនគួរឱ្យមានស្នាមឆ្នូតផ្សេងៗពីបបូរមាត់ឡើងទៅខាងលើទេ ព្រោះវាបង្ហាញឱ្យឃើញពីជោគជតាមិនល្អចំពោះបញ្ហាលុយកាក់ហើយអាចរលាយរលត់បានក្នុងពេលមានអាយុ54និង55ឆ្នាំ។ បើទាំងតំណែងទី52និង53ស្តើង ដូចនឹងតំណែងទី54 និង55នោះមានន័យថានឹងមានជំងឺដែលព្យាបាលមិនងាយជានៅក្នុងកំឡុងអាយុនេះ ហើយយើងក៏មិនចង់ឃើញស្នាមជាំនៅត្រង់នេះដែរ ព្រោះវាបង្ហាញឱ្យឃើញពីជំងឺដែលទាក់ទងនឹងតម្រង់នោម បញ្ហាទាក់ទងនឹងប្រដាប់របត់ឈាម ឬ ការឈឺថ្កាត់ដែលទាក់ទងនឹងទឹក។






www.elibraryofcambodia.org

## អាយុ៥៦_៥៧ ឆ្នាំ ខ្សែសំណើច

តំណែងទី56និង57តំណាងឱ្យខ្សែសំណើច (ហ្វាលីង)ដែលអាចបង្ហាញឱ្យឃើញច្បាស់នៅពេលដែលយើងសើច ឬ ញញឹម ។




ប្រការដែលទាក់ទងនឹងខ្សែសំណើចមានពីរគឺ ប្រការទីមួយគឺវាមិនគួរមើលឃើញបានមុនពេលមានអាយុ45ឆ្នាំ ចំណែកប្រការទីពីរវិញគឺអ្នកចង់ឱ្យខ្សែសំណើចបង្ហាញចេញ( បើខ្សែសំណើចបង្ហាញចេញមុនពេលអ្នកមានអាយុ45ឆ្នាំ បង្ហាញឱ្យឃើញពីជីវិតដែលមានសេចក្តីទុក្ខលំបាកត្រូវធ្វើការធ្ងន់) តែប្រការសំខាន់នោះគឺត្រូវមានខ្សែញញឹមដែលល្អគឺថាវាមានលក្ខណៈវែង ហើយជ្រៅល្មម ខ្សែសំណើចដែលវែងជាសញ្ញាការមានអាយុយឺនយូរ ។

ក្រៅពីបង្ហាញឱ្យឃើញពីលក្ខណៈនៃការមានអាយុវែងហើយនោះ ខ្សែសំណើចនៅមានទំនាក់ទំនងនឹងកេរ្តិ៍ឈ្មោះរបស់យើងផងដែរ ជាធម្មតាអ្នកដែលមានឋានៈខ្ពស់ក្នុងសង្គមតែងតែមានខ្សែញញឹមជ្រៅ ហើយទូលាយ( មានន័យថាវាមិនត្បៀតជិតមាត់) ទាំងមានលក្ខណៈច្បាស់ ហើយមិនដាច់ទៀតផង ។ បើខ្សែសំណើចដាច់មានន័យថាម្នាក់នោះនឹងមានគ្រោះអាក្រក់ក្នុងអាយុ56-57 ឆ្នាំ បើខ្សែសំណើចច្បាស់មិនដាច់នៅពេលអាយុ56និង57នឹងមានសំណាង



www.elibraryofcambodia.org

ល្អមានដំណើរជីវិតរលូនហើយបានឡើងឋានៈទៀតផង ។

សម្រាប់មនុស្សស្រីខ្សែសំណើចមានលក្ខណៈសំខាន់ណាស់ ព្រោះវាទាក់ទងនឹងសមត្ថភាពរបស់ពួកនាងដែលនឹងមានជីវិតដ៏សប្បាយរីករាយ ល្អល្អះ និងហ៊ឺហានេះ ។ ចូរចាំទុកថា សម្រាប់ជនជាតិចិនមនុស្សស្រីដែលត្រូវធ្វើការធ្ងន់មិនបានមានជីវិតល្អទេ ។

ខ្សែសំណើចដែលជ្រៅ បង្ហាញឱ្យឃើញពីជីវិតរបស់មនុស្សស្រីដែលមានតែភាពធុញថប់ហើយត្រូវស្ថិតនៅក្រោមគំនាបនៃការធ្វើការធ្ងន់ ។




ម្យ៉ាងទៀតខ្សែសំណើចដែលមិនល្អ បង្ហាញឱ្យឃើញពីភាពដែលអាចមានរបួសរហូតដល់ថ្នាក់បាក់ដៃបាក់ជើងសម្រាប់មនុស្សប្រុស ព្រោះការបាក់ជើងក្នុងវ័យនេះគឺអាស្រ័យលើថាខ្សែសំណើចខ្សែណាមួយ (ឆ្វេងឬស្តាំ) ។ អ្នកមើលទម្រង់មុខនៅអាចប្រាប់បានថាជើងដែលត្រូវបាក់ឆ្វេងឬស្តាំ ។

យើងក៏មិនចង់ឃើញខ្សែសំណើចដែលកោងទៅរកជ្រុងនៃមាត់ដែរ ព្រោះគេហៅថាពស់កំពុងចូលមាត់ដែលបង្ហាញឱ្យឃើញពីសេចក្តីស្លាប់ដែលបណ្តាលមកពីជំងឺមហារីកសួតនិងមហារីកក្រពះ ។



www.elibraryofcambodia.org

# អាយុ៥៨-៥៩ឆ្នាំ ត្រចៀកខ្លា

អាយុ58និង59ឆ្នាំស្ថិតនៅត្រង់ឆ្អឹងថ្គាមដែលគេឱ្យនាមថាត្រចៀកខ្លា (ហ៊ូអឺ) ។ ទោះជាវាមានឈ្មោះថាត្រចៀកខ្លាក៏ដោយតែមិនមានអ្វីដែលជាប់ទាក់ទងនឹងខ្លាទេ (វាក៏ដូចតែឈ្មោះជាច្រើនទៀតដែលគេប្រើក្នុងអភិទស្សនវិជ្ជាចិន ជូនកាលវាទាក់ទងនឹងរូបារម្មណ៍ដើម្បីឱ្យងាយស្រួលក្នុងការចងចាំតែប៉ុណ្ណោះ) ។




តំណែងទី58និង59 អាចកំណត់ជោគជតាអាយុរបស់មនុស្សយើងបាននៅពេលមានអាយុ 58និង59ឆ្នាំហើយ និងប្រាប់ពីភាពកតញ្ញូរបស់មនុស្សនោះទៀតផង ។ តើអ្នកអាចដឹងបានយ៉ាងដូម្តេចថាមនុស្សដែលអ្នកជួយដោយក្តីមេត្តាអាចចងចាំនូវគុណដែលអ្នកបានធ្វើចំពោះគេបានឬទេ? គឺអ្នកត្រូវមើលត្រង់តំណែងត្រចៀកខ្លា ឬ តំណែងទី58និង59 បើត្រង់បរិវេណឆ្អឹងថ្ងាសឡើងឆ្អឹងមានន័យថាគេម្នាក់នោះពុំមែនជាមនុស្សកតញ្ញូនោះទេ ។ បើវាឡើងឆ្អឹងនិងឆ្អឹងថ្គាមកាងមានន័យថា គេមិនត្រឹមតែមិនមែនជាមនុស្សកតញ្ញូទេហើយថែមទាំងពុំសូវមានមនោសញ្ចេតនាទៀតផង ។



www.elibraryofcambodia.org

គុណភាពរបស់តំណែងទី58និង59 អាស្រ័យលើគុណភាពរបស់ត្រចៀកនិងតំណែងដែលនៅលើឆ្អឹងថ្គាមតិចតួចដែលយើងហៅថាមជ្ឈមណ្ឌលទ្វារជីវិត។ បើមនុស្សម្នាក់មានអ្វីដែលយើងហៅថាទងត្រចៀកគុជ (ទងត្រចៀកដែលមានលក្ខណៈស្រដៀងនិងគ្រាប់គុជដែលហុចចេញមក) នោះទស្សនរបស់គេនឹងប្តូរទៅរកភាពកាន់តែប្រសើរឡើងព្រមជាមួយអាយុ ហើយពួកគេនឹងក្លាយជាមនុស្សកតញ្ញូដោយសន្សឹមៗហើយទទួលផលប៉ះពាល់តិចដោយសារឥទ្ធិពលរបស់ឆ្អឹងថ្គាមកាង។

អ្នកដែលមិនមានទងត្រចៀកគុជ ហើយមានឆ្អឹងថ្គាមកាងត្រង់តំណែងទី58និង59 រមែងជាមនុស្សសាហាវគ្មានត្រាប្រណី។ បើបរិវេណនេះឡើងឆ្អឹង ឬ ត្រចៀកមិនមានទង ហើយមជ្ឈមណ្ឌលកណ្តាលទ្វារជីវិតស្រុតនោះវាបង្ហាញឱ្យឃើញថានឹងមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរនៅពេលមានអាយុបាន58និង59ឆ្នាំ។

តែបើបុគ្គលណាមានលក្ខណៈទាំងអស់ដែលបានពោលខាងលើ ហើយមានច្រមុះស្រួចកោង បង្ហាញឱ្យឃើញថាការដើរថយក្រោយរបស់គេនោះនឹងត្រូវប្រឈមនៅពេលអាយុបាន58និង59គឺបញ្ហាលុយកាក់។



ទងត្រចៀកដែលល្អ



www.elibraryofcambodia.org

# អាយុ៦០ឆ្នាំ ផ្កាយទឹក

អាយុ60ឆ្នាំជំនួសដោយចំពុះមាត់ត្រង់បបូរមាត់លើ ហើយជាតំណែងដែលដូចគ្នាទាំងសម្រាប់មនុស្សប្រុសនិងមនុស្សស្រី គេស្គាល់វាក្នុងនាមថា "ផ្កាយទឹក ឬ គុជនៃទម្រង់មុខ"។




ក្នុងការសិក្សាពីធាតុទាំង5 ធាតុទឹកជាប់ទាក់ទងនឹងអារម្មណ៍របស់មនុស្សយើង ដូច្នេះហើយទើបបានជាមាត់ប្រាប់យើងឱ្យដឹងពីអារម្មណ៍ខាងក្នុង។ និយាយដោយខ្លីគឺមនុស្សនេះមានសេចក្ដីសុខ ឬ សេចក្ដីទុក្ខយើងអាចមើលដឹងតាមរយៈបបូរមាត់គួបផ្សំនឹងកែវភ្នែក។

ពេលយើងមើលត្រង់តំណែងទី60ត្រង់មាត់ យើងចង់បានមាត់ដែលធំបន្តិច។ នៅសម័យមុនមនុស្សមាត់តូចមិនសូវមានលុយនិងមិនសូវសម្បូរអាហារញ៉ាំ។ សម្រាប់បច្ចុប្បន្ននេះមនុស្សដែលមានមាត់តូចរមែងមានជីវិតលំបាកថែមទាំងសម្បូរជំងឺឈឺថ្កាត់នៅពេលជរា។



www.elibraryofcambodia.org

អ្នកប្រហែលជាឆ្ងល់ហើយថា តើយើងធ្វើដូចម្តេចទើបដឹងថាមាត់នោះតូចឬធំ? អ្នកមិនត្រឹមតែអាចមើលមាត់ដោយធៀបនិងទម្រង់មុខប៉ុណ្ណោះទេ( គួរសង្កេតមើលលក្ខណៈសមមាត្រគ្នា) តែអ្នកអាចមើលមាត់ដោយធៀបនឹងច្រមុះបានដែរ មាត់ដែលតូចគឺមាត់ដែលតូចជាងទំហំច្រមុះ ។



មាត់ធំគឺមាត់ដែលធំជាងទំហំច្រមុះ

ជោគជតានៅពេលមានអាយុ60ឆ្នាំអាចល្អបានលុះណាតែបបូរមាត់បិទជិត បើមិនដូច្នោះទេ ជោគជតារបស់គេម្នាក់នោះអាចនឹងមិនល្អក្នុងខណៈពេលដែលមានអាយុ60 ។



www.elibraryofcambodia.org




បបូរមាត់គួរមានរឹមបបូរមាត់ដែលមានលក្ខណៈច្បាស់ហើយមុំនៃមាត់គួរតែចង្អុលឡើង ទោះជាក្នុងពេលមិនកំពុងញញឹមក៏ដោយ ។ បើរឹមបបូរមាត់មិនមានលក្ខណៈច្បាស់ ហើយមុំនៃមាត់ធ្លាក់ចុះ វាបង្ហាញឱ្យឃើញថានឹងកើតភាពឯកោពេលមានអាយុ60ឆ្នាំ ហើយបង្ហាញឱ្យឃើញពីភាពជាមនុស្សអាត្មានិយមទៀតផង ។

សម្រាប់មនុស្សស្រីយើងអាចមើលបបូរមាត់តាមរយៈកម្រាស់របស់វាជាមូលដ្ឋាន ។ យើងមិនចង់ឱ្យបបូរមាត់របស់មនុស្សស្រីស្តើងហួសទេ ព្រោះមនុស្សដែលមានបបូរមាត់ស្តើងជាមនុស្សសាហាវ គ្មានទឹកចិត្ត ហើយមិនបានផ្តល់តម្លៃលើទំនាក់ទំនងផ្សេងៗដែលពួកនាងមានចំពោះអ្នកផ្សេង ។ ចំណែកឯមនុស្សស្រីគួរមានបបូរមាត់ក្រាស់សមល្មមដែលជាលក្ខណៈបង្ហាញឱ្យឃើញពីភាពទន់ភ្លន់និងមានទឹកចិត្ត ។

ទោះជាយ៉ាងណាក៏ដោយយើងក៏មិនចង់ឱ្យបបូរមាត់ក្រាស់ហួសទេ ព្រោះវាបង្ហាញឱ្យឃើញថាពួកនាងចូលចិត្តអន្ទងប្រុសៗ ។ សុភាពនារីទាំងឡាយចូរប្រយ័ត្នចំពោះមនុស្សប្រុសដែលមានបបូរមាត់ក្រាស់ព្រោះពួកគេជាមនុស្សមានតណ្ហាក្រាស់ ។



www.elibraryofcambodia.org

# អាយុ៦១ឆ្នាំ តំណែងឆឹងចៀង

តំណែងនេះមាននាមថាឆឹងចៀង ដែលស្ថិតនៅខាងក្រោមត្រង់ចំណុចពាក់កណ្ដាលនៃបបូរមាត់ក្រោមដូចមានបង្ហាញក្នុងរូប (សម្រាប់មនុស្សប្រុសនិងមនុស្សស្រី)។




យើងចង់ឱ្យតំណែងទី61 មានសាច់ ដែលលក្ខណៈនេះបង្ហាញឱ្យឃើញពីការចូលនិវត្តន៍ដ៏ល្អនិងការឈានចូលវ័យជរាយ៉ាងរលូន។ ហេតុអ្វីបានជាគេថានេះបញ្ហាសំខាន់? នេះមានន័យថា អ្នកនឹងមានកូនចៅចោមរោមច្រើន អ្នកនឹងមិនរស់នៅឯកាឡើយ។



www.elibraryofcambodia.org

បើអ្នកមាន "រន្ធ" ត្រង់តំណែងទី61 ដូចជាស្នាមផត ឬ មានសម្លាកត្រង់តំណែងទី61 វាជំនួសឱ្យស្ថានភាពរបស់គេក្នុងសង្គមទាបហើយមានអាយុខ្លី។ ក្រៅពីនេះវានៅបង្ហាញឱ្យឃើញថាគេម្នាក់នេះអាចមានអាយុមិនដល់70ឆ្នាំ តំណែងទី61ដែលស្តើងមានសម្លាក ឬ ផត ឬ "61ហ្លួងសៅ" មានន័យថាបរិវេណត្រង់នេះមើលទៅមាន "ស្នាមជាំ" ហើយមានស្នាមស្រមោលគ្របដណ្តប់ វាបង្ហាញឱ្យឃើញពីការមានបញ្ហាផ្នែកសុខភាព ភាពឯកោ ឬ វ័យជរាដែលវង្វេង និងសុរាដែរ។ តំណែងទី61ដែលមានសាច់បង្ហាញឱ្យឃើញថាក្នុងផ្ទះសម្បូរទៅដោយកូនចៅកតញ្ញូដែលចោមរោមរស់នៅជាមួយពោរពេញទៅដោយសេចក្តីសុខ។




ទោះជាយ៉ាងណាក៏ដោយតំណែងទី61 ត្រូវពិចារណារួមជាមួយខ្សែសំណើច ឬ ហ្វាលីងជានិច្ច បើខ្សែសំណើចខ្លីតំណែងទី61 ក៏មិនសំខាន់ដែរ តែបើខ្សែសំណើចវែងត្រូវប្រមើលមើលលើតំណែងទី61 ។



www.elibraryofcambodia.org

# អាយុ៦២-៦៣ឆ្នាំ ឃ្លាំងដី

តំណែងទី62និង63ស្ថិតនៅសងខាងតំណែងទី61ក្រោមបបូរមាត់ក្រោម (មើលក្នុងរូបភាព) តំណែងនេះត្រូវគេស្គាល់ក្នុងនាមជាឃ្លាំងដី (ទីឃូ)។ តំណែងទាំងពីរនេះមិនត្រឹមតែជំនួសជោគជតារបស់មនុស្សនៅអាយុ62និង63ឆ្នាំប៉ុណ្ណោះទេ វាថែមទាំងបានបង្ហាញឱ្យឃើញថាគេម្នាក់នោះមានទ្រព្យសម្បត្តិ ឬ មរតកទុកឱ្យដល់កូនចៅជំនាន់ក្រោយទៀតផង។




តំណែងទី62និង63ដែលឡើងឆ្អឹង វាមិនល្អទេសម្រាប់មនុស្សស្រី។ តំណែងទី62និង63ដែលស្តើងហើយឡើងឆ្អឹងមានន័យថាជាមេម៉ាយដែលមិនមានលុយ។ ការណ៍នេះអាចកើតឡើងច្រើនបំផុតបើមនុស្សស្រីនោះមានច្រមុះឡើងឆ្អឹងដែរ។ ព្រោះច្រមុះដែលឡើងឆ្អឹងបង្ហាញឱ្យឃើញពីភាពឯកានៅវ័យជរា ពេលយកមកផ្សំនឹងតំណែងទី62និង63ដែលឡើងឆ្អឹង វាបង្ហាញថាមានភាពឯកាហើយក្រីក្រទៀតផង។

បើតំណែងនេះស្រុត ឬ មានសម្លាក ត្រចៀកមិនមានទង ថែមទាំងកំណាប់ទ្រព្យក៏តូចចង្អៀត ហើយជុំវិញភ្នែកជាំទៀតផងនោះ វាបង្ហាញឱ្យឃើញថានឹងស្លាប់នៅពេលមានអាយុ62ឆ្នាំ។ តែបើតំណែងទាំងអស់នេះល្អ ជីវិតរបស់គេនឹងមានអាយុវែងមានកូនចៅដែលចាំជួយទំនុកបម្រុងនៅក្នុងវ័យចូលនិវត្តន៍។



www.elibraryofcambodia.org

## អាយុ ៦៤-៦៥ឆ្នាំ អ្នកធំនុកបម្រុងក្នុងវ័យជរា

តំណែងទី64និង65ស្ថិតនៅក្បែរតំណែងទី62និង63ដូចមានបង្ហាញក្នុងរូប។ តំណែងទាំងពីរនេះទាក់ទងនឹងវ័យជរារបស់មនុស្សយើង ហើយបង្ហាញឱ្យឃើញថាពួកគេនឹងមានអ្នកឧបត្ថម្ភ(គុយរ៉ុន) ក្នុងវ័យជរាឬអត់។

យើងចង់បានតំណែងទី64និង65ដែលមានសាច់ព្រោះវាបង្ហាញឱ្យឃើញថាអ្នកមានសមាជិកក្នុងគ្រួសារច្រើនសម្រាប់ពង្រីកពូជពង្សថែមទាំងមិត្តភក្តិច្រើននាក់នៅក្បែរខាងក្នុងវ័យនេះ។




យើងចង់ឱ្យបរិវេណក្រោមបបូរមាត់ក្រោមមានសាច់មិនស្តើង មិនឡើងឆ្អឹង។ ក្រៅពីនេះអ្វីដែលសំខាន់ដែលត្រូវយកមកគិតគឺមាត់មើលថាតើជាមាត់ដែលសោកសៅ ឬ ជាមាត់ដែលមានសេចក្តីសុខ។ បើនរណាមានបរិវេណក្រោមបបូរមាត់ស្តើងហើយមានមាត់សោកសៅតែម្នាក់នោះអាចបាត់បង់ភាពមានបានធំបំផុតនៅពេលមានអាយុ64និង65ឆ្នាំដែលជាផលវិបាកប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះជីវិតរបស់គេ។



www.elibraryofcambodia.org

តំណែងទី64និង65នៅក្បែរមាត់ដែលត្រូវគេស្គាល់ក្នុងនាមថាផ្កាយទឹកនៃទម្រង់មុខដូច្នេះហើយទើបបានជាយើងចង់ឱ្យសាច់ស្បែកត្រង់បរិវេណនេះមានលក្ខណៈទ្រលុកទ្រលន់ហើយស្រស់ថ្លាមិនស្ងួតនិងមិនមានស្នាមជ្រួញ។ បរិវេណជុំវិញផ្កាយទឹកក៏ដូចបរិវេណជុំវិញអូរដែរ គឺវាតែងតែមានសំណើមមិនស្ងួត។ ផ្កាយទឹកដែលស្ងួតបង្ហាញឱ្យឃើញពីបញ្ហាសុខភាពដែលទាក់ទងនឹងប្រដាប់របត់ឈាម។




តំណែងទី64និង65ត្រូវពិចារណាគួបផ្សំជាមួយទម្រង់មាត់និងខ្សែសំណើច ឬហ្វាលីងជានិច្ច ហើយត្រូវពិចារណាគួបផ្សំនឹងពណ៌នៃបបូរមាត់ដែរ។ បើតំណែងទី64និង65ទ្រលុកទ្រលន់ហើយមានសាច់ថែមទាំងមានបបូរមាត់ពណ៌ស៊ីជម្ពូនិងមានសំណើមបែបមានសុខភាពល្អដែរនោះ នោះវ័យជរារបស់អ្នកនឹងចម្រើនរុងរឿងហើយមានលក្ខណៈល្អជាក់ជាមិនខាន។

100តំណែងទោះជាកំណត់អាយុច្បាស់លាស់ តែវានៅតែមានទំនាក់ទំនងនឹងជោគជតាដោយរួមក្នុងជីវិតរបស់មនុស្សយើងទៀតផង។ ឧទាហរណ៍ដូចជា បើតំណែង64និង65គ្មានសាច់ហើយឡើងឆ្អឹងនិងមានចង្កាស្រុតនោះ វាបង្ហាញឱ្យឃើញថាគេម្នាក់នោះនឹងមានអាយុខ្លី។



www.elibraryofcambodia.org

# អាយុ ៦៦-៦៧ឆ្នាំ មុំមាត់

អាយុ66-67ឆ្នាំជំនួសដោយមុំមាត់។ តំណែងទី66គឺមុំមាត់ឆ្វេងសម្រាប់មនុស្សប្រុសនិងមុំមាត់ស្តាំសម្រាប់មនុស្សស្រីដូចមានបង្ហាញក្នុងរូប។




មុំមាត់ពុំត្រូវមានលក្ខណៈមូលដូចមុំមាត់របស់តួកំប្លែងទេ យើងមិនចង់ឃើញស្នាមប្រឡាក់របស់ក្រែមលាបបបូរមាត់ត្រង់មុំមាត់ទេ។ យើងចង់ឃើញមុំមាត់ដែលចង្អុលឡើងព្រោះទោះជាម្នាក់នោះមិនមែនកំពុងញញឹមក៏ដោយ ក៏មុំមាត់ដូចជាកំពុងញញឹមដែលបង្ហាញឱ្យឃើញថាគេជាមនុស្សមានសេចក្តីសុខមើលពិភពលោកក្នុងផ្លូវល្អជានិច្ច។ អ្នកដែលមានមុំមាត់ចង្អុលចុះជាអ្នកមានបញ្ហាផ្នែកសតិអារម្មណ៍ ឬ ជាមនុស្សសោកសៅជានិច្ច។ តំណែងនេះគួរតែចេញពណ៌សតិចៗ ព្រោះតំណែងនេះគេហៅថាចំណុចមាស (ជិនលី)។ ពណ៌របស់មាសសុទ្ធពុំមែនពណ៌មាសដូចដែលយើងគិតនោះទេគឺវាមានពណ៌ស ដូច្នេះបរិវេណនេះរបស់ទម្រង់មុខគួរមានពណ៌ស្លាំងតិចៗ ឬ ពណ៌ជម្ពូតិចៗហើយមិនត្រូវមានពណ៌ជាំទេ។



www.elibraryofcambodia.org

តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាអ្នកតែងតែមានអារម្មណ៍រំខានចិត្តពេលបានឮសម្ដីរបស់លោកA? (ទោះជាសម្ដីនោះមិនបានធ្វើឱ្យអ្នកអន្ដរាយក៏ដោយ) ចំណែកអ្នកដទៃខ្លះនិយាយដូចគ្នាតែអ្នកពុំទើសចិត្ត? ចំណុចមាសជំនួសឱ្យសមត្ថភាពនៃការអន្ទងចិត្តនិងអំណាចរបស់ពាក្យសម្ដី អ្វីដែលអ្នកនិយាយបានរំខានចិត្តគេដែរឬអត់ ឬ ថាធ្វើឱ្យពួកគេឈប់ស្ដាប់មិនចង់ឮអ្វីដែលអ្នកនិយាយ? បញ្ហានេះអាស្រ័យលើចំណុចមាសនោះឯង។

មនុស្សស្រីដែលរៀបការហើយគួរដឹងថាការមានចំណុចមាសល្អគឺមានតម្លៃស្មើនឹងមាសសុទ្ធ។ បើអ្នកមានចំណុចមាសល្អ ស្វាមីរបស់អ្នកនឹងស្ដាប់តាមអ្នកគ្រប់ម៉ាត់ ហើយបណ្ដោយឱ្យអ្នកធ្វើតាមចិត្តដោយពុំចាំបាច់ដំឡើងសំឡេងឡើយ។

យើងមិនចង់ឱ្យខ្សែសំណើច ឬ ហ្វាលីងប៉ះនឹងមុំមាត់ទេ។ អ្នកដែលមានខ្សែសំណើចប៉ះ ឬ ជិតមុំមាត់គឺជាមនុស្សចចេសក្បាលរឹង ពិបាកអន្ទងចិត្ត ឬ ពិបាកធ្វើឱ្យពួកគេផ្លាស់ប្ដូរចិត្តណាស់ តែបើចំណុចមាសមានសាច់ គេម្នាក់នោះនឹងមានស្ថានភាពក្នុងសង្គម ហើយជាអ្នកមានឥទ្ធិពលធ្វើឱ្យពាក្យសម្ដីនិងការប្រកាសរបស់ពួកគេមានទម្ងន់និងមានកម្លាំងទំនាញចិត្តខ្ពស់។



ខ្សែសំណើចដែលក្បែរចំណុចមាស
(អ៊ិនលី) ហួសពេក



www.elibraryofcambodia.org

# អាយុ៦៨-៦៩ឆ្នាំ ស្នាមញញឹម

មូលដ្ឋានទូទៅនៃការមើលទម្រង់មុខគឺយើងមិនចង់ឱ្យផ្នែកណាមួយនៃទម្រង់មុខស្រុតទេ។ ស្នាមបបូរមាត់លើជាប្រការលើកឡើងក្នុងច្បាប់នេះ បរិវេណដែលស្រុតត្រូវមើលថាជា "ផ្នែកដែលបាត់បង់ទៅ" នៃទម្រង់មុខ។

ស្នាមញញឹមអាចមើលទៅគួរឱ្យស្រឡាញ់សម្រាប់ក្មេងៗ ហើយអាចបន្ថែមមន្តស្នេហ៍ឱ្យដល់មនុស្សយើង (តើអ្នកដឹងទេថាអ្នកដែលមានស្នាមញញឹមជាអ្នកផឹកដ៏អស្ចារ្យ?) តែវានៅសំដៅលើភាពក្រលំបាកខ្លះក្នុងពេលមានអាយុ68និង69ឆ្នាំផងដែរ ជាពិសេសបើស្នាមញញឹមចេញច្បាស់ហើយជ្រៅខ្លាំង មានស្បែកស្រគាំត្រង់តំណែងទី68និង69 វាបង្ហាញឱ្យឃើញថាគេម្នាក់នោះជាមនុស្សចូលចិត្តកើតក្តីកង្វល់ដោយពុំមានមូលហេតុ។



ស្នាមញញឹម

ផ្ទុយមកវិញ បើតំណែងទី68និង69មានសាច់គឺបង្ហាញឱ្យឃើញថាគេនឹងមានសុខភាពល្អនឹងមានសេចក្តីសុខនិងភាពចម្រើនរុងរឿងក្នុងក្រុមគ្រួសារ ថែមទាំងមានអាយុយឺនយូរទៀតផង។



www.elibraryofcambodia.org

# អាយុ៧០ឆ្នាំ ចង្កា

ចំណុចពាក់កណ្តាលចង្កាជំនួសតំណែងជោគជតាអាយុទី70ឆ្នាំ ជាតំណែងដែលដូចគ្នាសម្រាប់មនុស្សប្រុសនិងមនុស្សស្រី តំណែងនេះជំនួសឱ្យវ័យជរា។ យើងចង់ឱ្យតំណែងនេះមានសាច់ស្មើ ហើយមិនមានស្នាមស្រុត ព្រមជាមួយគ្នានេះដែរយើងក៏ចង់ពិសោធថា គេម្នាក់នោះមានកែវភ្នែកដែលមានភាពស្រស់ថ្លាហើយរស់រវើកដែលបង្ហាញឱ្យឃើញពីចិត្តវិញ្ញាណដ៏ល្អរបស់កែវភ្នែក ហើយមានសំឡេងមិនស្អក សំឡេងមិនចាំបាច់ត្រូវខ្លាំង ឬមានអំណាចទេ តែគួរមានទឹកដម មានភាពស្រស់ថ្លាហើយច្បាស់។ ចង្កាដែលមានស្នាមស្រុតរួមទាំងសំឡេងដែលទន់ខ្សោយនិងស្អកវាបង្ហាញឱ្យឃើញពីបញ្ហាផ្នែកសុខភាពរបស់គេនោះក្នុងពេលមានអាយុ70ឆ្នាំ។




អ្នកប្រហែលជាគិតថាមនុស្សដែលមានវ័យ70ឆ្នាំ គួរតែមានស្នាមជ្រួញ តែវាមិនមែនអីចឹងទាំងស្រុងទេ។ ចូរអ្នកមើលម្ចាស់ក្សត្រីអេលីសាបែត វិរ៉េនបាហ្វេត លីកាឈីង( អ្នកជំនួញមហាសេដ្ឋីជនជាតិហុងកុង អ្នកមានជាប់លំដាប់ថ្នាក់ពិភពលោក) អ្នកអាចឃើញថាជាទម្រង់មុខដែលមិនមានស្នាម ឬ ភាពជ្រីវជ្រួញទាំងក្នុងពេលដែលមានអាយុច្រើនហើយ ហើយចំណុចនេះមិនទាក់ទងជានឹងទម្រង់មុខទេ តែវាទាក់ទងនឹងជោគសំណាងដែលមានលក្ខណៈល្អក្នុងវ័យជរានិងចង្កាដែលគួរឱ្យស្រឡាញ់។



www.elibraryofcambodia.org

# អាយុ៧១ឆ្នាំ ប៉មដី




តំណែងនេះត្រូវបានគេឱ្យនាមថារណ្តៅសពនៃទម្រង់មុខ ព្រោះវានៅត្រង់ចំណុចទាបបំផុតនៃទម្រង់មុខ។ យើងចង់ឱ្យចំណុចទី71នេះទូលាយមិនស្រួច ប៉មដីគួរមានលក្ខណៈដូចទួលភ្នំ ដែលឡើងខ្ពស់បន្តិចម្តងៗមិនមែនដូចដុំថ្មដែលដុះចេញមកទាំងដុលៗនោះទេ។

ប៉មដីដែលល្អគឺទូលាយហើយមានសាច់ បង្ហាញថាគេជាមនុស្សដែលមានទ្រព្យសម្បត្តិច្រើន ហើយមានតំណែងខ្ពស់និងទទួលបាននូវការគោរពពីសង្គមទៀតផង។ ប៉មដីគួរតែមានលក្ខណៈហុចឡើង តែយើងមិនចង់ឱ្យវាហុចឡើងហួសពេកទេ ហើយយើងក៏មិនចង់ឱ្យវាគ្រហ៊ីបបាក់ចូលក្នុងហួសដូចគ្នាដែរ។ តំណែងទី71ដែលហុចចេញក្រៅបង្ហាញឱ្យឃើញពីវ័យជរាដែលចម្រើនរុងរឿងនិងមានភាពហ៊ឺហាស្តុកស្តម្ភ ថែមទាំងមានកូនចៅកតញ្ញូច្រើននៅចាំចោមរោមថែទាំជានិច្ច។



www.elibraryofcambodia.org

សម្រាប់មនុស្សស្រីយើងចង់ឱ្យតំណែងនេះមូល ចំណែកមនុស្សប្រុសវិញយើងចង់ឱ្យតំណែងនេះរាងជ្រុងបន្តិច។ បើមនុស្សស្រីមានចង្កាជ្រុងមានន័យថានាងត្រូវធ្វើការ ទោះជាក្នុងវ័យជរាហើយក៏ដោយ ហើយគេមិនចាត់ទុកថាជាវ័យជរាដែលល្អសម្រាប់មនុស្សស្រីទេ។ បើចង្ការបស់មនុស្សស្រីរាងជ្រុងហើយស្រួចបង្ហាញឱ្យឃើញថាគេគឺជាមនុស្សចចេសរឹងរូសហើយចាំបាច់ត្រូវធ្វើការធ្ងន់ក្នុងវ័យជរា។ មនុស្សស្រីដែលមានចង្កាមូលហើយមិនលយស្រួចគឺជាចៅហ្វាយដែលមានពេលទំនេរសប្បាយៗច្រើន។



地閣
ប៉មជី (71)

សម្លាក ឬ ស្នាមឆ្កូតនៅត្រង់តំណែងទី71 បង្ហាញឱ្យឃើញពីបញ្ហាផ្នែកសុខភាព ឬមានបញ្ហារឿងកូន ថែមទាំងអាចបង្ហាញឱ្យឃើញពីភាពចចេសរឹងរូស ឬ ការមានជំងឺច្រើនក្នុងវ័យនេះទៀតផង។ ការមានស្នាមត្រង់ចង្កា ឬ ចង្កាព្រៃក បង្ហាញឱ្យឃើញពីលក្ខណៈនៃមនុស្សឆ្លាតវាងវៃមានគំនិតច្នៃប្រឌិតដ៏ប៉ិនប្រសប់ ជាពិសេសវាក៏នៅបង្ហាញឱ្យឃើញពីការមានបាននៅអាយុ71 ឆ្នាំទៀតផង។



www.elibraryofcambodia.org

## អាយុ៧២_៧៣ឆ្នាំ បរិវារ




អាយុ72និង73 ត្រូវគ្នានឹងវាំងបរិវារដែលនឹងត្រូវបានលើកមកនិយាយក្នុងមេរៀនទី4ដែលស្តីពីវាំងទាំង12 នៃផ្ទៃមុខ ។

ធាតុពិតរបស់វាំងបរិវារសំដៅលើសមត្ថភាពរបស់មនុស្ស យើងដែលថានឹងអាចក្លាយទៅជាចៅហ្វាយនាយ ឬនឹងមានកូនចៅ កូន ឬ កូនសិស្សដែលល្អឬយ៉ាងណា ។

ក្នុងវប្បធម៌ចិន គេចាត់ទុកថាជីវិតដែលល្អក្នុងវ័យជរាត្រូវមានមនុស្សមកហែហមចោមរោមដែលអាចជួយទំនុកបម្រុងខ្លួនបានស្រួលស្រេច វ័យជរាដែលល្អហើយចម្រើនរុងរឿងត្រូវមានមនុស្សនៅចាំបម្រើ ឬ មានកូនចៅកតញ្ញូច្រើន ។



www.elibraryofcambodia.org

បរិវេណនេះគួរតែរាបស្មើ ទូលាយ ហើយមិនមានខ្សែឆ្នូតកាត់ ថែមទាំងគួរមានសាច់និងស្បែកមិនណែនជាប់នឹងឆ្អឹង។ ស្បែកដែលស្វិតជ្រួញ ស្តើង ឬ មានស្នាមឆ្នូតឆ្លងកាត់ត្រង់តំណែងនេះ បង្ហាញឱ្យឃើញពីបញ្ហាទាក់ទងនឹងបរិវារក្នុងវ័យជរា (ឧទាហរណ៍ដូចជាស្រីបម្រើមិនល្អ កូនមិនស្តាប់បង្គាប់ ឬ អកតញ្ញូ ឬ មានជំងឺក្នុងពេលមានអាយុ72និង73ឆ្នាំ)។




ពណ៌ត្រង់បរិវេណនេះពុំគួរមានពណ៌ខ្មៅ ឬ ពណ៌បៃតងទេ ព្រោះវាបង្ហាញពីការមានគ្រោះថ្នាក់ដោយសារឧប្បត្តិហេតុ ឬ ស្លាប់ដោយសារមូលហេតុដែលមិនស្របតាមលក្ខណៈធម្មជាតិ។ ជាពិសេស បើគេម្នាក់នោះមានភ្នែកប៉ោងក្រឡោត មានគ្រាប់ពោកចេញមកធំ ហើយមានពណ៌បៃតង ឬ ខ្មៅត្រង់តំណែងទី72និង73 វាបង្ហាញឱ្យឃើញពីការស្លាប់ដោយឧប្បត្តិហេតុដូចជា គ្រោះថ្នាក់ចរាចរជាដើម។



www.elibraryofcambodia.org

# អាយុ៧៤-៧៥ឆ្នាំ ឆ្អឹងថ្គាម

សម្រាប់អាយុ74និង75ឆ្នាំ យើងអាចមើលឆ្អឹងថ្គាមរបស់គេម្នាក់នោះ។ តំណែងនេះគួរមានសាច់មិនឡើងឆ្អឹង ហើយមិនកាង។ ឆ្អឹងថ្គាមមិនត្រូវផុសពេកទេ តំណែងទី74និង75ដែលល្អគឺត្រូវមានសាច់ហើយមានពណ៌មិនស្រអាប់ តែគួរមានពណ៌ជម្ពូ។ ចំណែកឯបបូរមាត់គួរមានសម្រស់ដែលបង្ហាញឱ្យឃើញពីរយៈកាលដ៏រីករាយនិងចម្រើនរុងរឿងក្នុងខណៈអាយុបាន74និង75ឆ្នាំដែលមានកូនចៅ ឬ អ្នកជិតខាងមកហែហាមចាំជួយឧបត្ថម្ភគាំទ្រ។




មនុស្សដែលមានឆ្អឹងថ្គាមផុស ជាមនុស្សដែលពុំព្រមរាថយចំពោះអ្វីៗទាំងអស់ ពួកគេឈប់លុះត្រាតែទទួលបាននូវអ្វីដែលគេត្រូវការសិន ហើយពេលខ្លះគេអាចឈានទៅដល់ការក្បត់មិត្តភក្តិ ឬ គ្រួសារបានទៀតផង។ យើងក៏មិនចង់បានឆ្អឹងថ្គាមដែលផុសឃើញឆ្អឹងត្រមែងៗដែរ ជាពិសេសមនុស្សដែលមានភ្នែកធំ ព្រោះវាបង្ហាញឱ្យឃើញថាពួកគេងាយមានជំងឺដែលទាក់ទងនឹងផ្លូវភេទ។



www.elibraryofcambodia.org

# អាយុ៧៦_៩៩ឆ្នាំ សត្វស្ថានសួគ៌ទាំង១២

សម្រាប់អាយុពី76-99ឆ្នាំ ទម្រង់មុខនឹងប្រាប់លក្ខណៈសត្វទាំង12 ដោយប្រើចម្រុះជាមណ្ឌលកណ្ដាលនៃចំណុចរួមនិងរាំងទាំង12ដូចមានបង្ហាញក្នុងរូបខាងក្រោម ។ សម្រាប់មនុស្សប្រុសរូបតំណាងសត្វរៀងលំដាប់បញ្ច្រាសពីទ្រនិចនាឡិកាដោយចាប់ផ្ដើមពីខាងឆ្វេង ចំណែកមនុស្សស្រីវិញលក្ខណៈនេះត្រូវរៀបលំដាប់ស្របតាមទ្រនិចនាឡិកា ដោយចាប់ផ្ដើមពីខាងស្ដាំ ។






www.elibraryofcambodia.org






www.elibraryofcambodia.org

# មេរៀនទី៤

# ទាំងទាំង១២នៃទម្រង់មុខ

វាំងទាំង12ជាប្រធានបទដែលយើងតែងជួបប្រទះជានិច្ចក្នុងអភិទស្សនវិជ្ជាចិនក្នុងហោរាសាស្ត្រផ្កាយពណ៌ស្វាយ(ជឺវុិយតូវស៊ូ) មាន12វាំងក្នុងចំណោមបង្គោលទាំង4នៃជោគជតា (ប៉ាជឺ)ក៏មានវាំងទាំង12 ហោរាសាស្ត្រនៅបស្ចិមប្រទេសក៏មានប្រើផ្ទះជោគជតាទាំង12ជាចំណុចអះអាងដែរ។ ចំណែកឯក្នុងសាស្ត្រាការពិនិត្យមើលទម្រង់មុខ (មៀនសៀង) ក៏មានវាំងទាំង12ដែរ។

វាំងទាំង12កំណត់ជោគជតា12ផ្នែករបស់ជីវិតមនុស្សយើង។

មនុស្សស្រីជាច្រើនតែងតែចង់ដឹងនិងសាកសួររឿងគូស្រករ ឬ ជោគជតានៃជីវិតគូស្រករ។ ដូច្នេះហើយ ទើបទម្រង់មុខរបស់ពួកនាងអាចធ្វើឱ្យយើងអាចប្រឹក្សាបានដោយការស្គាល់ឱ្យបានច្បាស់នូវវាំងទាំង12។



www.elibraryofcambodia.org






www.elibraryofcambodia.org

# វាំងជីវិត

ជារៀងរាល់ព្រឹកពេលអ្នកភ្ញាក់ឡើង   អ្នកគួរឆ្លុះកញ្ចក់ដើម្បីប្រមើលមើលមុខរបស់អ្នកនៅថ្ងៃនេះ។  ថ្ងៃដំបូងដែលអ្នកគួរសម្លឹងមើលគឺវាំងជីវិត (ឬវាំងសំខាន់បំផុតដែលអ្នកគួរសម្លឹងមើលក្នុងករណីដែលអ្នកកំពុងប្រញាប់)។

វាំងជីវិតជាវាំងសំខាន់បំផុតក្នុងចំណោមវាំងទាំង12  ព្រោះវាជាផ្ទះជោគជតាជីវិតរបស់មនុស្សយើង ដូចជាភាពចម្រើនរុងរឿង សតិបញ្ញា ភាពមានបាន សុខភាព សុទ្ធតែអាស្រ័យលើគុណភាពរបស់វាំងជីវិតទាំងអស់។ បើវាំងជីវិតមិនល្អអាចបំផ្លាញប្រយោជន៍ទាំងពួងបាន។

តើវាំងជីវិតស្ថិតនៅត្រង់ណា? វានៅត្រង់ចន្លោះចិញ្ចើមដូចមានបង្ហាញក្នុងរូប។






www.elibraryofcambodia.org

# ប្រមើលមើលវាំងជីវិត-ច្បាប់ពីរធ្នាប់ដៃ

តើអ្នកអាចប្រមើលមើលគុណភាពនៃវាំងជីវិតរបស់អ្នកបានយ៉ាងដូចម្តេច? ជាការងាយស្រួលទេ វាំងជីវិតគួរមានទំហំយ៉ាងតិចណាស់២ធ្នាប់ដៃ។ ចូរឈរនៅមុខកញ្ចក់ ហើយមើលភ្លាមទៅថាតើអ្នកអាចដាក់ម្រាមដៃពីរចូលទៅចន្លោះចិញ្ចើមដោយមិនឱ្យប៉ះចិញ្ចើមបានឬទេ?



វាំងជីវិត-ទំហំពីរធ្នាប់ដៃ

វាំងជីវិតចង្អៀតបង្ហាញឱ្យឃើញពីគុណភាពជីវិតមិនល្អ ។ តើគុណភាពជីវិតមិនល្អមានន័យយ៉ាងដូចម្តេច? វាមិនបានមានន័យថាអ្នកនឹងក្រីក្រ ឬ មានជីវិតលំបាកនោះទេ ផ្ទុយទៅវិញពេលខ្លះសូម្បីតែអ្នកមានខ្លាំងយ៉ាងណាក៏គុណភាពជីវិតរបស់អ្នកមិនសូវល្អដែរ ។



វាំងជីវិតចង្អៀត មានទំហំត្រឹមតែមួយធ្នាប់ដៃ



www.elibraryofcambodia.org

ហេតុអ្វីបានជាអ្នកមានទ្រព្យតែបែរជាមានគុណភាពជីវិតមិនល្អទៅវិញ? ការមានលុយច្រើនមហាសាល តែសុខភាពមិនល្អ មិនហ៊ានចំណាយលុយទិញរបស់របរដែលអ្នកស្រឡាញ់... តើវាមានប្រយោជន៍អ្វីទៅ? ម្យ៉ាងទៀតអ្នកអាចក្លាយជាអ្នកមានខ្លាំង តែអ្នកមិនបានមានអារម្មណ៍ថាអ្នកមានសេចក្តីសុខ ឬ មានជីវិតល្អពេញលេញនោះទេ។ មនុស្សដែលមានវាំងជីវិតចង្អៀតរមែងជាមនុស្សមានអារម្មណ៍ក្តៅក្រហាយអន្ទះអន្ទែង ពួកគេមានអារម្មណ៍ថាខ្លួនមិនបានទទួលរបស់ដែលខ្លួនគួរទទួលបានជានិច្ច។ ចូរអ្នកសាកល្បងនឹកអំពីមនុស្សដែលអ្នកធ្លាប់ស្គាល់ដែលមានលក្ខណៈបែបនេះដូចជាអ្នកដែលប្រាថ្នាលើសលប់ក្នុងកន្លែងធ្វើការ (ដែលគិតថា ខ្លួនឯងមិនបានល្អដូចអ្នកដទៃ) អ្នកដែលមានអារម្មណ៍ថាជីវិតមិនយុត្តិធម៌។ មនុស្សដែលមានវាំងជីវិតចង្អៀតតែងតែមានគំនិតខាងផ្លូវអវិជ្ជមាន ឬ ទុទ្ទិដ្ឋិនិយមជានិច្ច។ ពួកគេតែងតែធុញថប់ក្តៅក្រហាយ ព្រោះការមិនសមបំណង។ លើសពីនេះទៅទៀត វាំងជីវិតចង្អៀតនៅបង្ហាញឱ្យឃើញពីភាពមានចិត្តចង្អៀតចង្អល់និងមិនព្យាយាមចង់សាកល្បងនូវអ្វីដែលថ្មី។

ផ្ទុយមកវិញ បើវាំងជីវិតទូលាយហើយមានសាច់ នេះបង្ហាញឱ្យឃើញពីមនុស្សដែលមានគំនិតសុទិដ្ឋិនិយមដែលតែងតែអាចផ្លាស់ប្តូរសភាពការណ៍លំបាកឱ្យក្លាយជាសភាពការណ៍ស្រួលបួលឡើងវិញបានភ្លាមៗ។ និយាយជារួមគឺជាមនុស្សដែលអាចបត់បែនគ្រប់កាលៈទេសៈ និងជាមនុស្សដែលចូលចិត្តស្វែងយល់ចង់សាកល្បងអ្វីដែលថ្មី។



វាំងជីវិតចង្អៀត



www.elibraryofcambodia.org

មនុស្សទាំងអស់នេះតែងមានក្តីត្រេកត្រអាលនឹងគុណភាពជីវិតដែលល្អ ទោះជាពួកគេមិនមែនជាអ្នកមានទ្រព្យក៏ដោយ ក៏ពួកគេមើលឃើញវត្ថុដែលគួរឱ្យរីករាយក្នុងជីវិតបានងាយស្រួល។ លើសពីនេះទៅទៀត គេអាចប្រើសមត្ថភាពរបស់ខ្លួនពេញទំហឹងដើម្បីប្រឈមនឹងការដើរថយក្រោយផ្សេងៗ ឬ ភាពបរាជ័យនានាក្នុងជីវិត។



វាំងជីវិតទូលាយ



www.elibraryofcambodia.org

# គុណសម្បត្តិរបស់វាំងជីវិត

វាំងជីវិតគួរមានសាច់ដោយមិនមានផុសឆ្អឹង ឬ មើលមិនឃើញឆ្អឹងផុសត្រង់វាំងជីវិត ។ ដោយសារវាំងជីវិតនៅក្នុងកម្រិតជាមួយនឹងចិញ្ចើម ទើបអ្នកខ្លះអាចមានឆ្អឹងលេចធ្លោចេញមកត្រង់ក្រោមចិញ្ចើម ឬ ត្រង់ប្រឡង់ភ្នែក។ បើវាំងជីវិតមិនមានសាច់ គេនោះត្រូវធ្វើការធ្ងន់ហើយត្រូវមានការព្យាយាមខ្ពស់ ឬ លះបង់ច្រើនដើម្បីធ្វើការងារងាយៗឱ្យបានសម្រេច ។ ក្រៅពីពួកគេអាចរកលុយបានដោយក្ដីលំបាកហើយ ពួកគេក៏មានការលំបាកក្នុងផ្នែកទំនាក់ទំនងដែរ ។



វាំងជីវិតឡើងឆ្អឹង

បើវាំងជីវិតទូលាយមានសាច់ហើយមានពណ៌ស្រស់ថ្លា គឺមានន័យថាគេម្នាក់នោះអាចសម្រេចគោលដៅផ្សេងៗបានដោយពុំចាំបាច់លះបង់ខ្ពស់ឡើយ ។ ដំណើរជីវិតប្រកបទៅដោយភាពរលូននិងធូរស្រាល ។ អ្នកដែលមានវាំងជីវិតទូលាយហើយមានសាច់ អាចទប់ទល់នឹងសភាពស្មុគស្មាញបានយ៉ាងល្អ ព្រោះពួកគេមើលពិភពលោកក្នុងផ្លូវវិជ្ជមាន ពួកគេច្រើនមានចិត្តបើកទូលាយ ដូច្នេះហើយទើបមានសមត្ថភាពអាចយកឈ្នះការលំបាក ឬ ដំណើរថយក្រោយផ្សេងក្នុងជីវិតរបស់ពួកគេបាន ។



វាំងជីវិតដែលមានសាច់



www.elibraryofcambodia.org

ម្យ៉ាងទៀត វាំងជីវិតនៅបានបង្ហាញឱ្យឃើញពីជីវិតគ្រួសាររបស់មនុស្សយើងទៀតផង ។ តើទំនាក់ទំនងដែលមនុស្សម្នាក់នោះមានចំពោះគ្រួសារនិងនៅក្នុងផ្ទះរបស់ពួកគេមានភាពល្អូកល្អិនឬទេ? វាំងជីវិតចង្អៀតបង្ហាញឱ្យឃើញពីជីវិតគ្រួសារស្ងប់ស្ងាត់ ( ផ្ទះដែលមានសភាពស្ងាត់ជ្រងំគ្មានជីវិតជីវ៉ា) ។

ចំណែកអ្នកដែលមានវាំងជីវិតទូលាយ ផ្តល់គុណតម្លៃដល់ជីវិតគ្រួសារហើយនឹងត្រឡប់ទៅផ្ទះទៅរកគ្រួសារដែលមានភាពកក់ក្តៅនិងយកចិត្តទុកដាក់ដោយមានការឯកភាពគ្នាជាចំបង ។

តែទោះជាយ៉ាងណាក៏ដោយ ក៏វាំងជីវិតពុំគួរមានលក្ខណៈទូលាយជ្រុលពេកដែរ ។

បើវាំងជីវិតមានទំហំធំជាងបីធ្នាប់ដៃ គេម្នាក់នោះនឹងមានចិត្តទូលាយហួស គេលែងមានក្តីទុក្ខកង្វល់អ្វីទាំងអស់ ។ គេមិនអាចមើលឃើញពីភាពសំខាន់នៃហេតុការណ៍ផ្សេងៗក្នុងជីវិតរបស់ពួកគេទេ ។ មនុស្សទាំងអស់នេះមិនអាចប្រាប់បានទេថាពេលណាស្ថានការណ៍ដល់ថ្នាក់ធ្ងន់ធ្ងរហើយត្រូវដោះស្រាយនិងពេលណាស្ថានការណ៍មិនដល់ថ្នាក់ស្លាប់ ។ ពួកគេតែងតែគ្មានគំនិតក្នុងការរៀបចំលុយកាក់ ហើយជាមនុស្សដែលមិនផ្តល់តម្លៃដល់ការសម្រេចខ្លួន ឬស្វែងរកចំណេះដឹង ។ ពួកគេភ្លេចឈឹងថាខ្លួនត្រូវចូលរួមក្នុងការអភិវឌ្ឍន៍ខ្លួន ជាពិសេសពួកគេជាមនុស្សចូលចិត្តដេកថ្ងៃ ។






www.elibraryofcambodia.org

បន្តទៅទៀតនេះគឺហេតុផលដែលពុំគួរធ្វើមុខតឹងតែង ទោះបីជាអ្នកកំពុងតែពិបាកចិត្តអាក់អន់ចិត្ត...គឺអ្នកគួរតែញញឹម ញញឹមឱ្យច្រើនតាមដែលអាចធ្វើទៅបាន។ ព្រោះថាការធ្វើមុខតានតឹងនឹងធ្វើឱ្យកើតស្នាមជ្រួញត្រង់វាំងជីវិតរបស់អ្នក (អ្នកអាចសាកល្បងធ្វើទៅមុខកញ្ចក់) ដែលបង្ហាញឱ្យឃើញពីជីវិតដែលមានតែរឿងក្ដៅក្រហាយធ្វើឱ្យកើតស្ត្រេសជាមនុស្សដែលមកដល់ផ្លូវបំបែកនៃអាជីពរបស់គេ។ ម្យ៉ាងទៀត មនុស្សដែលគិតច្រើនស្នាមជ្រួញត្រង់វាំងជីវិតនឹងបង្ហាញឱ្យឃើញពីភាពឯកោដែលមានន័យថាគេម្នាក់នោះកំពុងស្ថិតនៅក្រោមសម្ពាធផ្ទាំងថ្នាក់ចិត្ត សូម្បីតែមនុស្សជំនិត ឬ មនុស្សដែលគេស្រឡាញ់បំផុតក៏នៅមិនអាចយល់ចិត្តពួកគេបានដែរ។




ស្នាមជ្រួញរាងលេខ8របស់ចិន(八) ត្រង់វាំងជីវិត

សូម្បីតែស្នាមឆ្នូតមួយឆ្នូតដែលឆ្លងកាត់វាំងជីវិតក៏យើងមិនចង់បានដូចគ្នាដែរ លក្ខណៈនេះត្រូវ គេស្គាល់ក្នុងនាមជាម្ជុលចាក់ទម្លុះចិត្តមេឃ វាបង្ហាញឱ្យឃើញពីភាពឯកោនៃជីវិតគូស្រករដែលមិនល្អចំពោះមនុស្សស្រី។ ជាពិសេសម្ជុលចាក់ទម្លុះចិត្តមេឃបង្ហាញឱ្យឃើញពីការមិនមានស្វាមី ក្នុងភាពជាក់ស្តែងអ្នកនឹងបានជួបស្វាមី ឬ កូនរបស់អ្នកមិនញឹកញាប់ទេ ឬ ជួបដែរ ប៉ុន្តែអ្នកនឹងមិនមានភាពជិតស្និទ្ធនឹងពួកគេឡើយ។ បើមនុស្សប្រុសមានខ្សែត្រង់វាំងជីវិតនេះបង្ហាញឱ្យឃើញថា គេនឹងនៅឯកោ គេមិនមែនជាមនុស្សដែលស្រឡាញ់គ្រួសារទេ គេចំណាយពេលតិចតួចណាស់ជាមួយគ្រួសាររបស់គេ។


www.elibraryofcambodia.org



ម្ជុលចាក់ទម្លុះចិត្តមេឃ

វាំងជីវិតក៏ពុំគួរស្រុតដែរ  វាំងជីវិតដែលស្រុតបង្ហាញឱ្យឃើញថាជាមនុស្សឆាប់សោកសៅ ឬ ជាមនុស្សដែលត្រូវគេបញ្ឆោបានដោយងាយ ។ មនុស្សប្រភេទនេះតែងតែត្រចៀកស្រាល ហើយពេលប្រឈមនឹងឧបសគ្គគេតែងតែទន់ដៃទន់ជើងភ្លាម ។



វាំងជីវិតស្រុត



www.elibraryofcambodia.org

ក្នុងការប្រមើលមើលវាំងជីវិត អ្នកត្រូវប្រាកដក្នុងចិត្តថាអ្នកបានសង្កេតមើលគល់ចិញ្ចើមរួចហើយ។ រោមចិញ្ចើមត្រង់គល់ចិញ្ចើមមិនគួរចាក់ទៅខាងវាំងជីវិតទេ? តែគួរឡើងទៅខាងកន្ទុយចិញ្ចើម។

គល់ចិញ្ចើមដែលចាក់ទៅខាងវាំងជីវិតបង្ហាញឱ្យឃើញថាគេជាមនុស្សមិនសូវមានសមត្ថភាពសមស្របជាមួយនឹងអ្វីដែលពួកគេនិយាយថាអាចធ្វើបានឡើង។ ព្រោះតែគេមានមហិច្ឆិតាខ្ពស់ហួសពេក ហើយតែងតែធ្លាក់ចុះមកវិញដោយសារគោលបំណងនិងការចង់បានហួសពីសមត្ថភាពរបស់ខ្លួន។

រោមត្រង់គល់ចិញ្ចើមដែលចាក់ទៅខាងវាំងជីវិត





www.elibraryofcambodia.org

# វាំងអាជីព

វាំងអាជីពស្ថិតនៅត្រង់ពាក់កណ្តាលថ្ងាស គ្របដណ្តប់លើតំណែងទី 15, 19, 22, 25 និង28នៃផែនទី100ឆ្នាំ។ វាំងអាជីពប្រាប់ពីបញ្ហាទាក់ទងនឹងអាជីពតាមន័យឈ្មោះរបស់វា ប្រភេទនៃការងារដែលយើងអាចធ្វើបាន ប្រភេទនៃជំនួញដែលយើងអាចកាក់កបចម្រើនរុងរឿង ឬ ប្រភេទនៃបរិបទខាងអាជីពដែលយើងអាចទទួលយកវាបាន។




វាំងអាជីព

វាំងអាជីពធ្វើឱ្យយើងអាចប្រមើលមើលជោគជតាអាជីពរបស់មនុស្សបាន។ វាប្រាប់យើងថា យើងអាចសម្រេចបានទូវស្ថានភាពនិងតំណែងក្នុងជីវិត ក្នុងសង្គម ឬ ក្នុងក្រុមហ៊ុនបែបណា? គេម្នាក់នោះអាចធ្វើការងារក្នុងក្រុមហ៊ុនអន្តរជាតិ ឬ អង្គការអន្តរជាតិបានដែរឬអត់? ធ្វើជាបុគ្គលិករាជការទេ? ទាំងអស់នេះសុទ្ធតែមានបង្ហាញតាមរយៈការមើលវាំងអាជីពគួបផ្សំនិងវាំងមានបាន។



www.elibraryofcambodia.org

មនុស្សភាគច្រើនតែងតែយល់ឃើញថាវាលំបាកក្នុងការប្រាប់ថាថ្ងាសមួយខុសពីថ្ងាសមួយទៀតបានយ៉ាងដូចម្ដេច។ ការមើលទម្រង់មុខជាសិល្បៈនៃវត្ថុដែលខុសគ្នាតិចតួច ហើយមានការបង្កប់ន័យផ្សេងៗគ្នា ដូច្នេះអ្នកត្រូវស្វែងយល់ពីការមើលថ្ងាសក្រោមពន្លឺភ្លឺដែលខុសគ្នា ហើយនិងដោយមុំខុសគ្នាដែលអាចធ្វើឱ្យអ្នកមើលឃើញស្នាមខូង ផត ទូល និងសម្លាកបាន។ ឧទាហរណ៍ដូចជាការមើលលើផ្នែកខាងសមត្ថភាពជួយអ្នកឱ្យដឹងថាថ្ងាសនោះហុចមកខាងមុខ ឬ លឹបទៅខាងក្រោយ។

## ថ្ងាសខ្ពស់និងទាប

ចំណុចសំខាន់មួយសម្រាប់វាំងអាជីពគឺកម្ពស់ជាប្រការល្អ វាំងអាជីពគួរតែមានកម្ពស់ខ្ពស់ជានិច្ច។ តើធ្វើដូចម្ដេចទើបអាចដឹងថាថ្ងាសនោះខ្ពស់ឬអត់? ចូរមើលជើងសក់របស់អ្នក ហើយធ្វើការវាស់មើលថាតើវាមានទំហំប៉ុនប្រាំធ្នាប់ដៃឬអត់(រហូតដល់តំណែងទី28)? គ្រូមើលទម្រង់មុខចាត់ទុកថាថ្ងាសដែលមានទំហំតូចជាង៥ធ្នាប់ដៃជាថ្ងាសទាប។



ថ្ងាសទំហំ៥ធ្នាប់ដៃ



www.elibraryofcambodia.org

យើងចង់បានថ្ងាសដែលមានលក្ខណៈទូលាយហើយប្រាសចាកស្នាម ខ្វង ផត( ជាថ្ងាសដែលមិនប៉ោង ទូលមិនស្រុត ហើយមិនមានស្នាមសម្លាកត្រង់រាំងអាជីព) គួរជាថ្ងាស់ខ្ពស់ហើយស្មើ ។



កំពកត្រង់ថ្ងាស



ថ្ងាសដែលស្មើ

រាំងអាជីពដែលមានគុណភាពល្អគឺត្រូវខ្ពស់ហើយទូលាយ ពេលនេះអ្នកប្រហែលជាកំពុងគិតថាស្តាប់ទៅដូចរាំងជីវិតដែរមែនទេ? មែនហើយ រាំងជីវិតនិងរាំងអាជីពនោះវានៅជាមួយគ្នា រាំងជីវិតចង្អៀតមានន័យថារាំងអាជីពក៏ចង្អៀតដែរ បើរាំងអាជីពចង្អៀតវាក៏មានន័យថារាំងជីវិតក៏ចង្អៀតដែរ ។

បើអ្នកមានរាំងអាជីពខ្ពស់ អ្នកអាចក្លាយជាអ្នកនយោបាយដែលទទួលបានភាពជោគជ័យ ឬ តោងជណ្តើរក្រុមហ៊ុនឡើងទៅរហូតដល់តំណែងកំពូលនៃក្រុមហ៊ុនបាន ។ ចូរអ្នកក្រឡេកមើលទៅមនុស្សខ្លះដូចជា ចចប៊ូស ប៊ីលគ្លីនតុន សុទ្ធតែមានថ្ងាសខ្ពស់ហើយទូលាយ សូម្បីតែអាណុល ឆ្វារណិកកឺក៏មានថ្ងាសខ្ពស់ដែរ ដូច្នេះហើយទើបពួកគាត់ចូលប្រឡូកក្នុងវិស័យនយោបាយបានយ៉ាងជោគជ័យ ។ ទាំងនេះគឺអាស្រ័យលើរាំងអាជីពដែលមានលក្ខណៈស្មើហើយល្អ ។



www.elibraryofcambodia.org

តែបើថ្ងាសរបស់អ្នកកំពក ឬ មិនរាបស្មើច្រើនប៉ុនណោ អ្នកនឹងជួបនូវឧបសគ្គផ្សេងៗក្នុងពេលធ្វើការងារច្រើនប៉ុណ្ណោះដែរ។ ជាទូទៅអ្នកដែលធ្វើការងាររដ្ឋ ឬ ជាអ្នកនយោបាយបាននោះ ចាំបាច់ត្រូវមានថ្ងាសទូលាយ ហើយមានលក្ខណៈជ្រុង។ បើអ្នកចង់បានត្រឹមតែជា C.E.O (ស៊ីអ៊ីអូ) ឬ អ្នកជំនួយការរបស់អង្គការធំ ការមានថ្ងាសខ្ពស់ល្មមហើយមូលក៏អាចធ្វើបានដែរ។

ចំណែកអ្នកដែលមានថ្ងាសទាបហើយរាំងអាជីពទាបមិនមែនមានន័យថាគេម្នាក់នោះមិនឆ្លាត ឬ ខួរក្បាលអន់នោះទេ គ្រាន់តែថាពួកគេពុំគួរគិតគូរអំពីការងាររដ្ឋ ឬ កិច្ចការនយោបាយទេ។

ថ្ងាសទាបគឺមានន័យថាគេជាមនុស្សធ្វើការប្រភេទប្រើកម្លាំងកាយមិនមែនជាការងារប្រើសតិបញ្ញាទេ។ ការងារប្រភេទប្រើកម្លាំងកាយធ្វើឱ្យពួកគេទទួលបានលទ្ធផលល្អជាងប្រភេទការងារប្រើសតិបញ្ញា។ ប៉ុន្តែសូមចងចាំផងថាការប្រើកម្លាំងកាយសុទ្ធសាធអាចធ្វើឱ្យពួកគេក្លាយជាពលករដែលមិនអាចងើបក្បាលរួចអស់មួយជីវិត។



ថ្ងាសទាប



www.elibraryofcambodia.org

# លឿន ឬ យឺត? សង្កេតមើលត្រង់ថ្ងាស

ថ្ងាសមិនគ្រាន់តែប្រាប់យើងអំពីប្រភេទនៃអាជីពដែលគេម្នាក់នោះអាចធ្វើបានប៉ុណ្ណោះទេ តែវាជាគ្រឿងជំនួយក្នុងការចង្អុលបង្ហាញអំពីប្រភេទនៃការងារដែលគេអាចធ្វើបានទៀតផង។




អ្នកដែលមានថ្ងាសពើងតែងតែគិតអ្វីយឺតៗ បើថ្ងាសពើងតែចង្កាក្រពឹត នោះគេជាមនុស្សគិតយឺតតែធ្វើលឿន។ មនុស្សប្រភេទនេះត្រូវចំណាយពេលរាប់អាទិត្យទើបអាចសម្រេចចិត្តបាន តែគេនឹងធ្វើតាមនូវអ្វីដែលគេបានសម្រេចចិត្តហើយបានយ៉ាងឆាប់រហ័សនិងជោគជ័យជាទីគាប់ចិត្ត។



www.elibraryofcambodia.org

ថ្ងាសពើងតែចង្កាក្រពីត



បើថ្ងាសជាថ្ងាសពើង ថ្ងាសហុចនិងចង្កាហុចនោះជាទម្រង់មុខរបស់មនុស្សសម្ញែក។ គេជាមនុស្សគិតយឺត ធ្វើការយឺត គឺយឺតដូចខ្យងដើរ។

តែបើថ្ងាសក្រពីតមិនហុច នោះបង្ហាញឱ្យឃើញថាគេ ជាមនុស្សគិតលឿនតែពុំសូវបានលទ្ធផលល្អប៉ុន្មានទេ។



ថ្ងាសពើងនិងចង្កាហុច



ថ្ងាសនិងចង្កាក្រពីត



www.elibraryofcambodia.org

ចំណេះដឹងនេះមានប្រយោជន៍ជាពិសេសសម្រាប់អ្នកធ្វើការលក់ដូរនិងការងារទីផ្សារ ព្រោះអតិថិជនខ្លះចង់បានពេលសម្រាប់គិតច្រើនដងមុននឹងសម្រេចចិត្តទិញ។ ដូច្នេះហើយទើបអ្នកចាំបាច់ត្រូវផ្តល់ពេលវេលាឱ្យពួកគេគិតហើយអ្នកមិនត្រូវបង្ខាប់ពួកគេទេ បើមិនដូច្នេះទេអ្នកអាចនឹងបាត់បង់អតិថិជននេះបាន។ ចំណែកឯអតិថិជនខ្លះវិញជាអ្នកទិញដែល "សម្រេចចិត្តភ្លាមៗ" បើអ្នកទុកពេលឱ្យគេពិចារណា នោះពួកគេអាចនឹងបាត់បង់ចំណាប់អារម្មណ៍។ តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យដឹងថាគេជាមនុស្សប្រភេទណា? គ្រាន់តែសង្កេតមើលត្រង់ថ្ងាសនិងចង្ការបស់ពួកគេទៅក៏បានទៅហើយ អ្នកទិញដែលសម្រេចចិត្តពន្យារពេលគិតគឺមានថ្ងាសពើងនិងចង្កាហុច។

ចំណែកឯថ្ងាសដែលមានសរសៃឈាមលេចចេញមកនោះគឺបង្ហាញឱ្យឃើញពីសតិបញ្ញាខ្ពស់។ ពេលមានសរសៃឈាមផុសឡើងត្រង់វាំងអាជីពដោយមិនមានបង្ហាញឱ្យឃើញត្រង់តំណែងផ្សេងៗទេនោះ ជាធម្មតាអ្នកទាំងនោះច្រើនជាមនុស្សអរូបិយនិយមដែលចូលចិត្តសិក្សាពីបញ្ហាសាសនា ដូចជាទៅរៀននៅសាលាសាសនាជាដើម។



សរសៃឈាមពណ៌បៃតងលេចចេញ

លោកអ្នកដែលជាឪពុកម្តាយទាំងឡាយ អ្នកត្រូវប្រយ័ត្នប្រយែងកុំធ្វើឱ្យខូច ឬ ប៉ះពាល់ថ្ងាសកូនព្រោះស្នាមសម្លាកត្រង់ថ្ងាសបង្ហាញឱ្យឃើញពីភាពអន្តរាយចំពោះមុខអាជីព។ ស្នាមកំពកត្រង់ថ្ងាសបង្ហាញឱ្យឃើញពីឧបសគ្គផ្សេងៗនិងភាពថយក្រោយនៃដំណើរក្នុងមុខរបរ។



www.elibraryofcambodia.org

ពេលអ្នកមើលថ្ងាសរបស់អ្នកនៅមុខកញ្ចក់ អ្នកត្រូវប្រាកដក្នុងចិត្តថា សាច់ត្រង់ថ្ងាសស្រស់ថ្លា ហើយស្បែកក៏ស្រស់បស់ដែរ ។ ស្បែកដែលក្រិន ឬ ស្ងួតនៅត្រង់ថ្ងាសបង្ហាញឱ្យឃើញថាមានបញ្ហាក្នុងមុខអាជីព ។ ស្នាមជាំ ឬ ខ្មៅក៏មិនល្អដែរព្រោះវាបង្ហាញឱ្យឃើញថាអ្នកកំពុងប្ដូរការងារ ឬ អ្វីដែលអាក្រក់ជាងនេះទៅទៀតនោះគឺអ្នកកំពុងតែត្រូវគេបណ្ដេញចេញពីការងារ ។

អ្នកគ្រប់គ្រង ឬ អ្នកជំនួញត្រូវមានថ្ងាសបែបណា? អ្នកគ្រប់គ្រងដែលមានការគិតច្នៃប្រឌិតខ្ពស់តែងតែមានថ្ងាសពេញហើយទូលាយ ថ្ងាសខ្ពស់ពុំមានភាពចាំបាច់ទេព្រោះអ្នកគ្រប់គ្រងទាំងអស់ពុំចាំបាច់ធ្វើជា C.E.O (ស៊ីអ៊ីអូ) ឱ្យក្រុមហ៊ុនខ្លួនឯងទេ ។ អ្នកអាចសាកល្បងសង្កេតមើលថ្ងាសរបស់អ្នកបង្កើតក្រុមហ៊ុនយ៉ាហ៊ូ ឬ ហ្គូហ្គលបាន... ។ តែអ្នកគ្រប់គ្រងនិងអ្នកជំនួញតែងតែមានថ្ងាសទូលាយ ហើយអ្វីដែលសំខាន់បំផុតនោះគឺថ្ងាសមានសាច់ព្រោះវាបង្ហាញឱ្យឃើញពីបំនិនក្នុងការប្រតិបត្តិ សមត្ថភាពក្នុងការបង្កើតបណ្ដាញលក់ អ្នកគាំទ្រ និងការមានមិត្តភក្តិស្ថិតនៅតំណែងខ្ពស់ ។



ថ្ងាសខ្ពស់ ទូលាយ ហើយពេញ

តើអ្នកនៅចាំបានទេថាក្នុងវគ្គនេះអ្នកអាចមើលឃើញបានតែវត្ថុដែលមើលបានច្បាស់លើទម្រង់មុខតែប៉ុណ្ណោះ ដូច្នេះហើយទើបអាចទៅរួចបំផុតនោះគឺស្នាមកំពក ស្នាមក្រពឹតតូចៗ និងខ្សែផ្សេងៗទាំងអស់នេះបានផ្តល់ផលប៉ះពាល់ចំពោះគុណភាពនៃថ្ងាសទាំងអស់ ។ អ្វីទាំងអស់នេះមានលក្ខណៈបង្កប់ខ្លាំង ហើយអ្នកចាំបាច់ត្រូវត្រួតមើលឱ្យបានយ៉ាងជិតដល់បំផុតដើម្បីមើលឱ្យដឹងថាមានអ្វីទាំងអស់នេះត្រង់ថ្ងាសឬអត់ ។ លក្ខណៈមួយទៀតដែលគួរពិចារណាគួបផ្សំនឹងថ្ងាសនោះគឺរាំងមានបាននិងរាំងជីវិត ។



www.elibraryofcambodia.org

## វាំងមានបាន

អ្នករាល់គ្នាតែងតែចង់ដឹងពីបញ្ហាលុយនិងភាពសប្បាយ ។ ក្នុងការមើលទម្រង់មុខនេះ ក្រោយពីអ្នកបានស្វែងយល់អំពីភាពខុសគ្នាតិចតួចតាមរយៈការពិនិត្យមើលវាំងមានបានហើយ អ្នកស្ទើរតែអាចប្រាប់បានភ្លាមថានរណាខ្ជិលច្រអូសនិងនរណាមិនមានបានភ្លាមដោយគ្រាន់មើល ត្រង់ច្រមុះ! ចុងច្រមុះ! ស្លាបច្រមុះ! រន្ធច្រមុះ! និងត្រូវចាប់អារម្មណ៍លើខ្នង់ច្រមុះក្នុងកម្រិតមួយ ។



មនុស្សភាគច្រើនតែងតែគិតថាច្រមុះធំបង្ហាញឱ្យឃើញអំពីការក្លាយជាអ្នកមានដល់កំពូល តែនេះមិនគួរជាហេតុផលដែលធ្វើឱ្យអ្នកទៅធ្វើច្រមុះឱ្យធំនោះទេ ព្រោះបើវាមិនសមស្របនឹងទម្រង់មុខរបស់មនុស្សនោះក៏គ្មានប្រយោជន៍ដែរ ។ អ្នកមិនអាចប្តូរច្រមុះធំរបស់មនុស្សម្នាក់ទៅបិទនឹងទម្រង់មុខទំហំតូចរបស់មនុស្សម្នាក់ទៀតបានទេ ។ ច្រមុះមានទំហំធំគឺពេលប្រៀបធៀបជាមួយលក្ខណៈផ្សេងៗទៀតលើទម្រង់មុខរបស់បុគ្គលនោះផ្ទាល់ ។

## ច្រមុះល្អ បារមីគឺពាក្យគន្លឹះ

ផ្នត់គំនិតពីបញ្ហា "បារមី" ជាប្រការដែលពិបាកនឹងអធិប្បាយ ។ ក្នុងភាសាចិនពាក្យថា "បារមី" គេហៅថា "ឈីសី" ។

វិធីដែលល្អបំផុតក្នុងការស្វែងយល់លើអត្ថន័យរបស់ច្រមុះដែលមាន "បារមី" គឺសម្លឹងមើលរូបរបស់មនុស្សដែលមានទ្រព្យដូចជាបៀលហ្គេតជាដើម ដែលអាចធ្វើឱ្យអ្នកអាចបែងចែកបានដោយងាយស្រួល ។



www.elibraryofcambodia.org

ជាដំបូងសូមយើងពិនិត្យមើលទម្រង់របស់ច្រមុះជាមុនសិន។ ច្រមុះល្អមិនមែនជាច្រមុះក្រពឹតទេ ច្រមុះល្អត្រូវមានលក្ខណៈក្រាស់ទូលាយហើយមើលទៅមាំមួន ច្រមុះល្អក៏មិនត្រូវឡើងឆ្អឹងឡើយ ចុងច្រមុះគួរតែងុំបស្រួចដូចកណ្ដៀវ ។

យើងចង់ឱ្យច្រមុះមានសាច់មិនធាត់ក្រាស់ ។ ច្រមុះដែលមានសាច់បង្ហាញឱ្យឃើញថាជាមនុស្សចូលចិត្តធ្វើខ្លួនតាមសប្បាយនិងមិនចូលចិត្តធ្វើបាបគេឯងឡើយ ។



ច្រមុះស្តើង

ផ្ទុយទៅវិញ អ្នកដែលមានច្រមុះស្តើងជាមនុស្សអាត្មានិយម ហើយចូលចិត្តចងអាឃាត ឬ កើតមានអារម្មណ៍មិនល្អចំពោះអ្នកដទៃបានដោយងាយ មនុស្សច្រមុះស្តើងតែងតែគិតពីប្រយោជន៍របស់ខ្លួន ។ មនុស្សច្រមុះស្តើងអាចជាមនុស្សគ្មានសមត្ថភាពក្នុងការសន្សំលុយទេ និងអាចជាមនុស្សក្រលំបាកទៀតផង ។

ចុងច្រមុះជំនួសឱ្យសមត្ថភាពដែលអាចសាងភាពមានបាន ចំណែកស្លាបច្រមុះជំនួសឱ្យសមត្ថភាពក្នុងការរកលុយ ។ ចុងច្រមុះគួរតែមូល ដែលបង្ហាញឱ្យឃើញពីសមត្ថភាពដ៏ខ្លាំងដែលអាចធ្វើឱ្យខ្លួនមានបាន ។ ចូរអ្នកមើលច្រមុះបៀលហ្គេត អ្នកនឹងឃើញថាចុងច្រមុះរបស់គាត់មូលស្អាត ច្រមុះរបស់គាត់មិនធំក្រាស់ ឬ ជាដុំៗទេ តែវាស្រួចស្អាតដោយត្រង់ចុងច្រមុះមូល ។ ចូរអ្នកមើលរូបភាពដែលដាក់ភ្ជាប់លើទម្រង់ជំនួសឱ្យច្រមុះ ច្រមុះដែលមានបារមីគឺយ៉ាងនេះឯង ។



ច្រមុះដែលដុះហើយមានសាច់



www.elibraryofcambodia.org

ច្រមុះដែលល្អមិនត្រឹមតែស្ថិតលើទម្រង់ប៉ុណ្ណោះទេ តែត្រូវមានពណ៌និងស្បែកល្អទៀតផង ។ ស្បែកច្រមុះមានខ្ទាញ់រលោងតិចតួចក៏មិនអ្វីដែរ តែយើងមិនចង់ឱ្យច្រមុះមានខ្លាញ់រលើបពេកនោះទេ នេះបង្ហាញឱ្យឃើញថាវាំងមានបានត្រូវចោះ ។ ពេលវាំងមានបានត្រូវចោះនោះ ភាពមានបានរបស់អ្នកនឹងហូរទៅបាត់ទៅតាមនោះដែរ ។

សម្លាកត្រង់ច្រមុះ

អ្នកខ្លះមានខ្សែតូចច្រើនខ្សែដែលយើងអាចមើលឃើញបានច្បាស់ ។ ត្រង់ច្រមុះរបស់ពួកគេ ឬ ស្នាបច្រមុះរបស់ពួកគេមានខ្សែព្រំដែនមួយដែលអាចមើលឃើញច្បាស់ដូចនៅក្នុងរូបនេះ ។ គេមានតំរុយក្នុងការអាចរកលុយបានច្រើន តែមិនមានសមត្ថភាពក្នុងការសន្សំ ពួកគេជាមនុស្សត្បិតត្បៀត ជួនកាលពួកគេជាអ្នកមានតែជំពាក់បំណុលគេ ។



ខ្សែព្រំដែនស្នាបច្រមុះ

ក្នុងការប្រមើលច្រមុះ អ្នកក៏ត្រូវមើលត្រង់រន្ធច្រមុះដូចគ្នាដែរ ពេលមើលពីខាងមុខរបស់គេមិនគួរមើលឃើញរន្ធច្រមុះ ។ រន្ធច្រមុះដែលអាចមើលឃើញពីខាងមុខ ( ដោយសាររន្ធច្រមុះងើយ) បង្ហាញឱ្យឃើញថាវាំងមានបានជ្រុះ អ្នកដែលមានរន្ធច្រមុះងើយនោះគ្មានសមត្ថភាពក្នុងការសន្សែសន្សំប្រាក់ទេ ព្រោះគេតែងតែចាយវាយដោយខ្ជះខ្ជាយដោយពុំដឹងខ្លួន។ ច្រមុះដែលមើលមិនឃើញរន្ធ ពេលមើលចំពីមុខបង្ហាញឱ្យឃើញថាវាំងមានបានរឹងមាំទទួលបានការគ្រប់គ្រងនិងការការពារលុយកាក់បានល្អ ។



www.elibraryofcambodia.org





ពេលមើលចំពីខាងមុខមើលឃើញរន្ធច្រមុះ

ពេលមើលចំពីខាងមុខមើលមិនឃើញរន្ធច្រមុះ

ច្រមុះត្រូវយកមកពិចារណាគួបផ្សំនឹងថ្ពាល់ ថ្ពាល់ធំហើយទូលាយអាចធ្វើឱ្យច្រមុះធំមើលទៅឃើញថាតូចបាន ឬ វាអាចត្បៀតច្រមុះដែលជាហេតុធ្វើឱ្យមើលឃើញតូច ។



ថ្ពាល់ត្បៀតច្រមុះ



www.elibraryofcambodia.org

# ច្រមុះដែលមានស្វាមីល្អ

ច្រមុះរបស់មនុស្សស្រីជំនួសឱ្យស្វាមីរបស់ពួកនាង។ បើច្រមុះរបស់ពួកនាងមានបញ្ហាជាធម្មតានាងនឹងមានបញ្ហាទាក់ទងនឹងស្វាមី ឬ ជីវិតគូស្រករ។ ប្រជ្រុយ ឬ ស្នាមដៅត្រង់ច្រមុះជាសញ្ញាដែលមិនសូវល្អសម្រាប់សុភាពនារី ព្រោះប្រជ្រុយលើច្រមុះមិនត្រឹមតែបង្ហាញឱ្យឃើញពីបញ្ហាផ្នែកសុខភាពប៉ុណ្ណោះទេ វាថែមទាំងប្រាប់ឱ្យដឹងពីភាពមានអ្នកទីបីក្នុងជីវិតគូស្រករទៀតផង។

នៅលើផ្ទៃមុខរបស់មនុស្សស្រី ច្រមុះជំនួសឱ្យ "ផ្កាយស្វាមី" របស់នាង មនុស្សស្រីដែលនឹងមានស្វាមីល្អ នោះច្រមុះត្រូវមានសាច់ហើយខ្នង់ច្រមុះមានបារមី។

តើច្រមុះមានបារមីជាច្រមុះដូចម្តេច? ច្រមុះមានបារមីគឺច្រមុះដែលមានខ្នង់ច្រមុះកម្ពស់មធ្យមហើយមិនលិច ឬ ប៉ោងហួស ខ្នង់ច្រមុះដែលមានបារមីបង្ហាញឱ្យឃើញពីស្វាមីដែលមានសមត្ថភាព។



ខ្នង់ច្រមុះខ្ពស់



ខ្នង់ច្រមុះទាប



www.elibraryofcambodia.org



មនុស្សស្រីដែលច្រមុះមានបារមី



មនុស្សស្រីដែលមានច្រមុះតូច

ក្នុងជីវិតគ្រួសារជនជាតិចិន អ្វីដែលសំខាន់នោះគឺការដែលមនុស្សស្រីបានរៀបការជាមួយស្វាមីដែលមានសមត្ថភាពអាចមើលថែនាងបាន ។ ក្នុងសង្គមចិន មនុស្សស្រីដែលមានគុយឈី (ម្សៅជំនួយ) ដែលអាចប្រែបានថាជារស្មីនៃសោភ័ណតី ពេលនាងមានស្វាមីដែលមានទ្រព្យល្មម ហើយស្រឡាញ់នាង មើលថែនាង និងគ្រួសាររបស់នាងបានល្អ អាចធ្វើឱ្យនាងមានជីវិតរស់នៅបែបសប្បាយៗបាន ។

ជាទូទៅមនុស្សស្រីដែលមានច្រមុះតូចតែងតែក្លាយជាភរិយាទី២ ឬ ភរិយាលួចលាក់របស់គេ ។ មនុស្សស្រីដែលខ្ទង់ច្រមុះមានសាច់មិនគ្រហ៊ុប ហើយមិនមានឆ្អឹងផុស ព្រមទាំងមានចុងច្រមុះមូល និងស្លាបច្រមុះដែលមើលឃើញបានច្បាស់តែងតែនៅប្រទះនឹងបុរសដែលសម្បូរលុយ ។ ទោះបីថាមនុស្សស្រីទាំងអស់នោះមិនសូវស្អាតអស្ចារ្យដូចបវរកញ្ញាទាំងឡាយក៏ដោយ តែពួកនាងនឹងក្លាយជាអ្នកមានសំណាង ។

អ្នកប្រហែលជាឆ្ងល់ហើយថា យើងរំលងចំណុចនៃភាពមានបានទៅរកចំណុចរឿងស្វាមីបានទៅវិញ? សុភាពបុរសទាំងឡាយ ច្រមុះរបស់ភរិយាអ្នក (ឬ មិត្តស្រីរបស់អ្នក) គឺជាកញ្ចក់ឆ្លុះបង្ហាញពីអ្នកដែរ បើនាងមានច្រមុះមិនល្អ នោះមានន័យថាអ្នកដែលជាស្វាមីរបស់នាងមិនអាចកើតមានទ្រព្យច្រើនបានទេ បើច្រមុះរបស់នាងល្អ នោះវាមានន័យថាសំណាងល្អ ហើយអ្នកជាស្វាមីរបស់នាងក៏មានទ្រព្យសម្បត្តិដែរ ។

បើអ្នកជាបុរសដ៏ឈ្លាសវៃ អ្នកគួរជ្រើសរើសយកមនុស្សស្រីដែលមានច្រមុះត្រឹមត្រូវ (តែពុំចាំបាច់ល្អពេកទេ) ដើម្បីឱ្យខ្លួនអ្នកអាចក្លាយជាអ្នកមានបាននាពេលអនាគត ។



www.elibraryofcambodia.org

## វាំងផ្ទះសំបែង

វាំងផ្ទះសំបែងជំនួសឱ្យទ្រព្យសម្បត្តិនិងដីធ្លីរបស់អ្នក អ្វីដែលសំខាន់ជាងគេនោះគឺវាជំនួសឱ្យផ្ទះសំបែងរបស់អ្នកឬទីកន្លែងដែលអ្នករស់នៅ ថាតើអ្នករស់នៅក្នុងផ្ទះដែលមានសេចក្ដីសុខសប្បាយឬអត់? ផ្ទះនោះស្អាតមានតម្លៃថ្លៃឬអត់? ផ្ទះរបស់អ្នកមានបញ្ហាទុយោទឹក ឬ មានបញ្ហាតូចតាចជាច្រើនទាក់ទងគ្នាយ៉ាងណា? ការនេះវាសុទ្ធតែបង្ហាញអ្នកឱ្យដឹងតាមរយៈវាំងទ្រព្យសម្បត្តិ។

វាំងទ្រព្យសម្បត្តិក៏ដូចជាលក្ខណៈផ្សេងៗទៀតនៃទម្រង់មុខដែរ គឺយើងត្រូវមើលវាដោយភ្ជាប់ជាមួយនឹងវាំងមួយទៀតគឺវាំងមានបានដែលធ្វើឱ្យយើងចំណាំបានថា យើងជាម្ចាស់នៃទ្រព្យតិច ឬ ច្រើនប៉ុណ្ណានៅក្នុងជាតិនេះ។

វាំងទ្រព្យសម្បត្តិនៅចន្លោះភ្នែកនិងចិញ្ចើម យើងចង់បានវាំងទ្រព្យសម្បត្តិដែលទូលាយហើយច្បាស់លាស់ ព្រោះវាបង្ហាញឱ្យឃើញថាអ្នកនឹងមានផ្ទះល្អមួយពុំមានបញ្ហា ហើយជាផ្ទះដែលមានភាពសុខដុមរមនាគួរឱ្យចង់រស់នៅ។






www.elibraryofcambodia.org

## តើវាំងទ្រព្យសម្បត្តិប្រាប់អ្វីខ្លះដល់យើង?

យើងអាចមើលវាំងទ្រព្យសម្បត្តិបានយ៉ាងងាយដូចតទៅនេះ បើវាំងទ្រព្យសម្បត្តិចង្អៀតមានន័យថាចន្លោះរវាងភ្នែកនិងចិញ្ចើមវាចង្អៀត។ វាំងទ្រព្យសម្បត្តិចង្អៀតបង្ហាញថាគេទាំងអស់នោះអាចរស់នៅយ៉ាងមានសេចក្តីសុខក្នុងផ្ទះល្វែង ឬ ខុនដូ។ បើវាំងទ្រព្យសម្បត្តិមានផ្ទៃធំទូលាយគឺមានន័យថាគេម្នាក់នោះចូលចិត្តរស់នៅក្នុងផ្ទះធំ( ផ្ទះវិឡា ឬ ភូមិគ្រឹះ)គឺគេចង់និងអាចរស់នៅក្នុងផ្ទះមួយខ្នងដែលមានដីដំណាំជុំវិញ ឬ មានសួនដំណាំនៅក្រោយផ្ទះ។

ចង្អៀត





ទូលាយ

វាំងទ្រព្យសម្បត្តិចង្អៀត

វាំងទ្រព្យសម្បត្តិទូលាយ

បើរោមចិញ្ចើមធ្លាក់ចុះទៅរកវាំងទ្រព្យសម្បត្តិ ឬ ប៉ះវាំងទ្រព្យសម្បត្តិគឺមានន័យថាមានទ្រព្យសម្បត្តិតិច បើមនុស្សមានលក្ខណៈបែបនេះយើងនឹងស្គាល់ក្នុងនាម"ស្មៅវែងបាំងភ្នែក" តើមានអ្វីកើតឡើងជាមួយស្មៅដែលដុះឡើងខ្ពស់ ឬ វែងនោះ? មានន័យថាគេទាំងនោះមិនគ្រាន់តែមានវាំងទ្រព្យសម្បត្តិទាបតែប៉ុណ្ណោះទេ គឺពួកគេនៅជល់ពិដានកញ្ចក់នៅកន្លែងធ្វើការរបស់ ឬ ត្រូវតែជាន់ពន្លិចរហូតក្នុងពេលដែលខ្លួនកំពុងតែឡើងតំណែងមុខរបរ។



www.elibraryofcambodia.org

ជាទូទៅការមានទ្រព្យសម្បត្តិតិចមិនមែនជាការល្អសម្រាប់មនុស្សប្រុសនោះទេ។ ចិញ្ចើមទាបជាពិសេសគឺចិញ្ចើមដែលមើលទៅដូចគេសង្កត់ដួងជតាបង្ហាញឱ្យឃើញថាជាមនុស្សប្រុសដែលខ្លាចភរិយា ឬ ត្រូវភរិយាគាបសង្កត់ អ្នកអាចសួរថាតើច្បាប់នេះមានចំណុចលើកលែងដែរឬអត់? មាន! បើភ្នែកជ្រៅបន្តិច ភ្នែកវែង ឬ កែវភ្នែកមាន "ព្រលឹង" ល្អមាំទាំល្អ។



ភ្នែកដែលត្រូវចិញ្ចើមសង្កត់

ស្នាមជាំត្រង់បរិវេណជុំវិញភ្នែកនិងត្រង់វាំងទ្រព្យសម្បត្តិបង្ហាញឱ្យឃើញថាក្នុងផ្ទះមិនសូវមានសេចក្តីសុខ មិនមានសេចក្តីសុខផ្លូវចិត្តនៅក្នុងផ្ទះ ហើយមានបញ្ហាផ្ទៃក្នុងនិងក្នុងផ្ទះជាច្រើន។



ភ្នែកលិច ឬ ភ្នែកជ្រៅនិងស្នាមជាំត្រង់វាំងទ្រព្យសម្បត្តិ



www.elibraryofcambodia.org

# វាំងសុខភាព

វាំងសុខភាពគ្របដណ្តប់ពាក់កណ្តាលនៃខ្នង់ច្រមុះ តាមរយៈតំណែងទី44និង45នៃផែនទី100ឆ្នាំ តំណែងទាំងពីរនេះផ្សំគ្នាបានជាវាំងសុខភាព។ វាំងសុខភាពមិនត្រឹមតែទាក់ទងនឹងសុខភាពរបស់អ្នកនោះទេ វាថែមទាំងទាក់ទងនឹងសុខភាពរបស់អ្នកដែលនៅក្នុងផ្ទះរបស់គេទៀតផង។



វាំងសុខភាព

យើងមិនចង់ឱ្យមានខ្សែមកឆ្លងកាត់វាំងសុខភាពត្រង់តំណែងទី44និង45ទេមិនថាជាខ្សែបណ្តោយ ឬ ខ្សែទទឹងឡើយ។ បើមានខ្សែបណ្តោយ ឬ ខ្សែទទឹងកាត់ច្រមុះក្នុងពេលដែលគេម្នាក់នោះញញឹម វាបង្ហាញឱ្យឃើញពីបញ្ហាសុខភាពដែលកើតឡើងជាប្រចាំដោយជាទូទៅចំពោះអ្នកដែលមានខ្នង់ច្រមុះទាប (តំណែងទី41) មានទំនោរងាយធ្លាក់ខ្លួនឈឺញឹកញាប់ជាងអ្នកដែលមានខ្នង់ច្រមុះខ្ពស់ ព្រោះជាទូទៅអ្នកដែលមានខ្នង់ច្រមុះខ្ពស់មានសុខភាពមាំទាំជាង។

ខ្សែទៅចំវាំងសុខភាព





www.elibraryofcambodia.org

ពេលដែលយើងមើលត្រង់វាំងសុខភាព គួរចាប់អារម្មណ៍ត្រង់ខ្នង់ច្រមុះផងដែរ ។ បើខ្នង់ច្រមុះស្តើងត្រង់ផ្នែកខាង១នៃខ្នង់ច្រមុះ វាបង្ហាញឱ្យឃើញពីបញ្ហាឆ្អឹងខ្នង ។ បើច្រមុះរបស់អ្នកមានចេញសរសៃឈាមក្រហម ឬ មានសរសៃឈាមក្រហមច្រើនចេញត្រង់ច្រមុះរបស់អ្នកនោះ វាបង្ហាញឱ្យឃើញពីបញ្ហាដែលទាក់ទងនឹងឈាម ។ បើមានកំពកលើច្រមុះត្រង់វាំងសុខភាពនោះ វាបង្ហាញថាគេនោះមានបញ្ហាទាក់ទងនឹងប្រព័ន្ធប្រដាប់រំលាយអាហារ ។



ស្នាមជាំខាង១ខ្នង់ច្រមុះ

អ្នកមើលទម្រង់មុខតែងតែមើលច្រើនតំណែងបញ្ចូលគ្នាដើម្បីឱ្យទទួលបាននូវលក្ខណៈច្បាស់លាស់នៃស្ថានការណ៍ ។ ឧទាហរណ៍ដូចជាក្នុងពេលដែលយើងកំពុងតែពិចារណាលើបញ្ហាសុខភាព បើយើងមើលឃើញបញ្ហាត្រង់វាំងសុខភាព វាំងធ្វើដំណើរមានស្នាមជាំ ហើយចិញ្ចើមក៏សដែរនោះ បង្ហាញឱ្យឃើញពីឱកាសដែលអាចមានគ្រោះថ្នាក់ចរាចរណ៍ច្រើន ជួនកាលយើងអាចមើលលើពណ៌ ឬ គុណភាពនៃពណ៌ត្រង់ច្រមុះ ។ តើអ្នកដឹងទេថាយើងអាចមើលឃើញពីភាពខុសគ្នានៃពណ៌សំណាងនៅលើផ្ទៃមុខបាន? ពណ៌ស្រគាំ ឬ ពណ៌ខ្មៅបង្ហាញឱ្យឃើញពីបញ្ហាសុខភាព ជាពិសេសបើវាបង្ហាញចេញត្រង់ច្រមុះ ។

ការបែងចែកពណ៌ពុំមែនជាការងាយនោះទេគឺត្រូវពឹងលើការសង្កេតនិងការព្យាយាមយ៉ាងខ្លាំង ។ អ្នកមិនចាំបាច់ខ្វល់ខ្វាយពេកទេបើអ្នកមើលពណ៌មិនយល់ ព្រោះសម្រាប់ការមើលទម្រង់មុខ អ្នកត្រូវសង្កត់ធ្ងន់ទៅលើអ្វីដែលអ្នកអាចមើលឃើញ មិនមែនសង្កត់ធ្ងន់លើអ្វីដែលអ្នកមើលមិនឃើញនោះទេ ។



www.elibraryofcambodia.org

## ថ្ពាល់គូស្រករ

ក្នុងផ្នែកនេះយើងខ្ញុំនឹងបង្ហាញចំណុចលម្អិត ស៊ីជម្រៅចូលឱ្យដល់ក្នុងថ្ពាល់គូស្រករ របស់បុរសនារីគ្រប់រូប ។

## សម្រាប់នារី

ច្រមុះរបស់សុភាពនារីមានថ្ពាល់ត្រួតគ្នាពីរ គឺថ្ពាល់មានបាននិងថ្ពាល់គូស្រករ ។ នៅសម័យមុន មនុស្សស្រីមិនធ្វើការទេ ពួកនាងរស់នៅចាយលុយដោយសារស្វាមី ។ ទោះបីជាបច្ចុប្បន្ននេះនារីសម័យថ្មីភាពច្រើនចូលចិត្តចេញទៅធ្វើការងារក្រៅផ្ទះដោយខ្លួនឯង ក៏មិនមែនមានន័យថាមូលដ្ឋាននេះប្រើការមិនកើតនោះទេ ។






www.elibraryofcambodia.org

ច្រមុះរបស់មនុស្សស្រីគឺជាផ្កាយស្វាមីរបស់នាង ។ ក្នុងការមើលច្រមុះខ្លួនឯងនិងស្វាមី ក្នុងពេលអនាគតរបស់អ្នក ឬ ស្វាមីបច្ចុប្បន្នរបស់អ្នក អ្នកចាំបាច់ត្រូវមើលច្រមុះពីចំហៀងនិងចំពីមុខដែរ ។

យើងចង់ឱ្យខ្ទង់ច្រមុះត្រង់ដែលបង្ហាញឱ្យឃើញពីស្វាមីដែលមានសមត្ថភាពជាដៃគូអាជីពនឹងជាមេដឹកនាំក្នុងជីវិតរបស់គេ ។ បើច្រមុះរបស់អ្នកមានសាច់ ស្វាមីរបស់អ្នក (ឬអនាគតស្វាមីរបស់អ្នក) នឹងមានទំនោរជាអ្នកដឹកនាំ ខ្ទង់ច្រមុះកោងបង្ហាញថាមានស្វាមីជាអ្នកដឹកនាំដូចគ្នា ។



ច្រមុះខ្ពស់ហើយមានបារមី

មនុស្សស្រីភាគច្រើនចង់បានច្រមុះតូច តែក្នុងសាស្ត្រាការមើលទម្រង់មុខមិនចាត់ទុកថាច្រមុះតូចជាច្រមុះល្អទេ ។ នៅសម័យមុន មនុស្សស្រីដែលមានច្រមុះតូច ហើយថ្ពាល់ធំតែងតែជាប្រពន្ធទី2របស់គេ ។ ក្នុងបរិបទសម័យថ្មី មនុស្សស្រីបែបនេះតែងតែក្លាយជាប្រពន្ធលួចលាក់ ។ តែនេះពុំមែនមានន័យថាមនុស្សស្រីទាំងអស់ដែលមានច្រមុះតូចនិងថ្ពាល់ធំក្លាយជាប្រពន្ធចុងគេទាំងអស់នោះទេ ។ យើងសូមណែនាំមនុស្សស្រីដែលមានទម្រង់មុខលក្ខណៈដូចនេះចៀសវាងការរៀបការជាមួយមនុស្សប្រុសដែលលែងប្រពន្ធ ឬ មនុស្សប្រុសដែលមានអាយុច្រើនជាងខ្លួនពេក ។

សម្រាប់មនុស្សស្រីទម្រង់មុខដែលល្អគឺទម្រង់មុខដែលហៅថា "នាំសំណាងល្អមកឱ្យស្វាមីហើយផ្តល់ប្រយោជន៍ដល់កូន (វ៉ាំងហ្វូអ៊ីជី)" ។ ច្រមុះគឺបច្ច័យសំខាន់ក្នុងការសំគាល់សមត្ថភាពរបស់មនុស្សស្រីដែលនឹងមានជីវិតបែប " នាំសំណាងល្អមកឱ្យស្វាមី ហើយផ្តល់ផលប្រយោជន៍ដល់កូន" ច្រមុះមានសាច់គួបផ្សំជាមួយស្លាបច្រមុះដែលមានសាច់ រន្ធច្រមុះដែលមិនងើយខ្ទង់ច្រមុះ មានខ្សែត្រង់ពេលមើលពីចំហៀងនិងពីខាងមុខហើយកំពកថ្ពាល់មានសាច់ ពេលនោះច្រមុះរបស់មនុស្សស្រីដែលអាចនាំជោគសំណាងមកឱ្យស្វាមីរបស់នាងក្នុងសាស្ត្រការមើលទម្រង់មុខមនុស្សដែលមានទម្រង់មុខបែបនេះរមែងក្លាយជាចៅហ្វាយស្រី ឬ ជាភរិយារបស់អ្នកធំ ។



ច្រមុះមានសាច់ ខ្ទង់ច្រមុះខ្ពស់ ស្លាបច្រមុះមានសាច់



www.elibraryofcambodia.org

## សម្រាប់បុរស

ចុះចំពោះមនុស្សប្រុសវិញ? ចូរអ្នកមើលត្រង់វាំងគូស្រកររបស់មនុស្សប្រុសវិញ តើវាយ៉ាងម៉េចដែរ?

វាំងគូស្រកររបស់មនុស្សប្រុសហៅថាចៀនម៉ឹន វានៅឆ្ងាយពីភ្នែកប្រហែលមួយទទឹងម្រាមដៃ (ដូចក្នុងរូប) ហើយត្រូវបានគេស្គាល់ក្នុងនាមជាវាំងភរិយាទៀតផង។




វាំងគូស្រករ វាំងភរិយា



www.elibraryofcambodia.org

យើងចង់ឱ្យតំណែងនេះមានសាច់តិចតួចហើយប្រការសំខាន់បំផុតនោះគឺមិនផត។ វាំងតូស្រករផតបង្ហាញឱ្យឃើញពីទំនាក់ទំនងជាមួយភរិយាគ្មានសេចក្ដីសុខនិងមិនមានការពេញចិត្តរវាងគ្នានិងគ្នា។




វាំងតូស្រករពុំគួរមានសាច់ច្រើន ឬ ទូលហួសពេកនោះទេ លើកលែងតែអ្នកចង់មានចៅហ្វាយនៅផ្ទះ ឬ មានប្រពន្ធកើតឆ្នាំខាល។ ជាធម្មតាមនុស្សប្រុសដែលមានកំផ្លៀងមានសាច់ ឬ កំភ្លៀងទូល នឹងឃើញថាពួកគេជាប់សាច់ត្រូវចិត្តហើយរៀបការជាមួយសុភាពនារីដែលតាំងខ្លួនជាចៅហ្វាយ មិនថាពួកគេចូលចិត្ត ឬ មិនចូលចិត្តក៏ដោយចុះ។

ពេលយើងសម្លឹងមើលវាំងតូស្រកររបស់មនុស្សប្រុស យើងតែងតែរកមើលខ្សែផ្កា។ តើខ្សែផ្កាជាអ្វី? ពួកបស្ចិមប្រទេសស្គាល់វាច្រើនក្នុងនាមថាជើងក្អែក វាគឺជាខ្សែតូចៗដែលកើតឡើងត្រង់កន្ទុយភ្នែកពេលគេញញឹម តើអ្នកធ្លាប់ឃើញមនុស្សប្រុសញញឹមហើយមានស្នាមជ្រួញត្រង់កន្ទុយភ្នែកឬទេ? ស្នាមជ្រួញទាំងនេះហើយគេហៅថាខ្សែផ្កា តែអ្នកខ្លះហៅថាកន្ទុយត្រី។



www.elibraryofcambodia.org

មនុស្សប្រុសដែលមានកន្ទុយត្រីឬខ្សែផ្កាគឺជាមនុស្សរីករាយមានអាកប្បកិរិយាទន់ភ្លន់ ហើយធ្វើខ្លួនបានល្អ។ មនុស្សប្រុសប្រភេទនេះមានសមត្ថភាពក្នុងការនិយាយផ្អែមល្ហែម ពូកែធ្វើឱ្យមនុស្សស្រីរីករាយ។ ស្នេហាប្រភេទនេះមិនបានមានន័យថាពួកគេជាគូស្រករដែលមិនល្អ ឬ ជាអ្នកលេងព្រាននារីទាក់ស្រីនោះទេ វាគ្រាន់តែមានន័យថាពួកគេចូលចិត្តសប្បាយជាមួយការយកចិត្តទុកដាក់របស់សុភាពនារីទាំងឡាយតែប៉ុណ្ណោះ។



កន្ទុយត្រី

ខ្សែផ្កាជាមូលហេតុដែលគួរឱ្យព្រួយបារម្ភនៅពេលវាធ្លាក់ចុះ ឬ វែងហួសពេកកាត់ចូលដល់រាំងគូស្រករ ដែលបង្ហាញឱ្យឃើញពីភាពជាព្រាននារីដែលតែងតែនាំមកនូវទំនាក់ទំនងជាមួយស្រីញីដ៏គ្រោះថ្នាក់ ហើយអាចឈានទៅដល់ការលែងលះគ្នាទៀតផង។

តើខ្សែដែលអូសកាត់ចូលមកដល់រាំងគូស្រករសំដៅលើអ្វី? ចូរអ្នកមើលរូបនេះ!



ខ្សែផ្កា ឬ កន្ទុយត្រីអូសកាត់ចូលរាំងគូស្រករ

ជួនកាលខ្សែផ្កាកើតគួបផ្សំជាមួយរាំងគូស្រករដែលមានលក្ខណៈទូលដែលអាចបង្ហាញឱ្យឃើញថា មនុស្សប្រុសដែលចេញដើរលេងច្រើនដោយសារតែ "ខ្លាក្នុងផ្ទះ"របស់គេសាហាវពេកហើយមានអាកប្បកិរិយារឹងកំព្រឹស ដូច្នេះហើយទើបបានជាគេតែងតែចង់ទៅរកសេចក្តីសុខនៅខាងក្រៅ។



www.elibraryofcambodia.org

# វាំងបុត្រធីតា

វាំងបុត្រធីតាស្ថិតនៅខាងក្រោមភ្នែក វានៅត្រង់ថង់ក្រោមភ្នែក វាំងនេះជំនួសឱ្យកូន និងទំនាក់ទំនងជាមួយកូនរបស់អ្នក។ តើអ្នកមានទំនាក់ទំនងល្អជាមួយកូនរបស់អ្នកដែរទេ? តើកូនរបស់អ្នកជាកូនកតញ្ញូឬទេ? ទាំងនេះវាអាស្រ័យលើគុណភាពរបស់វាំងនេះ។




យើងចង់ឱ្យថង់ក្រោមភ្នែកមានភាពស្រស់ថ្លាសម្បុរភ្លឺថ្លា គ្មានស្នាមជ្រួញ ប្រការទាំងនេះបង្ហាញឱ្យឃើញពីភាពជិតស្និទ្ធជាមួយកូន។

បើវាំងបុត្រធីតាមានសាច់មានន័យថាវាមិនហើម តែមានសាច់ល្មមហើយមិនមានស្នាមជាំភ្នែក មិនលិចជ្រៅ (ឆ្អឹងចិញ្ចើមមិនប៉ោងឡើង) មានន័យថាកូនៗរបស់ពួកគេមានសមត្ថភាពដែលអាចនាំកេរ្តិ៍ឈ្មោះមកឱ្យគ្រួសារតាមរយៈទង្វើល្អៗ។ ក្រៅពីកូនមានសមត្ថភាពហើយ ពួកគេថែមទាំងបានជួយទំនុកបម្រុងឪពុកម្តាយ មិនបំផ្លាញប្រាក់កាសទៀតផង។



www.elibraryofcambodia.org

ជាច្រើនលើកច្រើនគ្រា ពេលជួបឪពុកម្ដាយដែលមានកូនពិការ យើងតែងតែឃើញខ្សែខ្មៅ ឬ ស្នាមជាំនៅក្រោមភ្នែករបស់ពួកគេ។ នេះមិនទាក់ទងនឹងការដែលថាពួកគេសម្រាន្តលក់ ឬ សម្រាន្តមិនគ្រប់គ្រាន់នោះទេ (មនុស្សភាគច្រើនគិតថាស្នាមជាំក្រោមភ្នែកវាកើតឡើងដោយការដេកមិនគ្រប់គ្រាន់)។ ជូនកាលថង់ក្រោមភ្នែកជាំកើតមកពីភាពខ្វាយខ្វល់របស់ឪពុកម្ដាយ ឬ បារម្ភនឹងកូនជ្រុលហួសពេក ជាពិសេសគឺម្ដាយ។



រាំងបុត្រធីតាដែល
ស្រអាប់ ឬ ស្រពោន



www.elibraryofcambodia.org

អ្នកដែលជាម្តាយគួរចាប់អារម្មណ៍មើលត្រង់ថង់ក្រោមភ្នែករបស់ខ្លួនឱ្យបានច្បាស់ ដើម្បីឱ្យបានដឹងថាកូនដែលនៅបរទេសរបស់អ្នកយ៉ាងម៉េចទៅហើយ ។ បើមានស្នាមជាំត្រង់ថង់ក្រោមភ្នែកតែម្ខាង បង្ហាញឱ្យឃើញថាមានបញ្ហាតែមួយឆាប់ៗដែលកើតឡើងជាមួយកូនម្នាក់របស់អ្នក ហើយវាកំពុងតែរសាត់បាត់ទៅហើយ ។ តែតើបញ្ហានេះកើតឡើងចំពោះកូនមួយណា? បើមានស្នាមជាំនៅត្រង់ថង់ក្រោមភ្នែកស្តាំ មានន័យថាអ្នកមានក្តីកង្វល់នឹងកូនស្រី ។ បើមានស្នាមជាំនៅត្រង់ថង់ក្រោមភ្នែកឆ្វេង កូនប្រុសជាមូលហេតុដែលធ្វើឱ្យអ្នកកើតក្តីកង្វល់ ។ បើមានស្នាមសៗត្រង់ក្រោមភ្នែករបស់អ្នកនោះ វាបង្ហាញឱ្យឃើញពីគ្រោះថ្នាក់ដែលអាចកើតឡើងលើកូនរបស់អ្នក ។

ជាទូទៅ យើងមិនចង់ឃើញខ្សែរឆ្លងកាត់ថង់ក្រោមភ្នែកដូចក្នុងរូបភាពខាងក្រោមនេះនោះទេ ។ ថង់ក្រោមភ្នែកជាំផ្សំជាមួយខ្សែរដែលអូសកាត់ថង់ក្រោមភ្នែកបង្ហាញឱ្យឃើញពីភាពឃ្លាតឆ្ងាយជាមួយកូន ឬមានកូនដែលនៅចាំបំផ្លាញ ឬ កូនគ្មានសមត្ថភាព ។



ខ្សែរឆ្នូតកាត់វាំងបុត្រធីតា





www.elibraryofcambodia.org

# វាំងបរិវារ

វាំងបរិវារទាក់ទងជាមួយអ្នកជំនួយការដែលអ្នកជូលឱ្យមកធ្វើការរាប់តាំងពីអ្នកបម្រើក្នុងផ្ទះ អ្នកមើលថែសួន រហូតដល់អង្គរក្សការពារសុវត្ថិភាព និងគណនេយ្យកររបស់អ្នក ។

វាជាវាំងដែលគ្រប់គ្រងទំនាក់ទំនងរបស់អ្នកជាមួយអ្នកដែល "ជួយអ្នក" វាំងបរិវារនៅត្រង់តំណែងទី74និង75ក្នុងផែនទី100ឆ្នាំក្បែរឆ្អឹងថ្គាម ពេលអ្នកមើលវាំងបរិវារ អ្នកត្រូវពិចារណាលើចង្កាគួបផ្សំជាមួយដែរ ។




នៅសម័យមុន វាំងបរិវារតែងតែមានទំនាក់ទំនងជាមួយនឹងការដែលយើងនឹងមានអ្នកបម្រើមកបម្រើយើងនៅវ័យជរាឬទេ? វប្បធម៌ចិនចាត់ទុកថាវាជាបញ្ហាសំខាន់ណាស់មិនត្រឹមតែយើងត្រូវមានអ្នកបម្រើមកជួយយើងប៉ុណ្ណោះទេ តែយើងត្រូវមានសមាជិកគ្រួសារនិងមិត្តភក្តិចាំជួយយើងផងដែរ ។



www.elibraryofcambodia.org

រាំងបរិវារពុំគួរមានស្នាមជ្រួញឆ្លងកាត់នោះទេ ព្រោះវាបង្ហាញឱ្យឃើញពីគ្រោងសាងដែលបែកបាក់និងបញ្ហាដែលកើតឡើងដោយសារកូនឈ្នួល អ្នកបម្រើ ឬ អ្នកដែលធ្វើការឱ្យអ្នក។ តែយើងខ្ញុំសូមបំភ្លឺនូវជំនឿដែលថាមនុស្សគ្រប់គ្នាតែងតែមានស្នាមជ្រួញនៅវ័យជរា។ សូមមើលម្ចាស់ក្សត្រីអេលីសាបែតទី2 លីកាឈីង ឬ វ៉ៃឡែន បាហ្វេត អ្នកទាំងអស់នេះមានអាយុចាស់ណាស់ទៅហើយ តែផ្ទៃមុខមិនសូវមានស្នាមជ្រួញច្រើនទេ។

## ធរាំងអស់នៅត្រង់ចង្កា

រាំងបរិវារគួរតែទូលាយហើយមានសាច់ គួរមានបរិវារទូលាយរវាងមាត់និងខ្សែជុំវិញចង្កាដែលបង្ហាញឱ្យឃើញថារាំងបរិវារនោះរឹងមាំ ធ្វើឱ្យក្នុងជីវិតអ្នកមិនត្រឹមតែមានអ្នកជួយការងារដែលល្អប៉ុណ្ណោះទេ តែនៅមានមិត្តភក្តិនិងញាតិសន្តានចាំជួយអ្នកនៅវ័យក្មេងនិងវ័យជរាទៀតផង សម្រាប់មនុស្សស្រីឆ្អឹងថ្គាមគួរមូល សម្រាប់បុរសឆ្អឹងថ្គាមគួរមានលក្ខណៈជ្រុង ទើបជាគុណសម្បត្តិនៃរាំងបរិវារល្អ។



ចង្កាទូលាយ រាំងបរិវារល្អ



www.elibraryofcambodia.org

យើងមិនចង់មានបរិវេណរវាងមាត់និងចង្កាជាផ្ទៃចង្អៀតនោះទេ តែយើងចង់បានផ្ទៃទូលាយត្រង់បរិវេណនេះ វាគួរតែមានសាច់ ហើយមិនឡើងឆ្អឹងដែលបង្ហាញឱ្យឃើញពីវ័យជរា ដែលមានភាពចម្រើនរុងរឿងសម្បូរសប្បាយ ។



ចង្កាចង្អៀត រាំងបរិវារមិនល្អ



www.elibraryofcambodia.org

# ទាំងឪពុកម្តាយ

នេះគឺតំណែងទី17និង18នៅលើផែនទី100ឆ្នាំ ហើយត្រូវបានគេស្គាល់ក្នុងនាមជាតំណែងអាទិត្យនិងចន្ទទៀតផង។ អាទិត្យជំនួសឱ្យឪពុក ចំណែកចន្ទជំនួសឱ្យម្តាយ។ តំណែងទាំងពីរនេះជំនួសឱ្យទំនាក់ទំនងរបស់អ្នកនិងឪពុកម្តាយ។ វាអាចបង្ហាញឱ្យដឹងពីសុខភាពឪពុកម្តាយរបស់អ្នកក្នុងពេលណាមួយ។




បើមានស្នាមសម្លាក ឬ មានស្នាមផតត្រង់វាំងឪពុកម្តាយ នោះវាបង្ហាញឱ្យឃើញថាឪពុកម្តាយរបស់គេស្លាប់នៅពេលគេនៅក្មេង។ ស្នាមផតនៅត្រង់តំណែងអាទិត្យបង្ហាញឱ្យឃើញថាក្នុងជីវិតនេះគេនឹងមិនបានទទួលការជួយទំនុកបម្រុងពីឪពុកម្តាយរបស់គេទេ ក្នុងទំនោរដូចគ្នាដែរ ស្នាមផតត្រង់តំណែងចន្ទបង្ហាញឱ្យឃើញថាក្នុងជីវិតនេះគេម្នាក់នោះនឹងមិនបានទទួលការជួយទំនុកបម្រុងពីម្តាយរបស់គេទេ។ បើថ្ងាសលាតធ្វើឱ្យអាទិត្យនិងចន្ទខ្ពស់ទាបមិនស្មើគ្នា ឬ មានគំនិតមិនស្មើគ្នាបង្ហាញឱ្យឃើញថាឪពុកម្តាយរបស់គេមានទំនាក់ទំនងមិនល្អចំពោះគ្នា ឪពុកអាចមានប្រពន្ធចុង ឬ មានសាហាយជាដើម។



www.elibraryofcambodia.org

ជើងសក់ក៏អាចប្រាប់យើងអំពីទំនាក់ទំនងរបស់គេម្នាក់នោះជាមួយឪពុកម្តាយរបស់គេបានដែរ ។ ជើងសក់ដែលមានលក្ខណៈដូចស្នាមមុខរណា ឬ ឈើអាវដែលធ្លាក់ចុះមកពីជើងសក់ បង្ហាញឱ្យឃើញថាគេនឹងនាំគ្រោះភ័យឱ្យឪពុកម្តាយរបស់គេ ។




តើការនាំគ្រោះភ័យមកឱ្យឪពុកម្តាយនោះមានន័យយ៉ាងដូចម្តេច? ប្រយោគនេះខ្ញុំមានន័យថាឪពុកម្តាយជាមួយកូនមិនសូវមានការឯកភាពគ្នា បើពួកគាត់និយាយពីគោ អ្នកនិយាយពីក្របី គឺមិនអាចមូលផ្លុងគ្នាបានឡើយ គឺប្រៀបដូចទឹកនិងប្រេង ។



www.elibraryofcambodia.org

ខ្សែភ្នែតឆ្លងកាត់ថ្ងាសបង្ហាញឱ្យឃើញពីជីវិតដែលលំបាក ឬ មានទុក្ខមុនអាយុ30ឆ្នាំ។ ឪពុកម្តាយមិនសូវគាំទ្រទំនុកបម្រុង  ដូចជាមិនផ្តល់ទុនល្អដល់អ្នកសម្រាប់ការចាប់ផ្តើមកសាងអនាគតជាដើម ។ ថ្ងាសដែលទាប ចង្អៀតហើយតាបត្រង់តំណែងអាទិត្យនិងចន្ទ បង្ហាញឱ្យឃើញពីមនុស្សដែលត្រូវឈប់រៀនតាំងពីនៅក្មេងវ័យដើម្បីជួយឪពុកម្តាយ ឬ ធ្វើការដើម្បីចិញ្ចឹមឪពុកម្តាយ ។



ខ្សែភ្នែតកាត់ថ្ងាស



www.elibraryofcambodia.org

# វាំងបងប្អូន

វាំងបងប្អូនស្ថិតនៅត្រង់ចិញ្ចើម វាំងនេះជំនួសឱ្យទំនាក់ទំនងរវាងអ្នកនិងបងប្អូនរបស់អ្នក។ វាបានបង្ហាញឱ្យឃើញពីគុណភាពនិងឧបនិស្ស័យរបស់បងប្អូនរបស់អ្នក។ ការមើលវាំងបងប្អូនអាចប្រាប់បានថាបងប្អូនរបស់គេម្នាក់នោះមានសេចក្តីសុខឬទេ ហើយបងប្អូនបានជួយគេទេ? ក្នុងការមើលវាំងបងប្អូនយើងអាចមើលប្រវែងរបស់ចិញ្ចើម ទិសរបស់រោមចិញ្ចើម និងកម្រាស់ ឬ កំហាប់របស់រោមចិញ្ចើម។




វាំងបងប្អូន

វិធីដែលលឿនបំផុតក្នុងការទាញប្រយោជន៍ពីវាំងបងប្អូនគឺវាអាចប្រាប់បានថាគេមកពីគ្រួសារតូច ឬ គ្រួសារធំ។ ក្នុងគ្រួសាររបស់ពួកអាស៊ី វាជារឿងធម្មតាទេដែលមនុស្សអាចសួរគ្នាទៅវិញទៅមក ថាអ្នកមានបងប្អូនប៉ុន្មាននាក់។ នេះគឺជាមូលហេតុដែលធ្វើឱ្យការមើលទម្រង់មុខក្នុងវិធីនេះក្លាយជារឿងដែលមានប្រយោជន៍ ព្រោះអ្នកអាចប្រាប់បានថាគេម្នាក់នោះមានបងប្អូនប៉ុន្មាននាក់ដោយពុំចាំបាច់សួរគេ។

ជាធម្មតាចិញ្ចើមដែលវែងជាងភ្នែកបង្ហាញឱ្យឃើញថាគេជាមនុស្សដែលមានបងប្អូនបួននាក់ ឬ ច្រើនជាងនោះ។ បើចិញ្ចើមវែងស្មើនឹងភ្នែក ឬខ្លីជាងភ្នែក គេម្នាក់នោះអាចមានបងប្អូនតិចជាងបួននាក់ ឃើញទេថាវាជាការងាយស្រួលណាស់។



www.elibraryofcambodia.org

ការមានបងប្អូនជារឿងមួយល្អ តែការមានបងប្អូនដែលចេះជួយគ្នាគឺជារឿងមួយអស្ចារ្យណាស់ ជាពិសេសបើអ្នកមានទំនាក់ទំនងល្អជាមួយពួកគេថែមទៀត។ អ្នកដែលមានបងប្អូនចេះជួយគ្នានិងមានទំនាក់ទំនងល្អជាមួយបងប្អូនអាចមានចិញ្ចើមក្រាស់មធ្យមនិងមានរោម ចិញ្ចើមដែលដុះក្នុងទិសស្របគ្នា។



រោមចិញ្ចើមដែលដុះក្នុងទិសស្របគ្នា

ហើយចុះទំនាក់ទំនងរវាងបងប្រុស ឬ ប្អូនប្រុសជាមួយបងស្រី ឬ ប្អូនស្រីនោះវិញតើវាមានលក្ខណៈដូចម្ដេចដែរ? អ្នកត្រូវមើលត្រង់រោមចិញ្ចើម ហើយមើលឱ្យឃើញថាវាដុះយ៉ាងដូចម្ដេច។ បើរោមចិញ្ចើមដុះក្នុងទិសបញ្ច្រាសគ្នា (មានន័យថារោមចិញ្ចើមខ្លះដុះទៅស្ដាំខ្លះដុះទៅឆ្វេង) បង្ហាញឱ្យឃើញថាបងប្អូននឹងស្អប់គ្នាក្នុងកម្រិតធ្ងន់ធ្ងរ ឬ យ៉ាងហោចណាស់បងប្អូនក៏មិនអាចរាប់រកគ្នាដែរ។ ចិញ្ចើមស្ដុកបង្ហាញឱ្យឃើញពីទំនាក់ទំនងដែលមិនពេញលេញរវាងបងប្អូន ព្រោះជួនល្អជួនអាក្រក់។



រោមចិញ្ចើមដែលដុះបញ្ច្រាសចុះបញ្ច្រាសឡើង



www.elibraryofcambodia.org

យើងក៏អាចប្រើចិញ្ចើមដើម្បីបង្ហាញឱ្យឃើញពីសុខភាពរបស់បងប្អូនបានដែរ។ ស្នាមចន្លោះឬមិនដុះរោមត្រង់ចិញ្ចើមបង្ហាញឱ្យឃើញពីសុខភាពមិនល្អ ឬ បញ្ហាទាក់ទងនឹងបេះដូង ឬ ក្នុងករណីដែលធ្ងន់ធ្ងរ វាបង្ហាញឱ្យឃើញពីគ្រោះថ្នាក់ដល់ជីវិត។ បើស្នាមចន្លោះ ឬ មិនដុះរោមនៅត្រង់ចិញ្ចើមស្តាំមានន័យថាបងប្អូនស្រីៗអាចមានបញ្ហា។ បើស្នាមចន្លោះ ឬ មិនដុះរោមនៅត្រង់ចិញ្ចើមឆ្វេងមានន័យថាបងប្អូនប្រុសៗកំពុងតែប្រឈមមុខនឹងបញ្ហាសុខភាព ឬ ស្ថានការណ៍គ្រោះថ្នាក់។



ស្នាមចន្លោះ ឬ មិនដុះរោមត្រង់ចិញ្ចើម

ចិញ្ចើមក៏បានបង្ហាញឱ្យឃើញពីទំនាក់ទំនងក្នុងគ្រួសារផងដែរ តើអ្នកធ្វើដូចម្តេចទើបអាចដឹងថាគេម្នាក់នោះមានម៉ែចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ មានបងប្អូនឪពុកផ្សេងគ្នា ឬ ម្តាយផ្សេងគ្នាឬអត់? ចិញ្ចើម "យិនយ៉ាង"គឺ ចិញ្ចើមដែលមានលក្ខណៈម្ខាងខ្ពស់ម្ខាងទាបពេលមើលចំពីមុខ លក្ខណៈបែបនេះបង្ហាញថាគេម្នាក់នោះមានឪពុកផ្សេងគ្នា ឬ ម្តាយផ្សេងគ្នា។ អ្នកអាចអះអាងដោយការត្រួតមើលរាំងឪពុកម្តាយនិងត្រចៀក។ បើត្រចៀកស្ថិតក្នុងកម្រិតដែលខ្ពស់ទាបពុំស្មើគ្នា (ម្ខាងខ្ពស់ម្ខាងទាប) នោះវាកាន់តែជាសញ្ញាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាគេម្នាក់នោះមានបងប្អូនដែលមានឪពុក ឬ ម្តាយផ្សេងគ្នា។



ចិញ្ចើមម្ខាងខ្ពស់ម្ខាងទាប



www.elibraryofcambodia.org

# វាំងធ្វើដំណើរ

វាំងធ្វើដំណើរស្ថិតនៅត្រង់តំណែងអស្សស្ថានសូត ។ វាំងធ្វើដំណើរជំនួសឱ្យការធ្វើដំណើរ និងការផ្លាស់ប្តូរ វាស្ថិតនៅត្រង់តំណែងទី23និង24 នៃផែនទី100ឆ្នាំស្ថិតនៅត្រង់ជ្រុងខាងឆ្វេង និងជ្រុងខាងស្តាំនៃថ្ងាស ។




វាំងធ្វើដំណើរកំណត់ថាការប្តូរទៅនៅទីកន្លែងផ្សេង ឬ ទៅក្រៅប្រទេសអាចជួបភាពជោគជ័យដែរឬទេ? វាំងធ្វើដំណើរទូលាយមានពណ៌ស្រស់ថ្លាបង្ហាញឱ្យឃើញពីមនុស្សដែលអាចប្តូរលំនៅដ្ឋាន ហើយចាប់ផ្តើមជីវិតថ្មីក្នុងប្រទេសថ្មីមួយបានដោយជោគជ័យ ។

ចំពោះការមើលបែបលឿន វាំងនេះអាចប្រាប់យើងថាគេម្នាក់នោះអាចជួបនូវភាពជោគជ័យក្នុងការធ្វើដំណើរទៅធ្វើជំនួញនៅប្រទេសក្រៅឬអត់ ។ អ្នកឃើញហើយថាយើងអាចមើលជោគជតាក្នុងថ្ងៃដ៏ច្បាស់លាស់មួយដោយការមើលពណ៌ស្បែកនិងភាពស្រស់ថ្លានៃទឹកមុខ ។ ត្រង់តំណែងផ្សេងៗ អ្នកដែលមានស្នាមជាំត្រង់វាំងធ្វើដំណើរគឺមានទំនោរនឹងជួបគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ (ដូចជាបាត់ឯកសារ ជួបឧប្បត្តិហេតុផ្សេងៗក្នុងពេលធ្វើដំណើរ) ឬ បង្ហាញឱ្យឃើញថាការធ្វើដំណើរនោះពុំបានបង្កើតឱ្យមានលទ្ធផលអ្វីឱ្យល្អណាស់ណាទេ ។



www.elibraryofcambodia.org

រាំងធ្វើដំណើរខ្ពស់ហើយមានសាច់ បង្ហាញឱ្យឃើញពីមនុស្សដែលត្រូវរកលុយតាមរយៈការធ្វើដំណើរ ឬ តាមរយៈជំនួញដែលត្រូវមានការធ្វើដំណើរញឹកញាប់ ។

បើរាំងធ្វើដំណើរទាប គេម្នាក់នោះល្អចំពោះការងារដែលធ្វើនៅនឹងកន្លែង ឬ ការងារមិនចាំបាច់ផ្លាស់ប្តូរកន្លែង ឬ ធ្វើដំណើរច្រើនឡើយ ពួកគេមានលក្ខណៈសមស្របជាមួយការងារការិយាល័យ ។



រាំងធ្វើដំណើរខ្ពស់



រាំងធ្វើដំណើរទាប



www.elibraryofcambodia.org

# វាំងជោគសំណាងនិងគុណធម៌

វាំងជោគសំណាងនិងគុណធម៌ស្ថិតនៅលើចិញ្ចើមបន្ទាប់ពីឆ្អឹងចិញ្ចើម ឬ ចាប់ពីចិញ្ចើមឡើងទៅដូចមានបង្ហាញក្នុងរូបភាព ។




វាំងជោគសំណាងនិងគុណធមិ

ជោគសំណាងនិងគុណធម៌គឺសំដៅទៅលើការស្គាល់នៃជីវិតដែលមានសេចក្តីសុខផ្លូវចិត្តនិងលើសព្វវត្ថុផ្សេងៗ ។ វាំងជោគសំណាងនិងគុណធម៌ត្រូវមើលផ្ទួបជាមួយនឹងចង្ការូមទាំងកែវភ្នែក ព្រោះការដែលមនុស្សម្នាក់មានគុណភាពជីវិតល្អបាន លុះត្រាតែបេះដូងរបស់គេជំនួសដោយកែវភ្នែករបស់គេ ឬ និយាយម្យ៉ាងទៀតថាត្រូវមានសេចក្តីសុខ ចំណែកចង្ការិញទាក់ទងនឹងសមត្ថភាពដែលគេនឹងរីករាយជាមួយនឹងការប្រើជីវិត ។ ដូច្នេះចង្កាដែលល្អវាបង្ហាញថាគេម្នាក់នោះអាចសប្បាយនឹងភាពរីករាយក្នុងជីវិតទាំងបែបសុខស្រួលនិងច្របូកច្របល់ ។

វាំងជោគសំណាងនិងគុណធម៌គួរតែមានសាច់ ដែលជាការបង្ហាញឱ្យឃើញពីការមើលពិភពលោកក្នុងផ្លូវល្អ មានមិត្តភក្តិច្រើនដែលអាចនាំសេចក្តីសុខឱ្យខ្លួន ដូចជាការបន្ថែមបន្ថយរសជាតិជីវិត ។ តែមិនគួរមានខ្សែឆ្នូត ឬ ខ្សែកាត់ត្រង់វាំងជោគសំណាងនិងគុណធម៌ឡើយ បើមិនដូច្នេះទេគេម្នាក់នោះពិបាកនឹងមានសេចក្តីសុខនិងសេចក្តីពេញចិត្តនៃជីវិតណាស់ ។



www.elibraryofcambodia.org

បើរាំងជោគសំណាងនិងគុណធម៌មានផុសឆ្អឹង មនុស្សនោះនឹងក្លាយជាមនុស្សម៉ឺងម៉ាត់ ហើយចូលចិត្តពឹងលើខ្លួនឯង។ ពួកគេច្រើនមានទស្សនៈតឹងតែង ហើយជីវិតរបស់ពួកគេក៏មិនមានអ្វីគួរជាទីពេញចិត្តដែរ ព្រោះពួកគេរវល់តែស្វែងរកភាពពេញលេញពេក។



ឆ្អឹងផុសត្រង់រាំងជោគសំណាងនិងគុណធម៌

រាំងជោគសំណាងនិងគុណធម៌ដែលមានខ្សែឆ្នូតច្រើនឆ្លងកាត់ បង្ហាញឱ្យឃើញពីមនុស្សដែលមានសីលធម៌មិនគង់វង្ស ឬ ប្រាសចាកមូលដ្ឋាននៃភាពគង់វង្ស។ ពួកគេត្រូវគេអូសទាញចិត្តឱ្យ " ពិចារណាលើជំហាររបស់ខ្លួនសាជាថ្មី" បានដោយងាយ ជាពិសេសបើគេម្នាក់នោះមានភ្នែកទន់ ឬ កែវភ្នែកគ្មានភាពរស់រវើក ឬ មានកែវភ្នែកស្លេកស្រពន់។



ខ្សែចាក់ចូលទៅក្នុងរាំងជោគសំណាងនិងគុណធម៌



www.elibraryofcambodia.org

រោមចិញ្ចើមពុំគួរចាក់ចូលទៅក្នុងវាំងជោគសំណាងនិងគុណធមិដូចនៅក្នុងរូបនេះទេ លក្ខណៈបែបនេះបង្ហាញឱ្យឃើញពីមនុស្សដែលមានចិត្តលឿន ធ្វើអ្វីដោយពុំបានពិចារណាឱ្យបានសព្វជ្រុងជ្រោយ ។



រោមចិញ្ចើមចាក់ចូលទៅក្នុងវាំងជោគសំណាងនិងគុណធមិ

អ្នកដែលមានសម្លាក ឬ ខ្សែឆ្នូតកាត់វាំងជោគសំណាងនិងគុណធមិតែងតែមានបញ្ហាមិត្តភាពដែលច្របូកច្របល់ ឬ ពិបាកបន្តិច ។ ពួកគេជាមិត្តរបស់អ្នកនៅថ្ងៃនេះ តែអាចប្រែក្លាយជាសត្រូវរបស់អ្នកនៅថ្ងៃស្អែក ឬ អ្នកនឹងមានទុក្ខដោយសារមិត្តភាពដែលក្លាយពីផ្អែមទៅជាល្វីង ។ អ្នកដែលមានសម្លាក ឬ ខ្សែឆ្លងកាត់វាំងជោគសំណាងនិងគុណធមិជាមនុស្សពិបាកចុះចំណោមនឹងគេ ព្រោះគេតែងតែបង្ហាញឱ្យឃើញនូវទស្សនៈតឹងរឹង ឬ ការយល់ឃើញដែលលប់លើការយល់ឃើញរបស់អ្នកដទៃ ។

ចំណេះដឹងដែលអ្នកទទួលបានអំពីផែនទី១០០ឆ្នាំនិងវាំងទាំង១២ពិតជាមានតម្លៃណាស់ ធ្វើឱ្យអ្នកទទួលបានទិន្នន័យនិងតិចណិចផ្សេងៗជាច្រើនដែលអាចឱ្យយើងមើលឃើញពីលក្ខណៈផ្សេងៗនៃមនុស្សដែលនៅជុំវិញយើង ។ វាំងទាំង១២មិនមែនជាចំណុចទាំងអស់នោះទេ ហើយក៏មិនមែនជាចំណុចចុងក្រោយនៃការមើលទម្រង់មុខដែរ ។

តាមពិតទៅវាំងទាំង១២នេះមានខ្លឹមសារនិងអត្ថន័យដែលទូលំទូលាយជាងនេះច្រើនណាស់ ដោយសារយើងស្ថិតក្នុងកម្រិតដំបូង ទើបខ្ញុំបកស្រាយខ្លឹមសារនិងអត្ថន័យរបស់វាត្រឹមតែប៉ុណ្ណោះ ដើម្បីឱ្យយល់និងងាយស្វែងយល់បន្ត ។ ឧទាហរណ៍ដូចជាវាំងបងប្អូន ដែលជំនួសដោយចិញ្ចើមនោះ វានៅមានជាប់ពាក់ព័ន្ធនឹងឧបនិស្ស័យនិងធម្មជាតិរបស់មនុស្សយើងដែរ ។ ពេល



www.elibraryofcambodia.org

គឺតើគេម្នាក់នោះមានចិត្តក្លាហាន? ជាមនុស្សប្រកាន់ភ្ជាប់នូវផែនការ ឬ ស្ទាក់ស្ទើរចំពោះផែនការ? ច្រមុះវាមិនបានគ្រាន់តែជាប់ពាក់ព័ន្ធនឹងភាពមានបានប៉ុណ្ណោះទេ តែវានៅជាប់ពាក់ព័ន្ធនឹងភាពស្មោះត្រង់និងភាពជឿជាក់ចំពោះខ្លួនឯងរបស់គេនោះទៀតផង ។

នៅពេលដែលអ្នកអានមេរៀនវគ្គផ្សេងៗទៅមុខទៀត សូមចងចាំថាយើងទើបតែដឹងបានមួយផ្នែកតូចតែប៉ុណ្ណោះ ។





www.elibraryofcambodia.org

# មេរៀនទី៥
# ប្រជ្រុយមានអត្ថន័យបែបណាខ្លះ?



ពេលដែលអ្នកអានមេរៀននេះ អ្នកនឹងបានដឹងថាការមើលប្រជ្រុយជាវិធីឆ្ពោះទៅរកការមើលទម្រង់មុខដ៏ល្អមួយ ហើយក៏ជាវិធីដែលធ្វើឱ្យយើងសប្បាយរីករាយផងដែរ ។



ជាបឋម អ្នកត្រូវចេះបែងចែកភាពខុសគ្នារវាងប្រជ្រុយនិងស្នាមដៅជាមុនសិន ។

ប្រជ្រុយជាដុំសាច់តូចៗពណ៌ខ្មៅជួនកាលវាដុះទូលចេញលើស្បែករបស់មនុស្សយើងវាតែងតែមានពណ៌ខ្មៅ ជួនកាលមានរោមតូចៗដុះនៅជាមួយផង ។ រីឯស្នាមដៅមិនមានដុះរោមហើយមិនមានទូលទេ វាតែងមានពណ៌ត្នោត និងពណ៌ខ្មៅព្រាលៗ ។

ប្រជ្រុយជាវត្ថុដែលគួរឱ្យបារម្ភណាស់ពេលយកមកប្រៀបនឹងស្នាមដៅ។

តាមតម្រាបុរាណមៀនសៀង ម៉ឺយអ៊ីវហារ៍មូបាននិយាយថាគ្មានប្រជ្រុយដែលល្អលើផ្ទៃមុខទេ ព្រោះជាទូទៅប្រជ្រុយទាំងនោះសុទ្ធតែផ្តល់នូវគុណវិបត្តិ ។ ដូច្នេះការកម្ចាត់វាចោលអាចធ្វើឱ្យយើងមានសុវត្ថិភាព ។

ទោះជាយ៉ាងណាក៏ដោយក៏វាមានករណីលើកលែងខ្លះៗដែរ ព្រោះមានប្រជ្រុយនៅលើមុខខ្លះនាំមកនូវលាភសំណាងជូនលោកអ្នកដែរ ។ តែជោគសំណាងវាក៏ត្រឹមតែមានទំនាក់ទំនងនឹងជោគជតាក្នុងកំឡុងពេលនៃអាយុណាមួយ ព្រោះវាគង់តែផ្តល់នូវផលប៉ះពាល់ផ្នែកអវិជ្ជមានចំពោះជោគជតាជាទូទៅរបស់អ្នកនោះនៅពេលក្រោយដដែល ។



www.elibraryofcambodia.org



ប្រជ្រុយត្រូវគេមើលឃើញថាជា "គ្រឿងរាំងស្ទះ" ជោគសំណាង ។ វិធីងាយស្រួលក្នុងការមើលប្រជ្រុយគឺកំណត់តំណែងអាយុដែលមានប្រជ្រុយតាំងនៅ ឬ វានៅត្រង់ក្នុងរាំងទាំង12 ហើយយើងអាចប្រាប់បានថាមនុស្សម្នាក់នោះពេលមានអាយុប៉ុន្មាននឹងជួបនូវការលំបាកផ្សេងៗ ។ ឧទាហរណ៍ថាគេមានប្រជ្រុយត្រង់តំណែងអាយុ45ឆ្នាំ វាបង្ហាញឱ្យឃើញពីការរាំងស្ទះនូវជោគសំណាងពេលមានអាយុ៤៥ ហើយក្ដីលំបាកលំបិនក៏មាននៅអាយុនោះដែរ ។

គឺវាងាយអីចឹង!

ផ្ទុយទៅវិញ ស្នាមដៅលើផ្ទៃមុខមិនជាក់ច្បាស់ វាអាស្រ័យលើតំណែងនិងទំហំរបស់វា ពេលខ្លះវាមិនមែនជាបញ្ហាក៏ថាបាន ហើយក្នុងស្ថានការណ៍ដែលពិបាករកខ្លះទៀត វាអាចបង្ហាញឱ្យឃើញពីជោគសំណាងក៏ថាបាន ។ តើហេតុអ្វីបានទៅជាអីចឹង? ព្រោះភាគច្រើនស្នាមដៅលើស្បែក វាមិនដុះឡើងទេ ហើយការដែលវាមិនផុសឡើងនេះហើយមានន័យថាវាមិនបានធ្វើឱ្យមាន "ការរាំងស្ទះ" ។

ក្នុងការមើលទម្រង់មុខ យើងចាត់ទុកថាប្រជ្រុយភាគច្រើននៅលើផ្ទៃមុខជាលក្ខណៈដែលមិនល្អ ។ យើងនឹងនិយាយអំពីប្រជ្រុយដែលមិនល្អជាមុនសិនទើបទៅមើលចំណុចលើកលែងខ្លះៗជាបន្តទៀត ។



www.elibraryofcambodia.org

# ប្រជ្រុយត្រូវគេលួចគូស្នេហ៍



ប្រជ្រុយលើថ្ពាល់ឆ្វេង

តើអ្នកធ្លាប់បានឮរឿងដែលថាមនុស្សដែលមានទំនាក់ទំនងគ្នាយូរយារជិតនឹងរៀបការទៅហើយ ស្រាប់តែសុខៗក៏បែរជារបូតមនុស្សដ៏សំខាន់របស់ខ្លួនធ្លាក់ទៅលើដៃអ្នកទី3ទៅវិញ? ពួកគេអាចមានប្រជ្រុយត្រូវគេលួចស្នេហ៍ក៏ថាបាន ប្រជ្រុយនេះនៅត្រង់ពាក់កណ្តាលថ្ពាល់ ហើយអាចនៅខាងថ្ពាល់ឆ្វេង ឬ ថ្ពាល់ស្តាំ ។

ប្រជ្រុយត្រូវគេលួចគូស្នេហ៍មានលក្ខណៈច្បាស់លាស់គឺពេលវាស្ថិតនៅលើថ្ពាល់ក្រោមភ្នែកចុះមកត្រង់ ។



www.elibraryofcambodia.org

ការមានប្រជ្រុយបែបនេះបង្ហាញឱ្យឃើញថាគេម្នាក់នោះនឹងមានមិត្តប្រុសមិត្តស្រី ឬគូស្រករដែលត្រូវអ្នកដទៃឆក់យកទៅបាត់ ឬ ក្នុងករណីស្នេហ៍ត្រីកោណ មនុស្សដែលមានប្រជ្រុយ នៅត្រង់កន្លែងនេះត្រូវគេយកគូស្នេហ៍ ឬ គឺជាអ្នកចាញ់។

ប្រជ្រុយត្រូវគេលួចគូស្រករគឺជាមូលហេតុដែលគួរឱ្យបារម្ភ ជាពិសេសពេលវាកើតឡើងគួបផ្សំនឹងខ្សែឆ្នូតខ្លះៗដែលឆ្លងកាត់វាំងគូស្រករត្រង់តំណែងទី41 ដែលបង្ហាញឱ្យឃើញពីទំនាក់ទំនងសាហាយស្មន់ ឬ បើមនុស្សប្រុសមានចិញ្ចើមក្រាស់ វានឹងបង្ហាញឱ្យឃើញថាមានមិត្តភក្តិខ្លួនអាចនឹងក្លាយជាអ្នកទីបីចូលមកជ្រៀតជ្រែកទំនាក់ទំនងស្នេហារបស់អ្នក។

ប្រជ្រុយត្រូវគេលួចគូស្នេហ៍ ក្រៅពីអាចបង្ហាញឱ្យឃើញពីការបាត់បង់គូស្នេហ៍របស់អ្នកទៅឱ្យអ្នកដែលអ្នកស្គាល់ហើយ វានៅបានបង្ហាញឱ្យឃើញពីការបាត់បង់ការគ្រប់គ្រង ឬសិទ្ធិអំណាចលើរបស់អ្វីមួយដែលអ្នកធ្លាប់មានភាពជាម្ចាស់ទៀតផង។ ឧទាហរណ៍ដូចជាត្រូវគេបណ្ដេញឱ្យចេញពីការងារ ឬត្រូវដៃគូជំនួញបង្ខំឱ្យចាកចេញពីកិច្ចការជំនួញរបស់អ្នក។ ឧទាហរណ៍ដូចជាព្រឹត្តិការណ៍មួយដែលយើងចាំបានគឺអ្នកជំនួញម្នាក់ដែលពង្រឹងខ្លួនដោយខ្លួនឯង ដឹកនាំក្រុមហ៊ុនរបស់ខ្លួនឱ្យឈានដល់កម្រិតល្អមួយ តែគួរឱ្យសោកស្ដាយដែលបញ្ហាបែរជាត្រូវចប់ ដោយការដែលគាត់ត្រូវអ្នកកាន់ភាគហ៊ុនបង្ខំឱ្យគាត់ចេញពីក្រុមហ៊ុនដោយខ្លួនឯង។



www.elibraryofcambodia.org

# ប្រជ្រុយប្រឆាំងនឹងជោគជតាស្វាមី



ប្រជ្រុយត្រង់តំណែងទី19

ប្រជ្រុយនៅត្រង់តំណែងទី19លើថ្ងាសគឺជាប្រជ្រុយប្រឆាំងនឹង "ជោគសំណាងអ្នកដឹកនាំ" ឬ ជោគសំណាងស្វាមីរបស់នាងនេះមានន័យថាជីវិតគូស្រករបស់នាងនឹងទទួលនូវការផលប៉ះពាល់មិនល្អ។ និយាយរួមគឺមនុស្សស្រីម្នាក់នោះអាចទទួលបាននូវការប្រតិបត្តិមិនល្អពីស្វាមី ឬ ជីវិតគូស្រករគ្មានសេចក្តីសុខ។

តំណែងទី19ជាផ្នែកមួយនៃស្នូលកណ្តាលនៃមុខរបរសម្រាប់មនុស្សស្រី។ ម្យ៉ាងទៀត រាំងមុខរបរក៏មានឥទ្ធិពលចំពោះគុណភាពរបស់គូស្រកររបស់នាងដែរ។ ប្រជ្រុយត្រង់តំណែងនេះបង្ហាញឱ្យឃើញថាការមានឥទ្ធិពលរបស់បុគ្គលទី៣ អាចជាមូលហេតុធ្វើឱ្យមានការរាំងស្ទះនូវសេចក្តីសុខក្នុងជីវិតគូស្រកររបស់នាង។

សម្រាប់មនុស្សប្រុសប្រជ្រុយត្រង់តំណែងនេះត្រូវគេស្គាល់ក្នុងនាមថាជាប្រជ្រុយប្រឆាំងមុខរបរ។ ប្រជ្រុយត្រង់តំណែងនេះបង្ហាញឱ្យឃើញថាអាជីពរបស់គេមានការរាំងស្ទះ ឬមកដល់ចំណុចដែលមិនអាចឡើងខ្ពស់ទៅលើទៀតបាន ឬ ចៅហ្វាយរបស់គេពុំព្រមឱ្យគេឈានទៅដល់កម្រិតតំណែងខ្ពស់ក្នុងក្រុមហ៊ុនទេ។

មនុស្សប្រុសដែលមានប្រជ្រុយត្រង់តំណែងនេះត្រូវរង់ចាំរហូតដល់មានអាយុ30ឆ្នាំទើបមានសំណាងល្អ ហើយគេពុំគួរធ្វើជាអ្នកនយោបាយព្រោះគេមិនទទួលបានជោគជ័យ។



www.elibraryofcambodia.org

## ប្រជ្រុយសុខភាព



ប្រជ្រុយលើខ្នង់ច្រមុះ

ប្រជ្រុយនៅលើខ្នង់ច្រមុះ បង្ហាញឱ្យឃើញថាត្រង់វាំងសុខភាពត្រូវបានរាំងខ្ទប់ ធ្វើឱ្យដំណើរជីវិតជួបតែនឹងភាពលំបាកដោយសារតែជំងឺឈឺថ្កាត់រ៉ាំរ៉ៃ ឬ ដោយសារជំងឺឈឺថ្កាត់ដែលជាប់ប្រចាំកាយជាយូរមកហើយ ។ អ្នកដែលមានប្រជ្រុយត្រង់តំណែងនេះ តែងតែមានបញ្ហាទាក់ទងនឹងដំណើររបត់ឈាម ឬ បញ្ហាក្រពះ ឬ ប្រព័ន្ធប្រដាប់បញ្ចេញចោល ហើយជាអ្នកងាយឆ្លងជំងឺផ្តាសាយជាងគេជាងឯង ។



www.elibraryofcambodia.org

# ប្រជ្រុយក្រោមភ្នែក



ប្រជ្រុយត្រង់ថង់ក្រោមភ្នែក

ប្រជ្រុយត្រង់ថង់ក្រោមភ្នែកគឺបង្ហាញឱ្យឃើញពីភាពមិននឹងនរនៃអារម្មណ៍។ សម្រាប់មនុស្សស្រីវាជំនួសឱ្យការឈឺចិត្តដោយសារទំនាក់ទំនង ឬ ដោយសារកូន។ មនុស្សដែលមានប្រជ្រុយត្រង់កន្លែងនេះជាមនុស្សឆាប់រំជួលចិត្តហើយងាយយំសោកមិនថាជាលទ្ធផលមកពីបញ្ហាផ្លូវអារម្មណ៍របស់ខ្លួនឯង ឬ ដោយសារការមើលរឿងកំសត់នោះទេ។

ប្រជ្រុយនេះអាចមាននៅភ្នែកខាងស្តាំឬនៅភ្នែកខាងឆ្វេង ។

ប្រជ្រុយរងទឹកភ្នែកបែបនេះវាតែងកើតមានឡើងចំពោះមនុស្សដែលមានភាពលំបាកខាងផ្នែកអារម្មណ៍ ពួកគេតែងតែមានក្តីកង្វល់ជានិច្ច សូម្បីតែរឿងតូចតាចក៏គេភិតភ័យខ្វាយខ្វល់ដែរ។



www.elibraryofcambodia.org

# ប្រជ្រុយបាក់ដៃបាក់ជើង



ប្រជ្រុយត្រង់ខ្សែសំណើច

ប្រជ្រុយបាក់ដៃបាក់ជើងស្ថិតនៅត្រង់ខ្សែសំណើច ឬ ហ្វាលីង ។ ប្រជ្រុយនៅខាងឆ្វេង បង្ហាញឱ្យឃើញថាជើងឆ្វេងបាក់ (សម្រាប់មនុស្សប្រុស) និងដៃឆ្វេងបាក់ (សម្រាប់មនុស្សស្រី) ។ បើប្រជ្រុយត្រង់ផ្នែកខាងស្តាំបង្ហាញឱ្យឃើញថាជើងស្តាំបាក់ (សម្រាប់មនុស្សប្រុស) ហើយនឹង ដៃស្តាំបាក់ (សម្រាប់មនុស្សស្រី) ។ ក្រៅពីនេះវានឹងបានបង្ហាញឱ្យឃើញពីអាការឈឺត្រង់ បរិវេណនោះដែរ ។

មនុស្សដែលមានប្រជ្រុយបែបនេះមានការប្រឈមនឹងការដើរថយក្រោយក្នុងការ ស្វែងរកនិងការទទួលស្គាល់ក្នុងអាជីពការងារ ឬ ក្នុងសង្គមរបស់ខ្លួនទៀតផង ព្រោះខ្សែសំណើច បង្ហាញឱ្យឃើញពីការគោរពនិងកិត្តយសដែលបានទទួលពីអ្នកដទៃ។ ពេលខ្សែនេះត្រូវរាំងខ្ទប់ ដោយប្រជ្រុយ នោះសមត្ថភាពក្នុងការធ្វើឱ្យគេគោរពវាធ្លាក់ចុះទៅតាមនោះដែរ ។



www.elibraryofcambodia.org

# ប្រជ្រុយចូលចិត្តដឹងពីរឿងអ្នកដទៃ

តើអ្នកធ្លាប់ឃើញមនុស្សដែលចូលចិត្តចង់ដឹងចង់ឮរឿងអ្នកដទៃឬទេ? លើកក្រោយពេលដែលអ្នកឃើញមនុស្សប្រភេទនេះទៀតចូរអ្នកសង្កេតមើលថាតើគេមានប្រជ្រុយនៅត្រង់ចង្កាឬអត់?



ប្រជ្រុយត្រង់ចង្កា

ប្រជ្រុយបែបនេះបង្ហាញឱ្យឃើញពីភាពពូកែស៊ើប ពូកែសួរ។ ប្រជ្រុយនេះអាចនៅក្បែរចង្កាខាងឆ្វេង ឬ នៅខាងស្តាំចង្កា។ ទំហំរបស់ប្រជ្រុយអាចកំណត់ថាគេម្នាក់នោះជាមនុស្សគួរឱ្យរំខានប៉ុណ្ណា។ ប្រជ្រុយតូចបង្ហាញឱ្យឃើញថាគេម្នាក់នោះចូលចិត្តស៊ើបចូលចិត្តសួរសមល្មម តែប្រជ្រុយធំបង្ហាញឱ្យឃើញថាគេជាមនុស្សពូកែសួរហួសហេតុពេក។



www.elibraryofcambodia.org

បើវាជាប្រជ្រុយធំហើយមានដុះរោមនោះ ការចូលចិត្តដឹងឮរឿងអ្នកដទៃអាចនឹងអាក្រក់ទ្វេដង ។

ប៉ុន្តែ ចូរចាំទុកដែរថាទោះនេះជាប្រជ្រុយដែលចូលចិត្តដឹងឮរឿងអ្នកដទៃក៏ពិតមែន តែពួកគេក៏មានសតិបញ្ញាខ្ពស់ហើយមានភាពវៃឆ្លាតណាស់ដែរ ដែលគេតែងតែស្វែងរកចម្លើយ និងខិតខំកែលម្អជីវិតរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងជានិច្ច ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺទម្លាប់ដ៏អាក្រក់ម្យ៉ាងរបស់មនុស្សស្រីមួយចំនួន (អ្នកខ្លះគ្មានប្រជ្រុយនេះក៏មានទម្លាប់អាក្រក់នេះដែរ) ។ បើសុភាពនារីទាំងឡាយអាចកាត់បន្ថយ ឬ អាចឈប់ចង់ដឹងចង់ឮរឿងរបស់អ្នកដទៃកាន់តែច្រើនប៉ុណ្ណាគឺកាន់តែល្អ កាន់តែត្រូវបានគេគោរពនិងកាន់តែមានមន្តស្នេហ៍ប៉ុនហ្នឹងដែរ ។





www.elibraryofcambodia.org

# ប្រជ្រុយចោរលួច

តើអ្នកធ្លាប់ចាប់អារម្មណ៍ដែរឬទេថាគេម្នាក់នោះតែងតែត្រូវចោរលួចឬចោរប្លន់រហូត? ឬ បើមិនអ៊ីចឹងទេ គេតែងតែធ្វើឱ្យបាត់របស់របរជានិច្ចកាល? ចូរអ្នកត្រួតមើលត្រង់ប្រជ្រុយចោរលួច។



ប្រជ្រុយត្រង់ចុងស្បែកភ្នែកខាងលើ

ប្រជ្រុយប្រភេទនេះតែងឃើញត្រង់ចុងរាំងទ្រព្យសម្បត្តិដែលវានៅពីលើភ្នែក ក្នុងតម្រាបុរាណគេហៅថាចោរក្រៅផ្ទះ។ មនុស្សប្រុសដែលមានប្រជ្រុយត្រង់តំណែងនេះនៅចុងស្បែកភ្នែកឆ្វេង អាចត្រូវចោរប្លន់ក្នុងផ្ទះខ្លួន ឬ ផ្ទះរបស់ឪពុកម្ដាយ។ ប្រជ្រុយត្រង់ចុងស្បែកភ្នែកស្ដាំបង្ហាញឱ្យឃើញថាគ្រួសាររបស់ភរិយានឹងត្រូវចោរប្លន់។ អ្នកដែលមានប្រជ្រុយបែបនេះតែងតែធ្វើឱ្យបាត់របស់ទ្រព្យ ឬ ទុកទ្រព្យសម្បត្តិរបស់របរខុសកន្លែងជាដើម។



www.elibraryofcambodia.org

# ប្រជ្រុយមនុស្សឆ្កួត

ស្តាប់ទៅគួរឱ្យចម្លែកទេ? នេះគឺជាពាក្យដែលយើងប្រើសម្រាប់ហៅមនុស្សដែលធ្វើអ្វីមិនបានគិតពីទំនៀមទំលាប់ប្រពៃណីសង្គម ឬធ្វើអាកប្បកិរិយាប្លុកពាចម្លែក ជូនកាលមើលទៅពួកគេធ្វើដើម្បីតែខ្លួនឯងដោយមិនខ្វល់អំពីអ្នកដទៃ។



ប្រជ្រុយត្រង់ទ្វារជីវិត

ក្នុងសាស្ត្រានៃការមើលទម្រង់មុខរបស់ចិន នៅមុខត្រចៀក ឬ ទ្វារជីវិតដែលជាចំណុចផ្លាស់ប្តូរចំណុចប្រព័ន្ធប្រសាទទាំងអស់ក្នុងរាងកាយ។ ពេលវាត្រូវរាំងខ្ទប់ដោយអ្វីម្យ៉ាង ដូចជាប្រជ្រុយធំមួយ គឺធ្វើឱ្យគេម្នាក់នោះអាចមានការប្រែប្រួលខ្លះ ឬ ក្នុងករណីខ្លះអាចធ្វើឱ្យគេមានបញ្ហាផ្លូវចិត្ត ជាពិសេសបើគេមានកែវភ្នែកដែលមើលទៅដូចជាស្លុក់ៗនិងមានថ្ងាសជាំ។



www.elibraryofcambodia.org

# ប្រជ្រុយក្តីក្តាំង

តើមានទម្រង់មុខដែលឆក់ទាញបញ្ហាក្តីក្តាំង ឬ ទំនាស់វិវាទផ្លូវច្បាប់ដែរឬទេ? ច្បាស់ជាមាន! វាត្រូវបានកត់ត្រាទុកក្នុងតម្រាបុរាណឈ្មោះថា "ចៀនម៉ឹងអ៊ីវជឹកូនហ្វឹយវ៉ាំង" ដែលមានន័យថា "ពេលមានប្រជ្រុយត្រង់កូនម៉ឹន វានឹងធ្វើឱ្យមានបញ្ហាលើផ្លូវច្បាប់" ។



ប្រជ្រុយត្រង់កំផ្លៀង

ប្រជ្រុយនេះនៅត្រង់តំណែងចៀនម៉ឹនដែលសំដៅដល់វាំងតូស្រេករ (សម្រាប់មនុស្សប្រុស) ដែលបង្ហាញឱ្យឃើញពីបញ្ហាផ្លូវច្បាប់យ៉ាងគ្មានព្រំដែន ឬ បញ្ហាលំបាកដែលកើតឡើងពេញមួយជីវិតរបស់គេ ដោយមានមូលហេតុមកពីការលួចខាំពីក្រោយ (គេលួចធ្វើបាប) រហូត ឬ ជាមនុស្សនៅចំកណ្តាលនៃបញ្ហាត្រូវគេនិន្ទា។ ព្រំដែននៃបញ្ហាអាស្រ័យលើទំហំនៃប្រជ្រុយ ឬ ស្នាមដៅ បើជាប្រជ្រុយទំហំតូចហើយមានពណ៌ច្បាស់បញ្ហានោះពុំជាបញ្ហាធំអ្វីទេ គ្រាន់តែវាធ្វើឱ្យមានការរំខានចិត្តខ្លះៗតែប៉ុណ្ណោះ។ តែបើប្រជ្រុយនោះជាប្រជ្រុយធំ នោះយើងអាចនិយាយថាបញ្ហានោះជាបញ្ហាធំ ។



www.elibraryofcambodia.org

# ប្រជ្រុយបណ្ដេញភាពមានបាន



ប្រជ្រុយត្រង់ច្រមុះ

ប្រជ្រុយបណ្ដេញភាពមានបានស្ថិតនៅត្រង់ច្រមុះ ឬ ស្លាបច្រមុះ ហើយត្រូវគេចាត់ទុកថាជារន្ធរបស់ឃ្លាំងនៃភាពមានបាន ព្រោះច្រមុះជាភាពមានបាន ហើយប្រជ្រុយត្រង់កន្លែងនេះបង្ហាញឱ្យឃើញពីការហូរចេញនៃភាពមានបាន ឬ បង្ហាញឱ្យឃើញពីបញ្ហាដែលទាក់ទងនឹងភាពមានបាន។ អ្នកដែលមានប្រជ្រុយ ឬ ស្នាមដៅត្រង់ចំណុចនេះមិនអាចសន្សំលុយបានទេ ឬ តែងតែជួបនូវភាពខាតបង់លុយកាក់រហូត នេះមកពីឃ្លាំងនៃភាពមានបានហូរចេញនេះឯង។ បើប្រជ្រុយ ឬ ស្នាមដៅមានទំហំធំពេក វាបង្ហាញឱ្យឃើញពីបញ្ហាពេញមួយជីវិតរបស់គេម្នាក់នោះ។ និយាយរួម វាមិនមែនជាប្រជ្រុយល្អទេ។



www.elibraryofcambodia.org

## ប្រជ្រុយភារៈ

ប្រជ្រុយនេះស្ថិតនៅលើស្មា ( ត្រង់ណាក៏ដោយ) បង្ហាញនូវការជួបបញ្ហាដោយសារតែអ្នកដទៃជារឿយៗ ឬ ត្រូវទទួលរែកពន់នូវទំនួលខុសត្រូវដែលមើលទៅដូចជាធ្វើឱ្យអ្នកមានសេចក្តីទុក្ខនិងភារៈក្នុងចិត្តច្រើន។



ប្រជ្រុយត្រង់ស្មា

លើសពីនេះទៅទៀត ប្រជ្រុយភារៈបង្ហាញឱ្យឃើញពីមនុស្សដែលត្រូវរែកពន់ភារកិច្ចគ្រួសារអស់មួយជីវិត។ បើប្រជ្រុយនេះនៅលើស្មាឆ្វេងជាភារៈពីញាតិភេទប្រុសដែលអ្នកត្រូវរែកពន់ បើប្រជ្រុយនេះនៅត្រង់ស្មាស្តាំនោះជាភារៈពីញាតិភេទស្រីរបស់អ្នក ដូចជាម្តាយរបស់អ្នក ឬ បងប្អូនស្រីរបស់អ្នកជាដើម។



www.elibraryofcambodia.org

## យើងសូមបង្ហាញជូននូវប្រជ្រុយល្អមួយចំនួនដូចខាងក្រោមនេះ

## ប្រជ្រុយកំណប់ទ្រព្យក្នុងព្រៃ



ប្រជ្រុយក្នុងជើងសក់

ប្រជ្រុយបែបនេះស្ថិតនៅក្នុងជើងសក់ត្រង់តំណែងខាងលើស្លឹកត្រចៀកផ្នែកចំហៀងនៃក្បាល។ ប្រជ្រុយនេះមើលមិនឃើញទេព្រោះវានៅក្នុងសក់ មានសក់បិទបាំងជិត តែបើអ្នកសម្លឹងមើលដោយយកចិត្តទុកដាក់អ្នកនឹងអាចមើលវាឃើញនេះជា "ប្រជ្រុយកំណប់ទ្រព្យក្នុងព្រៃ" ដែលបង្ហាញឱ្យឃើញពីអាថ៌កំបាំង ឬ សមត្ថភាពលេចធ្លោល្អឯក ជាមនុស្សមានពរពីស្ថានសួគ៌ ឬ ត្រូវជោគជតាកំណត់ឱ្យកើតមកជាមនុស្សអស្ចារ្យ ជាមនុស្សមានសមត្ថភាព មានឱកាសសម្រេចគោលបំណង ក្លាយជាមនុស្សដែលមានឈ្មោះបោះសំឡេងនិងមានបាន។ ក្នុងការសិក្សាអំពីការមើលទម្រង់មុខ សរសៃសក់ជំនួសដោយធាតុឈើដោយសារយើងមានសរសៃសក់លើក្បាលច្រើនជាងមួយសរសៃនោះហើយទើបបានជាយើងហៅថា "ព្រៃ"។



www.elibraryofcambodia.org

# ប្រជ្រុយទេពសេពសោយ



ប្រជ្រុយនៅលើមុំមាត់

ប្រជ្រុយទេពសេពសោយស្ថិតលើបបូរមាត់លើត្រង់មុំមាត់  បង្ហាញថាគេជាមនុស្សដែលសប្បាយរីករាយនឹងការសេពសុខអស់មួយជីវិត ថែមទាំងបានសប្បាយនឹងទស្សនីយ៍ភាពដ៏ល្អៗ រួមទាំងអាហារឆ្ងាញ់ និងស្រីស្អាតៗទៀតផង។ ប្រជ្រុយទេពសេពសោយអាចចូលក្នុងល័ក្ខខ័ណ្ឌខាងលើបានលុះណាតែវាមិនមែនជាប្រជ្រុយទំហំតូចៗ ឬ ជាស្នាមអុជ។ ពួកគេនឹងអាចសប្បាយរីករាយនឹងអាហារល្អៗ ជួនកាលមានគេចេញលុយឱ្យទៀតផង មានន័យថាពេលខ្លះ ពួកគេចេញទៅញ៉ាំអាហារក្រៅផ្ទះដោយមិនចាំបាច់ត្រូវចំណាយលុយថ្លៃអាហារឡើយ។



www.elibraryofcambodia.org

# ប្រជ្រុយកតញ្ញូ

តើប្រជ្រុយកតញ្ញូអាចជារឿងដ៏សំខាន់ចំពោះឪពុកម្តាយដែលចង់ដឹងថាកូនរបស់ខ្លួនមានភាពកតញ្ញូដែរឬទេ?



ប្រជ្រុយត្រង់ផ្នែកខាងក្រោយនៃស្លឹកត្រចៀក

ប្រជ្រុយប្រភេទនេះនៅផ្នែកខាងក្រោយនៃស្លឹកត្រចៀកដែលបង្ហាញថាគេគឺជាមនុស្សកតញ្ញូ ចេះមើលថែយកចិត្តទុកដាក់ចំពោះឪពុកម្តាយនិងញាតិមិត្តចាស់ទុំបានយ៉ាងល្អ។ មិនតែប៉ុណ្ណោះ គេជាមនុស្សចេះស្តាប់បង្គាប់ឪពុកម្តាយ បើកូនរបស់អ្នកមានប្រជ្រុយប្រភេទនេះអ្នកអាចប្រាកដក្នុងចិត្តបានថាពេលអ្នកចាស់ទៅ អ្នកពុំចាំបាច់ទៅនៅក្នុងមណ្ឌលចាស់ជរានោះទេ។



www.elibraryofcambodia.org

# ប្រជ្រុយទុកលុយ (ប្រជ្រុយស្រូបយកភាពរីកចម្រើនរុងរឿង)



ប្រជ្រុយក្រោមរន្ធច្រមុះ

បើអ្នកមានប្រជ្រុយក្រោមរន្ធច្រមុះ ឬ ក្បែររន្ធច្រមុះរបស់អ្នក ចូរកុំកាត់វាចោល! ព្រោះវាជាភ្នាក់ងាររក្សាសុវត្ថិភាពដែលការពារឃុំគ្រងឃ្លាំងនៃភាពមានបានរបស់អ្នកមិនឱ្យហូរចេញ។ អ្នកមិនត្រឹមតែបានសន្សំលុយទុកនោះទេ តែថែមទាំងមានសមត្ថភាពអាចទុកលុយបានដោយងាយ ឬ មានលុយទុកសម្រាប់ចាយវាយក្នុងគ្រាចាំបាច់ទៀតផង។



www.elibraryofcambodia.org

# ប្រជ្រុយគុជក្នុងគុម្ពស្មៅ



ប្រជ្រុយក្នុងចិញ្ចើម

តម្រាបុរាណហៅស្នាមអុជ ឬ ស្នាមដៅដែលបង្កប់នៅក្នុងចិញ្ចើមថា "គ្រាប់គុជក្នុងគុម្ពស្មៅ" ។ ប្រជ្រុយនេះបង្ហាញឱ្យឃើញពីកំណប់ទ្រព្យដែលត្រូវស្មៅដុះលប់ទៅហើយ វាបង្ហាញឱ្យឃើញពីការតាំងចិត្តខ្ពស់ គួបផ្សំនឹងការខិតខំព្យាយាមក្នុងការធ្វើអ្វីមួយ ហើយក្រោយពីបានចំណាយការខិតខំព្យាយាមអស់ទៅជាច្រើនហើយនោះ គ្រាប់គុជក៏ផុសឡើងមក ហើយសមត្ថភាពរបស់គេម្នាក់នោះនឹងត្រូវបានគេទទួលស្គាល់ ។ ប៉ុន្តែមានចំណុចខ្សោយមួយនៃការមានស្នាមអុជ ឬ ស្នាមដៅត្រង់តំណែងនេះគឺគ្រោះថ្នាក់ខាងផ្លូវទឹក ដូចជាអាចនឹងត្រូវរលាកទឹកក្តៅ ឬ រអិលដួលដោយសារទឹកលើផ្ទៃដី ឬ ក្នុងករណីធ្ងន់គឺអាចត្រូវលង់ទឹកស្លាប់ ។



www.elibraryofcambodia.org

# ស្លាមដៅសតិបញ្ញា



ប្រជ្រុយត្រង់ជាយត្រចៀក

នេះជាស្លាមដៅត្រង់ជាយខាងក្រៅនៃត្រចៀកដែលយើងអាចមើលឃើញបាន។ វាបង្ហាញឱ្យឃើញពីមនុស្សដែលមានសតិបញ្ញាខ្ពស់ឈ្លាសវៃជាងមនុស្សធម្មតា។ ម្យ៉ាងទៀតគេរមែងតែជាមនុស្សដែលប្រលងបានពិន្ទុខ្ពស់។



www.elibraryofcambodia.org

# ស្លាមដៅកូនភ្លោះ



ប្រជ្រុយត្រង់ប្រឡាយបបូរមាត់លើ

បើវាជាស្នាមដៅតូចៗដូចស្នាមអុជត្រង់ប្រឡាយបបូរមាត់លើនោះ វាបង្ហាញឱ្យឃើញថាគេ ម្នាក់នោះអាចនឹងផ្តល់កំណើតកូនភ្លោះ បើវាជាប្រជ្រុយ វានឹងបង្ហាញពីភាពលំបាកក្នុងការផ្តល់កំណើតកូនភ្លោះក្នុងពេលសម្រាល ព្រោះប្រឡាយបបូរមាត់លើត្រូវបានរាំងខ្ទប់គឺមានន័យថាវាជំនួសឱ្យអវយវៈបន្តពូជដែលត្រូវរាំងខ្ទប់ ។



www.elibraryofcambodia.org

# ប្រជ្រុយហុកឡុកស៊ីវ (ហ្វូលូសូវ)



-ហុក ( ហ្វូគឺសំណាង ឬ សេចក្តីចម្រើនរុងរឿង)

-ឡុក ( លូគឺភាពមានបាន)

-ស៊ីវ( សូវគឺ អាយុ វណ្ណៈ)

ជាគុណសម្បត្តិសំខាន់បីប្រការដែលមនុស្សភាគច្រើនរីករាយចង់ឱ្យមានវាបន្ថែមក្នុងជីវិត។ មានទាំងទ្រព្យរីករាយនិងភាពសម្បូរសុខសប្បាយក្នុងការមានទ្រព្យហើយប្រការសំខាន់ជាងនោះគឺសំណាងល្អហើយមានអាយុយឺនយូរ។

បើអ្នកមានប្រជ្រុយ3 គ្រាប់រៀងលំដាប់គ្នាដោយចាប់ផ្តើមពីឆ្អឹងខ្នង ឬ គល់ករហូតដល់ឆ្អឹងកំប៉េះគូថដែលគេហៅថាជាប្រជ្រុយហុកឡុកស៊ីវ ( ហ្វូលូសូវ) នោះ វាបង្ហាញឱ្យឃើញថាអ្នកនឹងមានសេចក្តីចម្រើនរុងរឿង ទ្រព្យសម្បត្តិនិងអាយុយឺនយូរ នេះជាប្រជ្រុយល្អតែកម្របានជួបណាស់។



www.elibraryofcambodia.org

# មេរៀនទី៦

# ផ្ទៃមុខមិនមានថ្ងៃដូចដើមទៀតទេ វិធីអនុវត្តការមើលទម្រង់មុខ

គន្លឹះសំខាន់សម្រាប់ការចាប់ផ្តើមអនុវត្តប្រើក្នុងការប្រើទម្រង់មុខ គឺ100តំណែងនៃផ្ទៃមុខនិងវាំងទាំង12 ព្រោះខ្លឹមសារពិតនៃការមើលទម្រង់មុខគឺការបែ្របអត្ថន័យតំណែងទាំង100ជាមួយនឹងវាំងទាំង12 ។

## ការត្រួតពិនិត្យមើលចំណុចស្នេហា

គឺស្ថិតនៅត្រង់វាំងគូស្រករ! បើអ្នកមិនប្រាកដក្នុងចិត្តថាតើវាំងគូស្រករនៅត្រង់ណាទេ ចូរអ្នកត្រឡប់ទៅមើលត្រង់មេរៀនទី4ដើម្បីរំលឹកការចងចាំរបស់អ្នក ។

តំណែងដែលខុសគ្នានៃវាំងគូស្រករគឺអាស្រ័យលើថាអ្នកសួរសំណួរជាមនុស្សស្រី ឬជាមនុស្សប្រុស វាំងគូស្រកររបស់មនុស្សស្រីស្ថិតនៅត្រង់ច្រមុះរបស់នាង ។ យើងពិនិត្យមើលទំហំច្រមុះរបស់នាងថាតើវាមានទំហំធំឬតូច ។

ត្រង់ចំណុចនេះអ្នកប្រហែលជាគិតថាកុំអាលសិន ទំហំជាបញ្ហានៃការប្រៀបធៀប ។ ពេលខ្លះខ្ញុំអាចគិតថាវាតូច តែអ្នកដទៃគិតថាវាធំក៏អាចថាបាន ។ តើខ្ញុំអាចយល់បានយ៉ាងម៉េចទៅ?

ចម្លើយគឺសម្រេចតាមការប្រៀបធៀបរវាងច្រមុះនិងទំហំផ្ទៃមុខរបស់នាង ។ បើផ្ទៃមុខរបស់នារីម្នាក់នោះទូលាយ ច្រមុះដែលធំត្រូវគេចាត់ទុកថាមានទំហំ "មធ្យម" តែបើផ្ទៃមុខរបស់អ្នកនាងតូច ច្រមុះដែលតូចចាត់ទុកថាមានទំហំ "មធ្យម" ។



www.elibraryofcambodia.org



មនុស្សស្រីដែលមានច្រមុះតូច

សម្រាប់ច្រមុះរបស់មនុស្សស្រី យើងចង់ឱ្យវាមានទំហំមធ្យម។ តើហេតុអ្វី? បើច្រមុះរបស់នាងធំហួសពេក វាចូលលក្ខណៈ "ភ្នំឯកោ"។ "ភ្នំឯកោ" គឺជាពាក្យដែលប្រើអធិប្បាយពីទម្រង់មុខដែលមានលក្ខណៈផ្សេងៗគ្នា។ តើឯកោសំដៅលើអ្វី? ឯកោបង្ហាញឱ្យឃើញពីវ័យជរាដែលមិនមានកូនចៅចោមរោមហែហម ហើយជួនកាលមានលុយកំណត់ក្នុងការចំណាយ ឬ ជាវ័យជរាដែលមានក្តីលំបាកលំបិន។ លក្ខណៈបែបនេះមិនមែនជា "ជីវិតល្អ"សម្រាប់មនុស្សស្រីទេ។

ចំណុចដែលសំខាន់ខ្លាំងសម្រាប់មនុស្សស្រីក្នុងពេលប្រមើលមើលច្រមុះគឺខ្នង់ច្រមុះ។ ខ្នង់ច្រមុះដែលល្អត្រូវតែត្រង់ហើយមានបារមីដែលបង្ហាញឱ្យឃើញពីស្វាមីដែលមានចំណេះដឹងមានសមត្ថភាព។

ច្រមុះដែលល្អបំផុតគឺច្រមុះដែលមានខ្នង់ច្រមុះត្រង់ ចុងច្រមុះមូល ហើយស្លាបច្រមុះមានសាច់ដែលមិនត្រឹមតែបង្ហាញពីស្វាមីដែលមានចំណេះដឹងនិងសមត្ថភាពតែប៉ុណ្ណោះទេ តែវាបង្ហាញឱ្យឃើញពីស្វាមីដែលជាអ្នកមានទៀតផង។



www.elibraryofcambodia.org



មនុស្សស្រីដែលច្រមុះមានសាច់

ពេលខ្លះយើងមិនត្រឹមតែចង់ដឹងពីរឿងគូស្រករបស់ខ្លួនប៉ុណ្ណោះទេ យើងថែមទាំងចង់ដឹងអំពីទំនាក់ទំនងក្នុងជីវិតគូស្រករបស់ខ្លួនទៀត ថាតើវាមានសេចក្ដីសុខប៉ុណ្ណា?



ក្នុងការសិក្សាសាស្ត្រការមើលទម្រង់មុខនោះ កែវភ្នែកមិនត្រឹមតែជាមាត់ច្រកនៃចិត្តវិញ្ញាណតែប៉ុណ្ណោះទេ តែវាជាច្រកទ្វារបេះដូងទៀតផង ។

តើអ្នកធ្វើដូចម្ដេចទើបដឹងថាអ្នកនោះសោកសៅក្នុងចិត្ត? តើអ្នកធ្វើដូចម្ដេចដើម្បីឱ្យដឹងថាគេម្នាក់នោះកំពុងមានសេចក្ដីសុខ? ចម្លើយគឺអ្នកអាចសម្លឹងមើលកែវភ្នែករបស់នាងបាន ។



www.elibraryofcambodia.org

កែវភ្នែកដែលមានសំណើម មានទឹកភ្នែក និងមានខ្លាញ់បង្ហាញឱ្យឃើញពីជីវិតគូស្រករ ឬ ទំនាក់ទំនងដែលលំបាក ។ កែវភ្នែកដែលមុតហើយស្រស់ថ្លាមានសម្រស់ បង្ហាញឱ្យឃើញពីទំនាក់ទំនងដែលមានសេចក្តីសុខ ។



ភ្នែកមុតហើយស្រស់ថ្លា

មនុស្សដែលមានភ្នែកជ្រៅ ( មានន័យថាលិចជ្រៅទៅក្នុងទម្រង់មុខ ឬមើលទៅដូចជាលិបចូលទៅក្នុងផ្ទៃមុខ មើលរូបខាងក្រោម) រមែងមានបញ្ហាផ្នែកសតិអារម្មណ៍ ទំនាក់ទំនង ឬជីវិតគូស្រកររបស់ពួកនាងមិនមានភាពជាទីពេញចិត្តទេ ។ បើអ្នកឃើញមនុស្សភ្នែកជ្រៅ ហើយកែវភ្នែករបស់ពួកនាងស្ពឹកស្រពន់ មិនរហ័សរហួន អ្នកអាចប្រាកដក្នុងចិត្តបាននាងគ្មានសេចក្តីសុខទេ( នេះមិនមែននិយាយអំពីការដែលគេងច្រើនហួសពេកនោះទេ) ។



កែវភ្នែកលិបចូលនិងស្រអាប់



www.elibraryofcambodia.org

# ជួបស្វាមីដែលល្អនោះជានៅឆ្ងាយរាប់រយយោជន៍



ច្រមុះគឺរាំងមានបានរបស់មនុស្សប្រុស។ វាបង្ហាញថា គេមានសមត្ថភាពក្នុងការរកទ្រព្យសម្បត្តិប៉ុណ្ណោះ។ ដូច្នេះវត្ថុដំបូងគឺត្រូវមើលត្រង់ច្រមុះរបស់គេ។ ហើយចុះច្រមុះល្អជាច្រមុះដូចម្ដេច? ចូរអ្នកពិនិត្យមើលថា ខ្នង់ច្រមុះត្រង់ហើយទូលាយ ចុងច្រមុះមូលហើយមានសាច់ ស្លាបច្រមុះទូលាយ ហើយអ្វីដែលសំខាន់បំផុតនោះមិនឃើញរន្ធច្រមុះពេលមើលចំពីមុខ។





www.elibraryofcambodia.org



ខ្ទង់ច្រមុះត្រង់ហើយទូលាយ ចុងច្រមុះមូលហើយមានសាច់

ច្រមុះវៀចហើយចុងច្រមុះស្រួចបង្ហាញឱ្យឃើញពីលក្ខណៈរបស់មនុស្សបោកប្រាស់ មិនស្មោះត្រង់ដែលមិនមែនជាបុរសដែលគួរយកមកធ្វើជាស្វាមីឡើយ។

រន្ធច្រមុះដែលអាចមើលឃើញបង្ហាញឱ្យឃើញពីការចំណាយខ្ជះខ្ជាយ មិនសំខាន់ឡើយថាចុងច្រមុះរបស់គេនោះធំប៉ុណ្ណា ឬ ស្លាបច្រមុះរបស់ពួកគាត់មានសាច់ច្រើនប៉ុណ្ណា សមត្ថភាពក្នុងការរកទ្រព្យសម្បត្តិមិនមានប្រយោជន៍អ្វីទេ បើគេបំផ្លាញលុយកាក់នោះ។ អូ! រោមច្រមុះក៏ដូចគ្នាដែរ វាមិនត្រឹមតែជាបញ្ហាដែលធ្វើឱ្យអស់អារម្មណ៍ប៉ុណ្ណោះទេ សុភាពនារីទាំងឡាយគួរចងចាំថា មនុស្សប្រុសប្រភេទនេះអាចរកលុយបានត្រឹមតែមួយចាយ១ខ្លួនឯងប៉ុណ្ណោះ កុំបាច់ឡើយនិយាយពីការចិញ្ចឹមអ្នកទៀតនោះ។



រោមច្រមុះល្បៀន



www.elibraryofcambodia.org

ចូរពិនិត្យមើលខ្នង់ច្រមុះ! បើខ្នង់ច្រមុះរបស់ពួកគេទាប ហើយរោមចិញ្ចើមរបស់គេធ្លាក់ចុះ គេនឹងមានការរាប់រកចំពោះខ្លួនឯងទាប ។ មនុស្សស្រីភាគច្រើនមិនចង់រៀបការជាមួយស្វាមីដែលធ្វើខ្លួនប្រដូចនឹងកម្រាលព្រំជូតជើងនោះទេ គេចង់បានមនុស្សប្រុសដែលមានជំនឿជាក់លើខ្លួនឯងជាស្វាមី ។



ខ្នង់ច្រមុះទាប

ខ្នង់ច្រមុះប៉ោងបង្ហាញឱ្យឃើញថាគេជាមនុស្សឆាប់ខឹង ជាពិសេសបើរោមចិញ្ចើមរបស់គេចង្អុលឡើងលើ រោមចិញ្ចើមដែលចង្អុលឡើងលើមិនត្រឹមតែធ្វើឱ្យគេម្នាក់នោះមើលទៅដូចជាកាចសាហាវប៉ុណ្ណោះទេ តែពេលយកមកផ្គួបនឹងខ្នង់ច្រមុះប៉ោងនោះវាកាន់តែបង្ហាញឱ្យឃើញពីភាពឆាប់ខឹងឆេវឆាវរបស់គេថែមទៀត ។



www.elibraryofcambodia.org



ខ្ទង់ច្រមុះខ្ពស់

អ្នកក៏អាចត្រួតមើលស្នាមឆ្នូតផ្សេងៗលើច្រមុះផងដែរ បើអ្នកកំលោះដែលអ្នកកំពុងពិចារណានោះមានស្នាមឆ្នូតនៅលើច្រមុះរបស់គេ លក្ខណៈបែបនេះបង្ហាញឱ្យឃើញថាគេមិនអាចចុះសម្រុងជាមួយគូស្រករគេបានទេ។ ប្រការសំខាន់ដែលត្រូវគិតនោះគឺមិនមែនជាកំហុសរបស់គូស្រករគេទេ។ វាមិនសំខាន់ទេថាបុរសម្នាក់នោះនៅជាមួយនរណា ព្រោះនៅទីបំផុតទំនាក់ទំនងរបស់គេក៏នឹងក្លាយទៅជាបែបនោះដោយខ្លួនឯង។ ទោះបីជាយើងម្នាក់ៗធ្លាប់កុហកលេងជាមួយអ្នកដទៃម្តងម្កាលក៏ដោយ តែមិនមាននរណាចូលចិត្តរៀបការជាមួយអ្នកដែលមាននិស្ស័យចូលចិត្តកុហកនោះទេ។ ដូច្នេះចូរប្រយ័ត្នប្រយែងចំពោះមនុស្សប្រុសដែលមានបបូរមាត់ស្តើង ព្រោះគេមិនត្រឹមតែជាមនុស្សនិយាយច្រើនប៉ុណ្ណោះទេ តែរាល់សម្តីរបស់គេមានបង្កប់នូវពាក្យកុហកខ្លះដែរ ជាពិសេសបើមាត់ដែលស្តើងនោះគួបផ្សំនឹងច្រមុះក្រពឹត។



www.elibraryofcambodia.org



ច្រមុះក្រពឹត

សន្មត់ថាបុរសម្នាក់នោះមានច្រមុះល្អហើយ ដូច្នេះយើងសូមបន្តទៅថ្ងាសទៀត ។ តើអ្នកចង់បានមនុស្សប្រុសដែលមានថ្ងាសខ្ពស់ហើយទូលាយដូចនៅក្នុងរូបខាងក្រោមដែរឬទេ?



ថ្ងាសខ្ពស់ ទូលាយ ហើយស្មើ ( មិនមានស្នាម )

ថ្ងាសខ្ពស់ហើយទូលាយមិនត្រឹមតែបង្ហាញឱ្យឃើញពីមនុស្សដែលមានមហិច្ឆិតាប៉ុណ្ណោះទេ តែវានៅបង្ហាញពីមនុស្សនោះនឹងឡើងដល់តំណែងខ្ពស់ ហើយមានមានឋានៈក្នុងសង្គមខ្ពស់ទៀតផង ។ នេះជាលក្ខណៈរបស់មនុស្សប្រុសដែលមានសតិបញ្ញានិងមានទស្សនក្នុងការវិភាគល្អ ។



www.elibraryofcambodia.org

ប្រការសំខាន់នោះគឺមិនត្រូវខ្វល់ខ្វាយចំពោះការមានថ្ងាសខ្ពស់ ទូលាយ និងថ្ងាសខ្ពស់តែពើងនេះទេ។ ជាពិសេសនៅត្រង់កណ្ដាលថ្ងាសដូចក្នុងរូបខាងក្រោម ថ្ងាសពើងជាពិសេសគឺពើងត្រង់កណ្ដាលថ្ងាសបង្ហាញឱ្យឃើញពីមនុស្សដែលនៅឯកោ។ មនុស្សប្រុសដែលមានថ្ងាសខ្ពស់ដែលមានលក្ខណៈទូលមិនស្មើគ្នាបង្ហាញឱ្យឃើញថាគេមានទស្សនក្នុងការវិភាគនិងសមត្ថភាពក្នុងការគិតទាប។



ថ្ងាសពើងតិចតួច

របាយការណ៍គុណសម្បត្តិបន្ថែមដែលមនុស្សស្រីត្រូវការគឺ ស្វាមីដែលមានទឹកចិត្តចេះសណ្ដោសមេត្តានិងព្យាយាមរក្សាទំនាក់ទំនងរវាងប្ដីប្រពន្ធឱ្យបានល្អ។



www.elibraryofcambodia.org

ការចង់និយាយថាគេម្នាក់នោះមានលក្ខណៈទន់ភ្លន់ប៉ុណ្ណានោះ យើងត្រូវមើលភ្នែករបស់គេ។ យើងចង់ឱ្យមនុស្សប្រុសមានភ្នែកធំបន្តិច ព្រោះវាជាសញ្ញាបង្ហាញថាគេជាមនុស្សមានមេត្តា មានចិត្តល្អបរិសុទ្ធ។ កែវភ្នែកស្រទន់បង្ហាញឱ្យឃើញពីមនុស្សដែលមានចិត្តល្អ មានមេត្តា។ កែវភ្នែកដាច់ខាតហើយមើលទៅដូចជាសំឡក់បង្ហាញថាគេជាមនុស្សកាចសាហាវ ដូច្នេះចូរចាំទុកថាកុំមើលតែច្រមុះរបស់គេអីគឺត្រូវមើលភ្នែកផងដែរ។



ភ្នែកទន់ភ្លន់



ភ្នែកសាហាវ

ទោះជាអ្នកមិនអាចរកលក្ខណៈឱ្យបានល្អសព្វគ្រប់លើបុរសក្នុងក្ដីស្រមៃរបស់អ្នកក៏ដោយ តែអ្នកត្រូវរៀបលំដាប់ចំណុចសំខាន់តាមតម្រូវការរបស់អ្នក ជួនកាលអ្នកអាចជួបនឹងបុរសដែលជាអ្នកមានទ្រព្យតែឆាប់ខឹងឆេវឆាវ ឬមួយគេអាចជាមនុស្សទន់ភ្លន់ហើយមានទឹកចិត្ត តែមិនមែនជាអ្នកមានតាមដូចដែលអ្នកចង់បានឡើយ។



www.elibraryofcambodia.org

សុភាសិតចិននិយាយថា "អាយុ3ឆ្នាំកំណត់អាយុ80ឆ្នាំ" មានន័យថាធម្មជាតិមូលដ្ឋានរបស់អ្នកខណៈពេលអាយុ៣ឆ្នាំនិងមានលក្ខណៈគង់វង្សដូចដើមរហូតដល់អ្នកអាយុ80ឆ្នាំ។ ធម្មជាតិមូលដ្ឋានរបស់មនុស្សម្នាក់នឹងមិនមានការប្រែប្រួលច្រើនទេសូម្បីតែក្នុងការមើលទម្រង់មុខដែលមានការប្រែប្រួលច្បាស់លាស់ក្នុងកម្រិតមួយ។ ទោះជាទម្រង់មុខរបស់មនុស្សយើងប្រែប្រួលទៅតាមពេលវេលាកន្លងទៅ តែគ្រោងឆ្អឹងរបស់ពួកគេមិនមានការប្រែប្រួលច្រើនទេ។ ផ្ទៃមុខរបស់ពួកគេអាចមានសាច់កាន់តែច្រើន ឬ តិចជាងមុនអាចមានសម្លាកស្នាកស្នាមមួយកន្លែងពីរកន្លែងទៅតាមពេលវេលាយូរឆ្នាំ តែមូលដ្ឋានរបស់វាមានលក្ខណៈដូចដើម។

ដូច្នេះចូរកុំសង្ឃឹមថាអាចប្តូរឧបនិស្ស័យរបស់មនុស្សពីបាតដៃមកជាខ្នងដៃបានឱ្យសោះព្រោះវាដូចជាការរែកថ្មឡើងដើមត្នោតអ៊ីចឹងដែរ ហើយវាមិនបានផលប្រយោជន៍អ្វីទេនៅទីបំផុតនោះ។ នារីមួយចំនួនតែងតែសង្ឃឹមថា ខ្លួននឹងអាចកែប្រែបុរសរបស់ខ្លួនក្រោយពីរៀបការហើយ ប៉ុន្តែសូមនាងចងចាំផងថាវាមិនងាយស្រួលដូចការគិតនោះឡើយ។

អ្នកអាចចង់ឃើញនូវ "ភាពអាចិកំបាំង" និងចង់ឃើញកិច្ចការវែងឆ្ងាយរបស់គេម្នាក់នោះ ចូរអ្នកកុំចង់ឃើញតែក្នុងរយៈពេលខ្លីថ្មី ជាពិសេសក្នុងកំឡុងពេលនោះមនុស្សម្នាក់អាចមិនមែនជាអ្នកមានទ្រព្យសម្បត្តិនាពេលនេះ តែមិនមែនមានន័យថាគេមិនអាចក្លាយជាអ្នកមានទៅអនាគតនោះទេ។ ដូចគ្នាដែរ មនុស្សប្រុសដែលមើលទៅទំនងដូចជានឹងមានអនាគតភ្លឺថ្លាក៏អាចមិនមានលក្ខណៈល្អយូរអង្វែងដែរ។

ចុងបញ្ចប់ ជួនកាលឧបនិស្ស័យជាមូលដ្ឋានមានភាពសំខាន់ច្រើនជាងទ្រព្យសម្បត្តិលុយកាក់ កិត្តិយសទៅទៀត។ ដូច្នេះសុភាពនារីទាំងឡាយ ចូរអ្នកគិតឱ្យបានសព្វជ្រុងជ្រោយទាក់ទងនឹងលក្ខណៈឧត្តមគតិដែលបុរសរបស់អ្នកគួរមាន។



www.elibraryofcambodia.org

# ត្រូវការមនុស្សស្រីល្អ



មនុស្សស្រីលួចសម្លឹងមើលបុរសដែលសមនឹងខ្លួនប៉ុណ្ណា ក៏រមែងមានមនុស្សប្រុសដែលលួចសម្លឹងរកមើលនារីដែលសមនឹងខ្លួនប៉ុណ្ណោះដែរ ។ មនុស្សស្រីខ្លាចការរៀបការជាមួយមនុស្សប្រុសខុសប៉ុណ្ណា មនុស្សប្រុសក៏បារម្ភបញ្ហារៀបការជាមួយមនុស្សស្រីខុសប៉ុណ្ណោះដែរ ។

យុគសម័យមុន មនុស្សប្រុសអាចមានប្រពន្ធដើមម្នាក់ ជាមួយប្រពន្ធចុង2-3នាក់ នៅក្នុងផ្ទះតែអាចនៅរួមគ្នាយ៉ាងមានសេចក្តីសុខក្នុងគ្រួសារ ។

ទោះជានៅសម័យមុនការរៀបការមានការប្រើពាក្យសម្បថក៏ដោយ តែការរៀបការជាមួយមនុស្សខុសក៏នៅតែបង្កើតឱ្យមានបញ្ហាលំបាកដដែល ។

បច្ចុប្បន្ននេះមនុស្សប្រុសភាគច្រើនដែលមានសេចក្តីសុខគឺភាគច្រើនតែងតែមានប្រពន្ធ (តែម្នាក់) ជាមនុស្សល្អដែលពោរពេញដោយការស្រឡាញ់ ភាពទន់ភ្លន់ ទំនាក់ទំនងល្អ ជាមនុស្សស្រីមានបញ្ញា ចេះយកចិត្តទុកដាក់ចំពោះកូន ពូកែធ្វើម្ហូប និងមានទំនាក់ទំនងល្អជាមួយភ្ញៀវ ឬអ្នកជិតខាងជាដើម...





www.elibraryofcambodia.org

សុភាពបុរសទាំងឡាយ! អ្នកអាចមើលលើភ្នែករបស់ពួកនាង។ ភ្នែកធំមានសំណើម ឬ មានខ្លាញ់រលើប វាជាទីទាក់ទាញចិត្ត បង្ហាញឱ្យឃើញពីមនុស្សស្រីដែលមានស្នេហ៍(ស្នេហ៍ផ្កាថ)តែពេលខ្លះបង្ហាញឱ្យឃើញថានាងជាមនុស្សដែលគិតតែពីអារម្មណ៍ខ្លួនឯងពេក។



ផ្កាថគឺផ្កាឈើមួយប្រភេទដែលមានទំនាក់ទំនងរឿងស្នេហារបស់ជនជាតិនិងវប្បធម៌ចិន។ ពេលជនជាតិចិននិយាយថាអ្នកកំពុង "មានជោគជតាផ្កាថ" មានន័យថាអ្នកកំពុងតែមានជោគសំណាង "អំពីរឿងស្នេហា"។ ពេលខ្លះអ្នកអាចជួបមនុស្សស្រីដែលគិតតែពីអារម្មណ៍ខ្លួនឯងដូចបានពោលខាងលើ ប៉ុន្តែបើសិនជាអ្នកអាចទប់ចិត្តមិនស្រលាញ់នារីប្រភេទនេះបាន ក៏ជាការល្អដែរ។ មនុស្សស្រីដែលមានភ្នែកធ្លាក់ ឬ កន្ទុយភ្នែកធ្លាក់ដូចក្នុងរូប វាបង្ហាញឱ្យឃើញថាគេជាមនុស្សចង់មានចង់បានហួស តែងតែប្រយ័ត្នប្រយែង ហើយតែងតែចាក់សោជានិច្ច។ នេះគឺជាប្រភេទមនុស្សស្រីដែលសេវលេខទូរស័ព្ទរបស់អ្នកដាក់ទុកតែមុនគេ ព្រោះនាងតែងតែចង់ដឹងថាអ្នកនៅទីណារៀងរាល់វិនាទី។ បើអ្នកចូលចិត្តឱ្យគេចាប់អារម្មណ៍គឺមិនអីទេ តែបើអ្នកមិនចូលចិត្ត ចូរចៀសវាងមនុស្សស្រីដែលមានភ្នែកដូចនេះ។



ភ្នែកធ្លាក់ ឬ កន្ទុយភ្នែកធ្លាក់



www.elibraryofcambodia.org

ម្តងនេះអ្នកត្រូវមើលច្រមុះរបស់នាង អ្នកចង់ជ្រើសរើសមនុស្សស្រីដែល "នាំសំណាង" មកឱ្យ តើអ្នកត្រូវមើលដូចម្តេច? បន្តទៅទៀតនេះគឺជាវិធីរបស់អ្នកពិនិត្យមើលច្រមុះរបស់នាង ព្រោះច្រមុះគឺជាផ្កាយស្វាមីរបស់នាង ។ ដូច្នេះការមើលលើច្រមុះរបស់នាងគឺវាប្រៀបបាននឹងការមើលលើរូបអ្នកផ្ទាល់ បើនាងមានច្រមុះល្អមានន័យថាអ្នកដែលជាស្វាមីរបស់នាងក៏ល្អដែរ ។

ក្នុងការមើលច្រមុះរបស់សុភាពនារី តើលក្ខណៈល្អហើយសំខាន់នោះគឺជាអ្វី? បើខ្នង់ច្រមុះរបស់នាងទាបហើយចុងច្រមុះរបស់នាងស្តើងនោះ ស្វាមីរបស់នាងមិនមែនជាមនុស្សមានសមត្ថភាព ឬ មិនមែនជាអ្នកមានទ្រព្យអ្វីឡើយ ។ អ្នកក៏ប្រហែលជាមិនចង់ក្លាយជាបុរសបែបនេះដែរ ។

ខ្នង់ច្រមុះរបស់នាងមិនគួរខ្ពស់ពេកទេ ខ្នង់ច្រមុះដែលខ្ពស់ហួសបង្ហាញថាជាមនុស្សស្រីដែលមានទស្សនៈតានតឹង ឬ តឹងតែងហួសពេក ។ អ្នកប្រហែលជាចូលចិត្តមិត្តស្រី (ឬភរិយា) ដែលមានខ្នង់ច្រមុះមិនខ្ពស់ហួសពេកទេ លើកលែងតែអ្នកជាមនុស្សចង់ឱ្យភរិយារបស់អ្នកជាមនុស្សត្រួតត្រាលើរូបអ្នក ។



ខ្នង់ច្រមុះខ្ពស់



ខ្នង់ច្រមុះទាប



www.elibraryofcambodia.org

អ្នកប្រហែលជាចង់ឱ្យនាងមានចុងច្រមុះមូលស្អាត ស្លាបច្រមុះមានសាច់ហើយមើលមិនឃើញរន្ធច្រមុះពេលមើលចំពីមុខ ទាំងអស់នេះបង្ហាញថានាងមានផ្កាយស្វាមីល្អ ឬ ស្វាមីដែលជួបនូវភាពជោគជ័យនិងភាពមានបាន ។



ថ្ពាល់មានសាច់ដែលជំនួសដល់ច្រមុះមានសាច់

មនុស្សប្រុសរមែងចង់ដឹងថាតើភរិយានឹងគាំទ្រនូវអាជីពរបស់គេដែរឬទេ? តើនាងនឹងអាចជួយគេក្នុងផ្នែកផ្សេងៗនៃការងារឬអត់? ចម្លើយគឺនៅត្រង់ថ្ពាល់របស់នាង ។

ថ្ពាល់របស់នាងគួរមានសាច់ ។ បើថ្ពាល់មានសាច់ វាជាជំនួយការរបស់ច្រមុះដ៏ល្អ ។ លក្ខណៈដូចនេះបង្ហាញឱ្យឃើញពីភរិយាដែលមិនត្រឹមតែជាជំនួយការដល់ស្វាមីតែប៉ុណ្ណោះទេ តែនាងអាចសង្គ្រោះស្វាមីបានទៀតផង ។ ចិនហៅលក្ខណៈផ្សំបែបនេះថា "ធ្វើឱ្យស្វាមីចម្រើនរុងរឿង (វ៉ាំងហ្វូ)" គឺមានន័យថាមនុស្សប្រុសនឹងមានទ្រព្យធនច្រើនក្រោយពីរៀបការជាមួយមនុស្សស្រីប្រភេទនេះ ។



www.elibraryofcambodia.org



## ថ្ពាល់ធំឡើងឆ្អឹងតែច្រមុះតូច

អ្វីដែលអ្នកមិនចង់បាននោះគឺថ្ពាល់ឡើងឆ្អឹង។ ត្រឹមត្រូវហើយអ្នកត្រូវប្រាកដក្នុងចិត្តថាថ្ពាល់របស់នាងជាថ្ពាល់ដែលជួយទំនុកបម្រុងដល់ស្វាមីមិនមែនជាថ្ពាល់ឡើងឆ្អឹងទេ មនុស្សស្រីដែលមានថ្ពាល់ឡើងឆ្អឹងនិងមានទំហំធំ មិនត្រឹមតែមិននាំនូវភាពមានបានដល់ស្វាមីរបស់ពួកនាងប៉ុណ្ណោះទេ ថែមទាំងគាបសង្កត់លើស្វាមីទៀតផង ព្រោះស្វាមីរបស់ពួកនាងគ្មានសមត្ថភាព ឬ គ្មានប្រសិទ្ធិភាពក្នុងការសម្រេចជោគជ័យ។ ថ្ពាល់ឡើងឆ្អឹងដែលធំបង្ហាញឱ្យឃើញពីមនុស្សស្រីដែលមិនបានជួបនូវសេចក្តីសុខក្នុងជីវិតគូស្រករ។

តើហេតុអ្វីទៅ? ព្រោះថ្ពាល់ឡើងឆ្អឹងវាគាបសង្កត់ច្រមុះ។ តើអ្នកនៅចាំបានទេថាវាគឺជាផ្កាយស្វាមីរបស់មនុស្សស្រី? បើទួលថ្ពាល់របស់នាង "គាប" ច្រមុះនោះគឺស្ថានការណ៍ដែលនឹងកើតឡើងក្នុងជីវិតគូស្រកររបស់នាង។ ភាសាចិនហៅថាស្រីលួចអំណាចប្តី (នីតូវហ្វូឆួន)។

ថ្ងាសរបស់សុភាពនារីក៏ជាចំណុចត្រូវពិចារណាក្នុងពេលជ្រើសរើសភរិយាដែលល្អដែរ។ សម័យនេះជាសម័យដែលភរិយាក៏ចេញធ្វើការក្រៅផ្ទះដែរ តែច្បាស់ណាស់ថានេះមិនមែនជាស្ថានការណ៍នៃជីវិតគូស្រករក្នុងឧត្តមគតិជានិច្ចនោះទេ (មានមនុស្សប្រុសជាច្រើននាក់មិនចាប់អារម្មណ៍ក្នុងរឿងនេះទេ)។



www.elibraryofcambodia.org

ជាទូទៅថ្ពាសបួនជ្រុងហើយទូលាយបង្ហាញថាជាមនុស្សស្រីដ៏ពូកែនិងមានចរិតរឹងមាំ មិនចំណុះនរណា ពួកនាងជាអ្នកសម្រេចចិត្តដ៏មានប្រសិទ្ធិភាព ។



ថ្ពាសមូល



ថ្ពាសជ្រុង

បើអ្នកកំពុងតែស្វែងរកមេផ្ទះដែលល្អហើយស្រួលនិយាយគ្នាចូរអ្នករកមើលមនុស្សស្រីដែលមានថ្ពាសមូល ។ ចូរចាំទុកថាថ្ពាសត្រូវស៊ីនិងចង្ការរបស់នាង ចង្កាមូលមានសាច់អាចមិនមែនជាស្រីអ្នកដឹកនាំ ឬ ជាភរិយាដែលមានសម្រស់ទុកអួតគេនោះទេ តែវាបង្ហាញពីវ័យជរាដែលល្អដែលចោមរោមទៅដោយកូនចៅដែលមានភាពកតញ្ញូ ។ បើភរិយារបស់អ្នកមានវ័យជរាដ៏ល្អនោះ វាជាលក្ខណៈដែលបង្ហាញឱ្យឃើញថាអ្នកដែលជាស្វាមីនឹងជួបនូវភាពជោគជ័យព្រោះអ្នកអាចផ្តល់ជីវិតដ៏ល្អឱ្យនាងបាន ក្នុងវប្បធម៌ចិនគេចាត់ទុកថាមនុស្សប្រុសមានវ័យជរាល្អបានបើគាត់មានផ្ទះដែលពោរពេញទៅដោយកូនចៅ ( ជីស៊ុនម៉ានថាង ) ។



www.elibraryofcambodia.org

## មួយ ពីរ ឬក្រុមធាល់ធាត់?

## ត្រួតមើលសមត្ថភាពក្នុងការផ្តល់កំណើតកូន

បញ្ហានេះមិនមែនជាបញ្ហាដែលមនុស្សអាចនិយាយគ្នាដោយបើកចំហបាននោះទេ ។ វាមិនដូចតួលេខបញ្ជីក្នុងធនាគារ ឬ ប្រាក់សុទ្ធដែលយើងអាចត្រួតមើលបានស្រួលនោះឡើយ ។ អ្នកមិនអាចសួររឿងនេះដោយមិនមានការលើសលស់ ខុសឆ្គងខ្លះបានទេ មិនអាចសាកប្រើមុនទិញ ឬ ធ្វើកិច្ចសន្យាជួលបានទេ ។ ការរៀបការជាហេតុការណ៍តែម្តងគត់ក្នុងជីវិតសម្រាប់មនុស្សជាច្រើន យើងមិននិយាយដល់ការរៀបការជាថ្មី ( ឬអាពាហ៍ពិពាហ៍ខកបំណងនោះទេ) ។



ដំណឹងល្អ! យើងមិនចាំបាច់សួរសំណួរដែលអាចធ្វើឱ្យមានការស្ទាក់ស្ទើរក្នុងចិត្តនោះទេ ឬ មិនចាំបាច់ធ្វើតាមដំណាក់កាល១ដូចពេទ្យនោះឡើយ ។ បើអ្នកចង់ដឹងពីបញ្ហាដែលទាក់ទងនឹងការបន្តពូជបង្កើតកូនចៅនោះ អ្នកមើលតែត្រង់ចង្កូរបបូរមាត់លើក៏បានដែរ ។

ក្នុងក្បួនមើលទម្រង់មុខ ចង្កូរបបូរមាត់លើគឺជាផ្នែកតែមួយនៃមុខដែលគួរតែមានលក្ខណៈផតហើយទូលាយ ។ ចង្កូរបបូរមាត់លើអាចប្រាប់ថា ប្រព័ន្ធទុយោគូស្រករបស់អ្នកមិនថាប្រុស ឬ ស្រីអាចធ្វើការល្អឬអត់? សូមអភ័យទោសពីសំណាក់ប្រិយមិត្តអ្នកអានដោយការប្រើភាសារបស់យើងខ្ញុំមានលក្ខណៈត្រង់បន្តិច ។



www.elibraryofcambodia.org



人
中
ចង្អូរបបូរមាត់លើ

សម្រាប់មនុស្សស្រីចង្អូរបបូរមាត់លើជំនួសឱ្យស្បូនរបស់នាង ។ បើវាខ្លី ឬ ចង្អៀតនោះ វាបង្ហាញថាការចាប់បដិសន្ធិពិបាក ឬ សម្រាលបុត្រពិបាក ។

សម្រាប់មនុស្សប្រុសចង្អូរបបូរមាត់លើវាជំនួសឱ្យ "ឧបករណ៍របស់គេ " តែអ្នកត្រូវវិភាគដោយផ្អែកទៅលើលក្ខណៈមួយទៀតគឺវិភាគទម្រង់មាត់ផ្គួបផ្សំនឹងចង្អូរបបូរមាត់លើដែរ ដើម្បីឱ្យប្រាកដក្នុងចិត្តអំពីបញ្ហាការបន្តពូជរបស់មនុស្សប្រុស ។ បើចង្អូរបបូរមាត់លើរបស់មនុស្សប្រុសតូចចង្អៀតហើយមាត់របស់គេតូចដែរ វាបង្ហាញឱ្យឃើញថាទឹកអសុចិ (ទឹកកាម) របស់គេមានតិច ។

មាត់តូចបង្ហាញថាធាតុទឹកចុះខ្សោយ ចំណែកចង្កាស្រួចបង្ហាញឱ្យឃើញពីភាពឯកោក្នុងវ័យជរា ។ ក្នុងវប្បធម៌ចិនភាពឯកោក្នុងវ័យជរាមានន័យថា "គ្មានកូនចៅច្រើននៅហែហម" ។ ការមើលទម្រង់មុខ យើងមិនបានវិភាគលក្ខណៈផ្សេងៗចេញពីគ្នាទេ តែយើងមើលចំណុចរួមទូទៅទាំងអស់ ។ ចង្អូរបបូរមាត់លើចង្អៀត មាត់តូច ហើយចង្កាស្រួច ទាំងអស់នេះពេលរួមគ្នាទៅវាជាសញ្ញាបង្ហាញឱ្យឃើញពីមនុស្សដែលមានសមត្ថភាពក្នុងការបន្តពូជទាប ។



www.elibraryofcambodia.org

# ភាពជាព្រាននារីត្រូវមើលត្រង់ណាទើបដឹង?

ឥឡូវនេះយើងមកមើលឱ្យដឹងពីមនុស្សប្រុសដែលមានលក្ខណៈជា "ព្រាននារី" វិញម្តង។ តើអ្នកធ្លាប់សង្កេតឬទេថាតារាភាពយន្តខ្លះជាពិសេសបុរសៗដែលបានទទួលពេញនិយមពីសំណាក់មនុស្សស្រី តើពួកគេមានស្នាមជ្រួញ ឬ ស្នាមជើងក្អែកត្រង់កន្ទុយភ្នែករបស់ពួកគេពេលដែលពួកគេញញឹមឬទេ?

ភាពជាព្រាននារីមិនចាំបាច់ត្រូវមានន័យថាគេម្នាក់នោះត្រូវប្រព្រឹត្តអំពីក្បត់ចិត្តរហូតនោះទេ មនុស្សប្រុសដែលមានមិត្តស្រីច្រើន (ឬ មានមិត្តស្រីជិតស្និទ្ធ) មិនមែនជាអ្នកក្បត់អ្នករហូតនោះទេ។ ដូច្នេះអ្នកពុំចាំបាច់បារម្ភពេកទេ គ្រាន់តែកុំបណ្តោយគេពេកទៅបានហើយ។



កន្ទុយត្រីវែង

ក្នុងការមើលទម្រង់មុខ ស្នាមជ្រួញទាំងអស់នេះហៅថាកន្ទុយត្រីដែលបង្ហាញឱ្យឃើញពីលក្ខណៈទន់ភ្លន់និងភាពជាព្រាននារី។ មនុស្សប្រុសទាំងអស់នេះនឹងទទួលបាននូវភាពជោគជ័យបើពួកគេធ្វើជំនួញ ឬ លក់ទំនិញឱ្យមនុស្សភេទផ្ទុយគ្នា។



www.elibraryofcambodia.org

ការចូលចិត្តទាក់ទងស្រីៗជារឿងមួយ តែការប្តូរពីមិត្តភាពរវាងប្រុសស្រីដែលរាប់អានគ្នាបែបធម្មតាៗទៅជាការព្រៀគ្នានោះជារឿងមួយផ្សេងទៀត ។



មនុស្សប្រុសនឹងក្បត់ចិត្តឬអត់នោះ វាអាស្រ័យលើកន្ទុយត្រីត្រង់រាំងគូស្រករបស់គេមានឬអត់?

តើអ្នកចាំបានទេថារាំងគូស្រកររបស់មនុស្សប្រុសមិនមែននៅត្រង់ច្រមុះនោះទេ គឺវានៅត្រង់កំផ្លៀង ។ បើកន្ទុយត្រីមិនប៉ះ ឬ មិនចាក់រាំងគូស្រករនោះ បុរសសំណព្វរបស់អ្នកមានលក្ខណៈព្រាននារីបានត្រឹមតែមើលនឹងភ្នែក ឬ និយាយនឹងមាត់តែប៉ុណ្ណោះឯង តែមិនមានដៃដល់ទេ ( ភាសាសាមញ្ញគឺជាមនុស្សដែលបានតែមាត់ ) ។

ប្រការដែលអ្នកចាំបាច់ត្រូវខ្វល់នោះគឺកែវភ្នែកផ្កាថ្គូបផ្សំនឹងកន្ទុយត្រីដែលនេះជាលក្ខណៈរបស់អ្នកប្រមាញ់មនុស្សស្រី ។ តើភ្នែកផ្កាថជាអ្វី? នេះគឺជាភ្នែកដែលគេហៅថា "ភ្នែកបន្ទប់គេង" ។ កែវភ្នែកបន្ទប់គេងគឺមានភ្នែកធំរលើប មានសំណើម រោមភ្នែកវែង ហើយចិញ្ចើមកោងស្អាត ។

នេះគឺជាភ្នែកដែលទាក់ទាញភេទផ្ទុយគ្នាឱ្យចូលមករក ប្រៀបដូចជាគំនរភ្លើងដែលទាក់ទាញសត្វមមៀចអីចឹង ។ បើមិត្តប្រុស ឬ ស្វាមីរបស់អ្នកមានលក្ខណៈបែបនេះអាចជាហេតុផលដែលអ្នកត្រូវចិត្តជាប់សាច់ជាប់ឈាមជាមួយគេតាំងពីដំបូងក៏អាចថាបាន ។

មនុស្សប្រុសដែលមានភ្នែកផ្កាថអាចមានការតាំងចិត្តពិតក្នុងការស្មោះត្រង់ជាមួយគូស្រកររបស់ខ្លួន ។ ពួកគេអាចមិនចង់ទទួលបានការចាប់អារម្មណ៍ជាពិសេសទេ តែមើលទៅដូចជាថាពួកគេគេចមិនផុតពីការចាប់អារម្មណ៍របស់មនុស្សស្រីដទៃឡើយ ។



www.elibraryofcambodia.org

បបូរមាត់ជាលក្ខណៈមួយទៀតដែលយើងត្រូវប្រមើលមើលដែរ បបូរមាត់ក្រោមក្រាស់ ឬ មានសាច់ច្រើនហួសដូចក្នុងរូបបង្ហាញឱ្យឃើញពីមនុស្សដែលមានការភ្ញាក់ផ្អើលពេលបានជួបនឹងអ្នកដទៃដែលមិនមែនជាគូស្រករបស់ខ្លួន។ ពួកគេជាមនុស្សដែលត្រូវការការស្ញប់ចិត្តផ្លែករាងកាយជានិច្ច បើមិនទទួលបានពីគូស្រករបស់ពួកគេ ពួកគេក៏មានទំនោរទៅរកអ្វីបន្ថែមនៅខាងក្រៅ។ បើអ្នកឃើញគូស្រករបស់អ្នកមានលក្ខណៈបែបនេះអ្នកចាំបាច់ត្រូវមើលថែចំពោះបញ្ហានេះដោយខ្លួនឯងឱ្យបានល្អ។



បបូរមាត់ក្រោមក្រាស់ (ទាំងបុរសនិងនារី)



www.elibraryofcambodia.org

# ទម្រង់មុខអ្នកមាន

សំណួរសួរថា "តើខ្ញុំនឹងក្លាយជាអ្នកមានបានដែរឬទេ?" ជាសំណួរដែលកើតឡើងជានិច្ចក្នុងពេលផ្តល់ការប្រឹក្សាបញ្ហាហោរាសាស្ត្រ ឬ ពិគ្រោះជោគជតា។ បើអ្នកកំពុងមើលទម្រង់មុខតើអ្នកត្រូវរកមើលអ្វី?

មានប្រការសំខាន់ពីរយ៉ាងដែលអ្នកត្រូវចាំទុកក្នុងចិត្តគឺ សមត្ថភាព (ដែលនឹងធ្វើឱ្យមានទ្រព្យ) និងជោគជតានៃការមានទ្រព្យ។ អ្នកចាំបាច់ត្រូវចែកឱ្យដាច់នូវប្រការទាំងពីរនេះក្នុងពេលដែលអ្នកមើលភាពមានបានរបស់មនុស្សម្នាក់តាមរយៈទម្រង់មុខ។

សមត្ថភាពសំដៅលើសមត្ថភាពរបស់មនុស្សដែលអាចសាងនិងសន្សំទ្រព្យសម្បត្តិពេញក្នុងមួយជីវិតរបស់គាត់។ ឯជោគជតានៃការមានទ្រព្យសំដៅលើអាជីពក្នុងបច្ចុប្បន្ន ឬ ការមើលឃើញហេតុការណ៍ទាក់ទងនឹងការមានបាន។ ដូច្នេះចូរធ្វើការសម្រេចចិត្តទៅថាអ្នកចង់បានអ្វី អ្នកមិនបាច់និយាយក៏បានដែរដឹងថាសមត្ថភាពនោះវាសំខាន់ជាងជោគជតា ព្រោះជោគជតាអាចប្រែប្រួលនិងអភិវឌ្ឍបាន។




ការពិនិត្យមើលលើសមត្ថភាពដែលនឹងអាចមានទ្រព្យរបស់ភេទទាំងពីរវាចាប់ផ្តើមពីច្រមុះ។ ច្រមុះជារាំងមានបាន (បុរសនិងស្ត្រី) ចុងច្រមុះស្អាតមូល ហើយមានសាច់គួបផ្សំនិងស្លាបច្រមុះមានសាច់ទូលាយ ហើយមានរន្ធច្រមុះមិនងើយបង្ហាញថារាំងមានបាននេះល្អ។ គុណភាពរបស់ច្រមុះត្រូវកំណត់ដោយថ្ពាល់រួមទាំងភាពស្រស់ស្អាតរបស់ថ្ងាសហើយនិងរាំងជីវិតរបស់មនុស្សយើង។

ច្រមុះត្រូវទទួលបាននូវជំនួយថ្ពាល់គឺជាសេនាដៃស្តាំនិងសេនាដៃឆ្វេងរបស់ស្តេច (ច្រមុះ)។ បើថ្ពាល់ទាប ទោះជាច្រមុះមានបារមីក៏ដោយក៏គេនោះមិនអាចមានបានដែរ។ ការ



www.elibraryofcambodia.org

មានច្រមុះធំត្រឹមតែប៉ុណ្ណោះមិនបានន័យថាគេនោះមានលាភអាចក្លាយជាអ្នកមានទ្រព្យបាននោះទេ គេក៏ត្រូវមានថ្ពាល់ដែលស៊ីគ្នានឹងច្រមុះដែរ ។



ថ្ពាល់មិនគាំទ្រច្រមុះ



ថ្ពាល់ដែលគាំទ្រច្រមុះ

ថ្ពាល់គឺជំនួសដោយអំណាចនិងថាមពលរបស់មនុស្ស ការមានទ្រព្យច្រើនធ្វើឱ្យមនុស្សមានអំណាចកាន់តែច្រើន ។ ថ្ពាល់ជំនួសឱ្យភាពជាអ្នកដឹកនាំ មានអ្នកមានទ្រព្យសម្បត្តិភាគច្រើន បានក្លាយជាអ្នកដឹកនាំ តែបើពួកគេដឹកនាំអ្នកដទៃមិនបានទេ គេក៏គ្មានឱកាសអាចមានទ្រព្យបានដែរ ។

ហើយចុះថ្ងាសវិញតើហេតុអ្វីទើបយើងចាំបាច់ត្រូវមើលគុណភាពរបស់ថ្ងាសដែរ? ព្រោះថ្ងាសវាជំនួសឱ្យអាជីពនិងជីវភាពក្នុងសង្គមរបស់យើង ។ ដូច្នេះថ្ងាសខ្ពស់ទូលាយហើយមានសាច់គឺជាប្រការសំខាន់ណាស់ចំពោះភាពជាអ្នកមានទ្រព្យ ព្រោះវាបង្ហាញនូវអាជីពឬលក្ខណៈលេចធ្លោរបស់អាជីពនៅក្នុងសង្គម ។



www.elibraryofcambodia.org



ថ្ពាសខ្ពស់ទូលាយហើយមានសាច់

ចុះមហាសេដ្ឋីដែលដេកស៊ីនោះ? មែនហើយមានមនុស្សតិចណាស់ដែលអាចរកលុយបានច្រើនទាំងក្នុងពេលដែលខ្លួនកំពុងដេកលក់ ។ ឧទាហរណ៍ដូចជាអ្នកដែលមានរបររកស៊ីទិញលក់ភាគហ៊ុន ។ អ្នកដែលទទួលជោគជ័យក្នុងរបរនេះកម្រកបានណាស់ តែមិនមែនថាគេគ្មានថ្ងៃខាតបង់នោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ទម្រង់មុខពួកគេមានចំណុចសំខាន់ច្រើនផ្ដេកដែលខុសគ្នា ជំនួសឱ្យការដែលពួកគេមានថ្ពាល់ដែលតាំទ្រច្រមុះទៅវិញ ពួកគេបែរជាមានថ្ពាសដែលមានអំណាចនិងត្រចៀកដែលគាំទ្រច្រមុះ ព្រោះការមានទ្រព្យដោយមិនចាំបាច់មានឥទ្ធិពលលើអ្នកដទៃទេ វាបង្ហាញឱ្យឃើញពីភាពលេចធ្លោនិងសតិបញ្ញាដ៏ខ្ពង់ខ្ពស់ ។ ថ្ពាសដែលខ្ពស់ហើយទូលាយគួបផ្សំនឹងត្រចៀកដែលវែងហើយមានសាច់ វាត្រូវគ្នានឹងឧបនិស្ស័យរបស់មនុស្សនោះ ។ បុគ្គលិកលក្ខណៈរបស់មនុស្សប្រភេទនេះមានចង្កាតូចបន្តិចព្រោះមានជំនួយពីការងារ ។





www.elibraryofcambodia.org

# រកគ្រូល្អ

សម័យនេះ ជាយុគសម័យដែលឪពុកម្តាយគ្រប់រូបយកចិត្តទុកដាក់លើការសិក្សារបស់កូនខ្លួនជាខ្លាំង ។ ការជួលគ្រូក្រៅម៉ោងមកបង្រៀនជាវិធីដ៏ល្អមួយ ប៉ុន្តែអ្វីដែលសំខាន់នោះគឺពិបាករកគ្រូដែលល្អ ទោះជាពួកគាត់មានសញ្ញាបត្រក៏ដោយ ។



គ្រូល្អគឺជាគ្រូដែលដឹងច្បាស់ពីអ្វីដែលពួកគាត់កំពុងបង្រៀន ហើយប្រការសំខាន់នោះគឺសមត្ថភាពក្នុងការបង្រៀនលើខ្លឹមសារនៃមេរៀនដែលមិនធ្វើឱ្យក្មេងមានការច្រឡំ ។ ដូច្នេះហើយ ទើបយើងមិនចង់បានគ្រូដែលមានការគិតច្របូលច្របល់មកធ្វើជាគ្រូរបស់កូនយើង ។ ដូច្នេះ ចូរមើលចិញ្ចើមគ្រូបង្រៀនកូនរបស់អ្នកដោយការប្រយ័ត្នប្រយែងគឺ ចិញ្ចើមរបស់គាត់ត្រូវតែមិនបះឡើង( មានន័យថារោមចិញ្ចើមបះឡើងទៅទិសផ្សេងៗគ្នា) ។

ទម្រង់មុខក៏ជួយបានច្រើនក្នុងការជ្រើសរើសគ្រូពិសេសៗឱ្យកូនរបស់អ្នកដែរ ។ ក្នុងការសិក្សាពីធាតុទាំង៥ ធាតុឈើជំនួសឱ្យការសិក្សានិងការបោះជំហានទៅមុខនៃការរៀនសូត្រ ទម្រង់មុខធាតុឈើបង្ហាញពីមនុស្សដែលចេះអត់ធន់ មានប្រសិទ្ធិភាពក្នុងការបង្រៀន ពូកែរៀន និងពូកែគិត ។



ទម្រង់មុខធាតុឈើបង្ហាញពីលក្ខណៈគ្រូដែលល្អ



www.elibraryofcambodia.org

គ្រូល្អត្រូវតែជាមនុស្សចេះអត់ធ្មត់ផងដែរ  ដូច្នេះត្រូវចៀសវាងលក្ខណៈមនុស្សដែលមានមុខហើម ឬ ថ្ពាល់ហើមដូចនៅក្នុងរូប។ លក្ខណៈបែបនេះបង្ហាញឱ្យឃើញថាជាមនុស្សចិត្តក្តៅហើយអារម្មណ៍ប្រែប្រួល ជាមនុស្សដែលមិនចេះអត់ធ្មត់ចំពោះកូនរបស់អ្នក។



មុខហើម



www.elibraryofcambodia.org

# ទម្រង់មុខគួរចៀសវាង

# មនុស្សបោកប្រាស់ រមិលគុណ

សម្រាប់មនុស្សភាគច្រើន ហេតុផលដែលល្អបំផុតមួយចំណុចនៃការសិក្សាស្វែងយល់ពីការមើលទម្រង់មុខ គឺគ្រាន់តែក្រឡេកមើលតែមួយភ្លែតក៏អាចដឹងបានថាគេជាមនុស្សគួរឱ្យរាប់អាន អាចទុកចិត្តបាន ឬ គេម្នាក់នោះមានចេតនាអាក្រក់។

នេះគ្រាន់តែជាសេចក្ដីណែនាំខ្លះៗ ដែលទាក់ទងនឹងការកំណត់ឧបនិស្ស័យក្នុងការមើលទម្រង់មុខ។ ទោះជាយ៉ាងណាក៏ដោយ តើអ្នកនៅចាំបានទេថាការមើលទម្រង់មុខគឺត្រូវពឹងលើលក្ខណៈដែលបង្ហាញនៅលើផ្ទៃមុខពីរយ៉ាង ឬ ច្រើនជាងពីរក្នុងការកំណត់ចេតនារបស់មនុស្សថានរណាល្អ នរណាអាក្រក់។ ប្រការសំខាន់ជាងនេះទៅទៀតគឺចាំបាច់ត្រូវពិចារណាពីអាកប្បកិរិយានិងដំណើរប្រែប្រួលដែលកប់នៅក្នុងខ្លួនរបស់ពួកគេនៅពេលដែលគេកំពុងនិយាយផងដែរ ដើម្បីឱ្យអ្នកច្បាស់ក្នុងចិត្តថាអ្វីដែលអ្នកបានឮនោះជាសម្ដីពិតឬកុហក។





www.elibraryofcambodia.org

## ភ្នែកពាដ្រុង

កែវភ្នែករបស់មនុស្សគេអាចប្រាប់អ្នកបានច្រើនដែលទាក់ទងនឹងធម្មជាតិរបស់មនុស្ស ថាតើគេជាមនុស្សល្អ ឬ អាក្រក់? ទាំងអស់នេះសុទ្ធតែអាស្រ័យលើកែវភ្នែក។ មានវិធីមួយដែលងាយបំផុតក្នុងការវិភាគចិត្តរបស់មនុស្ស គឺសង្កេតមើលរូបនិងទម្រង់ភ្នែករបស់គេ។ ជួនកាលយើងហៅកែវភ្នែករាងបីជ្រុងរបស់គេថា "ភ្នែកមូកគ្រប" ឬ "ភ្នែក3ជ្រុង"។

មនុស្សដែលមានភ្នែកបីជ្រុង(ដូចក្នុងរូប)តែងតែស្វែងរកវិធី "យកឈ្នះនិងគ្របដណ្តប់" អ្នកដទៃជាដរាប។ ធម្មជាតិពិតរបស់ពួកគេគឺរកមើលវិធីមានអំណាចលើគេហើយទទួលយកយោបល់ដែលល្អជាងគេ។ ពួកគេមិនចង់ "ចាញ់" ក្នុងហ្គេម ឬ ក្នុងជំនួញទេ។ មនុស្សដែលមានភ្នែកបីជ្រុងចូលចិត្តទាញប្រយោជន៍ពីអ្នកដទៃណាស់។



ភ្នែកបីជ្រុង

ចូរសង្កេតមើលការកែវភ្នែកក្នុងខណៈដែលកំពុងតែនិយាយ ការប្រទះកែវភ្នែកនឹងអាចធ្វើឱ្យអ្នកយល់ជម្រៅចិត្តរបស់គេ។



www.elibraryofcambodia.org

# ឆ្អឹងថ្គាមខ្លា

ជាការពិតណាស់មិនមាននរណាចូលចិត្តមនុស្សអកតញ្ញូទេ។ ទោះជាមិនមាននរណានិយាយថាពួកគេធ្វើគុណដល់អ្នកផ្សេងព្រោះចង់បានការតបស្នងក៏ដោយ តែយើងក៏ជឿជាក់ថាយើងមិនចង់ធ្វើអ្វីៗដើម្បីមនុស្សអកតញ្ញូដែរ។ ឆ្អឹងថ្គាមខ្លាមានន័យថាឆ្អឹងថ្គាមរបស់គេរឹងមាំណាស់ ហើយវាជាលក្ខណៈមួយដ៏សំខាន់នៃទម្រង់មុខ។ លក្ខណៈបែបនេះបង្ហាញថាពួកគេជាប្រភេទមនុស្សអកតញ្ញូ។ ហេតុអ្វីបានជាប្រើពាក្យថាអកតញ្ញូ? គឺសំដៅលើមនុស្សដែលមានប្រតិកម្មត្រជាក់ល្ហឹមចំពោះគុណស្រ័យដែលអ្នកដទៃធ្វើដាក់គេ។ ជាពិសេសក្នុងរឿងជំនួញ គេមិនបានធ្វើអ្វីដោយប្រាថ្នាការតបស្នង ឬ មិនចូលចិត្តតបស្នងគុណបុណ្យ ឬ អរគុណអ្នកដទៃឡើយ។



ឆ្អឹងថ្គាមខ្លា

ជួនកាលមិនមែនដោយសារពួកគេជាមនុស្សចិត្តអាក្រក់នោះទេ គឺគេគ្រាន់តែភ្លេចនូវអ្វីដែលអ្នកបានផ្តល់ឱ្យគេប៉ុណ្ណោះ។ បើមិនដូច្នេះគឺគេគ្រាន់តែមិនបានយកចិត្តទុកដាក់ចងចាំថាកាលពីអតីតកាលអ្នកធ្លាប់ជួយគេ។ បើអ្នកសម្រេចចិត្តថាចង់ជួយគេម្នាក់នេះ ចូរអ្នកធ្វើដោយកុំរំពឹងនូវការតបស្នងអ្វី បើមិនដូច្នេះទេ អ្នកនឹងមានអារម្មណ៍ថាស្តាយក្រោយមិនខាន។ ប៉ុន្តែក្នុងនាមជាមនុស្សល្អមិនគួររំពឹងគុណស្រ័យដែលយើងធ្វើល្អទៅលើគេទេ។



www.elibraryofcambodia.org

# ច្រមុះវៀច

មនុស្សច្រមុះវៀចមិនបានគិតអ្វីល្អ ឬ មិនមានការតាំងចិត្តបរិសុទ្ធទេ ជាពិសេសពេលមានរឿងលុយកាក់មកជាប់ពាក់ព័ន្ធជាមួយ មនុស្សច្រមុះវៀចគឺជាមនុស្សដែលមានចិត្តវៀចវេរ ។

តែវាមិនមានអ្វីប៉ះពាល់នឹងច្រមុះ "ផ្សៀង" ទេ។ ច្រមុះវៀចចង់មានន័យថាគឺច្រមុះដែលប៉ោងឡើងឆ្អឹងហើយខ្ទង់ច្រមុះមិនត្រង់ ច្រមុះមើលទៅដូចជាកំពៀតហើយប្រែប្រួល ។ បើមានចុងច្រមុះស្រួចទៀតនោះមនុស្សនោះជាមនុស្សដែលពិបាកទុកចិត្ត ព្រោះគេជាមនុស្សវៀចវេរបោកប្រាស់ដូចឆ្កែចចក ។



ច្រមុះវៀច



www.elibraryofcambodia.org

# បបូរមាត់ស្តើងជាមនុស្សពូកែកុហក

អ្នកត្រូវប្រយ័ត្នចំពោះមនុស្សដែលមានបបូរមាត់ស្តើង ពួកគេភាគច្រើនជាមនុស្សពូកែនិយាយហើយមានសម្តីផ្អែម ។ មនុស្សដែលយើងចាំបាច់ត្រូវប្រយ័ត្នគឺមនុស្សដែលមានបបូរមាត់ស្តើង ហើយមានកែវភ្នែករាងជ្រុង ជាពិសេសពេលដែលអ្នកចង់ទិញរបស់អ្វីមួយពីមនុស្សប្រភេទនេះពួកគេតែងតែមិនប្រាប់ការពិតដល់អ្នកឡើយ ។



បបូរមាត់ស្តើង



www.elibraryofcambodia.org

# មនុស្សដែលមានស្វាមីភក្តិហើយកតញ្ញូ

តើអ្នកធ្វើដូចម្តេចទើបដឹងថាកូនឈ្នួលរបស់អ្នកជាមនុស្សមានភក្តីភាពចំពោះអ្នក? តើអ្នកធ្វើដូចម្តេចទើបដឹងថាគេជាមនុស្សកតញ្ញូ? ប្រការដំបូងត្រូវមើលចិញ្ចើមវែង (វែងមានន័យថាវែងប៉ុនភ្នែក) ដែលមិនស្តុកហួស។ ចិញ្ចើមជំនួសឱ្យវាំងបងប្អូន ចិញ្ចើមល្អមានន័យថាវាវែងហើយមិនដាច់ លក្ខណៈបែបនេះបង្ហាញឱ្យឃើញថាជាមនុស្សដែលមានគុណធម៌និងឱ្យតម្លៃលើភាពជាបងប្អូននិងធ្វើអ្វីៗដើម្បីបងប្អូន។ ពួកគេឃើញប្រយោជន៍បងប្អូនជាមូលដ្ឋានហើយផ្តល់ភាពសំខាន់លើមិត្តភាពយ៉ាងខ្លាំង។ មនុស្សប្រភេទនេះមិនក្បត់ចំពោះការមិនទុកចិត្តដែលមិត្តភក្តិផ្តល់ឱ្យគេទេ។

យើងនៅចង់ឱ្យមនុស្សប្រភេទនេះមានច្រមុះត្រង់ហើយមានសាច់ទៀតផង ព្រោះវាបង្ហាញឱ្យឃើញពីភាពស្មោះត្រង់ ចំណុចចុងក្រោយត្រូវសង្កេតមើលដើម្បីឱ្យច្បាស់ក្នុងចិត្តថាត្រចៀកនៅបៀតក្បាល (មិនកាងចេញ) ហើយរង្វង់ត្រចៀកមានរូបរាងច្បាស់លាស់។



ត្រចៀកនៅបៀត
ជាប់នឹងក្បាល



www.elibraryofcambodia.org

## មនុស្សមានសតិបញ្ញាឆ្លាតវាងវៃ

គ្រប់ស្ថាប័នតែងចង់បានទីប្រឹក្សាដែលឆ្លាតវាងវៃ ឬ ជួនកាលអ្នកដែលពូកែគិតអាចជួយដោះស្រាយបញ្ហាបានលឿនទាំងនេះគឺជាប្រភេទមនុស្សដែលអ្នកចង់បានយកមកធ្វើការជាមួយដើម្បីជួយអ្នកដោះស្រាយបញ្ហា។

យើងចង់បានមនុស្សដែលមានត្រចៀកខ្ពស់ មានន័យថាត្រង់ចុងត្រចៀកលើនៅក្នុងកម្រិតជាមួយគ្នា ឬ ខ្ពស់ជាងចិញ្ចើម។ សញ្ញាបង្ហាញសំខាន់មួយទៀតគឺត្រចៀកដែលនៅខ្ពស់ត្រង់កម្រិតជាមួយចិញ្ចើម ឬ ខ្ពស់ជាងចិញ្ចើម បង្ហាញឱ្យឃើញពីកម្រិតសតិបញ្ញារបស់គេ។





www.elibraryofcambodia.org



ត្រចៀកនៅខ្ពស់ជាងចិញ្ចើម

ពេលនេះយើងកំពុងនិយាយអំពីកម្ពស់ មិនមែនទំហំរបស់ត្រចៀកទេ។

លក្ខណៈទីពីរដែលត្រូវបន្ថែមឱ្យត្រចៀកខ្ពស់គឺថ្ងាស។ យើងមិនបាច់ឆ្ងល់ទេ ថ្ងាសខ្ពស់បង្ហាញឱ្យឃើញពីសមត្ថភាពក្នុងការវិភាគនិងការប្រើគំនិត។ មានប្រការមួយដែលត្រូវប្រយ័ត្ននោះគឺមនុស្សដែលមានថ្ងាសខ្ពស់ហើយហុច គេមិនចាត់ទុកថាជាមនុស្សមានសតិបញ្ញាទេ។ ឥឡូវយើងកំពុងរកមើលថ្ងាសទូលាយ មានសាច់ ស្មើហើយខ្ពស់។ ប៉ុន្តែ ថ្ងាសដែលខ្ពស់តែមានកំពកចាត់ទុកថាជាថ្ងាសមិនល្អ។ មនុស្សដែលមានថ្ងាសបែបនេះមានការវិភាគក្នុងការប្រើគំនិតតិច ថ្ងាសពើងបង្ហាញឱ្យឃើញពីការគិតដែលមិនប្រសើរ។



www.elibraryofcambodia.org

កែវភ្នែកជំនួសឱ្យភាពស្អាតនៅក្នុងចិត្តនិងជំនួសឱ្យការគិតបានច្បាស់លាស់ ។ ភ្នែកដែលទុយមុយ ហើយមិនរហ័ស ឬ ភ្នែកស្រលៀង ពុំបានបង្ហាញពីគំនិតច្បាស់លាស់នោះទេ ។ ផ្ទុយមកវិញ មនុស្សដែលមានភ្នែកមុតស្រស់ថ្លារហ័សរហួន មានសម្រស់ហើយមានពន្លឺបង្ហាញពីភាពឆ្លៀវឆ្លាតនិងមានសតិបញ្ញាល្អ ។



ភ្នែកមុតហើយស្រស់ថ្លាមានសម្រស់



ភ្នែកស្ពឹក

លក្ខណៈផ្សេងៗទាំងអស់នេះ វាបង្ហាញពីមនុស្សដែលមានសមត្ថភាពខ្លាំង ដែលអាចគិតដោះស្រាយបញ្ហាផ្សេងៗ ។ គេជាមនុស្សពូកែដោះស្រាយបញ្ហា ហើយក៏ជាអ្នកផ្តល់ទីប្រឹក្សាដ៏ឆ្លាតវាងវៃដែរ ។





www.elibraryofcambodia.org

# មើលមនុស្សកំណាញ់ម៉ៅស្វិត

មនុស្សម៉ៅស្វិតមានរន្ធច្រមុះតូចដូចក្នុងរូប



រន្ធច្រមុះតូច

មនុស្សដែលមានរន្ធច្រមុះធំចាយលុយលឿនជាងគេ ព្រោះច្រមុះគឺជាឃ្លាំងមានបាន បើអ្នកមានរន្ធច្រមុះធំនោះបង្ហាញថាទ្រព្យសម្បត្តិវាហូរចេញក៏ធំដែរ ។

មនុស្សច្រមុះស្រួចមានទំនោរក្នុងការគិតទាំងផ្លូវល្អនិងផ្លូវអាក្រក់ ជាពិសេសបើពួកគេមានឃ្លាំងទ្រព្យសម្បត្តិហើម ។ តើហេតុអ្វីទៅ? ច្រមុះស្រួចបង្ហាញពីទំនោរក្នុងការវាស់ "គុណតម្លៃ" នៃវត្ថុផ្សេងៗ មនុស្សទាំងអស់នេះស្រួចស្រាវរឿងលុយកាក់ណាស់ ។ ឃ្លាំងទ្រព្យសម្បត្តិដែលហើម បង្ហាញឱ្យឃើញពីអារម្មណ៍ចង់បានចង់មាន "ហួសហេតុ" ។ ដូច្នេះពួកគេតែងតែមានទស្សនៈលោភលន់ ពេលបញ្ចូលប្រការទាំងពីរចូលគ្នា គេនឹងក្លាយជាមនុស្សដែលប្រកាន់ខ្លួនឯងជាមណ្ឌលកណ្ដាលនៃក្ដីកំណាញ់ ។

បន្តទៅទៀតនេះគឺជាការសម្ងាត់ក្នុងការទប់ទល់នឹងអ្នកលក់ប្រភេទនេះ ។ ចូរកុំដើរតេច តែត្រូវធ្វើឱ្យពួកគេមានអារម្មណ៍ថាអ្នកកំពុងតែមានប្រៀបតាមរយៈការតថ្លៃរហូត វិធីនេះអាចធ្វើឱ្យពួកគេឆ្លើយតបនឹងការលក់របស់អ្នកបានល្អឡើង ។



www.elibraryofcambodia.org

# មនុស្សអាក្រក់

មនុស្សអាក្រក់គឺសំដៅទៅលើមនុស្សដែលមិនគួរឱ្យស្រឡាញ់និងជាពិសេសគឺមនុស្សដែលចោទប្រកាន់និងនិន្ទាយើងពីក្រោយខ្នង  ហើយធ្វើឱ្យល្បីសុះសាយទៅដល់អ្នកដទៃ។ ពួកគេមិនមែនជាមនុស្សដែលអ្នកចង់សេពគប់ ឬ ចង់នៅក្បែរនោះទេ។

តើអ្នកត្រូវធ្វើដូចម្តេចទើបអាចចៀសវាងមនុស្សបែបនេះបាន?  ប្រការដំបូងត្រូវនៅឱ្យឆ្ងាយពីមនុស្សដែលមានស្បែកមុខតឹង។  ស្បែកមុខតឹងវាដូចគ្នានឹងស្បែកមុខដែលត្រូវទាញទៅខាងអាក្រក់ទាល់តែតឹងច្រមុះតែងតែសំប៉ែត ហើយមើលឃើញរន្ធច្រមុះបានយ៉ាងច្បាស់។

មនុស្សដែលមានមុខតឹងជាមនុស្សពូកែច្រណែនហើយគេឥតស្ទាក់ស្ទើរក្នុងការនិយាយអាក្រក់នៅពីក្រោយខ្នងអ្នកឡើយ។

បើមនុស្សដែលអ្នកស្គាល់មានភ្នែកនិងមាត់នៅក្បែរច្រមុះខ្លាំងពេក អ្នកច្បាស់ជាពុំចូលចិត្តមនុស្សប្រភេទនេះទេ ព្រោះពួកគេមិនមានភាពស្ទាក់ស្ទើរក្នុងការនិយាយប្រាប់អ្នកថាពួកគេមិនចូលចិត្តដូចម្តេចចំពោះអ្នកឡើយ។ បើពួកគេមិនចូលចិត្តនរណាម្នាក់ ពួកគេនឹងនិយាយចំៗភ្លាមតែម្តង  គឺមិនចូលចិត្តទុកមុខទុកមាត់ឱ្យអ្នកណាឡើយ។

មនុស្សដែលមានមុខហើម  ហើយមានភ្នែកបីជ្រុងជាមនុស្សពូកែច្រណែន។ តាមធម្មតាមនុស្សដែលពូកែច្រណែនគឺពូកែចងគំនុំ  ពេលពួកគេមិនបានទទួលនូវអ្វីដែលគេត្រូវការ។ ដូច្នេះការដឹងថានរណាម្នាក់មានទំនោរជាមនុស្សពូកែច្រណែនគឺជាប្រការល្អមួយ។



មុខហើមហើយមានភ្នែកបីជ្រុង



www.elibraryofcambodia.org

# ការមើលទម្រង់មុខ សិល្បៈនិងការកាត់សេចក្ដី

ពេលខ្លះអ្នកអាចមានអារម្មណ៍ភ័យៗ តែចូរកុំមានអារម្មណ៍បែបនេះអី ការមើលទម្រង់មុខត្រូវពឹងអាស្រ័យលើការហ្វឹកហាត់ខ្លះ ហើយពេលខ្លះអ្នកត្រូវមើលឱ្យ "ឃើញ" ពីលក្ខណៈខ្លះរបស់មនុស្សយើងមុននឹងអ្នកចំណាំវាបាន ។ ក្រៅពីនេះ ការមើលទម្រង់មុខគឺជាសិល្បៈម្យ៉ាង ព្រោះវាបង្កប់ទៅដោយភាពខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ពេលដែលហ្វឹកហាត់ញឹកញាប់ទៅ អ្នកនឹងមានអារម្មណ៍កាន់តែចូលចិត្តខ្លាំងឡើង ។

ដោយសារអ្នកកំពុងតែស្វែងយល់អំពីវិធីសាស្ត្រផ្សេងៗតាមរយៈការអានសៀវភៅនេះតែប៉ុណ្ណោះ អ្នកមិនបានឆ្លងកាត់ការរៀនក្នុងថ្នាក់រៀនដែលមានគ្រូបង្រៀនធ្វើឱ្យអ្នកត្រូវចំណាយពេលច្រើនបន្តិច (ហើយជួនកាលអាចពិបាកដោយត្រូវប្រើរូបារម្មណ៍នឹកឃើញតាមដូចដែលសៀវភៅបានសរសេរប្រាប់ដោយខ្លួនឯង) ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏យើងជឿជាក់ថាសៀវភៅនេះនឹងផ្ដល់ប្រយោជន៍ផ្សេងៗដល់អ្នកផ្ទាល់ ព្រមទាំងញាតិមិត្តជិតឆ្ងាយរបស់អ្នកផងដែរ ។ ព្រោះពេលខ្លះជាប្រការល្អម្យ៉ាងដែរ ដែលអ្នកអាចដឹងថានរណាមានជោគសំណាង ហើយនរណានឹងមានគ្រោះថ្នាក់ ។

ទម្រង់មុខដែលឆ្លុះពន្លឺដោយស្នាមញញឹមដ៏ពិតប្រាកដចេញមកអាចប្រាប់អ្នកថា គេម្នាក់នោះនឹងមានជោគសំណាង ។ ស្ដាប់មើលទៅដូចជាងាយពេកហើយមែនទេ? តើអ្នកដឹងអ្វីខ្លះទេថាមិនមាននរណានិយាយថាវាជារឿងលំបាកនោះទេ? ដូច្នេះចូរទុកចិត្តចំពោះការមើលទឹកមុខដោយសញ្ចេតិញ្ញាណរបស់អ្នកតាមរយៈក្បួនខ្នាតដ៏ត្រឹមត្រូវនេះទៅ ។





www.elibraryofcambodia.org



ទម្រង់មុខដែលមានជោគសំណាងគឺជាទម្រង់មុខដែលមាន "សេចក្តីសុខ" ។ ទោះបីជាអ្នកខ្លះអាចក្លែងធ្វើជាមានសេចក្តីសុខបាន" តែការពិតនោះគឺគ្រាន់តែជាមូលហេតុដែលធ្វើឱ្យអ្នកចាំបាច់ត្រូវស្វែងយល់ពីវិធីកាត់សេចក្តីមើលទម្រង់មុខដែលមានសេចក្តីសុខ "ពិតប្រាកដ" តែប៉ុណ្ណោះ ។ ពេលគេនោះញញឹម ចូរសង្កេតមើលថាតើកែវភ្នែករបស់គេកំពុងញញឹមដែរឬអត់? ការសង្កេតមើលគឺមានលក្ខណៈងាយៗបែបនេះឯង ។ អ្នកដែលកំពុងប្រឈមនឹងគ្រោះអាក្រក់មើលទៅមានលក្ខណៈស្រងូតស្រងាត់មានចេញទឹកភ្នែក ហើយមើលទៅហាក់ដូចជាពពកខ្មៅកំពុង ។ អណ្តែតលើក្បាលរបស់ពួកគេអ៊ីចឹង ។ និយាយបែបនេះមិនមែនសំដៅលើអ្នកដែលទើបត្រឡប់មកពីធ្វើការហត់ពេញមួយថ្ងៃនោះទេ គឺយើងចង់មានន័យថា តាមរយៈការសង្កេតគេជាលើកដំបូងគឺនៅពេលព្រឹក ។ បើតាមរយៈការមើលលើកដំបូងធ្វើឱ្យអ្នកមានអារម្មណ៍ថាគេនោះសោកសៅនោះ ជោគជតារបស់គេក៏មិនល្អដែរ ។



នៅសម័យមុន ការមើលទម្រង់មុខជាផ្លូវការទាំងអស់សុទ្ធតែធ្វើក្នុងពេលមានពន្លឺថ្ងៃ ។ ទោះបីជាវិធីសាស្ត្រខ្លះក្នុងសៀវភៅនេះអាចអនុវត្តប្រើក្នុងពេលណាក៏បានក៏ដោយ តែរឿងសំខាន់ជាពិសេសវត្តចាប់ផ្តើមគឺអ្នកត្រូវមើលទម្រង់មុខក្នុងកន្លែងដែលមានពន្លឺគ្រប់គ្រាន់អាចឱ្យអ្នកមើលឃើញលក្ខណៈនីមួយៗបានច្បាស់ល្អ ។



www.elibraryofcambodia.org

# តើការវះកាត់ប្លាស្ទិក (វះកាត់កែសម្ផស្ស Plastic Surgery) អាច "ដោះស្រាយ" ឬ "កែប្រែ" បញ្ហារបស់ទម្រង់មុខខ្ញុំបាន ដែរឬទេ?

តើការវះកាត់ប្លាស្ទិកអាចដោះស្រាយបញ្ហារបស់ខ្ញុំបានឬទេ? ការវះកាត់មិនអាច "ផ្លាស់ប្តូរ" ជោគសំណាងរបស់អ្នកបានទាំងស្រុងឡើយ តែទោះជាយ៉ាងណាក៏ដោយ វាក៏បានផ្លាស់ប្តូរ "អារម្មណ៍" របស់អ្នកចំពោះខ្លួនឯង ដូច្នេះវាក៏អាចជួយបានខ្លះដែរ ។



បើអ្នកមានអារម្មណ៍ "ល្អ" ចំពោះខ្លួនឯង អ្នកនឹងប្រែប្រួល "ចិត្ត" របស់អ្នក ហើយយើងទាំងអស់គ្នាដឹងថាបើអ្នកផ្លាស់ប្តូរចិត្តគំនិតរបស់អ្នក ទឹកមុខរបស់អ្នកនឹងបង្ហាញឱ្យឃើញពីការប្រែប្រួលនោះ ហើយជោគសំណាងរបស់អ្នកក៏ប្រែប្រួលទៅជាផលល្អតាមនោះដែរ ។



www.elibraryofcambodia.org

# សៀវភៅថ្មីៗដែលទើបចេញផ្សាយ




SPP អេស ភី ភី និមិត្តសញ្ញាសៀវភៅដែលមានគុណភាព

មានលក់នៅតាមគ្រប់បណ្ណាគារទូទាំងព្រះរាជាណាចក្រកម្ពុជា ទំនាក់ទំនងជាវដុំ 012 954 953

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ វ៉ាមុន
ខ្ញៅ ភារាជា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ចាន់ នីតា**

សីហា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

# សាលាអន្តរជាតិអាប៊ែនឌែនឡៃ (កម្ពុជា)

## Abundant Life International School

### 裕生国际学校-柬埔寨校区

បង្កើតនៅសហរដ្ឋអាមេរិក ឆ្នាំ ១៩៨៧

Licensed by ALIS America




សិស្សពូកែកម្ពុជាជាប់ជាសិស្សឆ្នើមនៅអាប៊ែនឌែនឡៃសហរដ្ឋអាមេរិក

東埔寨优秀学生受到美国裕生国际学校表彰

**កម្មវិធីសិក្សាភាសាចិន_អង់គ្លេសពេញម៉ោងមុនដំបូងគេបង្អស់នៅប្រទេសកម្ពុជា**

全国首家开办汉语-英语班全日制教程学校

ចាប់ផ្តើមទទួលចុះឈ្មោះសិស្សថ្មីពីថ្ងៃនេះហើយ ចាប់ទទួលសិស្សពីអាយុ ៦ខែឡើងទៅ ។

សិស្សកម្ពុជាទទួលយក០៥រូប សិស្សជនជាតិចិន១០រូប និងសិស្សសាសន៍ដទៃចំនួន០៥រូប ។

从今天起学生可报名注册,招收 6个月大以上学龄儿童。柬籍学生收5名,中国籍学生收10名,其他国籍学生收5名。

**កម្មវិធីសិក្សាមាន 3 ប្រភេទចាប់ពីមត្តេយ្យរហូតដល់ថ្នាក់ទី12**

១.កម្មវិធីសិក្សា២ភាសា ភាសាចិន_អង់គ្លេស

ភាសាចិនស្របតាមកម្មវិធីសិក្សារបស់ប្រទេសសិង្ហបុរី និងភាសាអង់គ្លេសស្របតាមកម្មវិធីសិក្សារបស់សហរដ្ឋអាមេរិក

២.កម្មវិធីសិក្សា២ភាសា ភាសាខ្មែរ.អង់គ្លេស

ភាសាខ្មែរស្របតាមកម្មវិធីសិក្សារបស់រដ្ឋ និងសញ្ញាបត្រចេញដោយក្រសួងអប់រំ យុវជននិងកីឡា

៣.កម្មវិធីសិក្សាអន្តរជាតិ(អាមេរិក)

សញ្ញាបត្រចេញដោយសាលាអន្តរជាតិអាប៊ែនឌែនឡៃនៅសហរដ្ឋអាមេរិក

9 789996 330421

从幼儿园到十二年级, 开办有三门不同的课程:

1.双语课程汉语-英语: 汉语科教内容来自新加坡,英语科教内容来自美国。

2.双语课程柬埔寨语-英语:柬文教材为国家指定教材,毕业证书为国家青年运动教育部所颁发。

3.国际课程:毕业证书为美国裕生国际学校总部颁发。

Tel 联系电话: 023 88 11 14 / 088 490 3333/ 023 88 11 04 / 088 690 1111

www.aliscambodia.com / www.alisamerica.com

www.elibraryofcambodia.org